សៀវភៅអ្នកសម្របសម្រួល

# សំណុំសកម្មភាព អប្បបរមាម៉ូឌុលទី ១០ អាហារូបត្ថម្ភ

កម្មវិធីជាតិអាហារូបត្ថម្ភ



ខែ មិនា ឆ្នាំ ២០០៩


USAID
ជំនួយពីពលរដ្ឋអាមេរិក
AED
Academy for Educational Development
A2Z
Micronutrients Sight Innovation

រៀបចំដោយកម្មវិធីជាតិអាហារូបត្ថម្ភ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ដោយមានការគាំទ្រ
បច្ចេកទេសពីគំរោងមីក្រូសារជាតិ A2Z, លោក Jan Berkvens និងក្រុមការងារអាហារូបត្ថម្ភ
ខែ មិនា ឆ្នាំ ២០០៩

### សៀវភៅអ្នកសម្របសម្រួល

# សំណុំសកម្មភាព អប្បបរមាម៉ូឌុលទី ១០

## អាហារូបត្ថម្ភ

រៀបចំដោយកម្មវិធីជាតិអាហារូបត្ថម្ភ
មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក
ដោយមានការគាំទ្របច្ចេកទេស
ពីគំរោងមីក្រូសារជាតិ A2Z, លោក Jan Berkvens
និងក្រុមការងារអាហារូបត្ថម្ភ

ខែមិនា ឆ្នាំ ២០០៩

# សទ្ទានុក្រម

## ពាក្យកាត់

| | |
|---|---|
| **BCG** | ការផ្តល់ថ្នាំបង្ការជម្ងឺរបេង |
| **BF** | ការបំបៅកូនដោយទឹកដោះម្តាយ |
| **DPT** | ការផ្តល់ថ្នាំបង្ការជម្ងឺខាន់ស្លាក់ ក្អកមាន់ និងតេតាណូស |
| **EDD** | កាលបរិច្ឆេទដែលនឹងត្រូវសម្រាល |
| **GP** | ការលើកកម្ពស់ការលូតលាស់ |
| **GA** | ការវាយតម្លៃការលូតលាស់ |
| **HB** | ការផ្តល់ថ្នាំបង្ការជម្ងឺរលាកថ្លើមប្រភេទបេ |
| **HC** | មណ្ឌលសុខភាព |
| **HC-1 (HIS )** | ទម្រង់របាយការណ៍មណ្ឌលសុខភាព-១/ទម្រង់ប្រព័ន្ធព័ត៌មានសុខាភិបាល បំពេញ និងផ្ញើរទៅឱ្យស្រុកប្រតិបត្តិប្រចាំខែ |
| **HIV** | មេរោគអេដស៍ដែលបង្កឱ្យកើតជាជម្ងឺអេដស៍ |
| **HIV+** | ផ្ទុកមេរោគអេដស៍ |
| **IDA** | ភាពស្លេកស្លាំងដែលបណ្តាលមកពីកង្វះជាតិដែក |
| **IMCI** | សមាហរណកម្មទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ |
| **IU** | ខ្នាតអន្តរជាតិ ( រង្វាស់សំរាប់ជីវជាតិអា) |
| **LMP** | រដូវចុងក្រោយ |
| **MC** | ប័ណ្ណម្តាយ |
| **Mg** | មីលីក្រាម |
| **MPA** | សំណុំសកម្មភាពអប្បបរមា |
| **Ms** | ខែ |
| **NFP** | អ្នកទទួលខុសត្រូវអាហារូបត្ថម្ភ |
| **NNP** | កម្មវិធីជាតិអាហារូបត្ថម្ភ |
| **OD** | ស្រុកប្រតិបត្តិ |
| **OPV** | ការផ្តល់ថ្នាំបង្ការជម្ងឺស្វិតដៃជើង |
| **OR** | ការចុះផ្តល់សេវាមូលដ្ឋាន |
| **ORS** | ជាតិទឹកដែលបង្គ្រប់ការបាត់បង់ជាតិទឹកតាមមាត់ |
| **PHD** | មន្ទីរសុខាភិបាលខេត្ត |
| **TT** | ការផ្តល់ថ្នាំបង្ការជម្ងឺតេតាណូល |
| **VAC** | គ្រាប់ថ្នាំជីវជាតិអា |
| **VHSG** | ក្រុមទ្រទ្រង់សុខភាពភូមិ |
| **Vit A** | ជីវជាតិអា |
| **Vit C** | ជីវជាតិសេ |
| **WRA** | ស្ត្រីក្នុងវ័យបន្តពូជ |
| **YC** | ប័ណ្ណលឿង ( ប័ណ្ណសុខភាពកុមារ) |
| **<** | តិចជាង |
| **>** | ច្រើនជាង |

# សទ្ទានុក្រម

**ភាពស្លេកស្លាំង** ភាពស្លេកស្លាំងគឺជាការខ្វះបរិមាណនៃអេម៉ូក្លូប៊ីននៅក្នុងឈាម (អេម៉ូក្លូប៊ីន គឺជាសារធាតុម្យ៉ាង ដែលនាំអុកស៊ីសែនក្នុងខ្លួន)។ ភាពចាំបាច់នៃជាតិដែក គឺដើម្បីផលិតនូវពពួកអេម៉ូក្លូប៊ីន។ កង្វះបរិមាណជាតិដែក គឺជាមូលហេតុដែលបណ្តាលឱ្យមានភាពស្លេកស្លាំងដែលបណ្តាលមកពីបញ្ហាកង្វះជាតិដែក។ សញ្ញារបស់វាគឺ មានភាពស្លេកស្លាំងនៅលើមុខ បបូរមាត់ ត្របកភ្នែក និងបាតដៃ។ ភាពស្លេកស្លាំងធ្ងន់ធ្ងរអាចបណ្តាលឱ្យស្លាប់។ គេអាចធ្វើការការពារភាពស្លេកស្លាំងដែលបណ្តាលមកពីបញ្ហាកង្វះជាតិដែកបានដោយគ្រាន់តែផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិកបន្ថែម និងបរិភោគអាហារណាដែលសំបូរដោយជាតិដែក។

**ទឹកដោះដំបូង/ទឹកដោះព្រៃ** ទឹកដោះដំបូង/ទឹកដោះព្រៃបានករកើតឡើងនៅក្នុងដំណាក់កាលចុងក្រោយនៃការមានផ្ទៃពោះ និងនៅក្នុងអំឡុងពេលពីរ ឬ បីថ្ងៃបន្ទាប់ពីទារកប្រសូត្រ។ ទឹកដោះដំបូងមានសារជាតិចិញ្ចឹម និងមានអង្គបដិបក្ខប្រាណជាច្រើនលើសលុប សំរាប់ជួយការពារកុមារពីជម្ងឺដង្កាត់នានា។ ទឹកដោះដំបូងគួរតែផ្តល់ឱ្យទារកនៅក្នុងម៉ោងដំបូងបន្ទាប់ពីសម្រាល។

**ការផ្តល់អាហារបន្ថែម** គឺជាការផ្តល់អាហារផ្សេងៗបន្ថែមទៅលើការបំបៅកូនដោយទឹកដោះម្តាយ។ ការផ្តល់អាហារបន្ថែមគួរតែចាប់ផ្តើមនៅពេលដែលកុមារមានអាយុចាប់ពី ៦ខែឡើងទៅ។ ការផ្តល់នូវអាហារបន្ថែមសមស្របមានន័យថា: បរិមាណ ចំនួនដង ភាពខាប់ គុណភាពសមស្របទៅតាមអាយុកុមារ។ អាហារបន្ថែមសមស្របគឺជាបបរដែលមានសណ្ឋានខាប់ដែលមិនងាយនឹងរអិលជ្រុះចេញពីស្លាបព្រាបានឡើយ នៅពេលដែលគេផ្អៀងស្លាព្រានោះ ហើយជាបបរដែលសំបូរទៅដោយសារជាតិចិញ្ចឹមផ្សេងៗដូចជា:

- សាច់ត្រី ស៊ុត ឈាមសត្វ សាច់ចិញ្ច្រាំ តៅហ៊ូ និងពពួកសណ្តែក
- បន្លែនានា : ស្លឹកត្រកួន ស្លឹកថ្មី ល្ពៅ ដំលូងជ្វា និងបន្លែផ្សេងៗទៀត
- ប្រេងឆា
- អំបិលអ៊ីយ៉ូដ

អាហារបន្ថែមគួរតែផ្តល់ឱ្យនៅក្នុងបរិមាណមួយត្រឹមត្រូវក្នុងមួយពេលៗ មានភាពខាប់ និងញឹកញាប់ទៅតាមអាយុកុមារ។

**ការផ្តល់ទឹកដោះម្តាយតែមួយមុខគត់** គឺជាការផ្តល់ឱ្យទារក នូវទឹកដោះម្តាយតែមួយមុខគត់ចាប់ពីពេលកើតរហូតដល់កុមារអាយុ ៦ខែ ដោយមិនត្រូវផ្តល់ឱ្យនូវអាហារ ឬភេសជ្ជៈអ្វីផ្សេងៗទៀតឡើយ ទោះបីជាទឹកផឹកក៏មិនចាំបាច់ត្រូវផ្តល់ឱ្យដែរ។

**ជាតិអ៊ីយ៉ូដ** គឺជាធាតុគីមីម្យ៉ាងដែលបានដាក់លាយបញ្ចូលទៅក្នុងអំបិលដើម្បីការពារជម្ងឺពកក។

**ជាតិដែក** គឺជាមីក្រូសារជាតិម្យ៉ាងដែលចាំបាច់សំរាប់បង្កើតកោសិកាគ្រាប់ឈាមក្រហម។ ការលេបគ្រាប់ថ្នាំជាតិដែកគ្រប់គ្រាន់ជួយការពារភាពស្លេកស្លាំង ដែលបណ្តាលមកពីបញ្ហាកង្វះជាតិដែកបាន។

**គ្រាប់ថ្នាំមេបង់ដាសុល** គឺជាគ្រាប់ថ្នាំសំរាប់ទម្លាក់ព្រូន

**សតិបញ្ញា** មានទំនាក់ទំនងជាមួយនឹងសតិ ឬខួរក្បាល

**អ្នកផ្តល់សារ** ជាអ្នកដែលផ្តល់នូវសារផ្សេងៗ

**រូបវន្ត (នៃកាយវិការ)** ដែលទាក់ទងទៅនឹងកាយវិការ

**ក្រោយសម្រាល** បន្ទាប់ពីសម្រាលកូនរួច

**ការផ្តល់អាហារផ្សេងៗ នៅមុនការផ្តល់ទឹកដោះដំបូង** អាហារ ឬភេសជ្ជៈផ្សេងៗ (មានទាំងទឹកផង) ដែលបានផ្តល់ឱ្យដល់ទារកមុនការបំបៅដោយទឹកដោះដំបូងរបស់ម្តាយ

**អ្នកទទួលសារ** បុគ្គលដែលជាអ្នកទទួលសារ

# មាតិកា


**១ សេចក្តីផ្តើម ..........**

១.១ សេចក្តីផ្តើម.......... ១០

១.២ គោលបំណងនៃសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី១០.......... ១០

១.៣ វិសាលភាព.......... ១១

១.៤ សារៈសំខាន់នៃបុគ្គលិកមណ្ឌលសុខភាព.......... ១១

១.៥ ការទទួលខុសត្រូវនៃបុគ្គលិកមណ្ឌលសុខភាពអំពីអាហារូបត្ថម្ភ.......... ១២

១.៦ កញ្ចប់បណ្តុះបណ្តាល.......... ១២

១.៧ សៀវភៅអ្នកសម្របសម្រួល.......... ១៤

១.៨ សម្ភារៈជំនួយការងារ.......... ១៤

១.៨.១ ការជួបពិនិត្យថៃទាំមុនពេលសម្រាល.......... ១៥

១.៨.២ ការជួបពិនិត្យថៃទាំពេលសម្រាល.......... ១៦

១.៨.៣ ការជួបពិនិត្យថៃទាំក្រោយពេលសម្រាល.......... ១៧

១.៨.៤ ការជួបពិនិត្យ ដើម្បីផ្តល់ថ្នាំបង្ការ.......... ១៨

១.៨.៥ ការជួបពិនិត្យថៃទាំកុមារឈឺនិងកុមារមានសុខភាពល្អ.......... ១៩

១.៨.៦ ការចែកចាយគ្រាប់ថ្នាំជីវជាតិអា.......... ២០

១.៩ ការវាស់វែងអំពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាល.......... ២០

១.១០ ប្រសិទ្ធភាពដ៏ល្អនៃការបណ្តុះបណ្តាលៈ ការគាំទ្រ.......... ២១

**២ ការសម្របសម្រួល.......... ២២**

២.១ សេចក្តីផ្តើម.......... ២២

២.២ សារៈសំខាន់នៃអ្នកសម្របសម្រួល.......... ២២

២.៣ ការសម្របសម្រួលដ៏មានប្រសិទ្ធភាព.......... ២៣

២.៤ សកម្មភាព.......... ២៣

២.៥ ការប្រជុំអ្នកសម្របសម្រួល.......... ២៣

២.៦ អ្នកសម្របសម្រួលម្នាក់ដែលមានប្រសិទ្ធភាព.......... ២៤

**ថ្ងៃសិក្សាទី ១ – អាហារូបត្ថម្ភ និងសម្ភារៈ.......... ២៥**

គោលបំណងថ្ងៃសិក្សាទី១.......... ២៧

គោលបំណងជំនាញថ្ងៃទី១ សំរាប់សិក្ខាកាម.......... ២៧

កាលវិភាគប្រចាំថ្ងៃសិក្សា.......... ២៨

សម្ភារៈដែលត្រូវការ.......... ២៩

សកម្មភាពថ្ងៃទី១.......... ២៩

**ថ្ងៃទី ២ ការថែទាំទារក និងកុមារតូច ............ ៤០**
គោលបំណងថ្ងៃសិក្សាទី២ ............ ៤០
គោលបំណងជំនាញថ្ងៃទី២ សំរាប់សិក្ខាកាម ............ ៤០
កាលវិភាគប្រចាំថ្ងៃសិក្សា ............ ៤១
សម្ភារះដែលត្រូវការ ............ ៤២
សកម្មភាពថ្ងៃទី២ ............ ៤៣

**ថ្ងៃទី ៣: កម្មវិធីថែទាំទារក និងកុមារ/ជីវជាតិអា ............ ៥៥**
គោលបំណងថ្ងៃសិក្សាទី៣ ............ ៥៥
គោលបំណងជំនាញថ្ងៃទី៣ សំរាប់សិក្ខាកាម ............ ៥៥
កាលវិភាគប្រចាំថ្ងៃសិក្សា ............ ៥៦
សម្ភារះដែលត្រូវការ ............ ៥៧
សកម្មភាពថ្ងៃទី៣ ............ ៥៧

**ថ្ងៃទី ៤: ជីវជាតិអា/ជាតិដែក ............ ៦៨**
គោលបំណងថ្ងៃសិក្សាទី៤ ............ ៦៨
គោលបំណងជំនាញថ្ងៃទី៤ សំរាប់សិក្ខាកាម ............ ៦៨
កាលវិភាគប្រចាំថ្ងៃសិក្សា ............ ៦៩
សម្ភារះដែលត្រូវការ ............ ៧០
សកម្មភាពថ្ងៃទី៤ ............ ៧០

**ថ្ងៃទី ៥: ជាតិដែក/អំបិលអ៊ីយ៉ូដ ............ ៨៣**
គោលបំណងថ្ងៃសិក្សាទី៥ ............ ៨៣
គោលបំណងជំនាញថ្ងៃទី៥ សំរាប់សិក្ខាកាម ............ ៨៣
កាលវិភាគប្រចាំថ្ងៃសិក្សា ............ ៨៤
សម្ភារះដែលត្រូវការ ............ ៨៥
សកម្មភាពថ្ងៃទី៥ ............ ៨៦

**ថ្ងៃទី ៦: ការផ្តល់ថ្នាំបង្ការ និងការពិនិត្យថែទាំមុនពេលសម្រាល ............ ៩៥**
គោលបំណងថ្ងៃសិក្សាទី៦ ............ ៩៥
គោលបំណងជំនាញថ្ងៃទី៦ សំរាប់សិក្ខាកាម ............ ៩៥
កាលវិភាគប្រចាំថ្ងៃសិក្សា ............ ៩៦
សម្ភារះដែលត្រូវការ ............ ៩៧
សកម្មភាពថ្ងៃទី៦ ............ ៩៨

**ថ្ងៃទី ៧: កម្មសិក្សាអនុវត្តននៅតាមមូលដ្ឋាន ការពិនិត្យថែទាំមុនពេលសម្រាល/ពេលសម្រាល និងក្រោយសម្រាល ............ ១០៧**
គោលបំណងថ្ងៃសិក្សាទី៧ ............ ១០៧
គោលបំណងជំនាញថ្ងៃទី៧ សំរាប់សិក្ខាកាម ............ ១០៧
កាលវិភាគប្រចាំថ្ងៃសិក្សា ............ ១០៨

សម្ភារៈដែលត្រូវការ ..... ១០៩
សកម្មភាពថ្ងៃទី៧ ..... ១០៩

**ថ្ងៃទី ៨: កម្មសិក្សាអនុវត្តន៍ ការពិនិត្យថែទាំក្រោយសម្រាល/ការផ្តល់ថ្នាំបង្ការ និងការពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ ..... ១១៨**
គោលបំណងថ្ងៃសិក្សាទី៨ ..... ១១៨
គោលបំណងជំនាញថ្ងៃទី៨ សំរាប់សិក្ខាកាម ..... ១១៨
កាលវិភាគប្រចាំថ្ងៃសិក្សា ..... ១១៩
សម្ភារៈដែលត្រូវការ ..... ១២០
សកម្មភាពថ្ងៃទី៨ ..... ១២០

**ថ្ងៃទី ៩ – ការចែកចាយគ្រាប់ថ្នាំជីវជាតិអា និងការគណនាស្តុក ..... ១២៨**
គោលបំណងថ្ងៃសិក្សាទី៩ ..... ១២៨
គោលបំណងជំនាញថ្ងៃទី៩ សំរាប់សិក្ខាកាម ..... ១២៨
កាលវិភាគប្រចាំថ្ងៃសិក្សា ..... ១២៩
សម្ភារៈដែលត្រូវការ ..... ១២៩
សកម្មភាពថ្ងៃទី៩ ..... ១៣០

**ថ្ងៃទី ១០ – កម្មសិក្សាអនុវត្តន៍បញ្ចប់ ..... ១៣៦**
គោលបំណងថ្ងៃសិក្សាទី១០ ..... ១៣៦
គោលបំណងជំនាញថ្ងៃទី១០ សំរាប់សិក្ខាកាម ..... ១៣៦
កាលវិភាគប្រចាំថ្ងៃសិក្សា ..... ១៣៧
សម្ភារៈដែលត្រូវការ ..... ១៣៧
សកម្មភាពថ្ងៃទី១០ ..... ១៣៨

**ឯកសារយោង ..... ១៤៦**
**ឧបសម្ព័ន្ធ ..... ១៤៧**
**គោលការណ៍ណែនាំ/បញ្ជីផ្ទៀងផ្ទាត់សំរាប់រៀបចំការបណ្តុះបណ្តាល ..... ១៤៨**
**វគ្គសម្របសម្រួលរយៈពេលកន្លះថ្ងៃសំរាប់ការបណ្តុះបណ្តាលអ្នកសម្របសម្រួល ..... ១៥១**
**តេស្តមុន/ក្រោយការសិក្សា ..... ១៦៤**
**ចម្លើយទៅនឹងតេស្តមុន និងក្រោយការសិក្សា ..... ១៦៩**
**ល្បែងថាមពលបន្ថែម ..... ១៧៨**
**សម្ភារៈជំនួយការបណ្តុះបណ្តាល – ១.១៣ ការរៀបមុខម្ហូបចូលគ្នា–ការងារតាមក្រុម ..... ១៨១**
**សម្ភារៈជំនួយការបណ្តុះបណ្តាល – ៣.៣ ការចិញ្ចឹមទារក និងកុមារ–ការងារតាមក្រុម ..... ១៨២**
**សម្ភារៈជំនួយការបណ្តុះបណ្តាល – ៣.៤ ការអនុវត្តនូវសារចិញ្ចឹមទារក និងកុមារ ..... ១៨៣**
**សម្ភារៈជំនួយការបណ្តុះបណ្តាល – ៦.៥ ការផ្តល់ថ្នាំបង្ការ–ការងារជាក្រុម ..... ១៨៤**
**បញ្ជីផ្ទៀងផ្ទាត់ការសម្របសម្រួល ..... ១៨៧**
**បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សា ..... ១៨៩**
**ឧបករណ៍/ឯកសារគាំទ្រមិត្តរួមការងារ ..... ១៩១**
**ទម្រង់វាយតម្លៃ ..... ១៩២**

# ០១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

ការបណ្តុះបណ្តាលសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ ស្តីពីអាហារូបត្ថម្ភ គឺជាកម្មវិធីបណ្តុះបណ្តាលនៅនឹងកន្លែងដែលជាផ្នែកមួយនៃកម្មវិធីសិក្សាសំណុំសកម្មភាពអប្បបរមារបស់មណ្ឌលសុខភាព។ សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី១០ គឺជាម៉ូឌុលអាហារូបត្ថម្ភដែលផ្តោតខ្លាំងទៅលើបទអន្តរាគមន៍អាហារូបត្ថម្ភចម្បងចំនួន ៥ ៖

- ការចិញ្ចឹមទារក និងកុមារ
- ការលើកកម្ពស់ និងការវាយតម្លៃការលូតលាស់របស់កុមារ
- ជីវជាតិអា
- ជាតិដែក
- ជាតិអ៊ីយ៉ូដ

សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ ត្រូវបានរៀបរៀងឡើងដំបូងនៅឆ្នាំ ១៩៩៨ ហើយត្រូវបានធ្វើការកែប្រែជាច្រើនដងរួចមកហើយ។ ការអនុវត្តម៉ូឌុលនេះចាប់ផ្តើមនៅឆ្នាំ ២០០៤។ សិក្ខាកាម អ្នកសម្របសម្រួល និងដៃគូអភិវឌ្ឍន៍ទាំងអស់បានផ្តល់នូវមតិយោបល់អំពីការកែប្រែនៃម៉ូឌុលនេះ។ ការកែប្រែនេះបានចាប់ផ្តើមនៅឆ្នាំ ២០០៧ ហើយបានបញ្ចប់នៅចុងឆ្នាំ២០០៨។ ម៉ូឌុលដែលបានកែប្រែនេះ ឆ្លើយតបទៅនឹងដៃគូពាក់ព័ន្ធទាំងអស់ដោយធ្វើឱ្យវាមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានសភាពច្បាស់លាស់ មានមូលដ្ឋានជំនាញច្រើនមុខ ងាយយល់និងងាយប្រើប្រាស់។

## ១.២ គោលបំណងនៃសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០

គោលបំណងនៃការបណ្តុះបណ្តាលសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី១០ គឺដើម្បីពង្រឹងចំណេះដឹង និងជំនាញដល់បុគ្គលិក មណ្ឌលសុខភាពស្តីអំពីអាហារូបត្ថម្ភដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពសុខភាពមាតា និងកុមារ សំដៅរួមចំណែកដើម្បីឱ្យសម្រេចដល់គោលដៅនៃរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយនូវអត្រាមរណៈភាពមាតា និងកុមារអាយុក្រោម ៥ ឆ្នាំ។

គោលបំណងនៃកម្មវិធីបណ្តុះបណ្តាលអាហារូបត្ថម្ភ (សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០) គឺ៖

- ធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភស្ត្រី និងកុមារដែលមានអាយុក្រោម៥ឆ្នាំ លើកកម្ពស់ និងគាំទ្រដល់ការអនុវត្តន៍សកម្មភាពអាហារូបត្ថម្ភដែលមានលក្ខណៈវិជ្ជមាន។
- ពង្រឹងគុណភាព និងលទ្ធភាពដែលអាចទទួលសេវាអាហារូបត្ថម្ភ ពិសេសចំពោះស្ត្រី និងកុមារអាយុក្រោម ៥ ឆ្នាំ។
- បង្កើនចំណេះដឹង និងជំនាញអាហារូបត្ថម្ភដល់បុគ្គលិកមណ្ឌលសុខភាព និងពង្រឹងដល់លទ្ធភាពនៃការ

បញ្ច្រៀតសកម្មភាពអាហារូបត្ថម្ភចូលទៅក្នុងសកម្មភាពទាំងពីររបស់បុគ្គលិកមណ្ឌលសុខភាពគឺ ការពិនិត្យសុខភាពនៅមណ្ឌលសុខភាព និងការធ្វើសកម្មភាពសេវាចុះមូលដ្ឋាននៅតាមសហគមន៍។

## ១.៣ វិសាលភាព

សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ មានការផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រជាតិដូចជាៈ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ (HSP 2)។ គោលដៅទី១ នៃផែនការយុទ្ធសាស្ត្រសុខាភិបាល គឺកាត់បន្ថយការឈឺ និង មរណៈភាពមាតា និងកុមារ។ មួយក្នុងចំណោមលទ្ធផលរំពឹងទុកទាំងឡាយ គឺការធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភរបស់កុមារ។ យុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ ២០០៨-២០១៥ នឹងរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅទី១ ទី៤ និង ទី៥ នៃគោលដៅអភិវឌ្ឍន៍សហវត្សន៍កម្ពុជា ដើម្បីលប់បំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន កាត់បន្ថយនូវមរណៈភាពកុមារ និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពសុខភាពមាតា និងការរស់រានមានជីវិតរបស់កុមារកម្ពុជា។ បទអន្តរាគមន៍លើប័ណ្ណពិន្ទុនៃការរស់រានមានជីវិតរបស់កុមារចំនួន ៤ ក្នុងចំណោមប័ណ្ណពិន្ទុទាំង១២ មានចំណងទាក់ទងផ្ទាល់ជាមួយនឹងអាហារូបត្ថម្ភៈ

- ការបំបៅកូនដោយទឹកដោះម្តាយ (ទឹកដោះដំបូង) ភ្លាមបន្ទាប់ពីសម្រាលរួច
- ការបំបៅកូនដោយទឹដោះម្តាយតែមួយមុខគត់រហូតដល់អាយុ ៦ ខែពេញ
- ចាប់ផ្តើមផ្តល់អាហារបន្ថែមសមស្របដល់កុមារចាប់ពីអាយុ ៦ ខែឡើងទៅ
- ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ដល់កុមារអាយុ ៦ ខែ ដល់ ៥ ឆ្នាំ ចំនួនពីរដងក្នុងមួយឆ្នាំ

ម៉ូឌុលបណ្តុះបណ្តាលសមាហរណកម្មទទួលបន្ទុកពិនិត្យ និងព្យាបាលជម្ងឺកុមារនៅសហគមន៍ (CIMCI) សំរាប់ក្រុមទ្រទ្រង់សុខភាពភូមិដែលបានកែសម្រួលឡើងវិញនាឆ្នាំ ២០០៩ នេះ បានពង្រីកសារអប់រំអំពីមីក្រូសារជាតិទៅក្នុងសហគមន៍។ ម៉ូឌុលបណ្តុះបណ្តាលសមាហរណកម្មទទួលបន្ទុកពិនិត្យ និងព្យាបាលជម្ងឺកុមារ និងការតាមដានក្រោយការបណ្តុះបណ្តាល នឹងត្រូវបានធ្វើឡើងដោយបុគ្គលិកមណ្ឌលសុខភាព។

## ១.៤ សារៈសំខាន់នៃបុគ្គលិកមណ្ឌលសុខភាព

បុគ្គលិកមណ្ឌលសុខភាពគឺជាមន្ត្រីគន្លឹះដ៏សំខាន់សំរាប់ធ្វើឱ្យស្ថានភាពសុខភាព និងអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារមានលក្ខណៈល្អប្រសើរឡើងពីព្រោះៈ

- បុគ្គលិកមណ្ឌលសុខភាពបានធ្វើឱ្យសហគមន៍មានជំនឿទុកចិត្ត
- ជាអ្នកដែលបានដឹងរាល់បញ្ហា និងស្ថានភាពនៅក្នុងសហគមន៍
- ជាអ្នកដែលបានជួបញឹកញាប់ជាមួយស្ត្រីនិងកុមារក្នុងមូលដ្ឋានគ្របដណ្តប់របស់ពួកគាត់

## ១.៥ ការទទួលខុសត្រូវរបស់បុគ្គលិកមណ្ឌលសុខភាព អំពីអាហារូបត្ថម្ភ

សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ គឺជាការធ្វើសមាហរណកម្មសកម្មភាពអាហារូបត្ថម្ភចូលទៅក្នុងរាល់សកម្មភាពទាំងឡាយរបស់បុគ្គលិកមណ្ឌលសុខភាព។ សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ ផ្តល់អោយបុគ្គលិកមណ្ឌលសុខភាព នូវចំណេះដឹង និងជំនាញ ដើម្បីធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភស្ត្រី និងកុមារ នៅកម្ពុជាកាន់តែប្រសើរឡើង។ បុគ្គលិកមណ្ឌលសុខភាពទទួលខុសត្រូវចំពោះ ៖



១ ការអប់រំដល់សហគមន៍ អំពីអាហារូបត្ថម្ភ និងផ្តល់សេវាអាហារូបត្ថម្ភនៅមណ្ឌលសុខភាព និងនៅតាមភូមិ

២ ផ្តល់ការគាំទ្រ ការបណ្តុះបណ្តាល និងការអភិបាលដល់អ្នកស្ម័គ្រចិត្តភូមិ

៣ ធ្វើការកត់ត្រា និងរាយការណ៍ ពីសកម្មភាពអាហារូបត្ថម្ភ និងប្រើប្រាស់ព័ត៌មានដែលប្រមូលបាន ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភនៅក្នុងសហគមន៍

## ១.៦ កញ្ចប់បណ្តុះបណ្តាល

បច្ចុប្បន្នភាពនៃសៀវភៅសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ ដែលបានកែប្រែ ផ្តោតទៅលើការជួបពិនិត្យថៃទាំទាំង៦ ដែលបុគ្គលិកមណ្ឌលសុខភាព ជួបជាមួយស្ត្រីមានផ្ទៃពោះ និងម្តាយ ព្រមទាំងកូនរបស់ពួកគាត់។ ការជួបពិនិត្យថៃទាំស្ត្រីគ្រប់ខែ និងម្តាយ ព្រមទាំងអ្នកថៃទាំផ្សេងទៀត គឺមាននៅក្នុងសៀវភៅនេះ។

**វិសោធនកម្មនៃសៀវភៅសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ នេះរួមមាន ៖**

- សៀវភៅសំរាប់អ្នកសម្របសម្រួល
- សៀវភៅសំរាប់សិក្ខាកាម
- សម្ភារៈជំនួយការងារ
- សន្លឹកស្លាយសំរាប់ធ្វើការបង្ហាញ
- បញ្ជីផ្ទៀងផ្ទាត់សំរាប់ការផ្តល់ប្រឹក្សា និងការប្រស្រ័យទាក់ទង

វគ្គបណ្តុះបណ្តាលនេះគឺជាមូលដ្ឋានដំបូងនៃជំនាញ និងមានលក្ខណៈជាការចូលរួមយ៉ាងសកម្ម និងទ្រឹស្តីមេរៀនសំខាន់ៗសំរាប់កម្មវិធី។ នៅក្នុងផ្នែក/ជំពូកនិមួយៗ រួមមានទ្រឹស្តី លំហាត់ និងការងារជាក្រុម។ លំហាត់ត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅសិក្ខាកាម និងសៀវភៅអ្នកសម្របសម្រួល។ នៅក្នុងលំហាត់និមួយមានតួអក្សរមួយ (ក ដល់ ឋ) ។ ការងារជាក្រុមមានតែនៅក្នុងសៀវភៅអ្នកសម្របសម្រួលទេ ហើយការងារនេះនឹងត្រូវបានពន្យល់ទៅសិក្ខាកាមដោយអ្នកសម្របសម្រួល។

សៀវភៅសិក្ខាកាមប្រើប្រាស់ជាឯកសារយោង។ សៀវភៅនេះមាន ១១ មេរៀន។ មេរៀនទី ១ ពន្យល់ពីគោលបំណងនៃសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០។ មេរៀនទី ២ បង្ហាញពីព័ត៌មានសាវតារនៃអាហារូបត្ថម្ភ។ មេរៀនទី ៣ (ពីការចិញ្ចឹមទារកនិងកុមារ) ទី៤ (ពីជីវជាតិអា) ទី៥ (ពីជាតិដែក) ទី៦ (ពីអ៊ីយ៉ូដ) ទី៧ (ពីការចាក់ថ្នាំបង្ការ) ដោយផ្តោតទៅលើកម្មវិធីជាតិ។ មេរៀនទី ៨ ពន្យល់ពីការជួបពិនិត្យថៃទាំគន្លឹះទាំង ៦ នៃអាហារូបត្ថម្ភ ដែលមេរៀនទី ៩ បង្ហាញពីព័ត៌មានស្តីអំពី ការកត់ត្រា និងរបាយការណ៍ មេរៀនទី ១០ បង្ហាញអំពីការគាំទ្រមិត្តរួមការងារ និង ទី ១១ បង្ហាញពីព័ត៌មានសាវតារស្តីអំពីការប្រស្រ័យទាក់ទង។

នៅថ្នាក់កណ្តាល ការបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលបង្គោលចំនួន ៥ថ្ងៃ ផ្តោតទៅលើការពង្រឹងជំនាញសម្របសម្រួល និងពីរបៀបដឹកនាំធ្វើសកម្មភាពបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពបំផុត។ នៅថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ ការបណ្តុះបណ្តាលអ្នកសម្របសម្រួលត្រូវធ្វើចំនួន ១០ ថ្ងៃ ដូចគ្នានឹងមាតិកាក្នុងសៀវភៅសិក្ខាកាមដែរ ដោយគ្រាន់តែបន្ថែមនូវមេរៀនខ្លះស្តីអំពីការសម្របសម្រួល ការឡើងបង្ហាញ និងការវាយតម្លៃ។ ការបណ្តុះបណ្តាលដល់បុគ្គលិកមណ្ឌលសុខភាព មានរយៈពេល ១០ ថ្ងៃ គឺជាមេរៀនបណ្តុះបណ្តាលដែលផ្តល់ដោយគ្រូបង្គោលថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ។

| ប្រភេទនៃការបណ្តុះបណ្តាល | សិក្ខាកាម | អ្នកសម្របសម្រួល | ចំនួនថ្ងៃ |
|---|---|---|---|
| អ្នកចូលរួម | បុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភ បុគ្គលិកក្រោមឱវាទក្រសួងសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល | បុគ្គលិកដែលបានជ្រើសរើស | ៥ |
| បណ្តុះបណ្តាលថ្នាក់ខេត្ត/ស្រុក | បុគ្គលិកខេត្ត/ស្រុក | បុគ្គលិកថ្នាក់ជាតិ | ១០ |
| បណ្តុះបណ្តាលថ្នាក់មណ្ឌលសុខភាព | បុគ្គលិកមណ្ឌលសុខភាព | បុគ្គលិកថ្នាក់ខេត្ត/ស្រុក | ១០ |

ការបណ្តុះបណ្តាលអ្នកសម្របសម្រួលនឹងធ្វើឡើងដោយផ្អែកលើការប្រើប្រាស់សៀវភៅសិក្ខាកាម សៀវភៅអ្នកសម្របសម្រួល និងកញ្ចប់បណ្តុះបណ្តាលផ្សេងៗទៀត (សម្ភារៈជំនួយការងារសំរាប់បុគ្គលិកសុខាភិបាល សន្លឹកស្លាយសំរាប់ធ្វើការបង្ហាញដោយមានកំណត់សម្គាល់សំរាប់អ្នកសម្របសម្រួល និងសម្ភារៈអប់រំផ្សេងៗទៀត)។ ពុំមានសៀវភៅផ្សេងដោយឡែកទៀតសំរាប់ការបណ្តុះបណ្តាលអ្នកសម្របសម្រួលទេ។ គ្រប់សកម្មភាពបណ្តុះបណ្តាលអ្នកសម្របសម្រួលមាននៅក្នុងជំពូកសំរាប់អ្នកសម្របសម្រួល។ រាល់សកម្មភាពទាំងអស់ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលអ្នកសម្របសម្រួល នឹងមានរយៈពេលខ្លីជាងសកម្មភាពបណ្តុះបណ្តាលសំរាប់ បុគ្គលិកមណ្ឌលសុខភាព ដោយសារសម្របសម្រួលនៅក្នុងការបណ្តុះបណ្តាលអ្នកសម្របសម្រួលសង្កត់ធ្ងន់លើ គឺការអនុវត្ត ជំនាញ គន្លឹះនៃការសម្របសម្រួល ជាជាងការផ្តល់ខ្លឹមសារទាំងមូលនៃជំពូកនោះ។ វាជាការសំខាន់ណាស់សំរាប់អ្នកសម្របសម្រួលបង្គោលក្នុងការគ្រប់គ្រងម៉ោងសិក្សារាល់ជំពូកនិមួយៗ និងផ្តល់ព័ត៌មានត្រឡប់ទៅឱ្យគ្រូបណ្តុះបណ្តាល ដោយប្រើប្រាស់បញ្ជីរផ្ទៀងផ្ទាត់ការសម្របសម្រួល។

## ១.៧ សៀវភៅអ្នកសម្របសម្រួល

សៀវភៅអ្នកសម្របសម្រួល មានការរៀបរាប់ពីជំពូកនៃសេចក្ដីផ្ដើម ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងផ្នែកសំរាប់ការបណ្ដុះបណ្ដាលរយៈពេល ១០ថ្ងៃ។ ជំពូកចុងក្រោយ គឺរៀបរាប់ពីការកត់ត្រា និងរបាយការណ៍ និងការគាំទ្រមិត្តរួមការងារ ។

សៀវភៅអ្នកសម្របសម្រួល មានការរៀបរាប់ពីការណែនាំសំរាប់ការបណ្ដុះបណ្ដាលរយៈពេល ១០ ថ្ងៃ។ គោលបំណង និងគោលបំណងជំនាញសំរាប់បុគ្គលិកមណ្ឌលសុខភាពសំរាប់ការសិក្សាមួយថ្ងៃៗ ត្រូវបានបង្ហាញជាមួយគ្នានឹងតារាងកាលវិភាគប្រចាំថ្ងៃ។ ការបណ្ដុះបណ្ដាលក្នុងថ្ងៃនិមួយៗមានផ្នែកខុសៗគ្នា។ សម្ភារៈចាំបាច់មួយចំនួនត្រូវបានរាយក្នុងបញ្ជី។

ជំពូកនិមួយៗ មានបង្ហាញនៅក្នុងទំព័រសង្ខេបតាមលំដាប់លំដោយ ដោយមានពេលវេលា គោលបំណង គោលបំណងជំនាញ វិធីសាស្ត្រ (បាឋកថា ការងារជាក្រុម ល្បែងដើរតួ ការពិភាក្សា សំណួរចម្លើយ ។ល។) តើអ្នកណាជាអ្នកទទួលខុសត្រូវ តើសម្ភារៈអ្វីដែលត្រូវការ និងការណែនាំសំរាប់ អ្នកសម្របសម្រួល។ កន្លែងដែលពាក់ព័ន្ធគ្នា គឺសៀវភៅអ្នកសម្របសម្រួលយោងតាមជំពូកនៅក្នុងសៀវភៅសិក្ខាកាម ។

លំហាត់និមួយៗត្រូវបានដាក់ទៅតាមលំដាប់រៀងអក្សរ ដែលឆ្លើយតបទៅនឹងតួអក្សរនៃលំហាត់នៅក្នុងឧបសម្ព័ន្ធសៀវភៅសិក្ខាកាម ។

ការងារក្រុមមានបង្ហាញតែនៅក្នុងសៀវភៅអ្នកសម្របសម្រួលប៉ុណ្ណោះ។ ការងារក្រុមនិមួយៗមានកាលវិភាគ និងការណែនាំលំអិត ។

ចំពោះការធ្វើបទបាឋកថា ស្លាយ និងកំណត់សម្គាល់ដែលពាក់ព័ន្ធនឹងព័ត៌មានអាហារូបត្ថម្ភ ត្រូវបានផ្ដល់ជូនដល់អ្នកសម្របសម្រួល។ ស្លាយទាំងអស់ត្រូវបានបង់លេខរៀង។ ស្លាយសំរាប់បទបាឋកថានិមួយៗ មាននៅក្នុងសៀវភៅអ្នកសម្របសម្រួល។

## ១.៨ សម្ភារៈជំនួយការងារ

សម្ភារៈជំនួយការងារត្រូវបានបង្កើតឡើងសំរាប់ការជួបពិនិត្យថែទាំនិមួយៗ។ សម្ភារៈ ជំនួយការងារបញ្ចូលនូវសារអាហារូបត្ថម្ភទៅក្នុងការជួបពិនិត្យថែទាំគន្លឹះដែលបុគ្គលិកមណ្ឌលសុខភាព ផ្ដល់ទៅឱ្យស្ដ្រីមានផ្ទៃពោះ និងម្ដាយទាំងឡាយ។ ការជួបពិនិត្យថែទាំគន្លឹះសំរាប់អាហារូបត្ថម្ភមាន :

១ ការជួបពិនិត្យថែទាំផ្ទៃពោះមុនពេលសម្រាល

២ ការជួបពិនិត្យថែទាំពេលសម្រាល

៣ ការជួបពិនិត្យថែទាំក្រោយពេលសម្រាល

៤ ការជួបពិនិត្យដើម្បីផ្ដល់ថ្នាំបង្ការ

៥ ការជួបពិនិត្យថែទាំកុមារឈឺ និង កុមារមានសុខភាពល្អ

៦ ការចែកចាយគ្រាប់ថ្នាំជីវជាតិអា

## ១.៨.១ ការជួបពិនិត្យផ្ទៃពោះមុនពេលសម្រាល

| | បុគ្គលិកមណ្ឌលសុខភាព | ស្ត្រីមានផ្ទៃពោះ |
|---|---|---|
| ១ | វាយតម្លៃសញ្ញាគ្រោះថ្នាក់ ។ ផ្តល់ការថែទាំបន្ទាន់ដ៏សមស្រប និងបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែកបើចាំបាច់ | ចូលរួមការពិនិត្យថែទាំមុនពេលសម្រាល |
| ២ | ផ្តល់ និងបំពេញប័ណ្ណសុខភាពមាតា | |
| ៣ | វាយតម្លៃស្ថានភាពសុខភាពរាល់ពេលស្ត្រីមកជួប | |
| ៤ | ព្យាបាលភាពស្លេកស្លាំង និងកង្វះជីវជាតិអា បើចាំបាច់ ដោយយោងទៅតាមគោលការណ៍ណែនាំ | លេបថ្នាំតាមវេជ្ជបញ្ជា និងត្រលប់មកវិញដើម្បីពិនិត្យតាំទ្រ |
| ៥ | ផ្តល់ប្រឹក្សាស្តីពីអាហារូបត្ថម្ភ | - អនុវត្តតាមសារអាហារូបត្ថម្ភ<br>- បរិភោគអាហារពេលបន្ថែម ១ពេលក្នុង១ថ្ងៃ យ៉ាងហោចណាស់បរិភោគអាហារ ៤ ពេលក្នុង១ថ្ងៃ និងបរិភោគទឹកឱ្យបានច្រើនយ៉ាងតិច ២ លីត្រក្នុង ១ថ្ងៃ<br>- បំបៅកូនរបស់អ្នកភ្លាមក្រោយពីសម្រាល<br>- ផ្តល់តែទឹកដោះម្តាយមួយមុខគត់រហូតដល់ ៦ ខែ |
| ៦ | ផ្តល់ប្រឹក្សាស្តីពីការថែទាំដោយខ្លួនឯងក្នុងអំឡុងពេលមានផ្ទៃពោះ | - ទៅពិនិត្យផ្ទៃទាំមុនពេលសម្រាល យ៉ាងតិចណាស់ឱ្យបាន ៤ ដង ក្នុងអំឡុងពេលមានផ្ទៃពោះ<br>- ចៀសវាងការជក់បារី និងផឹកគ្រឿងស្រវឹង<br>- សម្រាក និងចៀសវាងការលើករបស់ធ្ងន់ៗ |
| ៧ | លើកកម្ពស់ការស្រាវជ្រាវរកមេរោគអេដស៍ និងជម្ងឺកាមរោគ | ទៅរកកន្លែងដែលមានការស្រាវជ្រាវដើម្បីធ្វើតេស្ត |
| ៨ | ជួយស្ត្រីក្នុងការរៀបចំផែនការសម្រាល និងផែនការសង្គ្រោះបន្ទាន់ | រៀបចំសំរាប់ការសម្រាល និងការធ្វើដំណើរទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក |
| ៩ | ផ្តល់ប្រឹក្សាស្តីពីវិធីសាស្ត្រពន្យាកំណើត | |
| ១០ | ពិនិត្យមើល ការទទួលថ្នាំបង្ការតេតាណូស | ត្រលប់មកវិញដើម្បីធ្វើការគាំទ្រការផ្តល់ថ្នាំបង្ការ ដែលបានបង្ហាញនៅក្នុងប័ណ្ណ |
| ១១ | ផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ៦០គ្រាប់នៅពេលមកពិនិត្យលើកទី១ ។ ពន្យល់ពីផលរំខាននៃថ្នាំ ផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ៣០គ្រាប់នៅពេលមកពិនិត្យលើកទីពីរ | លេបគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិករៀងរាល់ថ្ងៃរហូតដល់អស់៩០គ្រាប់ |
| ១២ | ផ្តល់មេបង់ដាសុល១ដូស ( =៥០០មក្រ) នៅពេលផ្ទៃពោះមានអាយុលើសពី ៣ខែ | ទទួលទានថ្នាំពេលបានទទួល |
| ១៣ | ប្រឹក្សាពីការគាំទ្រ<br>កត់ត្រានៅក្នុងប័ណ្ណសុខភាពម្តាយ និងកត់ត្រានៅក្នុងសៀវភៅ | ត្រលប់មកតាមការចរចារ ។ សម្រាលនៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យ ។ យកប័ណ្ណសុខភាពម្តាយមកជាមួយរាល់ពេលមកពិនិត្យ |

## ១.៨.២ ការជួបពិនិត្យថែទាំពេលសម្រាល

| | បុគ្គលិកមណ្ឌលសុខភាព | ស្ត្រីមានផ្ទៃពោះ |
|---|---|---|
| ១ | វាយតម្លៃសញ្ញាគ្រោះថ្នាក់ បញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែក បើចាំបាច់ | ទៅសម្រាលនៅមណ្ឌលសុខភាព/មន្ទីរពេទ្យបង្អែក |
| ២ | សួររក/ផ្តល់ និងបំពេញប័ណ្ណសុខភាពម្តាយ | |
| ៣ | វាយតម្លៃស្ត្រីពេលឈឺពោះសម្រាល ឬ ការបែកទឹកភ្លោះ | |
| ៤ | ផ្តល់ការព្យាបាលសង្គ្រោះបន្ទាន់សមស្របទៅតាមវិធីសារថ្នាក់ជាតិ ឬរៀបចំការសម្រាល ប្រសិនបើមិនមានបញ្ហាអ្វីទេ | |
| ៥ | ផ្តល់ការថែទាំដល់ទារកទើបកើត | |
| ៦ | ផ្តល់ប្រឹក្សាស្តីពីការបំបៅកូនដោយទឹកដោះម្តាយ | - បំបៅកូនដោយទឹកដោះម្តាយភ្លាមក្រោយពីសម្រាល<br>- បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់កូនអាយុ ៦ ខែ<br>- បន្តបំបៅដោះកូនដោយទឹកដោះម្តាយរហូតដល់កូនអាយុបាន ២ ឆ្នាំ យ៉ាងតិច<br>- ចាប់ផ្តើមឱ្យអាហារបន្ថែមក្រោយពីកុមារអាយុ៦ខែ |
| ៧ | ផ្តល់ប្រឹក្សាស្តីពីអាហារូបត្ថម្ភ | - បរិភោគអាហារបន្ថែម ១ពេលក្នុង១ថ្ងៃ ដរាបណាម្តាយនៅបំបៅកូនដោយទឹកដោះម្តាយ និងបរិភោគជាតិទឹកឱ្យបានច្រើន យ៉ាងតិចឱ្យបាន ២ លីត្រក្នុង ១ ថ្ងៃ<br>- ចៀសវាងការតមអាហារបែបជំនឿ<br>- ប្រើអំបិលអ៊ីយ៉ូដ<br>- បរិភោគអាហារសំបូរជីវជាតិអា ជាតិដែក និងថាមពល |
| ៨ | ពិនិត្យមើលការទទួលថ្នាំបង្ការតេតាណូសរបស់ម្តាយ | ត្រលប់មកទទួលការផ្តល់ថ្នាំបង្ការដូចដែលបានប្រាប់ |
| ៩ | ផ្តល់ថ្នាំបង្ការជម្ងឺរបេង និងជម្ងឺរលាកថ្លើម បេ ដល់ទារកទើបកើត | |
| ១០ | ផ្តល់គ្រាប់ថ្នាំជីវជាតិអា (២០០.០០០ IU) ក្រោយសម្រាល | |
| ១១ | ផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ៤២គ្រាប់ ដល់ម្តាយ ពន្យល់ពីផលរំខាននៃថ្នាំ | លេបថ្នាំទៅតាមកំរិតដូស និងទុកដាក់តាមវេជ្ជបញ្ជា |
| ១២ | ផ្តល់មេបង់ដាសុល | |
| ១៣ | ផ្តល់ប្រឹក្សាស្តីពីវិធីសាស្ត្រពន្យាកំណើត | |
| ១៤ | បំពេញប័ណ្ណសុខភាពម្តាយ ហើយកត់ត្រាក្នុងសៀវភៅ ។ ផ្តល់ប័ណ្ណសុខភាពកុមារ សំរាប់ទារក | យកសៀវភៅសុខភាពមាតា ប័ណ្ណសុខភាពកុមារ មកជាមួយរាល់ពេលមកជួបពិនិត្យ |
| ១៥ | ចរចាពីការត្រលប់មកជួបពិនិត្យលើកក្រោយ | ត្រលប់មកវិញដូចដែលបានចរចាគ្នា |

## ១.៨.៣ ការជួបពិនិត្យថែទាំក្រោយពេលសម្រាល

| | បុគ្គលិកមណ្ឌលសុខភាព | ម្ដាយ / អ្នកថែទាំកុមារ |
|---|---|---|
| ១ | សួររក/ផ្ដល់ប័ណ្ណសុខភាពកុមារ និងប័ណ្ណសុខភាពម្ដាយ | មកពិនិត្យថែទាំក្រោយសម្រាល ដូចបុគ្គលិកមណ្ឌលសុខភាពបានឱ្យដំបូន្មាន |
| ២ | វាយតម្លៃសុខភាពរបស់ម្ដាយ ។<br>ធ្វើការព្យាបាលភាពស្លេកស្លាំង និងកង្វះជីវជាតិអា ប្រសិនជាចាំបាច់ ដោយប្រើប្រាស់ពិធីសារថ្នាក់ជាតិ | លេបថ្នាំទៅតាមកំរិតដូសតាមវេជ្ជបញ្ជា |
| ៣ | វាយតម្លៃសុខភាពកុមារ ធ្វើការព្យាបាលបើចាំបាច់ | ផ្ដល់ថ្នាំដូចដែលបានពន្យល់ |
| ៤ | វាយតម្លៃ និងផ្ដល់ប្រឹក្សាស្ដីអំពីការបំបៅកូនដោយទឹកដោះម្ដាយ | - បំបៅកូនដោយទឹកដោះម្ដាយភ្លាមក្រោយសម្រាល<br>- បំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ រហូតដល់កូនអាយុ៦ខែ<br>- បន្តបំបៅកូនដោយទឹកដោះម្ដាយរហូតដល់កូនអាយុបាន ២ ឆ្នាំ យ៉ាងតិច<br>- ចាប់ផ្ដើមឱ្យអាហារបន្ថែមដល់កុមារ ក្រោយពីអាយុ៦ខែ |
| ៥ | ពិនិត្យម្ដាយនិងទារក រកមើលសញ្ញាគ្រោះថ្នាក់ និងបញ្ជូនទៅមូលដ្ឋានសុខាភិបាល ប្រសិនបើមានសញ្ញាគ្រោះថ្នាក់ | |
| ៦ | ផ្ដល់ដំបូន្មានពីការថែទាំខ្លួនឯង និងអនាម័យ | |
| ៧ | ផ្ដល់ប្រឹក្សាស្ដីពីអាហារូបត្ថម្ភ | - បរិភោគអាហារបន្ថែម ១ ពេលទៀតក្នុង ១ ថ្ងៃ ដរាបណាម្ដាយនៅបំបៅកូនដោយទឹកដោះម្ដាយ<br>- ប្រើអំបិលអ៊ីយ៉ូដ<br>- បរិភោគអាហារសំបូរដោយជីវជាតិអា ជាតិដែក និងថាមពល |
| ៨ | ពិនិត្យមើលការទទួលថ្នាំបង្ការតេតាណូសរបស់ម្ដាយ | ត្រលប់មកទទួលការផ្ដល់ថ្នាំបង្ការដូចដែលបានប្រាប់ |
| ៩ | ពិនិត្យមើលស្ថានភាពផ្ដល់ថ្នាំបង្ការរបស់កុមារ | |
| ១០ | ពិនិត្យមើលម្ដាយមានបានទទួលគ្រាប់ថ្នាំជីវជាតិអាក្រោយសម្រាល<br>បើមិនបានទទួលទេ ផ្ដល់គ្រាប់ថ្នាំជីវជាតិអា ១គ្រាប់ (២០០.០០០ IU) | |
| ១១ | ផ្ដល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ៤២ គ្រាប់ ដល់ម្ដាយពន្យល់ពីផលរំខាននៃថ្នាំ | លេបថ្នាំទៅតាមកំរិតដូស និងទុកដាក់តាមវេជ្ជបញ្ជា |
| ១២ | ផ្ដល់មេបង់ដាសុល១ដូស (=៩០០មក្រ) ដល់ម្ដាយ | ទទួលទានថ្នាំពេលបានទទួល |
| ១៣ | ផ្ដល់ប្រឹក្សាការធ្វើតេស្ដរកមេរោគអេដស៍ | |
| ១៤ | ផ្ដល់ប្រឹក្សាស្ដីពីការពន្យាកំណើត | |
| ១៥ | បំពេញសៀវភៅសុខភាពមាតា ។ បំពេញប័ណ្ណសុខភាពកុមារ ។ កត់ត្រាក្នុងបញ្ជីមណ្ឌលសុខភាព | យកសៀវភៅសុខភាពមាតា និងប័ណ្ណសុខភាពកុមារ មកជាមួយរាល់ពេលមកជួបពិនិត្យ |
| ១៦ | ចរចាពីការត្រលប់មកជួបពិនិត្យលើកក្រោយ | ត្រលប់មកវិញដូចដែលបានចរចាគ្នា |

## ១.៨.៤ ការជួបពិនិត្យ ដើម្បីផ្តល់ថ្នាំបង្ការ

| | បុគ្គលិកមណ្ឌលសុខភាព | ម្តាយ / អ្នកថែទាំកុមារ |
|---|---|---|
| ១ | សួររក/ផ្តល់ប័ណ្ណសុខភាពកុមារ និងប័ណ្ណសុខភាពម្តាយ | |
| ២ | ផ្តល់ថ្នាំបង្ការទៅឱ្យកុមារ ប្រសិនបើចាំបាច់ | |
| ៣ | ពិនិត្យមើលការទទួលថ្នាំបង្ការតេតាណូសរបស់ម្តាយ | ត្រលប់មកទទួលការផ្តល់ថ្នាំបង្ការដូចដែលបានប្រាប់ |
| ៤ | វាយតម្លៃសុខភាពកុមារ ។ ធ្វើការព្យាបាលបើចាំបាច់ | ផ្តល់ថ្នាំទៅឱ្យកុមារដូចដែលបានពន្យល់ |
| ៥ | វាយតម្លៃសុខភាពម្តាយ<br>ធ្វើការព្យាបាលបើចាំបាច់ | លេបថ្នាំតាមវេជ្ជបញ្ជា |
| ៦ | វាយតម្លៃ និងផ្តល់ប្រឹក្សាស្តីអំពីការបំបៅកូនដោយទឹកដោះម្តាយ | - បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ រហូតដល់កូនអាយុ ៦ ខែ<br>- បំបៅកូនដោយទឹកដោះម្តាយរហូតដល់កូនអាយុបាន ២ ឆ្នាំ យ៉ាងតិច<br>- ចាប់ផ្តើមឱ្យអាហារបន្ថែមដល់កុមារ ក្រោយពីអាយុ ៦ ខែ ដូចដែលបានពន្យល់ |
| ៧ | ពិនិត្យមើលម្តាយមានបានទទួលគ្រាប់ថ្នាំជីវជាតិអាក្រោយសម្រាល ប្រសិនបើមិនបានទទួលទេ ផ្តល់គ្រាប់ថ្នាំជីវជាតិអា ១ គ្រាប់ (២០០.០០០ IU) | |
| ៨ | ពិនិត្យមើលម្តាយមានបានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ក្រោយសម្រាល ប្រសិនជាមិនបានទទួលទេ ផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ៤២គ្រាប់ ដល់ម្តាយ ពន្យល់ពីផលរំខាននៃថ្នាំ | លេបថ្នាំទៅតាមកំរិតដូស និងទុកដាក់តាមវេជ្ជបញ្ជា |
| ៩ | ពិនិត្យមើលម្តាយមានបានទទួលថ្នាំគ្រាប់មេបង់ដាសុលក្រោយសម្រាល បើមិនបានទទួលទេ ផ្តល់មេបង់ដាសុល ១ ដូស (=៥០០មក្រ) ដល់ម្តាយ | ទទួលទានថ្នាំពេលបានទទួល |
| ១០ | បំពេញប័ណ្ណសុខភាពកុមារ និងម្តាយ និងកត់ត្រាក្នុងសៀវភៅ | យកប័ណ្ណសុខភាពកុមារ និងសៀវភៅសុខភាពមាតាមកជាមួយរាល់ពេលមកជួបពិនិត្យ |
| ១១ | ចរចាពីការត្រលប់មកជួបពិនិត្យលើកក្រោយ | ត្រលប់មកវិញដូចដែលបានចរចាគ្នា |

## ១.៨.៥ ការជួបពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ

| | បុគ្គលិកមណ្ឌលសុខភាព | ម្តាយ/ អ្នកថែទាំកុមារ |
|---|---|---|
| ១ | សួររក/ផ្តល់ប័ណ្ណសុខភាពកុមារ និងប័ណ្ណសុខភាពម្តាយ | យកប័ណ្ណសុខភាពកុមារ និងសុខភាពម្តាយមកជាមួយ |
| ២ | វាយតម្លៃសុខភាពរបស់កុមារ | |
| ៣ | វាយតម្លៃ និងផ្តល់ប្រឹក្សាស្តីអំពីការបំបៅកូនដោយទឹកដោះម្តាយ | - បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ រហូតដល់កូនអាយុ ៦ ខែ<br>- បន្តបំបៅកូនដោយទឹកដោះម្តាយរហូតដល់កូនអាយុបាន ២ ឆ្នាំ យ៉ាងតិច<br>- ចាប់ផ្តើមឱ្យអាហារបន្ថែមដល់កុមារ ក្រោយពីអាយុ ៦ ខែ ដូចដែលបានពន្យល់ |
| ៤ | ផ្តល់ប្រឹក្សាស្តីពីអាហារូបត្ថម្ភ | ផ្តល់អាហារបន្ថែមទៅតាមអាយុរបស់កុមារ |
| ៥ | ផ្តល់ថ្នាំបង្ការដល់កុមារ បើចាំបាច់ | |
| ៦ | ប្រសិនបើកុមារអាយុលើសពី ១២ ខែត្រូវផ្តល់មេបង់ដាសុលទៅតាមគោលការណ៍ណែនាំ ប្រសិនជាកុមារមិនទាន់បានទទួល | |
| ៧ | បំពេញប័ណ្ណសុខភាពកុមារ ហើយកត់ត្រានៅក្នុងសៀវភៅ | យកប័ណ្ណសុខភាពកុមារមកជាមួយរាល់ពេលមកជួបពិនិត្យ |
| ៨ | ចរចាពីការត្រលប់មកជួបពិនិត្យលើកក្រោយ | មកកាន់មណ្ឌលសុខភាពដើម្បីគាំទ្រ<br>មកកាន់មណ្ឌលសុខភាពពេលអ្នក ឬកូនអ្នកឈឺ<br>មកទទួលគ្រាប់ថ្នាំជីវជាតិអា ១ ឆ្នាំ ២ ដង |

## ១.៨.៦ ការរួមចំណែកចាយគ្រាប់ថ្នាំជីវជាតិអា

| | បុគ្គលិកមណ្ឌលសុខភាព | ម្ដាយ ឬអ្នកថែទាំកុមារ |
|---|---|---|
| ១ | សួររក/ផ្ដល់ប័ណ្ណសុខភាពកុមារ | យកប័ណ្ណសុខភាពកុមារមកជាមួយ |
| ២ | ផ្ដល់គ្រាប់ថ្នាំជីវជាតិអា និងមេបង់ដាសុល ទៅឱ្យកុមារទៅតាមពិធីសារ | |
| ៣ | ផ្ដល់ប្រឹក្សាស្ដីពីអាហារូបត្ថម្ភ និងអាហារសំបូរដោយជីវជាតិអា | ប្រើអំបិលអ៊ីយ៉ូដ<br>បរិភោគអាហារសំបូរជីវជាតិអា ជាតិដែក និងថាមពល |
| ៤ | វាយតម្លៃ និងផ្ដល់ប្រឹក្សាពីការបំបៅកូនដោយទឹកដោះម្ដាយ និងការផ្ដល់អាហារបន្ថែម | - បំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់រហូតដល់កូនអាយុ ៦ ខែ<br>- បំបៅកូនដោយទឹកដោះម្ដាយរហូតដល់កូន អាយុបាន ២ ឆ្នាំ យ៉ាងតិច<br>- ចាប់ផ្ដើមឱ្យអាហារបន្ថែមដល់កុមារ ក្រោយពីអាយុ ៦ ខែ |
| ៥ | បំពេញប័ណ្ណសុខភាពកុមារ<br>ហើយកត់ត្រានៅក្នុងសៀវភៅ។<br>ចរចាពីការត្រលប់មកជួបពិនិត្យលើកក្រោយ | - យកប័ណ្ណសុខភាពកុមារមកជាមួយរាល់ពេលមកជួបពិនិត្យ<br>- មកទទួលការថែទាំក្រោយសម្រាលតាមដំបូន្មានបុគ្គលិកមណ្ឌលសុខភាព<br>- មកកាន់មណ្ឌលសុខភាពពេលអ្នក ឬកូនអ្នកឈឺ<br>- នាំកូនរបស់អ្នកមកទទួលគ្រាប់ថ្នាំជីវជាតិអា ១ ឆ្នាំ ២ដង នៅសេវាចុះមូលដ្ឋាន ឬមណ្ឌលសុខភាព |

# ១.៩ ការវាស់វែងអំពីប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាល

**លទ្ធផលនៃការបណ្ដុះបណ្ដាលនឹងត្រូវវាស់វែងដោយៈ**

១ ការធ្វើតេស្ដមុន និងក្រោយការសិក្សា

២ ការវាយតម្លៃរយៈពេលខ្លីនៅចុងបញ្ចប់នៃថ្ងៃទី ១០

៣ របាយការណ៍ពីអ្នកទទួលខុសត្រូវអាហារូបត្ថម្ភ ស្ដីពីជោគជ័យ បញ្ហាប្រឈមមុខ និងដំណោះស្រាយដែលបានរកឃើញនៅពេលធ្វើការប្រជុំគាំទ្រមិត្តរួមការងារ។

## ១.១០ ប្រសិទ្ធភាពដ៏ល្អនៃការបណ្តុះបណ្តាល៖ ការគាំទ្រ

ដើម្បីឱ្យច្បាស់ថា ការបណ្តុះបណ្តាលមានប្រសិទ្ធភាពនោះ ការគាំទ្រក្រោយវគ្គបណ្តុះបណ្តាល គឺជាការសំខាន់។ ក្នុងរយៈពេលនៃការគាំទ្រ បញ្ហាដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍នៃអ្វីដែលបានសិក្សាក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាល ត្រូវបានលើកឡើងពិភាក្សារវាងសិក្ខាកាម ហើយបញ្ហាទាំងឡាយនោះអាចត្រូវបានដោះស្រាយ។ ការយកមកអនុវត្តន៍នូវចំណេះដឹង និងជំនាញដែលបានសិក្សាក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនឹងធ្វើឱ្យប្រសើរឡើងលើសពី ៦៥% នៅពេលដែលមានការគាំទ្រ។

មេរៀនសិក្សាស្តីពីការគាំទ្រមិត្តរួមការងារ ត្រូវបានដាក់បញ្ចូលនៅថ្ងៃចុងក្រោយបង្អស់។ មេរៀននេះ ជួយដល់សិក្ខាកាមឱ្យចេះរៀបចំសកម្មភាពគាំទ្រដៃគូរបស់ពួកគេ ដោយមានការគាំទ្រពីមន្ទីរសុខាភិបាល ខេត្ត/ស្រុកប្រតិបត្តិ។

ការគាំទ្រមិត្តរួមការងារគួរតែធ្វើនៅមណ្ឌលសុខភាព និងនៅស្រុកប្រតិបត្តិ ក្រោយពីការបណ្តុះបណ្តាលបាន ៣ ទៅ ៦ ខែ។ ការគាំទ្រមិត្តរួមការងារនេះ គឺវាមានប្រសិទ្ធភាពបំផុត ប្រសិនបើការគាំទ្រនេះធ្វើឡើងជាទៀងទាត់។ សកម្មភាពគាំទ្រមិត្តរួមការងារ អាចដាក់បញ្ចូលទៅក្នុងការប្រជុំប្រចាំខែរបស់មណ្ឌលសុខភាព។

# ០២ ការសម្របសម្រួល

## ២.១ សេចក្តីផ្តើម

ការសម្របសម្រួលមានន័យថាអ្នកធ្វើឱ្យអ្វីមួយអាចកើតឡើងបាន។ ការសម្របសម្រួលនៃការសិក្សាមានន័យថា: ជួយឱ្យនរណាម្នាក់អាចរៀនបាន។ នៅពេលអ្នកធ្វើការសម្របសម្រួលដល់ការសិក្សារបស់អ្នកណាម្នាក់នោះ អ្នកខំប្រឹងព្យាយាមដើម្បីធ្វើឱ្យការសិក្សារបស់គាត់ មានប្រសិទ្ធភាព។ ការសម្របសម្រួលការសិក្សាមួយកាន់តែល្អ អ្នកសិក្សាកាន់តែចងចាំបានល្អ និងអាចប្រើប្រាស់ចំណេះដឹង និងជំនាញដែលអ្នកជួយគាត់ឱ្យទទួលបាន។

ចំណេះដឹង និងជំនាញមានលក្ខណៈដាច់ដោយឡែកពីគ្នា។ ចំណេះដឹង គឺគ្រាន់តែផ្តល់ឱ្យនូវសារតារនៃប្រធានបទតែប៉ុណ្ណោះ។ អ្នកខ្លះមានចំណេះដឹងជ្រៅជ្រះលើប្រធានបទណាមួយ ប៉ុន្តែពុំចេះប្រើប្រាស់នូវចំណេះដឹងទាំងអស់នោះឱ្យមានប្រសិទ្ធភាពឡើយ។ អ្វីដែលជំនាញមាននោះគឺ ជាមធ្យោបាយដែលធ្វើឱ្យអ្នកណាម្នាក់អាចប្រើប្រាស់ចំណេះដឹងបាន។ ក្រៅពីចំណេះដឹង និងជំនាញ ឥរិយាបទគឺជាចំណុចទី ៣ ដែលមានសារៈសំខាន់ និងចាំបាច់។ ឥរិយាបទគឺជាអ្វីដែលចាំបាច់មួយ ដើម្បីជួយធ្វើឱ្យអ្វីដែលយើងបានសិក្សា អាចយកមកប្រើប្រាស់ជាផ្នែកមួយនៃការងារប្រចាំថ្ងៃ។ ឧទាហរណ៍: ឆ្មបម្នាក់មានចំណេះដឹងជ្រៅជ្រះ អំពីសារៈសំខាន់នៃគ្រាប់ថ្នាំជីវជាតិអា ហើយមានជំនាញសមស្របនៅក្នុងការចែកចាយគ្រាប់ថ្នាំជីវជាតិអា ប៉ុន្តែបើឆ្មបនោះមិនមានភាពរាក់ទាក់ស្និទ្ធស្នាល ស្ត្រីដែលបានមកមណ្ឌលសុខភាព នឹងមិនមកលើកក្រោយទៀតទេ ឬមួយប្រហែលជាគាត់លែងចង់ស្តាប់ឆ្មបនោះទៀតដែរ។ ដូច្នេះអ្វីៗដែលឆ្មបនោះបានរៀនសូត្រ គឺមិនមានប្រសិទ្ធភាពឡើយ ពីព្រោះគាត់មិនអាចផ្តល់ប្រឹក្សាដល់ស្ត្រីបាន។

## ២.២ សារៈសំខាន់នៃអ្នកសម្របសម្រួល

អ្នកសម្របសម្រួល គឺជាចំណែងមួយដ៏សំខាន់បំផុតដើម្បីផ្ទេរចំណេះដឹង និងជំនាញនៅក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាល។ ប្រសិនបើសិក្ខាកាមមានភាពងាយស្រួលក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាល សិក្ខាកាមនឹងទទួលការសិក្សាបានប្រសើរច្រើនជាង នៅពេលពួកគាត់មានអារម្មណភ័យខ្លាច និងមិនមានការគោរព។ ស្មេរភាពនៃការសម្របសម្រួលជាទិដ្ឋភាពមួយដ៏មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធ្វើឱ្យសិក្ខាកាមមានអារម្មណ៍ងាយស្រួល។ រាល់ការបណ្តុះបណ្តាលនិមួយៗ អ្នកសម្របសម្រួលគួរតែមានគ្នាយ៉ាងច្រើន ៤ នាក់ ហើយត្រូវមានវត្តមានក្នុងពេញវគ្គសិក្សានោះ។

អ្នកសម្របសម្រួលគួរតែត្រៀមរៀបចំនូវវគ្គនិមួយៗទុកជាមុន។ ការរៀបចំរួមមានការអាននូវជំពូកសមស្របទាំងសៀវភៅសិក្ខាកាម និងទាំងសៀវភៅអ្នកសំរបសំរួល។ ការរៀបចំនេះរួមបញ្ចូលផងដែរនូវការអានស្លាយសំរាប់បង្ហាញ កំណត់សម្គាល់ស្លាយ និងសម្ភារៈដទៃទៀតដែលចាំបាច់សំរាប់វគ្គនេះ ។

វាជាការទទួលខុសត្រូវរបស់អ្នកសម្របសម្រួលក្នុងការធ្វើឱ្យប្រាកដថាម៉ោងសិក្សានិមួយៗ មានដំណើរការប្រកបដោយភាពរលូនជាមួយនឹងសម្ភារៈថតចម្លងនានា សម្ភារៈប្រើប្រាស់មានដំណើរការបានល្អ និងការរៀបចំកន្លែងអង្គុយបានសមស្រប។ ចំនុចសំខាន់មួយទៀតនៃការសម្របសម្រួលនោះគឺ ធ្វើការវាយតម្លៃវគ្គបណ្តុះបណ្តាល។ ថ្ងៃសិក្សានិមួយៗ គួរបញ្ចប់ដោយការវាយតម្លៃប្រចាំថ្ងៃ ដែលមានលក្ខណៈសាមញ្ញ ដែលធ្វើឡើងដោយសិក្ខាកាម ប៉ុន្តែគួរមានការផ្តល់ព័ត៌មានត្រលប់របស់អ្នកសម្របសម្រួលផងដែរ។ នៅចុងបញ្ចប់នៃថ្ងៃសិក្សានិមួយៗ អ្នកសម្របសម្រួលទាំងអស់ត្រូវជួបជុំគ្នា ប្រហែល ២០ នាទី ដើម្បីវាយតម្លៃប្រចាំថ្ងៃ និងរៀបចំសំរាប់ថ្ងៃបន្ត។

## ២.៣ ការសម្របសម្រួលដ៏មានប្រសិទ្ធភាព

**ការសម្របសម្រួលដែលមានប្រសិទ្ធភាពអាចប្រព្រឹត្តទៅបានដោយការប្រើប្រាស់:**

១ ការគួបផ្សំនៃបទបាឋកថា លំហាត់ និងការអនុវត្តន៍

២ ការប្រើប្រាស់វិធីសាស្ត្របង្រៀនចំរុះ

៣ ការលេងល្បែងកំសាន្តដូចជា ការបំបែកដុំទឹកកក និងល្បែងថាមពល

៤ សកម្មភាពដែលមានការចូលរួម

## ២.៤ សកម្មភាព

នៅក្នុងអំឡុងពេលការបណ្តុះបណ្តាលសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ បទបាឋកថានឹងត្រូវបានធ្វើឡើងក្នុងរយៈពេលខ្លី និងមិនត្រូវឱ្យលើសពីមួយម៉ោងឡើយ។ ចំពោះការធ្វើបទបាឋកថា ស្លាយសំរាប់បង្ហាញ និងកំណត់សម្គាល់ទាំងឡាយផ្តល់នូវព័ត៌មានដែលចាំបាច់ទាំងអស់។

បន្ទាប់ពីបទបាឋកថា មានការធ្វើលំហាត់បែបបុគ្គល លំហាត់ដែលធ្វើជាគូ ឬការងារជាក្រុម។ នៅក្នុងអំឡុងពេលការធ្វើសកម្មភាពទាំងនេះ អ្នកសម្របសម្រួលគួរដើរជុំវិញដោយធ្វើការសង្កេតមើល តើមានអ្វីកើតឡើង (ឧទាហរណ៍: មើលឃើញ ស្តាប់លឺ និងយល់ពីអ្វីដែលសិក្ខាកាមកំពុងធ្វើ)។ បើចាំបាច់ អ្នកសម្របសម្រួលគួរតែធ្វើការណែនាំទៅដល់សិក្ខាកាមអំពីលំហាត់របស់ពួកគាត់ ដោយផ្តល់ព័ត៌មាន ឬធ្វើសំណួមពរឱ្យរកមធ្យោបាយផ្សេងៗទៀតដើម្បីដំណើរការ។ ក្រោយសកម្មភាពនិមួយៗ អ្នកសម្របសម្រួលគួរតែធ្វើការសង្ខេប លើកពីចំនុចសំខាន់ៗ និងស្រាយបំភ្លឺរាល់ទស្សនៈយល់ខុសទាំងឡាយ។

## ២.៥ ការប្រជុំអ្នកសម្របសម្រួល

នៅចុងបញ្ចប់នៃថ្ងៃសិក្សានិមួយៗ អ្នកសម្របសម្រួលប្រជុំគ្នាដើម្បីធ្វើការវាយតម្លៃប្រចាំថ្ងៃ។ ពួកគាត់ពិភាក្សាគ្នាអំពីអ្វីខ្លះដែលដំណើការទៅល្អ និងអ្វីខ្លះដែលដំណើរការទៅមិនសូវបានល្អ។ អ្នកសម្របសម្រួលអាចផ្តល់ដំបូន្មានឱ្យគ្នាទៅវិញទៅមកពីរបៀបសម្របសម្រួលក្រុម តើសិក្ខាកាមណា ឬក្រុមសិក្ខាកាមណាត្រូវការ ការយកចិត្តទុកដាក់បន្ថែម និងវិធីសាស្ត្រដើម្បីគាំទ្រដល់ពួកគាត់។ ការវាយតម្លៃប្រចាំថ្ងៃរបស់សិក្ខាកាម អាចជាជំនួយដល់អ្នក

សម្របសម្រួល ។ ការប្រជុំអ្នកសម្របសម្រួលក៏ផ្តល់ពេលវេលាដើម្បីរៀបចំផែនការសំរាប់ថ្ងៃបន្ទាប់ផងដែរ ។ តើអ្នកណានឹងត្រូវធ្វើអ្វី? តើមានការផ្លាស់ប្តូរចាំបាច់ណាមួយទេនៅក្នុងកម្មវិធីនេះ? ការរៀបចំដែលចាំបាច់សំរាប់ថ្ងៃនោះ តើអ្នកណាជាអ្នករៀបចំ? ហើយរៀបចំនៅពេលណា?

បញ្ជីផ្ទៀងផ្ទាត់ខាងក្រោមនេះ គឺជាជំនួយដល់អ្នកសម្របសម្រួល ។ ការប្រជុំអ្នកសម្របសម្រួលជាធម្មតា តែងចំណាយពេលប្រហែល ៣០ នាទី ប៉ុន្តែអាចប្រើពេលយូរជាងនេះ អាស្រ័យលើអ្នកសម្របសម្រួល ។

## ២.៦ ជាអ្នកសម្របសម្រួលម្នាក់ដែលមានប្រសិទ្ធភាព

១ រៀបចំមេរៀនសិក្សាបានល្អ

២ មានវិជ្ជាជីវៈ និងមានភាពស្អិទ្ធស្អាល

៣ បង្កើតបរិយាកាសប្រកបដោយសុវត្ថិភាពមួយដើម្បីរៀនសូត្រ

៤ យល់ដឹងទូលំទូលាយ

៥ មានការយកចិត្តទុកដាក់រៀងរាល់ពេល

៦ ធ្វើការសង្កេតរាល់សកម្មភាពនិមួយៗ

៧ មកដល់បន្ទប់រៀនទាន់ពេល ចាប់ផ្តើមតាមពេលវេលា បញ្ចប់ត្រឹមត្រូវទាន់ពេល

៨ ចូលរួមការប្រជុំអ្នកសម្របសម្រួលនៅរាល់ការបញ្ចប់ថ្ងៃសិក្សា ដើម្បីវាយតម្លៃថ្ងៃសិក្សា និងរៀបចំសកម្មភាពសំរាប់ថ្ងៃបន្ទាប់ទៀត

**អ្នកសម្របសម្រួលល្អ គឺតែងតែប្រើប្រាស់សកម្មភាពចូលរួម និងតែងតែធ្វើការច្រើនជាងសិក្ខាកាមផ្តល់ព័ត៌មានត្រលប់ មតិយោបល់ និងធ្វើការគាំទ្រអំពីការសិក្សាៗ**

# ការសម្របសម្រួលលំហាត់ទី ១:
## អ្នកសម្របសម្រួលល្អ (៤៥នាទី)

**គោលបំណង :** ដើម្បីអោយមានការឯកភាពគ្នាលើជំនាញនៃការសម្របសម្រួលដែលចង់បានសំរាប់អ្នកសម្របសម្រួល

**អ្នកណា :** ក្រុមដែលមានគ្នាចំនួន ៤ នាក់ (យ៉ាងច្រើន)

**សម្ភារៈ :** ក្រដាសផ្ទាំងធំ២ផ្ទាំង ដោយមានរូបតុក្កតាគូរនៅលើនោះ
ប៊ិចហ្វឺត
បង់ស្កុត

### សន្និទានភាព :

លំហាត់នៃការសម្របសម្រួលនេះ គឺសំរាប់តែការបណ្តុះបណ្តាលអ្នកសម្របសម្រួលប៉ុណ្ណោះ។ លំហាត់នេះផ្តោតទៅ លើលក្ខណៈវិនិច្ឆ័យនៃអ្នកសម្របសម្រួលល្អ។ លំហាត់ខាងក្រោមនេះ នឹងរៀបរាប់លំអិតពីវិធីដែលមានលក្ខណៈជាការអនុវត្តន៍ជាក់លាក់ជាង។

### ការណែនាំ:

ផ្តល់ដល់ក្រុមនិមួយៗនូវក្រដាសផ្ទាំងធំចំនួនពីរផ្ទាំងដែលមានរូបតុក្កតានៅលើនោះ។ ក្រដាសផ្ទាំងធំ ទី១ គឺសំរាប់កត់ត្រាអំពីចរិកលក្ខណៈនៃអ្នកសម្របសម្រួលល្អ។ ឯផ្ទាំងក្រដាសទី ២ គឺសំរាប់កត់ត្រាអំពី ចរិកលក្ខណៈនៃអ្នកសម្របសម្រួលដែលមិនល្អ។ ក្រដាសផ្ទាំងធំទី ១ គឺនឹងឆ្លុះបញ្ចាំងទៅនឹងជំនាញសម្របសម្រួលដែលចង់បាន ហើយក្រដាសផ្ទាំងធំទី ២ គឺជាការសម្របសម្រួលដែលគេមិនចង់បាន។ ចូលប្រាប់ទៅសិក្ខាកាមថា ពួកគាត់អាចធ្វើការឆ្នៃប្រឌិត។

អនុញ្ញាតិឱ្យក្រុមនិមួយៗបញ្ចប់ការងារនេះក្នុងរយៈពេល ១០ នាទី។ បន្ទាប់មកក្រុមនិមួយៗមានពេល ៥ នាទី ដើម្បីធ្វើការបង្ហាញ។ បន្ទាប់ពីការបង្ហាញ អ្នកសម្របសម្រួលនឹងធ្វើការសង្ខេប ព្រមទាំងធ្វើការបង្ហាញអំពីមាតិកានៃជំពូកនេះ។

# ការសម្របសម្រួលលំហាត់ទី ២៖
## ការវាយតម្លៃការសម្របសម្រួល (កំពុងដំណើរការ ១០នាទី)

**គោលបំណង ៖** ដើម្បីវាយតម្លៃការសម្របសម្រួល និងបញ្ចូលបទពិសោធនមេរៀនទៅលើជំនាញសម្របសម្រួលផ្ទាល់ខ្លួន។

**អ្នកណា ៖** សិក្ខាកាម

**សម្ភារៈ៖** បញ្ជីផ្ទៀងផ្ទាត់ការសម្របសម្រួល

### សន្និទានភាព ៖

ជំនាញនៃការសម្របសម្រួល គឺជាអ្វីដែលបានរៀនតាមរយៈការអនុវត្តនជាក់ស្តែង និងតាមរយៈការយកគំរូតាមនូវអ្វីដែលអ្នកសម្របសម្រួលផ្សេងៗទៀតធ្វើ។ បញ្ជីផ្ទៀងផ្ទាត់ការសម្របសម្រួលនឹងជួយដល់សិក្ខាកាម សំរាប់វាយតម្លៃវិធីសម្របសម្រួលនៅក្នុងមេរៀនសិក្សានិមួយៗ និងអាចប្រើប្រាស់ដើម្បីពិភាក្សាលើការសម្របសម្រួល។ ក្នុងវគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួល អ្នកសម្របសម្រួលម្នាក់ៗគួរត្រូវបានវាយតម្លៃលើជំនាញនៃការសម្របសម្រួលរបស់ខ្លួន។

### ការណែនាំ៖

ជាសំណើ គឺថា រាល់មេរៀនអនុវត្តន៍ជាក់ស្តែងនៃ "វគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួល" (គ្រប់មេរៀនទាំងអស់លើកលែងតែបាឋកថា) ត្រូវបានសម្របសម្រួលដោយសិក្ខាកាមម្នាក់។ សិក្ខាកាមផ្សេងទៀតនិងអ្នកសម្របសម្រួលទាំងអស់ធ្វើទៅតាមមេរៀននេះ ដែលដឹកនាំការសម្របសម្រួលដោយសិក្ខាកាម ឬអ្នកសម្របសម្រួលហើយវាយតម្លៃជំនាញសម្របសម្រួលនៅចុងបញ្ចប់នៃមេរៀនដោយប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ការសម្របសម្រួល។ នៅចុងបញ្ចប់នៃមេរៀននិមួយៗ ចំណាយពេលខ្លីមួយដើម្បីធ្វើការពិភាក្សាពីជំនាញនៃការសម្របសម្រួល។

ចូរពន្យល់ទៅសិក្ខាកាមថា ការផ្តល់ព័ត៌មានត្រលប់ គឺមានសារៈសំខាន់ខ្លាំងណាស់សំរាប់ការសិក្សា។ វិធីនៃការផ្តល់ព័ត៌មានត្រលប់គឺមានសារៈសំខាន់ខ្លាំង។ ការផ្តល់ព័ត៌មានត្រលប់មិនគួរផ្តល់តាមលក្ខណៈប្រឈមមុខដាក់គ្នានោះទេ ប៉ុន្តែគួរផ្តល់ក្នុងលក្ខណៈវិជ្ជមានជានិច្ច។ ឧទាហរណ៍៖

"ខ្ញុំចូលចិត្តរបៀបដែលអ្នកនិយាយ... ប៉ុន្តែវាអាចមានប្រសិទ្ធភាពជាងនេះទៅទៀត ប្រសិនបើ..."

ជំនួសដោយប្រយោគដែលថា៖

"ធ្វើរបៀបហ្នឹងគឺអាក្រក់ណាស់ ។ លើកក្រោយអ្នកគួរតែធ្វើតាមរបៀបនេះវិញ ..."

នៅក្នុងឧទាហរណ៍ទី១ ការផ្តល់ព័ត៌មានត្រលប់ ធ្វើឡើងតាមបែបវិជ្ជមាន និងប្រកបដោយការស្វាគមន៍។ ឧទាហរណ៍ទី២ គឺមានលក្ខណៈអវិជ្ជមាន ហើយលក្ខណៈបែបនេះវាពុំបង្កើតបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពនោះឡើយ។

វិធីផ្តល់ព័ត៌មានត្រលប់ទៅកាន់សិក្ខាកាមបែបនេះហៅថា "គំរូសាំងវិច" ។ តំបូងអ្នកត្រូវផ្តល់កំណត់សម្គាល់ វិជ្ជមាន (នំប៉័ងមួយបន្ទះ) បន្ទាប់មកអ្នកត្រូវផ្តល់យោបល់ (សាច់នៅចន្លោះ) ហើយបន្ទាប់មកទៀតអ្នកត្រូវ បញ្ចប់ដោយកំណត់សម្គាល់វិជ្ជមានមួយទៀត (នំប៉័ងមួយបន្ទះទៀត)។

ចំណាយពេលប្រហែល ១០នាទី ក្រោយពីមេរៀន និមួយៗក្នុងការផ្តល់ព័ត៌មានត្រលប់ជាក្រុមទៅឱ្យអ្នកសម្របសម្រួល។

# ថ្ងៃសិក្សាទី ១- អាហារូបត្ថម្ភ និងសម្ភារៈ

## គោលបំណង ៖

១ ដើម្បីណែនាំសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០ នៃអាហារូបត្ថម្ភទៅដល់សិក្ខាកាម

២ ដើម្បីផ្តល់នូវទស្សនៈទូទៅនៃអាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា និងកម្មវិធីជាតិអាហារូបត្ថម្ភនៃប្រទេសកម្ពុជា

៣ ដើម្បីអោយសិក្ខាកាមស្គាល់នូវសម្ភារៈជំនួយការងារ ដែលសម្ភារៈទាំងនេះគឺជាគន្លឹះសំរាប់ការផ្តល់ការប្រឹក្សាប្រកបដោយប្រសិទ្ធភាព

## គោលបំណងជំនាញថ្ងៃទី ១ សំរាប់សិក្ខាកាម

នៅចុងបញ្ចប់នៃថ្ងៃនេះ សិក្ខាកាមនឹងអាច

១ ធ្វើការប្រស្រ័យទាក់ទងដោយមានទំនុកចិត្ត ថាហេតុអ្វីបានជាពួកគាត់គឺជាមនុស្សសារៈសំខាន់ក្នុងការផ្តល់សារអាហារូបត្ថម្ភ និងផ្តល់ប្រឹក្សាដល់ស្រ្តីស្តីអំពីអាហារូបត្ថម្ភ

២ ធ្វើការប្រស្រ័យទាក់ទងអំពីការទទួលខុសត្រូវរបស់ពួកគេចំពោះសកម្មភាពអាហារូបត្ថម្ភ

៣ ផ្តល់ប្រឹក្សាដល់ស្រ្តីអំពីការជ្រើសរើសក្រុមអាហារផ្សេងៗគ្នា និងអាហារដែលមានតុល្យភាពសំរាប់ក្រុមគោលដៅ

# កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៧:៣០ | ៦០ | ១.១ | ពិធីបើកវគ្គ | មន្ត្រី |
| ៨:៣០ | ៣០ | ១.២ | តើអ្នកឈ្មោះអ្វី?<br>ការបំបែកដុំទឹកកកដើម្បីឱ្យសិក្ខាកាម<br>ស្គាល់ឈ្មោះគ្នាទៅវិញទៅមក | ទាំងអស់គ្នា |
| ៩:០០ | ៣០ | ១.៣ | តើយើងចេះអ្វី?<br>ការធ្វើតេស្តដើម្បីវាស់ចំណេះដឹងសិក្ខាកាម | ទាំងអស់គ្នា |
| ៩:៣០ | ២០ | | សម្រាក | |
| ៩:៥០ | ១៥ | ១.៤ | គោលបំណងនៃ MPA ១០ និងថ្ងៃទី១<br>បាឋកថាស្តីពីគោលបំណងនៃម៉ូឌុលនិងថ្ងៃទី១ | អ្នកសម្របសម្រួល |
| ១០:០៥ | ៣០ | ១.៥ | តួនាទីសំខាន់របស់បុគ្គលិកមណ្ឌលសុខភាពចំពោះ<br>សកម្មភាពអាហារូបត្ថម្ភ<br>ពិភាក្សា និងសង្ខេប | ក្រុម |
| ១០:៣៥ | ១៥ | ១.៦ | ការទទួលខុសត្រូវនិងតួនាទីរបស់បុគ្គលិកមណ្ឌលសុខភាព<br>បាឋកថា | អ្នកសម្របសម្រួល |
| ១០:៥០ | ៣០ | ១.៧ | ការបង្ហាញពីសម្ភារៈជំនួយការងារ<br>បាឋកថាពីការជួបពិនិត្យថែទាំសំខាន់ៗនិងសម្ភារៈ<br>ជំនួយការងារ | អ្នកសម្របសម្រួល |
| ១១:២០ | ១០ | ១.៨ | សេចក្តីសន្និដ្ឋាននៅពេលព្រឹក<br>សង្ខេប | អ្នកសម្របសម្រួល |
| ១១:៣០ | ១២០ | | សម្រាក | |
| ១៣:៣០ | ១០ | ១.៩ | តើអ្វីនៅពីក្រោយខ្នងអ្នក?<br>លំហាត់ថាមពល ដើម្បីបង្កើនការលើកទឹកចិត្ត | ក្រុម |
| ១៣:៤០ | ៥០ | ១.១០ | អាហារូបត្ថម្ភទូទៅ<br>បាឋកថាពីសារៈសំខាន់នៃសារអាហារូបត្ថម្ភ | អ្នកសម្របសម្រួល |
| ១៤:៣០ | ៤០ | ១.១១ | អាហារដែលសំបូរទៅដោយ ...<br>លំហាត់សំរាប់បុគ្គលម្នាក់ៗ ឬជាគូ ដើម្បីកំណត់រកអាហារ<br>សំបូរជីវជាតិអា ជាតិដែក អ៊ីយ៉ូដ | សិក្ខាកាមម្នាក់ៗ |
| ១៥:១០ | ២០ | | សម្រាក | |
| ១៥:២០ | ៣០ | ១.១២ | តើយើងត្រូវធ្វើអ្វី នៅពេលណា?<br>លំហាត់សំរាប់បុគ្គលម្នាក់ៗ ដើម្បីធ្វើការសម្រេចចិត្តថា<br>នៅពេលណាបុគ្គលិកមណ្ឌលសុខភាពត្រូវធ្វើអ្វី? | សិក្ខាកាមម្នាក់ៗ |
| ១៥:៥០ | ៤៥ | ១.១៣ | ដាក់អាហារពេលរួមគ្នា<br>ការងារជាក្រុមដើម្បីធ្វើម្ហូបដែលសំបូរទៅដោយ<br>សារជាតិចិញ្ចឹម | ក្រុម |
| ១៦:៣៥ | ២៥ | ១.១៤ | សេចក្តីសន្និដ្ឋានសំរាប់ពេលរសៀល<br>សង្ខេប | |
| ១៧:០០ | | | ចប់ថ្ងៃទីមួយ | |

## សម្ភារៈដែលត្រូវការ ៖

- ភ្លេងជាតិ
- កូនបាលតូចៗចំនួន ៣
- ក្រដាសថតចម្លងសំណួរសាកល្បង
- ក្រដាសផ្ទាំងធំដែលមានសរសេរគោលបំណងនៃការបណ្តុះបណ្តាលលើនោះ
- ផ្ទាំងក្រដាសធំ ដែលមានរូបតុក្កតា
- ប៊ិចហ្វឺត
- បង់ស្អិត
- ក្រដាសផ្ទាំងធំដែលមានរូបនាឡិកាបង្ហាញពេលវេលានៅលើនោះ
- ស្លាយទី ១-៣១
- រូបភាពមុខម្ហូបខ្មែរមួយសំរាប់ (សេចក្តីបន្ថែម)

# សកម្មភាពថ្ងៃទី ១

## ១.១ ពិធីបើកវគ្គ (៦០ នាទី)

**គោលបំណង** ៖ ដើម្បីបើកវគ្គបណ្តុះបណ្តាលដល់សិក្ខាកាម

**អ្នកណា** ៖ មន្ត្រី

**សម្ភារៈ** ៖ ភ្លេងជាតិ

## ១.២ តើអ្នកឈ្មោះអ្វី? (៣០ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងចាំឈ្មោះគ្នាទៅវិញទៅមក

**វិធីសាស្ត្រ** ៖ ការបំបែកដុំទឹកកក

**អ្នកណា** ៖ សិក្ខាកាមទាំងអស់ សម្របសម្រួលដោយអ្នកសម្របសម្រួលម្នាក់

**សម្ភារៈ** ៖ កូនបាល់តូចៗចំនួន៣ ដែលមានពណ៌ខុសៗគ្នា

**ការណែនាំ:**

- ផ្តល់នូវផ្លាកសុី គឺទៅដល់សិក្ខាកាម និងអ្នកសម្របសម្រួល ។ សុំឱ្យពួកគាត់ឱ្យសរសេរឈ្មោះពួកគាត់នៅលើផ្លាក ហើយបិទជាប់នៅទ្រូង ។
- អញ្ជើញសិក្ខាកាម និងអ្នកសម្របសម្រួលឱ្យឈរជារង្វង់មូល ។ សុំឱ្យពួកគាត់ចងចាំឈ្មោះ និងទីកន្លែងធ្វើការរបស់សិក្ខាកាមផ្សេងទៀត ។
- ដំបូងចាប់ផ្តើមដោយការប្រាប់ឈ្មោះ និងទីកន្លែងធ្វើអោយគ្នាទៅវិញទៅមកមួយជុំ ។ បន្ទាប់មកប្រាប់ឈ្មោះ និងទីកន្លែងធ្វើការមួយជុំទៀត ប៉ុន្តែអោយលឿនតាមដែលអាចធ្វើទៅបាន ។
- ចាប់ផ្តើមបង្ហាញកូនបាល់ និងប្រាប់ដល់សិក្ខាកាមឱ្យបោះកូនបាល់ទៅឱ្យម្នាក់ទៀត និងបោះបាល់ ជាបន្តបន្ទាប់ដោយហៅឈ្មោះរបស់គេផង ។ ប្រាប់ដល់សិក្ខាកាមទាំងអស់ឱ្យចាំអ្នកដែលគាត់បានបោះបាល់ទៅឱ្យ ។ ប្រាប់ពួកគាត់ឱ្យលើកដៃខ្វែងបន្ទាប់ពីបានបោះបាល់រួចដើម្បីឱ្យបានប្រាកដថា រាល់សិក្ខាកាមទាំងអស់ពិតជាទទួលបាននូវកូនបាល់នេះគ្រប់ៗគ្នា ។
- នៅពេលដែលសិក្ខាកាមលើកដៃខ្វែងគ្រប់គ្នាអស់ហើយ ល្បែងនេះត្រូវលេងម្តងទៀត ព្រមទាំងចាប់ផ្តើមបង្ហាញបាល់ទីពីរ និងទីបី ។ បាល់ទីពី គឺនិយាយអំពីទីកន្លែងធ្វើការ និងបាល់ទីបីប្រាប់ពីអ្វីដែលសិក្ខាកាមចូលចិត្តធ្វើនៅពេលគាត់មានពេលទំនេរ ។

## ១.៣ តើអ្នកចេះអ្វីខ្លះ (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាម និងអ្នកសម្របសម្រួលនឹងដឹងអំពីចំណេះដឹង និងជំនាញរបស់សិក្ខាកាមមុនចាប់ផ្តើមការបណ្តុះបណ្តាល ។

**វិធីសាស្ត្រ** : ការធ្វើតេស្តសាកល្បង

**នរណា** : សិក្ខាកាមម្នាក់ៗ

**សម្ភារៈ** : សន្លឹកថតចម្លងសំណួរសាកល្បង (សេចក្តីបន្ថែម)

**ការណែនាំ:**

- ពន្យល់ទៅដល់សិក្ខាកាមថាការធ្វើសំណួរសាកល្បងនេះ គឺដើម្បីផ្តល់នូវព័ត៌មានអំពីចំណេះដឹង និងជំនាញរបស់ពួកគាត់ម្នាក់ៗនៅមុនពេលធ្វើការបណ្តុះបណ្តាល ។ លទ្ធផលដែលប្រមូលបាននឹងត្រូវយកទៅប្រៀបធៀបជាមួយលទ្ធផលនៃការធ្វើតេស្តក្រោយពេលសិក្សា ដែលនឹងត្រូវធ្វើម្តងទៀតនៅក្រោយវគ្គបណ្តុះបណ្តាល ។
- ប្រាប់ទៅដល់សិក្ខាកាមឱ្យអង្គុយនៅឆ្ងាយៗពីគ្នា
- ពន្យល់ពួកគាត់ថា ម្នាក់ៗត្រូវឆ្លើយទៅនឹងសំណួរដែលមាននៅលើក្រដាសទៅតាមការយល់ឃើញរបស់ខ្លួន ។ ពួកគាត់មានពេលចំនួន ៣០ នាទី ដើម្បីបំពេញសំនួរសាកល្បងនេះ ។
- នៅពេលបំពេញសំណួររួចរាល់ហើយនោះ សិក្ខាកាមទាំងអស់ត្រូវរក្សាភាពស្ងៀមស្ងាត់ ដើម្បីទុកពេលឱ្យសិក្ខាកាមឯទៀតបំពេញសំណួររបស់ពួកគាត់ ។
- ការប្រើប្រាស់សៀវភៅ ឬ សម្ភារៈជំនួយការងារមិនត្រូវបានអនុញ្ញាតិនៅពេលកំពុងធ្វើតេស្តនេះ ។

**សម្រាក (២០ នាទី)**

## ១.៤ គោលបំណងនៃការសិក្សាថ្ងៃទី ១ នៃសំណុំសកម្មភាពអប្បបរមា ម៉ូឌុលទី ១០ (១៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមដឹងអំពីគោលបំណងនៃការសិក្សាថ្ងៃទី ១ នៃសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០។

**វិធីសាស្ត្រ** : បាឋកថា

**នរណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយបង្ហាញ ១-១៣

**សៀវភៅសិក្ខាកាម :** ជំពូក ១.២

### ការណែនាំៈ

- ធ្វើការបង្ហាញ និងពន្យល់តាមស្លាយ ១-១៣ ទៅដល់សិក្ខាកាម

## ១.៥ សារៈសំខាន់របស់បុគ្គលិកមណ្ឌលសុខភាពចំពោះអាហារូបត្ថម្ភ (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ បុគ្គលិកមណ្ឌលសុខភាពអាចបញ្ជាក់ថាហេតុអ្វីបានជា បុគ្គលិកមណ្ឌលសុខភាព គឺជាមន្ត្រីរាជការដ៏មានសារៈសំខាន់ក្នុងការផ្តល់នូវសារ និងការផ្តល់ប្រឹក្សាដល់ស្ត្រីមានផ្ទៃពោះ និងម្តាយអំពីអាហារូបត្ថម្ភ។

**វិធីសាស្ត្រ** : ការពិភាក្សា

**នរណា** : ក្រុមសិក្ខាកាមដែលមានសមាជិក ៥ នាក់

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលបានរៀបចំជាស្រេច និងរូបតុក្កតាដែលបានគូរនៅលើនោះ ប៊ិចហ្វិត

**សៀវភៅសិក្ខាកាម :** ជំពូក ១.៣ - ១.៤

### ការណែនាំៈ

- ប្រាប់សិក្ខាកាមថា ពួកគាត់គឺជាបណ្តាញដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្តល់សារអប់រំអាហារូបត្ថម្ភ ដល់ស្ត្រីមានផ្ទៃពោះ និងមាតា។
- សួរសិក្ខាកាមថាៈ ហេតុអ្វីបានជាបុគ្គលិកមណ្ឌលសុខភាព គឺជាបណ្តាញដ៏មានប្រសិទ្ធភាពក្នុងការផ្តល់សារអប់រំ អាហារូបត្ថម្ភទៅដល់ស្ត្រី និងមាតា?
- រៀបចំក្រុមដែលមានសមាជិកចំនួន ៥នាក់ ក្នុងមួយក្រុម និងផ្តល់ឱ្យនូវក្រដាសផ្ទាំងធំ ១ សន្លឹក ដែលបានរៀបចំទុកជាមុន និងប៊ិចហ្វឺត។ ពន្យល់ឱ្យសរសេររាល់មតិយោបល់របស់ពួកគាត់នៅផ្នែកខាងឆ្វេងនៃក្រដាសផ្ទាំងធំ។ សុំឱ្យពួកគាត់សរសេរនូវគំនិតរបស់ក្រុមដែលថាតើហេតុអ្វីបានជាយើង (បុគ្គលិកមណ្ឌលសុខភាព)

គឺជាអ្នកដ៏មានប្រសិទ្ធភាពក្នុងការផ្តល់សារអប់រំស្តីពីអាហារូបត្ថម្ភ ទៅដល់ស្ត្រី និងម្តាយៗ។

- ចូរធ្វើឱ្យមានសកម្មភាពផ្ទៃប្រឌិត និងរស់រវើក។
- នៅពេលដែលក្រុមបានបញ្ចប់ការពិភាក្សារួចរាល់ សុំឱ្យពួកគាត់ធ្វើការពិភាក្សាអំពីតួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកមណ្ឌលសុខភាពក្នុងសកម្មភាពអាហារូបត្ថម្ភ។
- ប្រាប់ដល់ពួកគាត់ឱ្យកត់ត្រានូវមតិយោបល់នៅផ្នែកខាងស្តាំនៃក្រដាសផ្ទាំងធំ។
- សុំឱ្យពួកគាត់ ចេះធ្វើការឆ្នៃប្រឌិត។
- នៅពេលដែលក្រុមទាំងអស់បានបញ្ចប់ការពិភាក្សារួចរាល់ហើយ ចូរសុំឱ្យពួកគាត់យកក្រដាសផ្ទាំងធំទាំងនោះទៅបិទនឹងជញ្ជាំង។ ទុករយៈពេល ៥ នាទី ដើម្បីឱ្យសិក្ខាកាមមើលគំនិតដែលបានសរសេរលើក្រដាសផ្ទាំងធំ។ ពុំមានការឡើងបង្ហាញទេ។

## ១.៦ តួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកមណ្ឌលសុខភាពចំពោះអាហារូបត្ថម្ភ (១៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងយល់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកមណ្ឌលសុខភាពចំពោះអាហារូបត្ថម្ភ

**វិធីសាស្ត្រ :** បាឋកថា

**នរណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ក្រដាសផ្ទាំងធំ ស្លាយទី ១៤-១៦

**សៀវភៅសិក្ខាកាម :** ជំពូក ១.៣-១.៤

### ការណែនាំ:

- ធ្វើការប្រៀបធៀបគំនិតរបស់ក្រុមនិមួយៗ ដែលមាននៅលើក្រដាសផ្ទាំងធំ
- គូសចំណាំនូវមតិយោបល់ណាដែលប្រហាក់ប្រហែលគ្នា និងមតិយោបល់ណាខ្លះដែលខុសគ្នា។
- សង្ខេបដោយធ្វើការប្រៀបធៀបលទ្ធផលរបស់ក្រុម ជាមួយការបង្ហាញស្លាយទី ១៤, ១៥ និង១៦

## ១.៧ ការបង្ហាញពីសម្ភារៈជំនួយការងារ (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចប្រើប្រាស់សម្ភារៈជំនួយការងារ សំរាប់ការជួបពិនិត្យថៃទាំ ស្តីពីអាហារូបត្ថម្ភ

**វិធីសាស្ត្រ :** បាឋកថា និងសំណួរចម្លើយ

**នរណា :** អ្នកសម្របសម្រួល

**សម្ភារៈ:**	សម្ភារៈជំនួយការងារ ស្លាយបង្ហាញ ១៧ និង ១៨

**ការណែនាំ:**

- បង្ហាញសិក្ខាកាមនូវស្លាយទី ១៧ ដែលមានការជួបពិនិត្យផ្ទៃទាំសំខាន់ៗដែលទាក់ទងនឹងអាហារូបត្ថម្ភ
- ពន្យល់ពីសារអប់រំអាហារូបត្ថម្ភ និងសកម្មភាពដែលបញ្ជ្រៀតចូលគ្នាទៅក្នុងសេវាសុខាភិបាល
- បង្ហាញស្លាយទី ១៨
- បង្ហាញសម្ភារៈជំនួយការងារ និងបង្ហាញពីរបៀបដែលសម្ភារៈជំនួយការងារទាំងនេះ រៀបចំឡើង

## ១.៨ សេចក្តីសន្និដ្ឋានសំរាប់ពេលព្រឹក (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តទៅលើចំណេះដឹង និងជំនាញដែលបានរៀន
**វិធីសាស្ត្រ :** សង្ខេប
**នរណា :** អ្នកសម្របសម្រួល
**សម្ភារៈ :** ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងបង្ហាញពីពេលវេលា

**ការណែនាំ:**

សង្ខេប និងរំលឹកឡើងវិញនូវអ្វីដែលបានរៀនកាលពីព្រឹក

- ហេតុអ្វីបានជាបុគ្គលិកមណ្ឌលសុខភាពជាបុគ្គលសំខាន់ចំពោះការងារអាហារូបត្ថម្ភ
- តួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកមណ្ឌលសុខភាពចំពោះការងារអាហារូបត្ថម្ភ
- គោលបំណង និងការប្រើប្រាស់សម្ភារៈជំនួយការងារ

ធ្វើការបង្ហាញក្រដាសផ្ទាំងធំជាមួយតារាងកាលវិភាគ និងម៉ោងដែលសិក្ខាកាមត្រូវត្រឡប់មកវិញ។

**សម្រាក (១២០ នាទី)**

## ១.៩ តើអ្វីនៅពីក្រោយខ្នងអ្នក? (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីនាពេលល្ងាច
**វិធីសាស្ត្រ :** ល្បែងថាមពល
**នរណា :** សិក្ខាកាម និងអ្នកសម្របសម្រួលនៅក្នុងក្រុមដែលមានសមាជិក ១០ នាក់។
**សម្ភារៈ :** ក្រដាសអា៤ដែលមានរូបភាពជារបស់ដែលយើងជួបប្រទះរាល់ថ្ងៃ (ច្រាសដុះធ្មេញ ផ្លែម្នាស់ ។ល។) បង់ស្អិតសំរាប់បិទទៅលើខ្នងរបស់សិក្ខាកាម

### ការណែនាំ:

- ប្រាប់ដល់សិក្ខាកាមថាការធ្វើលំហាត់នេះ គឺដើម្បីបង្កើតថាមពលនៅក្រោយការបរិភោគអាហាររួច។ ក្រោយពីធ្វើលំហាត់ថាមពលរួច សិក្ខាកាមទាំងអស់អាចផ្ទង់គំនិតមកលើការសិក្សាបានច្រើន ហើយលទ្ធផលនឹងទទួលបានល្អប្រសើរ។
- ធ្វើការពន្យល់ដល់សិក្ខាកាមថា នៅក្នុងក្រុមនិមួយៗ សិក្ខាកាមម្នាក់នឹងសុំឱ្យនៅឆ្ងាយពីក្រុម។ ហើយសមាជិកនៃក្រុមសម្រេចចិត្តគូររូបអ្វីមួយដែលគេចង់គូរ ហើយបិទនៅលើខ្នងអ្នកសមាជិកដែលឈពីមុខបន្តគ្នា
- នៅពេលដែលពួកគាត់គូររួចហើយ ពួកគាត់បិទរូបនេះនៅលើខ្នងសមាជិកក្រុមរបស់ខ្លួនម្នាក់នោះ ដោយមិនបង្ហាញឱ្យគាត់ឃើញពីរូបភាពនោះទេ។
- សិក្ខាកាមនោះត្រូវតែទាយថា រូបអ្វីដែលគេបិទនៅលើខ្នងរបស់ខ្លួន ដោយសួរសំណួរផ្សេងៗ ដែលសមាជិកក្រុមអាចឆ្លើយតែពាក្យ" បាទ/ចាស៎ ឬ ទេ" ប៉ុណ្ណោះ។
- សិក្ខាកាមមានពេលវេលាត្រឹមតែ ៤ នាទី ដើម្បីធ្វើការទស្សទាយរូបភាពនោះ។
- ក្រោយពេល ៤ នាទី ឬនៅពេលដែលបានទស្សទាយហើយ ទើបគេអនុញ្ញាតឱ្យគាត់មើលរូបភាពដែលនៅពីក្រោយខ្នងគាត់បាន។
- សុំឱ្យសិក្ខាកាមជ្រើសរើសអ្នកផ្សេងទៀត ហើយធ្វើសកម្មភាពដូចលើកមុន។
- សិក្ខាកាមដទៃទៀតគូររូបភាពនៅលើក្រដាស ហើយបិទនៅលើខ្នងសមាជិកបន្ទាប់ទៀត ដោយមិនបង្ហាញអោយដឹងថាជារូបអ្វី។

## ១.១០ អាហារូបត្ថម្ភទូទៅ (៥០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងយល់ដឹងអំពីសារៈសំខាន់នៃអាហារូបត្ថម្ភ

**វិធីសាស្ត្រ** : បាឋកថា

**នរណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយបង្ហាញ ១៩ - ២៩

**សៀវភៅសិក្ខាកាម :** ជំពូក ២.១ - ២.៥

### ការណែនាំ:

- ពន្យល់សិក្ខាកាមថាហេតុអ្វីបានជាអាហារូបត្ថម្ភមានសារៈសំខាន់ ដោយផ្អែកទៅលើជំពូកអាហារូបត្ថម្ភទូទៅនៃសៀវភៅនេះ។
- ប្រើប្រាស់ស្លាយ ១៩-២៩

## ១.១១ អាហារដែលសំបូរដោយសារជាតិ,,, លំហាត់ ក (៤០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចធ្វើការផ្តល់ប្រឹក្សាដល់ស្ត្រី និងអ្នកថែទាំទាំងឡាយ អំពីអាហារដែលសំបូរដោយជីវជាតិអា ជាតិដែក ប្រូតេអ៊ីន និងអាហារដែលសំបូរទៅដោយថាមពល ។

**វិធីសាស្ត្រ :** ការធ្វើលំហាត់ជាគូ ឬតែឯង

**ធនធាន :** សិក្ខាកាម

**សម្ភារៈ :** លំហាត់ ក នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម ស្លាយបង្ហាញទី ២៩ ដែលមានអាហារផ្សេងៗគ្នា

### ការណែនាំៈ

- ពន្យល់ទៅដល់សិក្ខាកាមថានេះជាលំហាត់ជាលក្ខណៈបុគ្គល ដែលសិក្ខាកាមម្នាក់ៗត្រូវធ្វើដោយខ្លួនឯងនឹងមានរយៈពេល ២០ នាទី ។
- បន្ទាប់ពី ២០ នាទីមក សិក្ខាកាមអាចផ្ទៀងផ្ទាត់ជាមួយសិក្ខាកាមឯទៀតៗដែលនៅក្បែរ ដើម្បីប្រៀបធៀបលទ្ធផលដោយចំណាយពេល ១០ នាទី ។
- ប្រាប់សិក្ខាកាមពីទំព័រនៃលំហាត់នេះដែលមាននៅក្នុងសៀវភៅសិក្ខាកាម
- អ្នកសម្របសម្រួលត្រូវប្រើរយៈពេល ១០ នាទី ក្នុងការផ្តល់ចម្លើយត្រឹមត្រូវទៅឱ្យសិក្ខាកាម ។
- ខាងក្រោមនេះជារូបភាពនៃប្រភេទអាហារផ្សេងៗ ។ មុខអាហារខ្លះសំបូរដោយជាតិដែក អាហារខ្លះទៀតសំបូរដោយជីវជាតិអា និងខ្លះទៀតសំបូរដោយជាតិអ៊ីយ៉ូដ ។ ហើយមានអាហារខ្លះទៀតនោះក៏សំបូរទៅដោយថាមពលផងដែរ ។ សូមមើលរូបភាពខាងក្រោម ។
- សូមធ្វើការសម្រេចចិត្តថាតើនៅក្នុងមុខអាហារណា ដែលសំបូរដោយសារជាតិចិញ្ចឹមអ្វី រួចគូសរង្វង់ជុំវិញអាហារទាំងនោះដោយប្រើប្រាស់ទម្រង់ដែលបញ្ជាក់ពីសារជាតិជាក់លាក់ ដែលបានបង្ហាញនៅខាងក្រោម ។
- បង្ហាញស្លាយទី ២៩ ក្រោយពីការធ្វើលំហាត់រួច ដើម្បីពិភាក្សាចម្លើយរបស់សិក្ខាកាម ។

## លំហាត់

○ ជីវជាតិអា　　　　□ ជាតិដែក

◇ អ៊ីយ៉ូដ　　　　△ ថាមពល



សម្រាក (២០ នាទី)

## ១.១២ តើយើងត្រូវធ្វើអ្វី នៅពេលណា? លំហាត់ ខ (៣០ នាទី)

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងដឹងពីប្រភេទសារជាតិចិញ្ចឹម និងសារអប់រំអំពីអាហារូបត្ថម្ភសំរាប់ក្រុមគោលដៅមួយៗ។

**វិធីសាស្ត្រ** : លំហាត់ជាគូ

**នរណា** : សិក្ខាកាម ២ នាក់ (គូ)

**សម្ភារៈ** : លំហាត់ ខ នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម ស្លាយទី ៣០ (ដោយមានតារាង)

### ការណែនាំ:

- ពន្យល់ដល់សិក្ខាកាមថាពួកគាត់ត្រូវធ្វើការជាគូ (២ នាក់) ដើម្បីបំពេញតារាងមួយ។ ពួកគាត់អាចប្រើសៀវភៅសិក្ខាកាមជំពូកអាហារូបត្ថម្ភ ធ្វើជាព័ត៌មានសារតារ។
- បន្ទាប់ពីរយៈពេល ២០ នាទី អ្នកសម្របសម្រួលនឹងផ្តល់នូវចម្លើយត្រឹមត្រូវដោយប្រើប្រាស់ ស្លាយទី ៣០ ដើម្បីធ្វើការពិភាក្សាទៅលើចម្លើយរបស់សិក្ខាកាម។

## លំហាត់ ៖

ណែនាំសិក្ខាកាមឱ្យអានជំពូកអាហារូបត្ថម្ភនៅក្នុងសៀវភៅរបស់ពួកគាត់ និងប្រើតារាងលំហាត់ ខ នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម។ សុំឱ្យសិក្ខាកាមមើលតារាង។ នៅផ្នែកខាងឆ្វេងដៃ គឺជាក្រុមគោលដៅផ្សេងៗគ្នា។ នៅក្នុងជួរកូលោនបញ្ឈរគឺជាសកម្មភាព។ គូសសញ្ញាខ្វែងនៅពេលដែលសកម្មភាពនៅក្នុងកូលោនបញ្ឈរឆ្លើយទៅនឹងក្រុមគោលដៅ។ គេអាចគូសខ្វែងច្រើនដងសំរាប់ក្រុមគោលដៅនិមួយៗ។ ឧទាហរណ៍ៈ ស្ត្រីមានផ្ទៃពោះគួរបរិភោគនូវអាហារបន្ថែមមួយពេលទៀតក្នុងមួយថ្ងៃ។

| ក្រុមគោលដៅ | អាហារពេលបន្ថែម | បរិមាណតិចតួច | បំបៅកូនដោយទឹកដោះម្តាយ | អាហារបន្ថែម (បបរគ្រឿង) | អាហារក្រៅពេល | អាហារគ្រួសារពាចឱ្យម៉ត់ ឬកាត់ជាដុំតូចៗ |
|---|---|---|---|---|---|---|
| ស្ត្រីមានផ្ទៃពោះ | X | | | | | |
| កុមារកំពុងត្រូវការលូតលាស់ | | | | | | |
| កុមារ និងមនុស្សពេញវ័យទើបតែងើបពីឈឺ | | | | | | |
| កុមារ ០-៦ខែ | | | | | | |
| កុមារ៦-១១ខែ | | | | | | |
| កុមារ១-២ឆ្នាំ | | | | | | |
| កុមារលើស ២ ឆ្នាំ | | | | | | |

## ១.១៣ ដាក់អាហារពេលបញ្ចូលគ្នា-ការងារជាក្រុម (៤៥ នាទី)

**គោលបំណង ៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចផ្តល់ដំបូន្មាន ថាតើគ្រឿងផ្សំណាដែលគួរប្រើក្នុងការធ្វើម្ហូបដើម្បីឱ្យទទួលបាននូវមីក្រូសារជាតិផ្សេងៗ ដោយអនុវត្តនតាមអនុសាសន៍នៃសម្ភារៈជំនួយការងារ។

**វិធីសាស្ត្រ** ៖ ការងារជាក្រុម

**អ្នកណា** ៖ ក្រុមការងារដែលមានសមាជិក ៥ នាក់ យ៉ាងច្រើន

**សម្ភារៈ** ៖ រូបភាពមុខម្ហូបខ្មែរ សំរាប់ក្រុមនិមួយៗ (សម្ភារៈជំនួយការងារមាននៅក្នុងឧបសម្ព័ន្ធ)

### សន្និទានភាព

គោលគំនិតនៃការធ្វើសកម្មភាពនេះ គឺដើម្បីឱ្យក្រុមចេះឆ្នៃប្រឌិតធ្វើអាហារពេលមួយមុខដែលគេស្រម៉ៃថា វាសំបូរទៅដោយជីវជាតិអា ជាតិដែក ជាតិអ៊ីយ៉ូដ និងថាមពល។ ម្ហូបនេះគឺធ្វើឡើងសំរាប់សមាជិកគ្រួសារដែលមានគ្នាចំនួន ៥ នាក់។ ម្ហូបអាហារនេះ គួរតែមានសារជាតិចិញ្ចឹមច្រើនមុខ ប៉ុន្តែជាមួយគ្នានេះផងដែរ ប្រភេទអាហារទាំងឡាយនោះគួរអាចរកបាននៅតាមសហគមន៍ និងមានតម្លៃថោក។

ក្រុមការងារចាំបាច់ត្រូវឡើងបង្ហាញ និងពន្យល់ពីមូលហេតុដែលពួកគាត់ជ្រើសរើសមុខម្ហូបទាំងនេះ។

**ការណែនាំ:**

- សមាជិកក្រុមដែលមានគ្នា ៥ នាក់
- ពន្យល់ថា ក្រុមនិមួយៗចាំបាច់ត្រូវតែរៀបចំធ្វើម្ហូបមួយមុខ ដោយប្រើប្រាស់រូបភាពនៅលើប័ណ្ណ
- ជាគោលការណ៍សារជាតិចិញ្ចឹមទាំងអស់ត្រូវតែមាននៅក្នុងមុខម្ហូបនោះ ប៉ុន្តែម្ហូបនោះគួរតែមានតម្លៃថោកតាមដែលអាចធ្វើទៅបាន។
- ក្រោយពីរយៈពេល ២៥ នាទីមក ក្រុមនិមួយៗដើរជុំវិញដើម្បីមើល ថាតើក្រុមផ្សេងទៀតធ្វើម្ហូបអ្វី។
- នៅក្នុងរយៈពេល ៥ នាទីចុងក្រោយ អ្នកសម្របសម្រួលជ្រើសយកម្ហូបមួយជាឧទាហរណ៍ និងធ្វើការពន្យល់នូវចំណុចល្អចំពោះម្ហូបអាហារនោះ និងអ្វីដែលអាចធ្វើឱ្យម្ហូបនេះកាន់តែប្រសើរ។

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ពន្យល់ | ៥ |
| ការងារជាក្រុម | ២៥ |
| សង្កេតការងាររបស់ក្រុមផ្សេងទៀត | ១០ |
| ព័ត៌មានត្រឡប់ពីអ្នកសម្របសម្រួល | ៥ |
| | |
| **សរុប** | **៤៥** |

## ១.១៤ ការសន្និដ្ឋាននៅពេលរសៀល (២៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តទៅលើចំណេះដឹង និងជំនាញដែលបានរៀន

**វិធីសាស្ត្រ :** ការសង្ខេប

**នរណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងម៉ោងបញ្ជាក់ពេលវេលា

**ការណែនាំ:**

សង្ខេបនិងពិនិត្យឡើងវិញនូវអ្វីដែលបានរៀនកាលពីថ្ងៃរសៀល

- តើអាហារអ្វីសំបូរទៅដោយមីក្រូសារជាតិអ្វី ?
- តើសារអាហារូបត្ថម្ភអ្វីខ្លះដែលមានសារៈសំខាន់សំរាប់ក្រុមចំណុចនិមួយៗ ?

- ឧទាហរណ៍ នៃអាហារដែលមានសារជាតិខុសៗគ្នា?
- ស្នើសិក្ខាកាមទាំងអស់ឱ្យឈរជាជួរទល់មុខគ្នានៅចំកណ្តាលថ្នាក់រៀន ។
- សុំឱ្យពួកគាត់បិទភ្នែក
- ហើយពន្យល់
- ល័ក្ខខ័ណ្ឌដូចខាងក្រោមៈ
- ប្រសិនបើគេយល់ព្រម សុំឱ្យពួកគាត់ដើរមួយជំហានទៅមុខ ។
- ប្រសិនបើពួកគេមិនយល់ព្រមទេ ពួកគាត់ត្រូវដើរមួយជំហានថយក្រោយ ។
- កត់សម្គាល់ពីចំនួនសិក្ខាកាមដែលបោះជំហានទៅមុខ និងថយក្រោយ ។
- សុំឱ្យសិក្ខាកាមត្រលប់ចូលជួរវិញបន្ទាប់ពីបានសាកសួរនូវសំណួរនិមួយៗរួច
- សួរសំណួរទៅសិក្ខាកាមម្តងមួយៗមានដូចខាងក្រោមៈ

  ១. តើអ្នកចូលចិត្តថ្ងៃនេះទេ?

  ២. តើអ្នកទទួលបានចំណេះដឹងថ្មីៗទេ?

  ៣. តើអ្នកទទួលបានជំនាញថ្មីៗទេ?

  ៤. តើច្បាស់សំរាប់អ្នកទេ?

  ៥. តើអ្នកចូលចិត្តវិធីសម្របសម្រួលនៅថ្ងៃនេះដែរឬទេ?

បង្ហាញក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងបញ្ជាក់ពីពេលវេលាដែលត្រូវត្រឡប់មកវិញ ។

# ថ្ងៃទី ២ ការចិញ្ចឹមទារក និងកុមារតូច

## គោលបំណងថ្ងៃទី ២៖

១ ដើម្បីណែនាំពីកម្មវិធីចិញ្ចឹមទារក និងកុមារតូច

២ ដើម្បីពង្រឹងជំនាញ និងចំណេះដឹង ស្តីពីសកម្មភាពចិញ្ចឹមទារក និងកុមារតូច

៣ ដើម្បីអនុវត្តការផ្តល់ប្រឹក្សាពីការបំបៅកូនដោយទឹកដោះម្តាយ

៤ ដើម្បីអនុវត្តការផ្តល់ប្រឹក្សាពីការលើកកម្ពស់ និងគាំទ្រការលូតលាស់

៥ ដើម្បីប្រើប្រាស់បណ្ណ័សុខភាពកុមារ (ប័ណ្ណលឿង) សំរាប់ការចិញ្ចឹមទារក និងកុមារ ហើយនិងការលើកកម្ពស់និងការវាយតម្លៃការលូតលាស់

## គោលបំណងជំនាញ សំរាប់សិក្ខាកាមថ្ងៃទី ២៖

**នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចៈ**

១ ធ្វើការប្រស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនៅពេលដែលពួកគាត់ធ្វើការផ្តល់ប្រឹក្សាដល់ម្តាយ និងអ្នកថែទាំផ្សេងៗទៀត។

២ ស្គាល់ពីសញ្ញានៃការកង្វះអាហារូបត្ថម្ភ និងអាចធ្វើការផ្តល់ប្រឹក្សាដល់ម្តាយ និងអ្នកថែទាំកុមារ អំពីការចិញ្ចឹមកុមារឱ្យបានសមស្រប។

៣ ផ្តល់ប្រឹក្សាដល់ម្តាយ ប្រកបដោយប្រសិទ្ធភាព អំពីការអនុវត្តការបំបៅកូនដោយទឹកដោះម្តាយ។

៤ ផ្តល់ប្រឹក្សាដល់ម្តាយ និងអ្នកថែទាំកុមារពីការផ្តល់អាហារបន្ថែមដ៏សមស្រប។

៥ ផ្តល់សារក្នុងការលើកកម្ពស់ការលូតលាស់ និងធ្វើការវាយតម្លៃពីការលូតលាស់របស់កុមារ រួមទាំងបំពេញបណ្ណ័សុខភាពកុមារ។

# កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨ :០០ | ១០ | ២.១ | ល្បែងថាមពល សេរិនអាប់ | ទាំងអស់គ្នា |
| ៨:១០ | ១០ | ២.២ | គោលបំណងថ្ងៃទី ២<br>បាឋកថា - បង្ហាញពីគោលបំណងប្រចាំថ្ងៃ | អ្នកសម្របសម្រួល |
| ៨:២០ | ២០ | ២.៣ | បាឋកថា - ប្រសិទ្ធភាពនៃការទំនាក់ទំនង | អ្នកសម្របសម្រួល |
| ៨:៤០ | ៤០ | ២.៤ | ចំណុចសំខាន់ៗនៃកម្មវិធីពីម្សិលមិញ<br>ការងារក្រុម-រំលឹកឡើងវិញ និងបង្ហាញអ្វីដែលសំខាន់បំផុតដែលបានរៀនពីម្សិលមិញ | ក្រុម |
| ៩:២០ | ២០ | ២.៥ | សេចក្តីផ្តើម ពីការចិញ្ចឹមទារក និងកុមារ<br>បាឋកថា ស្តីពីសារៈសំខាន់នៃការចិញ្ចឹមទារក និងកុមារ | អ្នកសម្របសម្រួល |
| ៩:៤០ | ២០ | | សម្រាក | |
| ១០:០០ | ៣០ | ២.៦ | ការបំបៅកូនដោយទឹកដោះម្តាយ<br>បាឋកថា ពីការបំបៅកូនដោយទឹកដោះម្តាយ<br>សម្គាល់: មេរៀននេះគួរសម្របសម្រួលដោយអ្នកជំនាញ | អ្នកសម្របសម្រួល<br>ជំនាញ |
| ១០:៣០ | ២០ | ២.៧ | គំរូក្នុងការអនុវត្តការបំបៅកូនដោយទឹកដោះម្តាយ<br>នៅក្នុងមេរៀនគំរូនេះ អ្នកសម្របសម្រួលបង្ហាញពីរបៀបបំបៅកូនដោយទឹកដោះម្តាយ<br>សម្គាល់: ផ្នែកនេះគួរសម្របសម្រួលដោយអ្នកជំនាញ | អ្នកសម្របសម្រួល<br>ជំនាញ |
| ១០:៥០ | ៣០ | ២.៨ | ការអនុវត្តការបំបៅកូនដោយទឹកដោះម្តាយ<br>ការងារជាក្រុមដោយអនុវត្តការបំបៅកូនដោយទឹកដោះម្តាយ ដោយមានការអភិបាលពីអ្នកជំនាញ | ក្រុម |
| ១១:២០ | ១០ | ២.៩ | ការសន្និដ្ឋាននៅពេលព្រឹក<br>សង្ខេប | អ្នកសម្របសម្រួល |
| ១១:៣០ | ១២០ | | សម្រាក | |
| ១៣:៣០ | ១០ | ២.១០ | ការរុញច្រានដៃគូ<br>ល្បែងថាមពលដើម្បីបង្កើតថាមពល និងការលើកទឹកចិត្តជាវិជ្ជមាន | ជាគូ |
| ១៣:៤០ | ៥០ | ២.១១ | ការលើកកម្ពស់ការលូតលាស់<br>បាឋកថា ស្តីពីសារៈសំខាន់នៃការលើកកម្ពស់ការលូតលាស់ | អ្នកសម្របសម្រួល |
| ១៤:៣០ | ៤០ | ២.១២ | ឧបករណ៍ថ្នាក់ជាតិសំរាប់ការអប់រំការលើកកម្ពស់ការលូតលាស់ការងារជាក្រុម-គូសបញ្ជាក់ពីសារៈសំខាន់នៃការលើកកម្ពស់ការលូតលាស់ | ក្រុម |
| ១៥:១០ | ២០ | | សម្រាក | |

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ១៥:៣០ | ៣០ | ២.១៣ | ប័ណ្ណសុខភាពកុមារ (ប័ណ្ណលឿង)<br>បាឋកថាពីសារៈសំខាន់ និងការប្រើប្រាស់ប័ណ្ណសុខភាពកុមារ | អ្នកសម្របសម្រួល |
| ១៦:០០ | ២៥ | ២.១៤ | ផល្លា និង មុន្នី<br>លំហាត់ - ប័ណ្ណសុខភាពកុមារ | ជាគូ ឬក្រុម |
| ១៦:២៥ | ២៥ | ២.១៥ | ការលូតលាស់របស់ដារ៉ាវុធ<br>លំហាត់ - ប័ណ្ណសុខភាពកុមារ | ជាគូ ឬក្រុម |
| ១៦:៥០ | ១០ | ២.១៦ | ការសន្និដ្ឋាន នៅពេលល្ងាច<br>សង្ខេប | អ្នកសម្របសម្រួល |
| ១៧:០០ | | | បញ្ចប់ម៉ោងសិក្សា | |

## សម្ភារៈដែលត្រូវការ ៖

- ស្លាយសំរាប់បង្ហាញ ពីទី ៧២-៧៤
- ក្រដាសផ្ទាំងធំដែលបានរៀបចំជាស្រេចដោយមានឧទាហរណ៍
- ក្រដាសផ្ទាំងធំ
- ប៊ិចហ្វឺត
- កូនក្រមុំជ័រ
- សន្លឹកផ្ទាត់ នៃការចិញ្ចឹមទារក និងកុមារ
- ប័ណ្ណសុខភាពកុមារថតចម្លង (ប័ណ្ណលឿង)
- ជញ្ជីង
- ប្រតិទិន
- ប័ណ្ណសុខភាពកុមារដែលមិនទាន់បំពេញ

# សកម្មភាព ថ្ងៃទី ២

## ២.១ សេរិនអាប់ (7-Up) (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីបន្តមេរៀនព្រឹកនេះ។

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាមទាំងអស់ ដែលសម្របសម្រួលដោយអ្នកសម្របសម្រួលម្នាក់

**សម្ភារៈ** : មិនមានសម្ភារៈដែលត្រូវការ

**ការណែនាំ:**

- អញ្ជើញសិក្ខាកាមទាំងអស់ឱ្យក្រោកឈរជារង្វង់ទាំងអស់គ្នា ។
- អ្នកសម្របសម្រួលចាប់ផ្តើមដោយស្រែក "**មួយ**" ដោយយកដៃស្តាំចង្អុលទៅរកអ្នកដែលនៅខាងឆ្វេងដៃរបស់គាត់។
- ហើយអ្នកដែលគេចង្អុលនោះស្រែកថា "**ពីរ**" ហើយចង្អុលដោយដៃស្តាំទៅរកអ្នកដែលនៅខាងឆ្វេងដៃរបស់គាត់។ អ្នកនោះស្រែកថា "**បី**"។ ការធ្វើបែបនេះរហូតដល់អ្នកទី ៧ ដែលជាអ្នកស្រែកថា "**សេរិនអាប់**" ព្រមទាំងលើកដៃទាំងពីររបស់គាត់ទៅលើ។
- អ្នកនៅខាងឆ្វេងដៃចាប់ផ្តើមជុំថ្មីដោយស្រែក "**មួយ**" ហើយចង្អុលដៃស្តាំទៅអ្នកដែលនៅខាងឆ្វេងដៃ។ បញ្ឈប់ល្បែងថាមពលនេះក្រោយពីលេងបាន ១០ នាទី ហើយអញ្ជើញសិក្ខាកាមទាំងអស់ឱ្យចូលទៅកាន់កន្លែងអង្គុយរបស់ខ្លួនវិញ។

## ២.២ គោលបំណងនៅថ្ងៃទី ២ (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមដឹងពីគោលបំណងនៃការបណ្តុះបណ្តាលនៃថ្ងៃទី ២ នេះ

**វិធីសាស្ត្រ** : បាឋកថា

**នរណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយសំរាប់បង្ហាញ ទី ៣១-៣៣

**ការណែនាំ:**

បង្ហាញ និងពន្យល់ស្លាយទី ៣១, ៣២ និង៣៣ ដល់សិក្ខាកាម

## ២.៣ ការប្រស្រ័យទាក់ទងដែលមានប្រសិទ្ធភាព (២០ នាទី)

**គោលបំណង៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមដឹងពីវិធីធ្វើឱ្យប្រសើឡើងនូវជំនាញក្នុងការផ្តល់សារអាហារូបត្ថម្ភ។

**វិធីសាស្ត្រ** ៖ បាឋកថា

**នរណា** ៖ អ្នកសម្របសម្រួល

**សម្ភារៈ** ៖ ស្លាយសំរាប់បង្ហាញ ទី ៣៤-៣៨
ឧទាហរណ៍នៃសន្លឹកផ្ទាត់ ដែលពុំមានអក្សរស្មេកស្មុះ

**សៀវភៅសិក្ខាកាម** ៖ ជំពូក ១១.១ - ១១.៦

### ការណែនាំ៖

- រៀបចំឧទាហរណ៍ដ៏ល្អមួយនៃការប្រើប្រាស់សន្លឹកផ្ទាត់ដែលមានចំណុចគោល និងមានពណ៌ចំរុះ
- បង្ហាញសិក្ខាកាមនូវស្លាយទី ៣៤-៣៨

## ២.៤ ចំណុចគន្លឹះនៃកម្មវិធីរម្លឹលមិញ-ការងារជាក្រុម (៤០ នាទី)

**គោលបំណង៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចផ្តល់ព័តិមានប្រកបដោយប្រសិទ្ធភាព ដោយអនុវត្តតាមទ្រឹស្តីជាមូលដ្ឋាននៃការប្រស្រ័យទាក់ទង។

**នរណា** ៖ ក្រុមដែលមានសមាជិកយ៉ាងច្រើន ៥ នាក់

**សម្ភារៈ** ៖ ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត
ក្រដាសពណ៌បៃតង ៥ សន្លឹក សំរាប់សិក្ខាកាមនិមួយៗ ( មានទំហំ អា ៥ )
ក្រដាសពណ៌លឿង ៥ សន្លឹក សំរាប់សិក្ខាកាមនិមួយៗ ( មានទំហំ អា ៥ )

### សន្និទានភាព

ក្នុងអំឡុងពេលមេរៀននេះ សិក្ខាកាមធ្វើការងារជាក្រុម ដើម្បីរំលឹកឡើងវិញ និងសង្ខេបពីចំណុចសំខាន់ៗពីថ្ងៃមុន។ បង្ហាញតែអំពីជំពូកនៃអាហារូបត្ថម្ភ។ ការបង្ហាញពីមាតិកានៃជំពូកអាហារូបត្ថម្ភ ដើម្បីជួយឱ្យសិក្ខាកាមចងចាំឡើងវិញពីជំពូកនៃអាហារូបត្ថម្ភទាំងនោះ។

### ការណែនាំ៖

- ពន្យល់ទៅក្រុមនិមួយៗថា ពួកគាត់មានពេល ១០ នាទី សំរាប់រៀបចំការបង្ហាញ អំពីការងារដែលជាផ្នែកមួយនៃជំពូកអាហារូបត្ថម្ភ ៖

១. សេចក្តីផ្តើម
២. ប្រភេទផ្សេងៗគ្នា
៣. អាហារដែលបញ្ចូលសារជាតិចិញ្ចឹម និងអាហារសំរាប់អ្នកជម្ងឺ
៤. អាហារបន្ថែម
៥. ការចិញ្ចឹមទារក និងកុមារ និងការបំបៅកូនដោយទឹកដោះម្តាយ

- បន្ទាប់ពីបានរៀបចំហើយ ក្រុមនិមួយៗមានពេលវេលា ៥ នាទី ដើម្បីបង្ហាញទៅក្រុមធំ។ សិក្ខាកាមនិមួយៗនៃក្រុមធំ មានក្រដាសតូចៗពណ៌បៃតងចំនួន ៥ សន្លឹក និងពណ៌លឿងចំនួន ៥ សន្លឹក។
- ចំពោះការបង្ហាញនិមួយៗ សិក្ខាកាមសរសេរពីការកត់សម្គាល់តាមបែបវិជ្ជមាន អំពីការសម្របសម្រួល/ការបង្ហាញនៅលើសន្លឹកក្រដាសពណ៌បៃតង។
- សរសេរពីអ្វីដែលត្រូវកែលំអរនៅលើសន្លឹកពណ៌លឿង។
- នៅចុងបញ្ចប់នៃការបង្ហាញនិមួយៗ កំណត់សម្គាល់ទាំងនេះត្រូវបានសរសេរនៅលើសន្លឹកក្រដាសពណ៌បៃតង និងពណ៌លឿង ហើយប្រគល់ទៅឱ្យក្រុមដែលបានធ្វើការបង្ហាញ។
- ក្រុមនិមួយៗអាចធ្វើការពិភាក្សាគ្នានៅក្នុងអំឡុងពេលអាហារសម្រន់។

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ពន្យល់ | ៥ |
| ការរៀបចំក្នុងក្រុម | ១០ |
| ការបង្ហាញ (ក្រុមនិមួយៗ មាន ៥ នាទី) | ២០ |
| ផ្តល់ពត៌មានត្រលប់ ដោយអ្នកសម្របសម្រួល | ៥ |
| **សរុប** | **៤០** |

## ២.៥ សេចក្តីផ្តើម ស្តីពីការចិញ្ចឹមកុមារ និងទារក (២០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមស្គាល់ច្បាស់ពីសារៈសំខាន់នៃការចិញ្ចឹមទារក និងកុមារ និងអាចស្គាល់សញ្ញានៃការកង្វះអាហារូបត្ថម្ភ។

**វិធីសាស្ត្រ** : បាឋកថា

**នរណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយសំរាប់បង្ហាញពីទី ៣៩-៤៧

**សៀវភៅសិក្ខាកាម :** ជំពូក ៣.១-៣.៦

**ការណែនាំ :**

- បង្ហាញ និងពន្យល់សិក្ខាកាមនូវស្លាយ ៣៩-៤៧
- ពន្យល់ពីការលើសទម្ងន់

សម្រាក (២០ នាទី)

## ២.៦ ការបំបៅកូនដោយទឹកដោះម្ដាយ (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមដឹងពីសារគន្លឹះសំរាប់ការផ្ដល់ប្រឹក្សាពីការបំបៅកូនដោយទឹកដោះម្ដាយ

**វិធីសាស្ត្រ :** បាឋកថា

**នរណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយសំរាប់បង្ហាញទី ៣៨-៥៩
កូនក្រមុំតុក្កតា

**សៀវភៅសិក្ខាកាម :** ជំពូក ៣.៧-៣.១០

**ការណែនាំ:**

- សូមប្រើកូនក្រមុំជ័រដើម្បីធ្វើការបង្ហាញពីការអនុវត្តន៍ការបំបៅកូនដោយទឹកដោះម្ដាយ
- បង្ហាញស្លាយ ទី ៤៨-៥៩

## ២.៧ គំរូនៃការបំបៅកូនដោយទឹកដោះម្ដាយ (២០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមចេះពីរបៀបផ្ដល់ប្រឹក្សាដល់ស្ត្រីពីការបំបៅកូនដោយទឹកដោះម្ដាយ ។

**វិធីសាស្ត្រ :** ការធ្វើជាគំរូ

**អ្នកណា :** ចំពោះមេរៀននេះ គួរអញ្ជើញអ្នកដែលមានជំនាញក្នុងការងារនេះ (ការបំបៅកូនដោយទឹកដោះម្ដាយ)

**សម្ភារៈ :** កូនក្រមុំតុក្កតា បញ្ជីផ្ទៀងផ្ទាត់ផ្ដល់ប្រឹក្សាសំរាប់សិក្ខាកាម

**សៀវភៅសិក្ខាកាម :** ជំពូក ៣.៧

### ការណែនាំ

- ពន្យល់ពីរបៀបប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ផ្ដល់ប្រឹក្សា។
- សុំឱ្យសិក្ខាកាមសង្កេតអ្វីដែលអ្នកសម្របសម្រួលកំពុងធ្វើ និងផ្ដល់ព័ត៌មានត្រឡប់ទៅអ្នកសម្របសម្រួល ដោយប្រើបញ្ជីផ្ទៀងផ្ទាត់សំរាប់ការផ្ដល់ប្រឹក្សា
- អ្នកជំនាញដែលបានអញ្ជើញ និងអ្នកសម្របសម្រួលម្នាក់ទៀតធ្វើជាឧទាហរណ៍ក្នុងវគ្គ ការផ្ដល់ប្រឹក្សាការបំបៅកូនដោយទឹកដោះម្ដាយចំនួនពីរដង។
- ក្នុងអំឡុងពេល ៥ នាទីដំបូង ពួកគាត់បង្ហាញពីវគ្គដែលអ្នកជំនាញផ្ដល់ដំបូន្មានខុស។ ធ្វើការពិភាក្សាជាមួយសិក្ខាកាមរយៈពេល ៥ នាទី។
- បង្ហាញពីវគ្គដែលអ្នកជំនាញយើងផ្ដល់ដំបូន្មានដ៏ត្រឹមត្រូវ។
- ធ្វើការពិភាក្សាជាមួយសិក្ខាកាមរយៈពេល ៥ នាទី។

## ២.៨ ការអនុវត្តន៍ការបំបៅកូនដោយទឹកដោះម្ដាយ–ការងារក្រុម (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្ដល់ប្រឹក្សាដល់ស្ត្រីប្រកបដោយប្រសិទ្ធភាព ស្ដីពីការបំបៅកូនដោយទឹកដោះម្ដាយ

**វិធីសាស្ត្រ :** ល្បែងដើរតួ

**ធនធាន :** ក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់

**សម្ភារៈ :** សម្ភារៈជំនួយការងារ កូនក្រមុំជ័រ

**សៀវភៅសិក្ខាកាម :** ជំពូក ៣.៧-៣.៨

### ការណែនាំ

- ប្រសិនជាមានកូនក្រមុំជ័រច្រើនសំរាប់ការអនុវត្តន៍ការបំបៅកូនដោយទឹកដោះម្ដាយ ផ្ដល់កូនក្រមុំជ័រមួយ សំរាប់មួយក្រុម។
- អនុញ្ញាតិឱ្យក្រុមនិមួយៗអនុវត្តការងារនេះរយៈពេលពី ៥ ទៅ ១០ នាទី។
- ប្រសិនជាមានកូនក្រមុំជ័រតែមួយ ត្រូវឱ្យច្បាស់ថាកូនក្រមុំជ័រនេះត្រូវបានអនុវត្តដោយក្រុមផ្សេងទៀត។
- សុំឱ្យសិក្ខាកាមចែកជាក្រុមដែលមានសមាជិកយ៉ាងច្រើន ៥ នាក់។
- សិក្ខាកាមម្នាក់ដើរតួជាបុគ្គលិកសុខាភិបាល ម្នាក់ទៀតដើរតួជាស្ត្រីបំបៅកូនដោយទឹកដោះម្ដាយ។ ចំណែកសមាជិកផ្សេងទៀតចាំសង្កេត និងប្រើប្រាស់បញ្ជីផ្ទៀតផ្ទាត់។
- បន្ទាប់ពីអនុវត្តន៍ ៥ នាទី បញ្ចប់ ហើយពិភាក្សាលើការដើរតួរនេះ។
- ផ្លាស់ប្ដូរអ្នកដើរតួ ពីរដងទៀត ដើម្បីឱ្យច្បាស់ថាសិក្ខាកាមទាំងអស់បានចូលរួមក្នុងការដើរតួនេះ។

## ២.៩ ការសន្និដ្ឋាននៅពេលព្រឹក (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តអំពីចំណេះដឹង និងជំនាញដែលគាត់បានរៀនពីព្រឹក ។

**វិធីសាស្ត្រ** : សង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា ព្រមទាំងបញ្ជាក់ពេលវេលា

បូកសរុបសកម្មភាពពេលព្រឹក ដោយរំលឹកឡើងវិញនូវអ្វីដែលបានរៀន :

- របៀបរៀបចំសន្ទីកផ្ទាត់ និងរបៀបផ្តល់សារគន្លឹះដោយប្រសិទ្ធភាព
- សារៈសំខាន់នៃការចិញ្ចឹមទារក និងកុមារ
- មូលហេតុ និងសញ្ញាគ្លីនិកនៃកង្វះអាហារូបត្ថម្ភ
- ការបំបៅកូនដោយទឹកដោះម្តាយ

បង្ហាញសិក្ខាកាមពីក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងពេលវេលាដែលត្រូវត្រលប់មកវិញ ។

**សម្រាក (១២០ នាទី )**

## ២.១០ ដៃគូរុញគ្នា (Pushy Partners) (១០ នាទី )

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីពេលល្ងាច ។

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : ជាគូ

**សម្ភារៈ** :

### ការណែនាំ

- ត្រូវឱ្យច្បាស់ថាមានកន្លែងធំល្មមសំរាប់សិក្ខាកាមឈរជាគូ និងអាចដើរពីកន្លែងមួយទៅកន្លែងមួយទៀតបាន ។
- ពន្យល់សិក្ខាកាមថាសកម្មភាពនេះ គឺគ្រាន់តែជាការលេងសប្បាយ និងបង្កើតថាមពលប៉ុណ្ណោះ ។
- អញ្ជើញសិក្ខាកាមឱ្យឈរជាពីរជួរទល់មុខគ្នាជាគូៗ ។
- អ្នកដែលទល់មុខគ្នាគឺជាគូ ។
- ឱ្យពួកគេដាក់ដៃទៅមុខទល់គ្នានឹងដៃរបស់ដៃគូគេដែលឈរទល់មុខ ។
- ឱ្យពួកគេចាប់ផ្តើមរុញគ្នាតិចៗ បន្ទាប់មករុញខ្លាំងឡើងៗ ។

- ហើយភ្លាមៗនោះ ស្រែកថា " ឈប់!"
- ឱ្យជួរនិមួយៗខិតទៅខាងស្តាំមួយជំហាន ដូចនេះពួកគាត់បង្កើតបានជាគូថ្មី។
- អ្នកដែលនៅចុងគេខាងស្តាំបំផុតនៃជួរ ត្រូវទៅចុងបំផុតនៃជួរមួយផ្សេងទៀត។
- បន្តការធ្វើបែបនេះ។

## ២.១១ ការលើកកម្ពស់ការលូតលាស់ (៥០ នាទី)

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចយល់ច្បាស់ពីអនុសាសន៍នៃការលើកកម្ពស់ការលូតលាស់

**វិធីសាស្ត្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយបង្ហាញទី ៦០-៦៦

សន្លឹកផ្ទាត់ការចិញ្ចឹមទារក និងកុមារមួយសន្លឹក ផ្នែកការផ្តល់អាហារបន្ថែម

**សៀវភៅសិក្ខាកាម :** ជំពូក ៣.១១-៣.១៤

### ការណែនាំ

- បង្ហាញស្លាយទី ៦០-៦៦
- ពន្យល់ពីសន្លឹកផ្ទាត់ការចិញ្ចឹមទារកនិងកុមារ សន្លឹកនៃផ្នែកការផ្តល់អាហារបន្ថែមមួយទំព័រ

## ២.១២ សន្លឹកផ្ទាត់ការចិញ្ចឹមទារកនិងកុមារ សំរាប់ការលើកកម្ពស់ការលូតលាស់ -ការងារក្រុម (៤០ នាទី):

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចប្រើប្រាស់សន្លឹកផ្ទាត់ជាសម្ភារៈជំនួយការងារសំរាប់ការផ្តល់ប្រឹក្សាការលើកកម្ពស់ការលូតលាស់។

**វិធីសាស្ត្រ** : ការងារជាក្រុម

**អ្នកណា** : ក្រុមដែលមានគ្នា ៥ នាក់

**សម្ភារៈ** : សន្លឹកផ្ទាត់ការចិញ្ចឹមទារក និងកុមារចំនួន ៦
បញ្ជីផ្ទៀងផ្ទាត់ជំនាញក្នុងការផ្តល់ប្រឹក្សា

**សៀវភៅសិក្ខាកាម :** ជំពូក ៣.១១-៣.១៤

### ការណែនាំ

- ចែកសិក្ខាកាមជា៥ក្រុម
- ក្រុមនិមួយៗប្រើសន្លឹកផ្ទាត់ការចិញ្ចឹមទារក និងកុមារ សំរាប់ការអនុវត្តការផ្តល់ប្រឹក្សាការលើកកម្ពស់ការលូតលាស់
- សិក្ខាកាមម្នាក់ៗនៅក្នុងក្រុមនិមួយៗ អនុវត្តការផ្តល់សារសំរាប់ការលើកកម្ពស់ការលូតលាស់។ សិក្ខាកាមផ្សេងទៀតស្តាប់ និងផ្តល់ព័ត៌មានត្រឡប់។
- ពន្យល់សិក្ខាកាមថាពួកគាត់គួរតែផ្លាស់វេនគ្នាក្នុងការអនុវត្តការផ្តល់ប្រឹក្សាទៅកាន់ម្តាយដែលកូនមានអាយុខុសៗគ្នា: កុមារដែលមានអាយុ ៦ ខែ ៨ ខែ និង ១២ ខែ។
- ក្រុមគួរតែប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ផ្តល់ប្រឹក្សា ដើម្បីផ្តល់ព័ត៌មានត្រលប់ទៅឱ្យសិក្ខាកាមដែលបានអនុវត្តជំនាញផ្តល់ប្រឹក្សា។

**សម្រាក (២០ នាទី)**

## ២.១៣ ប័ណ្ណសុខភាពកុមារ (៣០នាទី)

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចយល់ច្បាស់ពីប័ណ្ណសុខភាពកុមារសំរាប់ការផ្តល់ប្រឹក្សា និងការវាយតម្លៃការលូតលាស់។

**វិធីសាស្រ្ត** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយសំរាប់បង្ហាញ ទី ៦៧-៧០
ជញ្ជីង
ប្រតិទិន
ប័ណ្ណសុខភាពកុមារ

**សៀវភៅសិក្ខាកាម :** ជំពូក ៣.១៥-៣.១៩

### ការណែនាំ

- មុនពេលធ្វើបាឋកថានេះ សូមអានផ្នែកស្តីពីការវាយតម្លៃការលូតលាស់យ៉ាងប្រុងប្រយ័ត្ន។
- ចំពោះរយៈពេល ៣០ នាទី នៃបាឋកថានេះ ព្យាយាមបង្ហាញតាមបែបការធ្វើបង្ហាញ។
- ចាប់ផ្តើមដោយការបង្ហាញ គ្រប់ផ្នែកទាំងអស់នៃប័ណ្ណសុខភាពកុមារ ដោយប្រើប្រាស់ស្លាយ ៦៧-៧០។
- ពន្យល់ថាពេលនេះ គឺផ្តោតទៅលើសារគន្លឹះស្តីពីការលើកកម្ពស់ការលូតលាស់ និងការវាយតម្លៃការលូតលាស់។
- ធ្វើបង្ហាញពីរបៀបថ្លឹងកុមារ (សូមមើលឧបសម្ព័ន្ធនៅក្នុងសៀវភៅសិក្ខាកាម)។
- ពន្យល់ពីរបៀបកត់ត្រាពីទម្ងន់ និងចុះថ្ងៃខែនៅលើប័ណ្ណ ដោយប្រើប្រាស់ឧទាហរណ៍ កុមារអាយុ ១២ ខែម្នាក់។
- ប្រើប្រាស់ស្លាយ ៦៧-៧០។
- ពន្យល់ផ្នែកនិមួយៗនៃប័ណ្ណ និងរបៀបបកស្រាយវា។

## ២.១៤ ផល្លា និង មុនី – លំហាត់ គ (២៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចបំពេញប័ណ្ណសុខភាពកុមារបានត្រឹមត្រូវ ។

**វិធីសាស្ត្រ :** លំហាត់ជាគូ

**អ្នកណា :** សិក្ខាកាមជាគូ ឬ ជាក្រុមដែលមានសមាជិក ៣ នាក់

**សម្ភារៈ :** លំហាត់ គ នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម ស្លាយសំរាប់បង្ហាញ ៧១-៧២

### ការណែនាំ

- ចែកសិក្ខាកាមជាគូៗ
- សុំឱ្យសិក្ខាកាមបំពេញលំហាត់ គ នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម
- ប្រើប្រាស់ស្លាយ ៧១ និង ៧២ ដើម្បីពិភាក្សាពីលទ្ធផលជាមួយសិក្ខាកាម



| **ផល្លា**<br>ផល្លាទើបសម្រាលបានកូនស្រីមួយយ៉ាងស្រស់ស្អាត |
|---|
| តើសំណួរអ្វីដែលអ្នកនឹងសួរគាត់? |
| តើអ្នកផ្តល់ដំបូន្មានអ្វីខ្លះទៅឱ្យគាត់? |
| តើការគាំទ្រអ្វីដែលអ្នកផ្តល់ឱ្យគាត់? |



| **មុនី**<br>អ្នកជួបជាមួយមុនី និងកូនរបស់គាត់នៅពេលចុះមូលដ្ឋាន ។ កូនប្រុសរបស់គាត់តូច ហើយស្គម ។ កូនគាត់អាយុបាន ៧ ខែ ហើយ មុនីនៅតែបន្តការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ |
|---|
| តើសំណួរអ្វីដែលអ្នកនឹងសួរគាត់? |
| តើអ្នកផ្តល់ដំបូន្មានអ្វីខ្លះទៅឱ្យគាត់? |
| តើការគាំទ្រអ្វីដែលអ្នកផ្តល់ឱ្យគាត់? |

## ២.១៥ ការលូតលាស់របស់ដារ៉ាវុទ្ធ-លំហាត់ ឃ (២៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចបំពេញប័ណ្ណសុខភាពកុមារបានត្រឹមត្រូវ។

**វិធីសាស្ត្រ :** លំហាត់ជាគូ ឬ ជាក្រុមដែលមានសមាជិក ៣ នាក់

**អ្នកណា :** សិក្ខាកាមជាគូ ឬ ជាក្រុមដែលមានសមាជិក ៣ នាក់

**សម្ភារៈ :** ប័ណ្ណសុខភាពកុមារដែលមិនទាន់បានបំពេញ លំហាត់ ឃ នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម ស្លាយសំរាប់បង្ហាញទី ៧៣

### ការណែនាំ

- ពន្យល់ទៅសិក្ខាកាមថា ពួកគាត់មានពេលវេលា ២០ នាទី ដើម្បីធ្វើលំហាត់នេះ។
- លំហាត់នេះ នឹងត្រូវពិភាក្សានៅថ្ងៃស្អែក ប្រសិនបើមិនមានពេលនៅថ្ងៃនេះទេ។
- ទុកពេលឱ្យសិក្ខាកាមបំពេញទិន្នន័យ និងដៅចំណុចនៅលើប័ណ្ណ។
- ប្រើប្រាស់ស្លាយ ទី ៧៣ ដើម្បីពិភាក្សាពីលទ្ធផលជាមួយសិក្ខាកាម។

### លំហាត់:

ដារ៉ាវុទ្ធ ពេលនេះអាយុ ១៨ ខែ។ គេបានថ្លឹងនៅមណ្ឌលសុខភាព ស្ទើតែរៀងរាល់ ២ ខែម្តង។ លទ្ធផលនៃការថ្លឹង គឺនៅក្នុងតារាងខាងក្រោម។ អ្វីដែលអ្នកត្រូវធ្វើគឺ :

**១.** ប្រើប្រាស់តារាងដើម្បីដៅចំណុចទម្ងន់របស់ដារ៉ាវុទ្ធ នៅក្នុងតារាងលូតលាស់ខាងក្រោម។

**២.** សរសេរពីដំបូន្មានរបស់អ្នករាល់ការពិនិត្យនៅក្នុងកូលោនក្រោយបង្អស់នៃតារាង។

| អាយុ | ថ្ងៃ ខែ ថ្លឹងទម្ងន់ | ទម្ងន់ | ដំបូន្មាន |
|---|---|---|---|
| ០ | ២៤ តុលា ០៦ | ៣,១០ គីឡូ | |
| ២ ខែ | ២០ ធ្នូ ០៦ | ៣,៦០ គីឡូ | |
| ៤ ខែ | ១៥ កុម្ភៈ ០៧ | ៤,៦០ គីឡូ | វាយតម្លៃលើការចិញ្ចឹម និងណែនាំពីការបំបៅកូនដោយទឹកដោះម្តាយ ។ ជជែកសួរកការរាករូស |
| ៦ ខែ | ២១ មេសា ០៧ | ៥,០០ គីឡូ | វាយតម្លៃលើការចិញ្ចឹមកុមារ ។ ពិភាក្សាពីការផ្តល់អាហារបន្ថែមដល់សមស្របសំរាប់ក្រុមអាយុនេះ និងផ្តល់ការណែនាំឱ្យបន្តការបំបៅកូនដោយទឹកដោះម្តាយ ។ ជជែកសួរកការរាករូស ។ ជំរុញឱ្យប្រើប្រាស់ម្ហូបអាហារ ដែលសំបូរទៅដោយជីវជាតិអា និងជាតិដែក ។ ប្រសិនបើកុមារមិនទាន់បានទទួលគ្រាប់ថ្នាំជីវជាតិអាទេ ផ្តល់គ្រាប់ជីវជាតិអា ហើយកត់ត្រានៅក្នុងប័ណ្ណលឿង ។ |
| ៨ ខែ | ១៨ មិថុនា ០៧ | ៦,៦០ គីឡូ | ពិភាក្សាពីការផ្តល់អាហារបន្ថែម សមស្របសំរាប់ក្រុមអាយុនេះ ។ ផ្តល់ដំបូន្មានឱ្យបន្តការបំបៅកូនដោយទឹកដោះម្តាយ ។ លើកសរសើរម្តាយក្នុងការចិញ្ចឹមថែទាំកូន ។ |
| ១០ ខែ | ១៩ សីហា ០៧ | ៧,៥០ គីឡូ | ពិភាក្សាពីការផ្តល់អាហារបន្ថែមសមស្របសំរាប់ក្រុមអាយុនេះ ។ ផ្តល់ដំបូន្មានឱ្យបន្តការបំបៅកូនដោយទឹកដោះម្តាយ ។ លើកសរសើរម្តាយក្នុងការចិញ្ចឹមថែទាំកូន ។ |
| ១២ ខែ | ១០ តុលា ០៧ | ៧,៥០ គីឡូ | វាយតម្លៃលើការចិញ្ចឹមកុមារ និងណែនាំពីការបំបៅកូនដោយទឹកដោះម្តាយ ។ ជជែកសួរកការរាករូស ។ ជំរុញឱ្យប្រើប្រាស់ម្ហូបអាហារដែលសំបូរដោយជីវជាតិអា និងជាតិដែក ។ ប្រសិនបើកុមារមិនទាន់បានទទួលគ្រាប់ថ្នាំជីវជាតិអាទេ ផ្តល់គ្រាប់ជីវជាតិអា ។ ប្រសិនបើកុមារមិនទាន់បានទទួលមេបង់ដាសុលទេ ផ្តល់មេបង់ដាសុល ។ |
| ១៤ ខែ | ១២ ធ្នូ ០៧ | ៨,៥០ គីឡូ | ពិភាក្សាពីការផ្តល់អាហារសមស្របទៅតាមក្រុមអាយុ ។ ផ្តល់ដំបូន្មានឱ្យបន្តការបំបៅកូនដោយទឹកដោះម្តាយ ។ លើកសរសើរម្តាយក្នុងការចិញ្ចឹមថែទាំកូន ។ |
| ១៦ ខែ | ១៤ កុម្ភៈ ០៨ | ៩,០០ គីឡូ | ពិភាក្សាពីការផ្តល់អាហារសមស្របសំរាប់ក្រុមអាយុនេះ ។ ផ្តល់ដំបូន្មានឱ្យបន្តការបំបៅកូនដោយទឹកដោះម្តាយ ។ លើកសរសើរម្តាយក្នុងការចិញ្ចឹមថែទាំកូន ។ |
| ១៨ ខែ | ០៧ មេសា ០៨ | ៩,៥០ គីឡូ | ពិភាក្សាពីការផ្តល់អាហារសមស្របសំរាប់ក្រុមអាយុនេះ ។ ផ្តល់ដំបូន្មានឱ្យបន្តការបំបៅកូនដោយទឹកដោះម្តាយ ។ លើកសរសើរម្តាយក្នុងការចិញ្ចឹមថែទាំកូន ។ |

## ២.១៦ ការសន្និដ្ឋាននៅពេលល្ងាច (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តទៅលើចំណេះដឹង និងជំនាញដែលបានរៀន។

**វិធីសាស្ត្រ** : ការសង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងមានបង្ហាញពេលវេលា

### ការណែនាំ

**សង្ខេប និងរំលឹកឡើងវិញនូវអ្វីដែលបានរៀនកាលពីថ្ងៃរសៀល**

- សារៈសំខាន់ស្ដីពីការលើកកម្ពស់ការលូតលាស់
- របៀបផ្ដល់ប្រឹក្សាស្ដីពីការលើកកម្ពស់ការលូតលាស់
- សារៈសំខាន់ស្ដីពីការវាយតម្លៃការលូតលាស់
- របៀបប្រើប្រាស់ប័ណ្ណលឿង

សុំឱ្យក្រុមដើរទៅកាន់ជ្រុងម្ខាងនៃបន្ទប់។ ប្រាប់ពួកគាត់ថាកន្លែងដែលពួកគាត់កំពុងតែឈរនោះ គឺ "**មិនមានប្រយោជនទេ**"។ **ផ្នែកម្ខាងទៀតនៃបន្ទប់គឺ "មានប្រយោជនណាស់ "**។

សុំឱ្យពួកគាត់ឆ្លើយតបថា តើពួកគាត់មានអារម្មណ៍យ៉ាងណាចំពោះមេរៀនថ្ងៃនេះ ហើយឱ្យពួកគាត់ឈរនៅកន្លែងចន្លោះណាមួយ "**មិនមានប្រយោជន៍** " និង "**មានប្រយោជន៍ណាស់** " សំរាប់កម្មវិធីថ្ងៃនេះ។

សុំអោយពួកគាត់ធ្វើការឆ្លុះបញ្ចាំងពីមេរៀនថ្ងៃនេះ ដោយឈរនៅកន្លែង "**មិនមានប្រយោជន៍**" និង "**មានប្រយោជន៍ណាស់**" សំរាប់ថ្ងៃនេះ។

ប្រាប់ឱ្យសិក្ខាកាមដើរទៅកាន់ចុងម្ខាងនៃបន្ទប់វិញ។ ពេលនេះស្នើពួកគាត់ឈរម្ដងទៀត។ ទីកន្លែងដែលពួកគេកំពុងនៅនោះ គឺ " **ខ្ញុំយល់មិនសូវច្បាស់** " នៅជ្រុងម្ខាងទៀត "**ខ្ញុំយល់បានច្បាស់ណាស់**"។

បង្ហាញពួកគាត់ពីក្រដាសផ្ទាំងធំ ដែលមានរូបនាឡិកា និងបញ្ជាក់ពីពេលវេលាដែលត្រូវត្រលប់មកវិញ។

# ថ្ងៃទី ៣ ៖ កម្មវិធីចិញ្ចឹមទារក និងកុមារ/ ជីវជាតិអា

## គោលបំណងថ្ងៃទី ៣ ៖

១ ដើម្បីរំលឹកពីមេរៀនដែលបានរៀនពីកម្មវិធីចិញ្ចឹមទារក និងកុមារ ពីម្សិលមិញ
២ ដើម្បីបណ្ដុះបណ្ដាលជំនាញផ្ដល់ប្រឹក្សា សំរាប់សកម្មភាពចិញ្ចឹមទារក និងកុមារ
៣ ដើម្បីផ្ដល់ចំណេះដឹង ស្ដីពីកម្មវិធីជីវជាតិអា (ការការពារ និងការព្យាបាល)
៤ ដើម្បីបណ្ដុះបណ្ដាលជំនាញ ស្ដីពីការអប់រំសុខភាព និងការចែកចាយជីវជាតិអា

## គោលបំណងជំនាញ សំរាប់សិក្ខាកាមនៅថ្ងៃទី ៣ ៖

**នៅចុងបញ្ចប់នៃមេរៀនថ្ងៃនេះ សិក្ខាកាមនឹងអាច៖**

១ ផ្ដល់សារគន្លឹះនៃការចិញ្ចឹមទារក និងកុមារ ទៅឱ្យម្ដាយ និងអ្នកថែទាំកុមារ ។
២ កំណត់បានពីអាហារដែលសំបូរទៅដោយជីវជាតិអា និងជំរុញឱ្យម្ដាយនិងអ្នកថែទាំកុមារ ប្រើប្រាស់អាហារទាំងនេះ ។
៣ ផ្ដល់ការអប់រំសុខភាពដល់ម្ដាយ និងអ្នកថែទាំកុមារអំពីការផ្ដល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ។
៤ កំណត់បាននូវអ្នកប្រឈមមុខទៅនឹងការខ្វះជីវជាតិអា និងអ្នកដែលមានសញ្ញាកង្វះជីវជាតិអា ព្រមទាំងធ្វើការផ្ដល់ប្រឹក្សាបានសមស្រប ។

## កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨ :០០ | ១០ | ៣.១ | ខ្ញុំបោះ ..<br>ល្បែងថាមពលដើម្បីបង្កើតការលើកទឹកចិត្ត និង ថាមពលវិជ្ជមាន | ទាំងអស់គ្នា |
| ៨:១០ | ១០ | ៣.២ | គោលបំណងនៅថ្ងៃទី ៣<br>បាឋកថា បង្ហាញពីគោលបំណងនៅថ្ងៃទី ៣ | អ្នកសម្របសម្រួល |
| ៨:២០ | ៤៥ | ៣.៣ | ការចិញ្ចឹមទារក និងកុមារ<br>ការងារក្រុមដើម្បីពង្រឹងសារគន្លឹះ | ក្រុម |
| ៩:០៥ | ៥៥ | ៣.៤ | ការអនុវត្តសារការចិញ្ចឹមទារកនិងកុមារ និងការដៅចំណុចការលួតលាស់<br>ការងារក្រុមៈ អនុវត្តន៏ការដៅចំណុច | ក្រុម |
| ១០:០០ | ២០ | | សម្រាក | |
| ១០:២០ | ៦០ | ៣.៥ | ការចិញ្ចឹមទារក និងកុមារ<br>សំណួរ និង ចម្លើយ | អ្នកសម្របសម្រួល និងសិក្ខាកាម |
| ១១:២០ | ១០ | ៣.៦ | ការសន្និដ្ឋាននៅពេលព្រឹក<br>សង្ខេប | អ្នកសម្របសម្រួល |
| ១១:៣០ | ១២០ | | សម្រាក | |
| ១៣:៣០ | ១០ | ៣.៧ | ស្រែកយ៉ាងខ្លាំង<br>ល្បែងថាមពលដើម្បីបង្កើតការលើកទឹកចិត្ត និង ថាមពលវិជ្ជមាន | ទាំងអស់គ្នា |
| ១៣:៤០ | ៥០ | ៣.៨ | សារៈសំខាន់នៃជីវជាតិអា<br>បាឋកថា ស្តីអំពីជីវជាតិអា | អ្នកសម្របសម្រួល |
| ១៤:៣០ | ១០ | ៣.៩ | លំហាត់ៈ អាហារដែលសំបូរជីវជាតិអា<br>ការកំណត់រកអាហារដែលសំបូរជីវជាតិអា | បុគ្គលម្នាក់ៗ |
| ១៤:៤០ | ៣០ | ៣.១០ | ការការពារ និងការព្យាបាលកង្វះជីវជាតិអា<br>បាឋកថា | អ្នកសម្របសម្រួល |
| ១៥:១០ | ២០ | | សម្រាក | |
| ១៥:៣០ | ៨០ | ៣.១១ | លំហាត់ៈ ករណីសិក្សារឿងជីវជាតិអា<br>ការអនុវត្តផ្តល់សារជីវជាតិអា ការព្យាបាលនិងការការពារ | បុគ្គលម្នាក់ៗ ឬជាគូ |
| ១៦:៥០ | ១០ | ៣.១២ | ការសន្និដ្ឋាននៅពេលល្ងាច<br>សង្ខេប | អ្នកសម្របសម្រួល |
| ១៧:០០ | | | បញ្ចប់ម៉ោងសិក្សា | |

## សម្ភារៈដែលត្រូវការ

- ស្លាយសំរាប់បង្ហាញ ៧៤-១០៣
- ក្រដាសផ្ទាំងធំ
- រូបភាព
- សន្លឹកផ្ទាត់ស្តីពីការចិញ្ចឹមទារក និងកុមារ
- ប័ណ្ណលឿង
- ជញ្ជីង
- ក្រដាសបិទពីរពណ៌ ឬ ប៊ិចហ្វឺត២ដែលមានពណ៌ខុសគ្នា
- សម្ភារៈជំនួយការងារ

# សកម្មភាពថ្ងៃទី ៣

## ៣.១ ខ្ញុំចោល............ (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីថ្ងៃនេះ។

**វិធីសាស្ត្រ :** ល្បែងថាមពល

**អ្នកណា :** សិក្ខាកាមទាំងអស់ ដែលសម្របសម្រួលដោយអ្នកសម្របសម្រួលម្នាក់

**សម្ភារៈ :** មិនមានសម្ភារៈដែលត្រូវការ

### ការណែនាំ

- ស្នើឱ្យសិក្ខាកាមឈរជារង្វង់។
- ពន្យល់ សិក្ខាកាមថាសកម្មភាពនេះ គឺគេត្រូវនិយាយបំផ្លើសឱ្យបានច្រើនតាមតែអាចធ្វើទៅបាន។
- សិក្ខាកាមម្នាក់ចោលវត្ថុស្រមើលស្រមៃមួយទៅសិក្ខាកាមម្នាក់ទៀត ដោយនិយាយបំផ្លើសតាមតែអាចធ្វើបាន។
- ឧទាហរណ៍ អ្នកសម្របសម្រួលចាប់ផ្តើមដោយស្រមៃថាបានចោលដំរីដ៏ធំមួយ។
- និយាយអ្វីដែលអ្នកបានចោល ហើយបំផ្លើស។
- បន្ទាប់ពីបានចោលវត្ថុនោះហើយ អ្នកត្រូវអោបដៃ ដើម្បីបញ្ជាក់ថាអ្នកបានចោលរួចហើយ។

- នៅពេលដែលសិក្ខាកាមទាំងអស់បានចោលអស់អ្វីៗហើយ លាដៃវិញ ហើយនិយាយថា វាគួរតែបំផ្លើសឱ្យខ្លាំងជាងនេះ ។ លេងលើកទី ២ ។
- បញ្ឈប់ល្បែងនេះបន្ទាប់ពីលេងបាន ១០ នាទី និងអញ្ជើញសិក្ខាកាមឱ្យទៅកាន់កន្លែងអង្គុយរៀងៗខ្លួន ។

## ៣.២ គោលបំណងថ្ងៃទី ៣ (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមយល់ច្បាស់ពីគោលបំណងមេរៀនថ្ងៃទី ៣ ។

**វិធីសាស្ត្រ :** បាឋកថា

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយសំរាប់បង្ហាញ ៧៤-៧៦

### ការណែនាំ

ការបង្ហាញស្លាយ ទី៧៤-៧៦ ដល់សិក្ខាកាម

## ៣.៣ ការចិញ្ចឹមទារក និងកុមារ : ការងារជាក្រុម (៤៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្ដល់សារនៃការចិញ្ចឹមទារក និងកុមារ ដល់ក្រុមគោលដៅសមស្រប ។

**វិធីសាស្ត្រ :** ការងារជាក្រុម

**អ្នកណា :** ក្រុមដែលមានសមាជិកយ៉ាងច្រើន ៥ នាក់

**សម្ភារៈ :** ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត និងរូបភាព (សម្ភារៈជំនួយការបណ្ដុះបណ្ដាលនៅក្នុងឧបសម្ព័ន្ធ)

**សៀវភៅសិក្ខាកាម :** ជំពូក ៣.១១

### សន្និទានភាព

គំនិតនៃកិច្ចការនេះ គឺថា ក្រុមនិមួយៗ បង្កើតតារាងមួយដែលបង្ហាញពីទិដ្ឋភាពទូទៅនៃក្រុមអាយុកុមារដែលត្រូវទទួលការបំបៅដោយទឹកដោះម្ដាយ និងការផ្ដល់អាហារបន្ថែម ។ សិក្ខាកាមនឹងកំណត់ចំនួននៃអាហារ ភាពខាប់ និងភាពញឹកញាប់នៃការផ្ដល់អាហារដល់កុមារទៅតាមអាយុ ។ ក្រុមការងារនឹងធ្វើដូច្នេះដើម្បីបង្កើតជាកូលោន ៨ នៃរូបភាព (ដូចដែលបានបង្ហាញនៅខាងក្រោម) ។

| ក្រុមអាយុ | ការបំបៅកូនដោយទឹកដោះម្ដាយ | ការផ្ដល់អាហារបន្ថែម | អាហារគ្រួសារ | សណ្ឋានអាហារ | ចំនួនអាហារក្នុងមួយថ្ងៃ | ភាពញឹកញាប់ | ផ្ដល់អាហារសម្រន់ប៉ុន្មានដងក្នុង១ថ្ងៃ |
|---|---|---|---|---|---|---|---|
| | | | | | | | |

**ការណែនាំ ៖**

- រៀបជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់។
- ប្រគល់ឱ្យក្រុមនិមួយៗនូវក្រដាសផ្ទាំងធំ និងប៊ិចហ្វឺត ដើម្បីឱ្យពួកគាត់បង្កើតតារាងដោយខ្លួនឯង។
- ពន្យល់ថាលំហាត់នេះ គឺអំពីការបំបៅកូនដោយទឹកដោះម្ដាយ និងអាហារបន្ថែម។ សុំឱ្យក្រុមធ្វើការពិភាក្សាការអនុវត្តន៍ការចិញ្ចឹមកុមារទៅតាមក្រុមអាយុ (០-៦ខែ ៧-៨ខែ ៩-១១ខែ និង ១២-២៤ខែ ព្រមទាំងបំពេញតារាង)
- ធ្វើការណែនាំក្រុមថា ពួកគាត់គួរតែគូសសញ្ញាខ្វែងនៅក្នុងកូលោនដែលស៊ីគ្នា គូសខ្វែងនៅក្នុងកូលោន ប្រសិនបើកុមារត្រូវការបំបៅដោយដោះម្ដាយ និងគូសខ្វែងនៅក្នុងកូលោនប្រសិនបើកុមារត្រូវការអាហារបន្ថែម ឬអាហារគ្រួសារ។
- ប្រសិនបើកុមារត្រូវការអាហារបន្ថែម ឬអាហារគ្រួសារ ចូលសរសេរលំអិតបន្ថែមនៅក្នុងកូលោននៃភាពខាប់ (សណ្ឋានអាហារ) បរិមាណ និងចំនួនដងនៃអាហារដែលត្រូវផ្ដល់ឱ្យ។
- បន្ទាប់ពីធ្វើបាន ២០នាទីមក ក្រុមការងារបិទលទ្ធផលនៅលើជញ្ជាំង។
- រយៈពេល ២០ នាទីចុងក្រោយ អ្នកសម្របសម្រួលប្រៀបធៀបលទ្ធផលរបស់ក្រុម ហើយឆ្លើយនឹងសំណួររបស់សិក្ខាកាម។

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ពន្យល់ | ៥ |
| ការរៀបចំនៅក្នុងក្រុម | ២០ |
| ការប្រៀបធៀប និងផ្ដល់ព័ត៌មានត្រលប់ដោយអ្នកសម្របសម្រួល | ២០ |
| **សរុប** | **៤៥** |

## ៣.៤ ការអនុវត្តសារគន្លឹះនៃការចិញ្ចឹមទារក និងកុមារ និងការដៅចំណុចការលូតលាស់៖ ការងារជាក្រុម (៥៥ នាទី)

**គោលបំណង៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចប្រើប្រាស់សារអប់រំការចិញ្ចឹមទារក និងកុមារដោយមានទំនុកចិត្ត។

**វិធីសាស្ត្រ** ៖ ការងារជាក្រុម

**នរណា** ៖ សិក្ខាកាមជាក្រុមដែលមានសមាជិកយ៉ាងច្រើន ៥ នាក់

**សម្ភារៈ** : សន្លឹកផ្ទាត់អប់រំការចិញ្ចឹមទារក និងកុមារ និងសម្ភារៈជំនួយការងារ
បណ្ណលឿងដែលមិនទាន់បំពេញ
ជញ្ជីង
បណ្ណសំរាប់ការសំដែងតួ (សម្ភារៈជំនួយការងារនៅក្នុងឧបសម្ព័ន្ធ)

**សៀវភៅសិក្ខាកាម :** ជំពូក ៣.១៥-៣.១៩

## សន្និទានភាព

ក្នុងអំឡុងពេលនៃការសំដែងតួនេះ សិក្ខាកាមរៀន និងអនុវត្តពីរបៀបផ្តល់ប្រឹក្សាដល់ម្តាយ និងរបៀបថ្លឹងទម្ងន់កុមារ។ គួរបញ្ជាក់ថា ការថ្លឹងទម្ងន់កុមារគឺធ្វើនៅតែមណ្ឌលសុខភាពប៉ុណ្ណោះ ហើយនិងមិនធ្វើនៅពេលចុះមូលដ្ឋាននោះទេ។ ការសំដែងតួ គឺពង្រឹងការប្រស្រ័យទាក់ទង និងជំនាញនៃការផ្តល់ប្រឹក្សារបស់សិក្ខាកាម។ សូមអានផ្នែកស្តីពីជំនាញនៃការប្រស្រ័យទាក់ទងនៅក្នុងសៀវភៅ មុននឹងធ្វើការសំដែងតួ។

## ការណែនាំ :

- រៀបចំជាក្រុមដែលមានសិក្ខាកាម ៤ នាក់។
- ផ្តល់ឱ្យក្រុមនិមួយៗ នូវសាច់រឿងសំរាប់ការសំដែងតួមួយសំរាប់ដែលមាន ២ រឿង។
- សាច់រឿងនិមួយៗ សិក្ខាកាមម្នាក់ដើរតួជាបុគ្គលិកមណ្ឌលសុខភាព និងសិក្ខាកាមម្នាក់ទៀតដើរតួជាម្តាយដែលបានយកកូនមកជាមួយ។ សិក្ខាកាម ២ នាក់ ផ្សេងទៀតជាអ្នកសង្កេត។
- កំណត់តួនាទី អ្នកសំដែងអានបណ្ណសាច់រឿងរបស់គាត់ បន្ទាប់មកសម្តែងមិនឱ្យលើសពី ១០ នាទី។
- បន្ទាប់មក ការសំដែងតួត្រូវបានពិភាក្សាក្នុងក្រុម ដោយមិនឱ្យលើសពី ៥ នាទី។
- បន្ទាប់ពីការពិភាក្សាយ៉ាងខ្លីមក ការសំដែងតួត្រូវធ្វើឡើងម្តងទៀត តាមអនុសាសន៍ដែលបានពិភាក្សាយ៉ាងខ្លីនោះ។
- ការសម្តែងឡើងវិញនេះ នឹងមិនត្រូវចំណាយពេលឱ្យលើសពី ៥ នាទីទេ។
- ចំពោះការសម្តែងលើកទី ២ ដែលមានរយៈពេល ៣០ នាទីនោះ អ្នកសង្កេតការត្រូវធ្វើជាអ្នកសំដែងតួម្តង ហើយអ្នកដែលសំដែងតួពីលើកមុន ដើរតួជាអ្នកសង្កេតការ។
- បណ្ណសាច់រឿងទី ២ ត្រូវបានប្រើសំរាប់ការសំដែងនេះ។ ទម្រង់ការណែនាំ គឺដូចដែលបានរៀបរាប់ខាងលើ ដែលធ្វើការសង្ខេបដោយអ្នកសម្របសម្រួលនៅទីបញ្ចប់។
- សូមមើលតារាងខាងក្រោម សំរាប់ការបញ្ជាក់ពីពេលវេលា។

## កាលវិភាគ

| ជុំទី ១ | ពេលវេលា | ជុំទី ២ | ពេលវេលា |
|---|---|---|---|
| អានប័ណ្ណ | ៥ នាទី | អានប័ណ្ណ | ៥ នាទី |
| សម្តែងលើកទី១ | ១០ នាទី | សម្តែងលើកទី១ | ១០ នាទី |
| ពិភាក្សា | ៥ នាទី | ពិភាក្សា | ៥ នាទី |
| សម្តែងម្តងទៀត | ៥ នាទី | សម្តែងម្តងទៀត | ៥ នាទី |
| | | សង្ខេប | ៥ នាទី |
| **សរុប** | **២៥ នាទី** | | **៣០ នាទី** |
| | | | **៥៥ នាទី** |

សម្រាក (២០ នាទី)

## ៣.៥ ការពង្រឹងការចិញ្ចឹមទារក និងកុមារ (៦០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាដល់ស្ត្រីពីការចិញ្ចឹមទារក និងកុមារដោយប្រើប្រាស់សារដ៏ត្រឹមត្រូវ ។

**វិធីសាស្ត្រ :** សំណួរ និង ចម្លើយ

**អ្នកណា :** អ្នកសម្របសម្រួលដោយធ្វើព្យុះគំនិតជាមួយសិក្ខាកាម

**សម្ភារៈ :** ក្រដាសស្អិតសំរាប់បិទពីរពណ៌ ឬ ប៊ិចហ្វឺត ២ ដែលមានពណ៌ខុសគ្នា
ក្រដាសផ្ទាំងធំ និងក្តារខៀនស

### ការណែនាំ

#### ជាមួយក្រដាសស្អិតសំរាប់បិទ

- ផ្តល់ក្រដាសស្អិតសំរាប់បិទដែលមានពីរពណ៌ខុសៗគ្នា ទៅឱ្យសិក្ខាកាមទាំងអស់ (សរុបទាំងអស់មាន ៦ សន្លឹក)
- ស្នើឱ្យសិក្ខាកាមសរសេរពីអ្វីដែលគាត់យល់ឃើញថាជាការពិបាកនៅលើក្រដាសពណ៌មួយ ។ បញ្ហាមួយនៅលើក្រដាសមួយ ។
- ពួកគាត់មិនអាចសរសេរបញ្ហាលើសពី ២ ទេ ដូចនេះប្រសិនបើចាំបាច់ ពួកគាត់ត្រូវតែធ្វើការជ្រើសរើស ។
- ចំពោះក្រដាសពណ៌មួយទៀត ពួកគេគួរសរសេរអ្វីដែលរកឃើញថាងាយស្រួលយល់ ឬ ងាយធ្វើ ។ ដូចគ្នានោះដែរ ពួកគាត់មិនអាចសរសេរលើសពី ២ ទេ ។
- អញ្ជើញសិក្ខាកាមឱ្យបិទក្រដាសស្អិត នៅលើក្តារខៀន ឬ ក្រដាសផ្ទាំងធំ ។

### បិទបញ្ចប់និងក្រដាសផ្ទាំងធំ:

- បង្កើតក្រដាសផ្ទាំងធំពីរ : មួយសំរាប់អ្វីដែលពិបាក និងមួយទៀតសំរាប់អ្វីដែលងាយស្រួលយល់ ឬ ងាយអនុវត្ត។
- សុំឱ្យសិក្ខាកាមសរសេរបញ្ហារបស់ពួកគេ នៅលើក្រដាសផ្ទាំងធំណាមួយ
- ប្រសិនបើគាត់ឯកភាពនឹងអ្វីដែលសិក្ខាកាមម្នាក់ទៀតបានសរសេររួចហើយ គាត់អាចគ្រាន់តែគូសសញ្ញាបញ្ជាក់នៅខាងក្រោយបញ្ហានោះ។

### ទីបញ្ចប់

- អ្នកសម្របសម្រួលពិនិត្យរកមើល បញ្ហារួម ហើយបង្ហាញបញ្ហាទាំងនោះទៅក្រុម
- សំរាប់រយៈពេល ៣៥ នាទីចុងក្រោយ អ្នកសម្របសម្រួលធ្វើការជ្រើសរើសយកបញ្ហារួមដែលបានចង្អុលបង្ហាញទាំងនោះ
- ពន្យល់/ធ្វើឱ្យពួកគាត់យល់ច្បាស់

## ៣.៦ ការសន្និដ្ឋាន នៅពេលព្រឹក (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តអំពីចំណេះដឹង និងជំនាញដែលបានសិក្សាពីព្រឹក។

**វិធីសាស្ត្រ** : សង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលរូបមាននាឡិកា និងបញ្ជាក់ពីពេលវេលា

### ការណែនាំ

- ល្បែងថាមពល
- គោលបំណង
- ការចិញ្ចឹមទារក និងកុមារ និងសកម្មភាពវាយតម្លៃការលូតលាស់របស់កុមារ
- បញ្ហាដែលពិបាក
- បង្ហាញពួកគាត់នូវក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងបញ្ជាក់ពីពេលវេលាដែលពួកគាត់ត្រូវត្រលប់មកវិញ

**សម្រាក (១២០ នាទី)**

## ៣.៧ ស្រែកយ៉ាងខ្លាំង (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីនាពេលល្ងាច

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់

**សម្ភារៈ** : មិនមានសម្ភារៈដែលត្រូវការ

### ការណែនាំ

- អញ្ជើញសិក្ខាកាមឱ្យចាប់យកលេខពីលេខ ១ ដល់ លេខ ៥ ហើយលាម្រាមដៃទៅតាមលេខដែលគាត់ចាប់បាន។
- ឱ្យពួកគាត់រកឱ្យឃើញយ៉ាងលឿនអ្នកដែលមានលេខដៃដូចគ្នានៅក្នុងដៃ។ ត្រូវឱ្យច្បាស់ថាក្រុមនិមួយៗ មានចំនួនសមាជិក ៥ នាក់ស្មើគ្នា។ ប្រសិនបើចាំបាច់ផ្លាស់ប្តូរមនុស្សទៅក្រុមផ្សេងទៀត។
- ឱ្យពួកគាត់តម្រង់ជាជួរដោយនៅបន្តពីក្រោយគ្នា ហើយឱ្យក្រុមរួមគ្នាបង្កើតជាពាក់កណ្តាលរង្វង់មួយ។ គឺអ្នកដែលនៅពីមុខគេនៃជួរនិមួយៗប៉ុណ្ណោះដែលអាចស្រែកបាន។ គេអាចស្រែកអ្វីក៏បានដរាបណាល្បែងនេះនៅបន្ត។
- យើងចាប់ផ្តើមពីអ្នកដែលនៅខាងឆ្វេង ហើយទៅខាងស្តាំ។ នៅពេលដែលនរណាម្នាក់ចាប់ផ្តើមស្ទាក់ស្ទើរភ្លាម គាត់ត្រូវដើរទៅខាងក្រោយនៃជួរ ហើយអ្នកទីពីរនឹងទទួលការងារនេះបន្ត។
- សូមចងចាំថា គាត់អាចស្រែកពាក្យអ្វីមួយក៏បាន : ពាក្យទាំងនោះមិនចាំបាច់ទាក់ទងគ្នាទេ ដូចជា "ព្រះអាទិត្យ" "កូនក្មេង" "ល្អណាស់" "លោកយាយ" "ម្នាស់"។
- នៅពេលដែលអ្នកណាម្នាក់បានចូលទៅជួរខាងក្រោយគាត់ត្រូវស្រែកថា "ខ្ញុំល្អណាស់"។
- បញ្ឈប់ល្បែងនេះបន្ទាប់ពីលេងបាន ១០ នាទី។
- ពន្យល់ទៅសិក្ខាកាមថា ការធ្វើឱ្យមានកំហុសឆ្គង ឬភ្លេចភ្លាំងមិនមែនជាបញ្ហាធំទេ ប៉ុន្តែត្រូវសួរខ្លួនឯងថា: តើខ្ញុំអាចធ្វើដូចម្តេចដើម្បីឱ្យបានល្អជាងនេះនៅពេលក្រោយ?

## ៣.៨ សារៈសំខាន់នៃជីវជាតិអា (៥០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមយល់យ៉ាងច្បាស់នូវកម្មវិធីជីវជាតិអា សារគន្លឹះ និងសកម្មភាពជីវជាតិអា។

**វិធីសាស្ត្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយសំរាប់បង្ហាញ ទី ៧៧-៩១

**សៀវភៅសិក្ខាកាម :** ជំពូក ៤.១-៤.៧

### ការណែនាំ

- ប្រើប្រាស់ ស្លាយ ទី៧៧-៩១ ដែលមានសារជាមូលដ្ឋានដើម្បីធ្វើបាឋកថាស្តីអំពីនៃជីវជាតិអា

## ៣.៩ អាហារដែលសំបូរដោយជីវជាតិអា-លំហាត់ ង (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចកំណត់បាននូវអាហារដែលសំបូរដោយជីវជាតិអា។

**វិធីសាស្ត្រ :** លំហាត់សំរាប់បុគ្គលម្នាក់ៗ

**អ្នកណា :** សិក្ខាកាមម្នាក់ៗ

**សម្ភារៈ :** លំហាត់ ង នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម
ស្លាយសំរាប់បង្ហាញទី ៩៣

**សៀវភៅសិក្ខាកាម :** ជំពូក ៤.៨

### ការណែនាំ

- ស្នើឱ្យសិក្ខាកាមធ្វើការតែម្នាក់ឯង នៅលើលំហាត់ទាំងនេះ។
- ស្នើឱ្យសិក្ខាកាមមើលទៅរូបភាពអាហារនៅខាងក្រោម ហើយគូសជុំវិញអាហារ ៤ ដែលសំបូរដោយជីវជាតិអា។
- នៅពេលគូសរួចហើយ ប្រាប់ពួកគាត់ឱ្យពិនិត្យមើលអ្នកដែលនៅជិតគាត់និងគិតម្តងទៀតពីជម្រើសរបស់គាត់។



## ៣.១០ ការព្យាបាលកង្វះជីវជាតិអា (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមយល់ច្បាស់អំពីការព្យាបាលកង្វះជីវជាតិអា។

**វិធីសាស្ត្រ :** បាឋកថា

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយបង្ហាញទី ៩៤-១០០

**សៀវភៅសិក្ខាកាម :** ជំពូក ៤.៩-៤.១១

## ការណែនាំ

ប្រើប្រាស់ស្លាយទី ៩៤-១០០ ដើម្បីពន្យល់សិក្ខាកាមពីការការពារនិងការព្យាបាល ។

សម្រាក (២០ នាទី)

## ៣.១១ ករណីសិក្សា ជីវជាតិអា - លំហាត់ ច (៤០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ព័ត៌មានដ៏ត្រឹមត្រូវក្នុងអំឡុងពេលធ្វើការផ្តល់ប្រឹក្សាអំពីការការពារ និងការព្យាបាលកង្វះជីវជាតិអា ។

**វិធីសាស្ត្រ** : លំហាត់ជាលក្ខណៈ បុគ្គលម្នាក់ៗ និងជាគូ

**អ្នកណា** : បុគ្គលម្នាក់ៗ និងជាគូ

**សម្ភារៈ** : លំហាត់ ច នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម
សម្ភារៈជំនួយការងារ ជីវជាតិអា
ស្លាយបង្ហាញទី ១០០-១០៣

## ការណែនាំ

- ប្រាប់សិក្ខាកាមឱ្យអនុវត្តផ្នែកទី ១ នៃលំហាត់នេះដោយផ្ទាល់ខ្លួនដោយគ្មានពិភាក្សាជាមួយសិក្ខាកាមផ្សេងទៀត
- ស្នើឱ្យពួកគាត់បំពេញនៅក្នុងតារាងលំហាត់ ច (ដូចដែលបានបង្ហាញខាងក្រោម) ឱ្យបានល្អតាមតែអាចធ្វើទៅបានដោយប្រើប្រាស់សម្ភារៈជំនួយការងារជំពូកជីវជាតិអា ។
- រំលឹកសិក្ខាកាមថាពួកគេមានពេលវេលា ១០ នាទី សំរាប់ករណីសិក្សាមួយ (សរុបទាំងអស់ ៤០ នាទី) ។
- បន្ទាប់ពីបញ្ចប់ករណីសិក្សាទាំង ៤ សិក្ខាកាមអាចចែករំលែកលទ្ធផលជាគូ (២០ នាទី) ។
- នៅក្នុងរយៈពេល ២០ នាទីចុងក្រោយនៃការធ្វើលំហាត់ គឺជាពេលដែលអ្នកសម្របសម្រួលផ្តល់ព័ត៌មានត្រលប់ទៅឱ្យសិក្ខាកាម ។
- ប្រើប្រាស់ស្លាយទី ១០០-១០៣ ដើម្បីពិភាក្សាលទ្ធផលជាមួយសិក្ខាកាម

| | | | |
|---|---|---|---|
|  | **ពិដោ**<br>ពិដោ គឺជាស្ត្រីក្រោយសម្រាលដែលមានកូនអាយុ ៤ សប្តាហ៍ ។ នាងបានសម្រាលកូននៅផ្ទះ ។ នាងមិនបានជួបជាមួយបុគ្គលិកមណ្ឌលសុខភាពពីមុនមកទេ ប៉ុន្តែនាងបានសម្រាលកូនដោយឆ្មបបុរាណ ។ | | |
| តើសំណួរអ្វីខ្លះដែលអ្នកនឹងត្រូវធ្វើការសាកសួរ? | តើត្រូវផ្តល់អ្វី? | តើសារគន្លឹះអ្វីខ្លះត្រូវផ្តល់ឱ្យ? | តើកត់ត្រានៅកន្លែងណា? |

| | | | |
|---|---|---|---|
|  | **មូលី**<br>មូលី គឺជាម្តាយដែលមានកូនអាយុ៨ខែ ។ | | |
| តើសំណួរអ្វីខ្លះដែលអ្នកនឹងត្រូវធ្វើការសាកសួរ? | តើត្រូវផ្តល់អ្វី? | តើសារគន្លឹះអ្វីខ្លះត្រូវផ្តល់ឱ្យ? | តើកត់ត្រានៅកន្លែងណា? |

| | | | |
|---|---|---|---|
|  | **សុធា**<br>សុធា ជាកុមារអាយុ ៤ ឆ្នាំ ដែលមានជម្ងឺខ្វាក់មាន់ និងស្នាមប៊ីតូត ។ | | |
| តើសំណួរអ្វីខ្លះដែលអ្នកនឹងត្រូវធ្វើការសាកសួរ? | តើត្រូវផ្តល់អ្វី? | តើសារគន្លឹះអ្វីខ្លះត្រូវផ្តល់ឱ្យ? | តើកត់ត្រានៅកន្លែងណា? |

| | | | |
|---|---|---|---|
|  | **រក្សា**<br>រក្សា មានអាយុ ៧ ខែ ដែលមានជម្ងឺកញ្ជ្រិល ។ | | |
| តើសំណួរអ្វីខ្លះដែលអ្នកនឹងត្រូវធ្វើការសាកសួរ? | តើត្រូវផ្តល់អ្វី? | តើសារគន្លឹះអ្វីខ្លះត្រូវផ្តល់ឱ្យ? | តើកត់ត្រានៅកន្លែងណា? |

## ៣.១២ ការសន្និដ្ឋាននៅពេលល្ងាច (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តទៅលើចំណេះដឹង និងជំនាញដែលបានរៀនពីសកម្មភាពមុននេះ

**វិធីសាស្ត្រ** : ការសង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងបញ្ជាក់ម៉ោងពេល
ក្រដាសបិទពណ៌បៃតង និងពណ៌ទឹកក្រូច
ក្រដាសផ្ទាំងធំដែលសរសេរពីកម្មវិធីថ្ងៃនេះ

## ការណែនាំ

**សង្ខេបនៅពេលល្ងាច ដោយរំលឹកឡើងវិញពីអ្វីដែលបានរៀន**

- សារៈសំខាន់នៃជីវជាតិអា
- លំហាត់ស្តីពី អាហារដែលសំបូរដោយជីវជាតិអា
- វិធានការទប់ស្កាត់កង្វះជីវជាតិអា និងការព្យាបាល
- ការកត់ត្រាពីការចែកចាយគ្រាប់ថ្នាំជីវជាតិអានៅលើប័ណ្ណលឿង
    - ឱ្យសិក្ខាកាមម្នាក់ៗ នូវក្រដាសបិទពណ៌បៃតង ២ និង ពណ៌ទឹកក្រូច ២
    - បិទក្រដាសផ្ទាំងធំនៅជិតទ្វារចេញ ហើយសុំឱ្យសិក្ខាកាមបិទក្រដាសរបស់គាត់នៅលើសកម្មភាពដែលគាត់ចូលចិត្ត (ក្រដាសពណ៌បៃតង) និងមិនចូលចិត្ត (ក្រដាសពណ៌ទឹកក្រូច)
    - ប្រសិនបើមិនមានសកម្មភាពណាដែលគេមិនចូលចិត្តទេ ប្រាប់ពួកគេថា មិនចាំបាច់ សរសេរនៅលើក្រដាសស្អិតពណ៌ទឹកក្រូចទេ
    - ប្រើតារាងពេលវេលាប្រចាំថ្ងៃដែលបានសរសេរនៅលើក្រដាសផ្ទាំងធំកាលពីព្រឹក

បង្ហាញសិក្ខាកាមក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងពេលវេលាដែលពួកគាត់ត្រូវត្រលប់មកវិញ

# ថ្ងៃទី ៤: ជីវជាតិអា/ជាតិដែក

## គោលបំណងថ្ងៃទី ៤:

១ ដើម្បីរំលឹកឡើងវិញនូវមេរៀនដែលបានរៀនរួច ស្តីពីកម្មវិធីជីវជាតិអា កាលពីថ្ងៃម្សិលមិញ
២ ដើម្បីបណ្តុះបណ្តាលអំពីជំនាញក្នុងការធ្វើផែនការសកម្មភាពជីវជាតិអា
៣ ដើម្បីផ្តល់នូវចំណេះដឹងស្តីអំពីកម្មវិធីជាតិដែក
៤ ដើម្បីបណ្តុះបណ្តាលអំពីជំនាញក្នុងការផ្តល់សារស្តីពីជាតិដែក ដល់ស្ត្រី និងអ្នកថែទាំកុមារតូច

## គោលបំណងជំនាញសំរាប់សិក្ខាកាមនៅថ្ងៃទី ៤:

**នៅចុងបញ្ចប់មេរៀនថ្ងៃនេះ សិក្ខាកាមអាច :**

១ បំពេញសន្លឹកកត់ត្រា (tally sheet) សំរាប់ការចែកចាយគ្រាប់ថ្នាំជីវជាតិអា
២ រៀបចំជុំសំរាប់ចែកចាយគ្រាប់ថ្នាំជីវជាតិអា
៣ កំណត់បានអំពីចំណីអាហារសំបូរដោយជាតិដែក និងលើកកម្ពស់ផ្សព្វផ្សាយអំពីការប្រើប្រាស់ចំណីអាហារទាំងនោះដល់ស្ត្រី និងអ្នកថែទាំកុមារ
៤ កំណត់បានអំពីប្រជាជនដែលប្រឈមនឹងបញ្ហាកង្វះជាតិដែក និងប្រជាជនដែលស្តែងចេញនូវរោគសញ្ញាកង្វះជាតិដែក ព្រមទាំងធ្វើការផ្តល់ប្រឹក្សាឱ្យបានសមស្រប

# កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨ :០០ | ១០ | ៤.១ | រូបភាពក្នុងកញ្ចក់<br>ល្បែងថាមពល- ដើម្បីបង្កើតថាមពលវិជ្ជមាន<br>និង ការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ៨:១០ | ១០ | ៤.២ | គោលបំណងថ្ងៃទី ៤<br>បាឋកថា: បង្ហាញពីគោលបំណងប្រចាំថ្ងៃ | អ្នកសម្របសម្រួល |
| ៨:២០ | ៣០ | ៤.៣ | សន្លឹកកត់ត្រា (Tally Sheets)<br>បាឋកថា ពីរបៀបធ្វើការជាមួយសន្លឹកកត់ត្រា | អ្នកសម្របសម្រួល |
| ៨:៥០ | ៤០ | ៤.៤ | ធ្វើការជាមួយសន្លឹកកត់ត្រា<br>ការងារក្រុម-អនុវត្តការបំពេញសន្លឹកកត់ត្រា | ក្រុម |
| ៩:៣០ | ៤៥ | ៤.៥ | ជំហានក្នុងការធ្វើផែនការអំពីការចែកចាយគ្រាប់ថ្នាំជីវជាតិអា ប្រកបដោយប្រសិទ្ធភាព<br>ការងារជាក្រុមក្នុងការកំណត់ជំហានចាំបាច់ | ក្រុម |
| ១០:១៥ | ៦៥ រួមទាំងសម្រាក | ៤.៦ | ការងារតាមក្រុម-ការធ្វើផែនការការចែកចាយ<br>គ្រាប់ថ្នាំជីវជាតិអា | ក្រុម |
| ១១:២០ | ១០ | ៤.៧ | សេចក្តីសន្និដ្ឋានសំរាប់ពេលព្រឹក<br>សង្ខេប | អ្នកសម្របសម្រួល |
| ១១:៣០ | ១២០ | | សម្រាក | |
| ១៣:៣០ | ១០ | ៤.៨ | លេខ មិនកុហក<br>ល្បែងថាមពល-ដើម្បីបង្កើតថាមពលវិជ្ជមាន និង<br>ការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ១៣:៤០ | ៦០ | ៤.៩ | សារៈសំខាន់នៃជាតិដែក<br>បាឋកថាស្តីពីជាតិដែក | អ្នកសម្របសម្រួល |
| ១៤:៤០ | ១៥ | ៤.១០ | លំហាត់ - អាហារដែលសំបូរជាតិដែក<br>ការកំណត់អាហារដែលសំបូរជាតិដែក | បុគ្គលម្នាក់ៗ |
| ១៤:៥៥ | ៣០ | ៤.១១ | ការការពារនិងការព្យាបាលកង្វះជាតិដែក<br>បាឋកថា | អ្នកសម្របសម្រួល |
| ១៥:២៥ | ២០ | | សម្រាក | |
| ១៥:៥៥ | ៣០ | ៤.១២ | ការងារតាមក្រុម-សារគន្លឹះស្តីពីជាតិដែក | ក្រុម |
| ១៦:២៥ | ២៥ | ៤.១៣ | សំនួរ និងចម្លើយ អំពីជីវជាតិអា និងជាតិដែក<br>ស្រាយបំភ្លឺ | ទាំងអស់គ្នា<br>អ្នកសម្របសម្រួល |
| ១៦:៥០ | ១០ | ៤.១៤ | សេចក្តីសន្និដ្ឋានសំរាប់ថ្ងៃរសៀល | អ្នកសម្របសម្រួល |
| ១៧:០០ | | | ចប់ថ្ងៃទី ៤ | |

## សម្ភារៈដែលត្រូវការ ៖

- ស្លាយសំរាប់បង្ហាញ ពីទី ១០៤-១៣៦
- សន្លឹកកត់ត្រា (Tally Sheet)
- បញ្ជីទិន្នន័យ
- ក្រដាសផ្ទាំងធំ
- ប៊ិចហ្វឺត
- សម្ភារៈជំនួយការងារ
- លំហាត់ ឆ-ជ
- ក្រដាសតូចៗ
- ប៊ិច
- ប្រអប់ដែលមានរន្ធមួយ

# សកម្មភាពថ្ងៃទី ៤

## ៤.១ រូបភាពក្នុងកញ្ចក់ (១០ នាទី)

**គោលបំណង ៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីព្រឹកនេះ។

**វិធីសាស្ត្រ ៖** ល្បែងថាមពល

**អ្នកណា ៖** សិក្ខាកាមទាំងអស់ ដែលសម្របសម្រួលដោយអ្នកសម្របសម្រួលម្នាក់។

**សម្ភារៈ ៖**

### ការណែនាំ

- ស្នើសិក្ខាកាមឱ្យក្រោកឈរឡើង ហើយជ្រើសរើសលេខពីលេខ ១ ដល់ លេខ ១០។
- ប្រាប់ពួកគាត់ឱ្យដើរហើយស្រែកប្រាប់ពីលេខរបស់ខ្លួនម្នាក់ៗ រហូតទាល់តែពួកគេបានជួប អ្នកណាម្នាក់ទៀតដែលស្រែកលេខដូចគ្នា។ ពួកគាត់នឹងធ្វើជាដៃគូជាមួយគ្នាសំរាប់សកម្មភាពនេះ។
- នៅពេលដែលគ្រប់គ្នាមានដៃគូរៀងៗខ្លួនហើយសុំឱ្យពួកគាត់ឈរទល់មុខគ្នា ហើយដាក់ដៃទាំងពីរនៅពីមុខពួកគាត់។

- សុំឱ្យអ្នកដែលមានសក់វែងជាងគេចាប់ផ្ដើមធ្វើចលនា ចំណែកឯម្នាក់ទៀតត្រូវធ្វើចលនាតាមឱ្យដូចរូបភាពនៅក្នុងកញ្ចក់។
- ចូររំលឹកទៅសិក្ខាកាមថា ពួកគាត់អាចនឹងបង្កើតគំនិតច្នៃប្រឌិតដោយខ្លួនឯងបាន។
- ៣ នាទីក្រោយមក ចូរប្រាប់ពួកគាត់ឱ្យប្ដូរតួនាទីម្ដង។
- ៣ នាទីក្រោយមកទៀត ចូរប្រាប់ទៅគូនិមួយៗឱ្យដឹកនាំ និងធ្វើតាមនៅពេលតែមួយ។
- ពន្យល់ប្រាប់សិក្ខាកាមថា ធ្វើការងាររួមគ្នាជាទូទៅធ្វើឱ្យការងារកាន់តែមានភាពងាយស្រួលជាងមុន។

## ៤.២ គោលបំណងថ្ងៃទី ៤ (រយៈពេល ១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមយល់ច្បាស់ពីគោលបំណងមេរៀនថ្ងៃទី ៤។

**វិធីសាស្ត្រ :** បាឋកថា

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយសំរាប់បង្ហាញ ១០៤-១០៦

### ការណែនាំ

ការបង្ហាញស្លាយ ទី ១០៤-១០៦ ដល់សិក្ខាកាម

## ៤.៣ បាឋកថាស្ដីពីសន្លឹកកត់ត្រា (Tally sheet) (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមដឹងពីរបៀបបំពេញបញ្ជីកត់ត្រាសំរាប់ការចែកចាយគ្រាប់ថ្នាំជីវជាតិអា។

**វិធីសាស្ត្រ :** បាឋកថា

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយសំរាប់បង្ហាញពីទី ១០៧-១១១
សន្លឹកកត់ត្រា

**សៀវភៅសិក្ខាកាម :** ជំពូក ៩.៤

### ការណែនាំ

- បង្ហាញសន្លឹកកត់ត្រាដល់សិក្ខាកាម និងពន្យល់ពីរបៀបប្រើប្រាស់សន្លឹកកត់ត្រានេះ
- ប្រើប្រាស់ស្លាយទី ១០៧-១១១
- ធ្វើការគណនាដូចខាងក្រោម :

## ធ្វើការគណនាក្រុមចំណុចសំរាប់ ជីវជាតិអា មេបង់ដាសុល និងជាតិដែក

ឧទាហរណ៍: គ្រាប់ថ្នាំជីវជាតិអាសំរាប់សកម្មភាពចែកចាយពីរដងក្នុងមួយឆ្នាំ។ សន្លឹកកត់ត្រាផ្សេងទៀតគឺធ្វើតាមរបៀបដូចគ្នានេះដែរ។

*នៅក្នុងឧទាហរណ៍នេះ ភាគរយ សំរាប់ខេត្តកណ្តាល នៅក្នុងឆ្នាំ ២០០៧ /២០០៨។*

១ រកមើលភាគរយនៃអត្រាកើត ស្ត្រីក្រោយសម្រាលក្រោម ៦ សប្តាហ៍ ក្រុមកុមារអាយុ ០-១ និង ០-៥ ឆ្នាំ

| | | |
|---|---|---|
| កុមារអាយុ | ០-១ ឆ្នាំ | **២.៤%** (នៃប្រជាជនសរុប) |
| | ០-៥ ឆ្នាំ | **១១.១%** (នៃប្រជាជនសរុប) |
| ស្ត្រីក្រោយសម្រាល < ៦ សប្តាហ៍ | | **២.៦%** (នៃប្រជាជនសរុប) |

២ គណនាភាគរយនៃកុមារអាយុ ពី៦-១១ ខែ (សំរាប់គ្រាប់ថ្នាំជីវជាតិអាលេខ ១០០.០០០ IU)

| | | | |
|---|---|---|---|
| កុមារអាយុ | ០-១ ឆ្នាំ | **២,៤%** | |
| កុមារអាយុ | ៦-១១ ខែ គឺ ½ ដូចនេះ | **២,៤%/២** | = **១,២%** |

៣ គណនាភាគរយនៃកុមារអាយុ ពី១២-៥៩ ខែ (សំរាប់គ្រាប់ថ្នាំជីវជាតិអាលេខ ២០០.០០០ IU)

| | | | |
|---|---|---|---|
| កុមារអាយុ | ០-៥ ឆ្នាំ | **១១,១%** | |
| កុមារអាយុ | ១២-៥៩ ខែ គឺ | **១១,១% - ២,៤%** | = **៨,៧%** |

៤ គណនាចំនួនប៉ាន់ប្រមាណកុមារអាយុ ពី៦-១១ ខែ នៅក្នុងភូមិមួយ
ប/ស (ចំនួនប្រជាជនសរុបនៅក្នុងភូមិ) **x ១,២ / ១០០**
ប/ស (ចំនួនប្រជាជនសរុបនៅក្នុងភូមិ) **x ០,០១២ = ?**

៥ គណនាចំនួនប៉ាន់ប្រមាណកុមារអាយុ ពី ១២-៥៩ ខែ នៅក្នុងភូមិមួយ
ប/ស (ចំនួនប្រជាជនសរុបនៅក្នុងភូមិ) **x ៨,៧ / ១០០**
ប/ស (ចំនួនប្រជាជនសរុបនៅក្នុងភូមិ) **x ០,០៨៧ = ?**

៦ គណនាចំនួនប៉ាន់ប្រមាណស្រីក្រោយសម្រាល ៦ សប្តាហ៍ នៅក្នុងភូមិមួយ
ប/ស (ចំនួនប្រជាជនសរុបនៅក្នុងភូមិ) **x ២,៦ / ១០០**
ប/ស (ចំនួនប្រជាជនសរុបនៅក្នុងភូមិ) **x ០,០២៦ = ...** (ក្នុង ១ឆ្នាំ)

៧ កត់ត្រាលទ្ធផលទៅក្នុងប្រអប់នៃជ្រុងខាងលើផ្នែកខាងស្តាំ នៃក្រុមចំណុចសំរាប់ភូមិនិមួយៗ

៨ បូកចំនួនដូសប៉ាន់ប្រមាណទាំងអស់ចូលគ្នានៅផ្នែកខាងក្រោយនៃទំព័រម្ខាងទៀតនៃសន្លឹកកត់ត្រា

៩ ស្នើសុំស្តុកឱ្យបានគ្រប់គ្រាន់ពីស្រុកប្រតិបត្តិ សំរាប់ជុំចែកចាយលើកក្រោយ (ឬក្នុង ១ ខែម្តង)

## ការបូកសរុបស្តុកដែលបានបែងចែក បន្ទាប់ពីធ្វើការចែកចាយរួច

សូមធ្វើតាមជំហានដូចខាងក្រោម៖

១ បូកសរុបរាល់ដូសទាំងអស់ដែលបានធ្វើការចែកចាយ នៅក្នុងប្រអប់ធំមួយទៅតាមក្រុមគោលដៅ ទៅតាមភូមិនិមួយៗ

២ គណនាភាពខុសគ្នារវាងចំនួនដូសប៉ាន់ប្រមាណ និងចំនួនដូសដែលបានចែកចាយ បន្ទាប់ពីកុមារសមស្រប អាយុ ៦-៥៩ ខែ និងស្ត្រីទាំងអស់បានទទួលដូសចែកចាយ

៣ តើមានស្ត្រី និងកុមារសមស្របនៅសល់ដែរ ឬ ទេ? ហេតុអ្វី?

៤ តើអ្នកធ្វើយ៉ាងណា ដើម្បីចែកចាយដល់ស្ត្រី និងកុមារសមស្របទាំងនោះ?

## ៤.៤ សន្លឹកកត់ត្រា – ការងារក្រុម –(៤០ នាទី)

**គោលបំណង :** ចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចបំពេញសន្លឹកកត់ត្រា។

**វិធីសាស្ត្រ** : ការងារជាក្រុម

**អ្នកណា** : សិក្ខាកាមជាក្រុមដោយមានគ្នាយ៉ាងច្រើន ៥ នាក់

**សម្ភារៈ** : បញ្ជីទិន្នន័យ

**សៀវភៅសិក្ខាកាម :** ជំពូក ៩.៤

### សន្និទានភាព

ចំពោះលំហាត់នេះ ក្រុមនិមួយៗនឹងអនុវត្តការបំពេញសន្លឹកកត់ត្រាសំរាប់ការចែកចាយគ្រាប់ថ្នាំជីវជាតិអា។ ធ្វើការចែករំលែកនូវលទ្ធផលជាមួយក្រុមដែលនៅជិតខាងខ្លួន។ សិក្ខាកាមទាំងអស់ចាំបាច់ត្រូវធ្វើការ ពិភាក្សាគ្នាពីការសម្រេចចិត្តរបស់ពួកគាត់។

### ការណែនាំ

- សុំឱ្យសិក្ខាកាមបំពេញសន្លឹកកត់ត្រាដោយប្រើប្រាស់ករណីសិក្សានៃភូមិមួយឈ្មោះភូមិស្វាយធំ។ ភូមិស្វាយធំមាន ២០០ គ្រួសារ ហើយមានប្រជាជនប្រហែល ១,២០០ នាក់។ ដើម្បីរៀបចំជុំចែកចាយគ្រាប់ថ្នាំ ជីវជាតិអា គេត្រូវធ្វើការប៉ាន់ប្រមាណចំនួនកុមារអាយុពី ៦-១១ ខែ ដែលត្រូវការគ្រាប់ថ្នាំជីវជាតិអា រួចបញ្ចូលតួលេខនេះទៅក្នុងកន្លែងដ៏ត្រឹមត្រូវនៅលើសន្លឹកកត់ត្រា។ ធ្វើការប៉ាន់ប្រមាណចំនួនកុមារអាយុពី ១២-៥៩ ខែ ដែលនឹងត្រូវការគ្រាប់ថ្នាំជីវជាតិអា និងមេបង់ដាសុល រួចបញ្ចូលតួលេខនេះទៅក្នុងសន្លឹកកត់ត្រា។ ធ្វើការប៉ាន់ប្រមាណចុងក្រោយមួយទៀតគឺចំនួនស្ត្រីមានផ្ទៃពោះ ដែលមាននៅក្នុងភូមិនោះ។
- នៅក្នុងអំឡុងពេលសកម្មភាពចុះមូលដ្ឋាន គូសនៅលើសន្លឹកកត់ត្រា ចំនួនកុមារតាមក្រុមអាយុដែលបានទទួលគ្រាប់ថ្នាំជីវជាតិអា និងចំនួនស្ត្រីក្រោយសម្រាល (ក្នុង ៦ សប្តាហ៍ ដំបូងក្រោយការសម្រាល) ដែលបានទទួលគ្រាប់ថ្នាំជីវជាតិអា។

- ចំនួនកុមារអាយុពី ៦-១១ ខែ ដែលបានទទួលគ្រាប់ថ្នាំជីវជាតិអា គឺ ៩ នាក់
- ចំនួនកុមារអាយុពី ១២-៥៩ ខែ ដែលបានទទួលគ្រាប់ថ្នាំជីវជាតិអា និងមេបង់ដាសុល គឺ ៦០ នាក់
- ចំនួនស្ត្រីក្រោយសម្រាលដែលបានទទួលគ្រាប់ថ្នាំជីវជាតិអា គឺ ៣ នាក់
- សូមគិតជាភាគរយនៃកុមារដែលសមស្របនៅក្នុងភូមិស្វាយធំ ដែលបានទទួលគ្រាប់ថ្នាំជីវជាតិអា

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ពន្យល់ | ៥ |
| ការរៀបចំនៅក្នុងក្រុម | ២០ |
| ការចែករំលែកលទ្ធផលរវាងក្រុមជិតខាង | ៥ |
| យោបល់ត្រលប់របស់អ្នកសម្របសម្រួល | ១០ |
| **សរុប** | **៤០** |

## ៤.៥ ជំហានក្នុងការធ្វើផែនការអំពីការចែកចាយគ្រាប់ថ្នាំជីវជាតិអាប្រកបដោយប្រសិទ្ធភាព-លំហាត់ ឆ (១៥ នាទី)

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាចធ្វើផែនការសំរាប់ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអាប្រកបដោយប្រសិទ្ធភាព។

**វិធីសាស្ត្រ** : ការងារជាក្រុម

**នរណា** : ក្រុមដែលមានគ្នាចំនួន ៥ នាក់

**សម្ភារះ** : តារាងដូចដែលមានបង្ហាញជូននៅខាងក្រោម លំហាត់ ឆ នៅក្នុងសៀវភៅសិក្ខាកាម ស្លាយបង្ហាញទី ១១២

**សៀវភៅសិក្ខាកាម :** ឧបសម្ព័ន្ធលំហាត់ ឆ

### ការណែនាំ

- សុំឱ្យសិក្ខាកាមបង្កើតជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់។
- សូមប្រាប់ពួកគាត់ពិភាក្សាអំពីតារាងស្តីពីដំណើរការនៃការចែកចាយគ្រាប់ថ្នាំជីវជាតិអា ហើយត្រូវដាក់សកម្មភាពទាំងនេះឱ្យត្រឹមត្រូវទៅតាមលំដាប់លំដោយពីលេខ ១-១៣។
- សូមពន្យល់ប្រាប់ពួកគាត់ថា សកម្មភាពនេះនឹងជាមូលដ្ឋានសំរាប់ការងារជាក្រុមបន្ទាប់។
- ប្រើប្រាស់ស្លាយ ១១២ ដើម្បីធ្វើការពិភាក្សាពីលទ្ធផលជាមួយសិក្ខាកាម។

| | សកម្មភាព | លេខ / ជំហាន |
|---|---|---|
| ក | ពិនិត្យផ្ទៀងផ្ទាត់ស្តុកគ្រាប់ថ្នាំជីវជាតិអា ។ តើវាស្ថិតនៅក្នុងល័ក្ខខ័ណ្ឌល្អដែរ ឬទេ ថ្ងៃផុតកំណត់ការប្រើប្រាស់? ស្នើសុំស្តុកថ្នាំពីស្រុកប្រតិបត្តិបើសិនជាចាំបាច់ | ៣ |
| ខ | ធ្វើការប៉ាន់ស្មាននៅលើសន្លឹកកត់ត្រានូវចំនួនប្រជាជន សរុបនៅតាមភូមិនិមួយៗ និងចំនួនប្រជាជនក្រុមគោលដៅ គឺស្ត្រីក្រោយសម្រាល និងកុមារអាយុក្រោម ៥ ឆ្នាំ | ២ |
| គ | ពិនិត្យផ្ទៀងផ្ទាត់ស្តុកគ្រាប់ថ្នាំមេបង់ដាសុល ។ ធ្វើការប៉ាន់ស្មាន តើអ្នកត្រូវការគ្រាប់ថ្នាំប៉ុន្មានគ្រាប់ សំរាប់កុមារអាយុពី ១២-៥៩ ខែ ស្ត្រីមានផ្ទៃពោះដែលមានផ្ទៃពោះលើសពី ៣ ខែ និងស្ត្រីក្រោយសម្រាលដែលបានសម្រាលកូនរួចក្នុងអំឡុងពេល ៦ សប្តាហ៍មុន | ៤ |
| ឃ | ធ្វើផែនការប្រជុំជាមួយនឹងអ្នកស្ម័គ្រចិត្តភូមិ ដើម្បីពិភាក្សាពីការធ្វើផែនការសំរាប់ជុំនៃការចែកចាយគ្រាប់ថ្នាំជីវជាតិអា នៅតាមភូមិនិមួយៗ | ៦ |
| ង | ធ្វើវគ្គរំលឹកឡើងវិញសំរាប់អ្នកស្ម័គ្រចិត្តភូមិ ក្នុងអំឡុងពេលប្រជុំប្រចាំខែអំពីការចែកចាយគ្រាប់ថ្នាំជីវជាតិអា និងពិភាក្សាអំពីតួនាទីដែលពួកគាត់ត្រូវប្រកាន់យកក្នុងអំឡុងពេលជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | ៧ |
| ច | ពិនិត្យផ្ទៀងផ្ទាត់បញ្ជីចុះឈ្មោះ(ឈ្មោះម្តាយ និងកុមារ) របស់អ្នកស្ម័គ្រចិត្តភូមិ និងធ្វើការប៉ាន់ស្មានស្ត្រីក្រោយសម្រាល និងកុមារដែលសមស្របបានទទួលគ្រាប់ថ្នាំជីវជាតិអាចំនួនសម្រាល និងចំនួនស្ត្រីក្រោយសម្រាល និងកុមារដែលគេចាំបាច់ត្រូវបន្តតាមរកដើម្បីផ្តល់គ្រាប់ថ្នាំជីវជាតិអា (សំរាប់កម្មវិធីបង្គ្រប់) | ១០ |
| ឆ | ធ្វើការប៉ាន់ស្មានពីចំនួនកុមារដែលគេចាំបាច់ត្រូវបន្តតាមរកដើម្បីផ្តល់គ្រាប់ថ្នាំជីវជាតិអា ហើយប្រគល់គ្រាប់ថ្នាំជីវជាតិអា ព្រមទាំងសន្លឹកកត់ត្រាទៅឱ្យអ្នកស្ម័គ្រចិត្តភូមិ | ១១ |
| ជ | ពិនិត្យផ្ទៀងផ្ទាត់សន្លឹកកត់ត្រា ឱ្យបានសព្វគ្រប់នៅមុនពេល ចាកចេញពីភូមិ | ១២ |
| ឈ | បំពេញលទ្ធផលដែលបានពីជុំនៃការចែកចាយគ្រាប់ថ្នាំជីវជាតិអាទៅក្នុងទម្រង់របាយការណ៍របស់មណ្ឌលសុខភាព (HC1) ។ | ១៣ |
| ញ | ធ្វើការប៉ាន់ប្រមាណរកចំនួនគ្រាប់ថ្នាំជីវជាតិអាដែលអ្នកនឹងត្រូវការ ដោយធ្វើការគណនារកចំនួនកុមារ អាយុ ពី ៦-៥៩ ខែ និងរកចំនួនស្ត្រីដែលទើបសម្រាលកូននាពេលថ្មីៗនេះ ហើយដែលកំពុងរស់នៅក្នុងតំបន់គោលដៅរបស់អ្នក | ១ |
| ដ | រៀបចំធ្វើការប្រជុំជាមួយបុគ្គលិកមណ្ឌលសុខភាព និងជាមួយអ្នកស្ម័គ្រចិត្តភូមិទាំងអស់ ដើម្បីកំណត់កាលបរិច្ឆេទដែលអ្នកនឹងត្រូវចុះទៅតាមភូមិនិមួយៗ | ៨ |
| ឋ | ផ្តល់ដំណឹងដល់ប្រធានភូមិ និងសហគមន៍ទាំងអស់នៅតាមភូមិនិមួយៗ អំពីជុំនៃការចែកចាយគ្រាប់ថ្នាំជីវជាតិអា | ៩ |
| ឌ | ពិនិត្យផ្ទៀងផ្ទាត់មើលថាតើអ្នកមានសម្ភារៈអប់រំផ្សព្វផ្សាយ និងសន្លឹកកត់ត្រាគ្រប់គ្រាន់សំរាប់ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអាដែរឬ ទេ ។ សូមស្នើសុំបើសិនជាចាំបាច់ | ៥ |

## ៤.៦ ការធ្វើផែនការចែកចាយគ្រាប់ថ្នាំជីវជាតិអា - ការងារតាមក្រុម : (៦៥ នាទី) (រួមទាំងត្រូវសម្រាកចាប់ពីម៉ោង ១០:០០ - ១០:២០)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចធ្វើផែនការសកម្មភាពចែកចាយ គ្រាប់ថ្នាំជីវជាតិអា របស់ខ្លួន ដោយយោងទៅតាមផែនការសកម្មភាពចែកចាយគ្រាប់ថ្នាំជីវជាតិអា ដែលពួកគេបានបង្កើត ។

**វិធីសាស្ត្រ :** ការងារជាក្រុម

**ធរណា :** សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន៥នាក់

**សម្ភារៈ :** ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត សម្ភារៈជំនួយការងារ

### សន្និទានភាព

ក្នុងអំឡុងពេលធ្វើសកម្មភាពនេះ ក្រុមនិមួយៗនឹងបង្កើតផែនការការងារសំរាប់ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអាលើកក្រោយ ។ សិក្ខាកាមនឹងរៀនពីរបៀបធ្វើផែនការសំរាប់ការងាររបស់ពួកគាត់ និងពីរបៀបធ្វើសកម្មភាព ដែលចាំបាច់សំរាប់ការចែកចាយគ្រាប់ថ្នាំជីវជាតិអា ។ ពួកគេក៏ត្រូវគិតផងដែរអំពីសារដែលត្រូវផ្តល់ និងពីវិធីផ្តល់ការអប់រំដល់ក្រុមប្រជាជន ។

### ការណែនាំ:

- រៀបចំបង្កើតជាក្រុម ដែលមានគ្នាយ៉ាងច្រើន ៥ នាក់
- ណែនាំនៅក្នុងក្រុមធំ អំពីសកម្មភាពនេះ
- ពន្យល់ទៅសិក្ខាកាមថា ក្រុមនិមួយៗត្រូវទទួលខុសត្រូវក្នុងការរៀបចំសំរាប់ការចែកចាយគ្រាប់ថ្នាំជីវជាតិអាជុំក្រោយនៅក្នុងតំបន់គ្របដណ្តប់នៃមណ្ឌលសុខភាពរបស់ខ្លួន
- សុំឱ្យពួកគាត់ធ្វើការជ្រើសរើសមណ្ឌលសុខភាពសំរាប់ក្រុមមួយ ហើយត្រូវគិតអំពីបញ្ហាដូចខាងក្រោមនេះ :

  **១** តើអ្នកត្រូវការគ្រាប់ថ្នាំជីវជាតិអាប៉ុន្មានគ្រាប់?

  **២** តើនៅថ្ងៃណាអ្នកនឹងចុះទៅភូមិនិមួយៗនៅក្នុងតំបន់គ្របដណ្តប់របស់អ្នក?

  **៣** តើអ្វីខ្លះដែលអ្នកត្រូវធ្វើមុនពេលអ្នកចុះទៅភូមិ/តើពេលណាអ្នកទៅដល់ទីនោះ/តើពេលណាអ្នកត្រលប់មកវិញ?

  **៤** តើអ្នកណាត្រូវធ្វើអ្វី? (តើម្នាក់ៗត្រូវធ្វើអ្វី)

  **៥** តើសម្ភារៈអប់រំអ្វីខ្លះដែលអ្នកគួររៀបចំ?

  **៦** តើអ្នកនឹងធ្វើការងារទាំងនោះយ៉ាងដូចម្តេច :

    **ក** ការប៉ាន់ស្មានពីអាយុរបស់កុមារ

    **ខ** ការចែកចាយគ្រាប់ថ្នាំដល់ម្តាយ/កុមារ

    **គ** ការអប់រំសុខភាពស្តីពីជីវជាតិអា

- ពន្យល់ទៅកាន់សិក្ខាកាមថា ពួកគាត់អាចធ្វើការសម្រេចចិត្ត ថាតើក្រុមគាត់នឹងធ្វើការបង្ហាញពីផែនការការងារដល់ក្រុមធំយ៉ាងដូចម្តេច?
- តើអ្នកណានឹងធ្វើការបង្ហាញនេះ? តើសិក្ខាកាមធ្វើយ៉ាងដូចម្តេចដើម្បីប្រាកដថា ពួកគាត់នឹងមិនប្រើពេលលើសពី ៥ នាទី ដែលបានកំរិតសំរាប់ការបង្ហាញ?
- ក្រុមការងារមានពេល ៣៥ នាទី ដើម្បីរៀបចំ
- ក្រុមនិមួយៗនឹងមានពេល ៥ នាទី ដើម្បីធ្វើការបង្ហាញ

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ពន្យល់ | ៥ |
| ការរៀបចំនៅក្នុងក្រុម | ៣៥ |
| ការឡើងធ្វើការបង្ហាញ | ២៥ |
| **សរុប** | **៦៥** |

## ៤.៧ សេចក្តីសន្និដ្ឋានសំរាប់ពេលព្រឹក (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តចំពោះចំណេះដឹង និងជំនាញដែលបានរៀននៅក្នុងអំឡុងពេលព្រឹកមិញ។

**វិធីសាស្ត្រ** : សង្ខេប

**នរណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងបញ្ជាក់ពីពេលវេលា

**ការណែនាំៈ**

**ធ្វើការសង្ខេប ដោយរលឹកឡើងវិញនូវអ្វីដែលបានសិក្សាកាលពីព្រឹកៈ**

- បំពេញសន្លឹកកត់ត្រាគ្រាប់ថ្នាំជីវជាតិអា
- ជំហានក្នុងការរៀបចំសំរាប់ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា
- របៀបបង្កើតផែនការសកម្មភាពចែកចាយគ្រាប់ថ្នាំជីវជាតិអា

បង្ហាញសិក្ខាកាមនូវ ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងម៉ោងដែលត្រូវត្រលប់មកវិញ ។

**សម្រាក (១២០ នាទី)**

## ៤.៨ លេខមិនកុហកទេ (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីពេលរសៀល ។

**វិធីសាស្ត្រ :** ល្បែងថាមពល

**នរណា :** សិក្ខាកាម និងអ្នកសម្របសម្រួល ជាក្រុមដែលមានគ្នាយ៉ាងច្រើន ១០ នាក់

**សម្ភារៈ :**

**ការណែនាំ:**

- ស្នើឱ្យសិក្ខាកាមឈរជាពាក់កណ្តាលរង្វង់ ។
- រាប់លេខពីដើមជួររហូតដល់ចុងដើម្បីឱ្យប្រាកដថា សិក្ខាកាមម្នាក់ៗមានលេខប្រចាំខ្លួនមួយ ។ អ្នកទី ១ ហៅលេខរបស់ម្នាក់ទៀត ។ ភ្លាមៗនោះ អ្នកនោះស្រែកហៅលេខរបស់នរណាម្នាក់ផ្សេងទៀត ។ ការហៅនេះត្រូវធ្វើឱ្យលឿន ។
- នៅពេលដែលនរណាម្នាក់ហៅលេខដែលមិនមាន ឬក៏ហៅលេខរបស់ខ្លួនឯងផ្ទាល់ គាត់ត្រូវដើរទៅខាងចុងជួរខាងស្តាំបង្អស់ ។ **ប៉ុន្តែ នៅពេលនោះ លេខត្រូវប្តូរ!**
- គ្រប់ពេលដែលនរណាម្នាក់ធ្វើខុស មុនពេលដើរទៅកាន់ខាងចុងជួរ គាត់ត្រូវស្រែកថា: "**បាទ/ចាស៎!**" ហើយអ្នកផ្សេងទៀតត្រូវនាំគ្នាទះដៃ ។
- ត្រូវបញ្ចប់ល្បែងនេះ ក្រោយពីលេងបានរយៈពេល ១០ នាទី ហើយត្រូវពន្យល់ថា វាជារឿងធម្មតាទេ ដែលធ្វើខុស និងត្រូវពន្យល់ថា យើងអាចរៀនពីកំហុសទាំងអស់នេះ ។ ក៏ប៉ុន្តែជានិច្ចកាល យើងត្រូវតែផ្តោតអារម្មណ៍ និងត្រូវយកចិត្តទុកដាក់ ។

## ៤.៩ សារៈសំខាន់នៃជាតិដែក (៦០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងយល់ដឹងអំពីសារៈសំខាន់ សារគន្លឹះ និងសកម្មភាពនៃជាតិដែក ។

**វិធីសាស្ត្រ :** បាឋកថា

**នរណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយសំរាប់បង្ហាញ ទី ១១៣-១៣០

**សៀវភៅសិក្ខាកាម :** ជំពូក ៥.១-៥.៦

**ការណែនាំ**

ប្រើប្រាស់ស្លាយ ១១៣-១៣០ ដើម្បីពន្យល់សិក្ខាកាមអំពី ភាពស្លេកស្លាំង និងសារៈសំខាន់នៃជាតិដែក

# ៤.១០ អាហារសំបូរជាតិដែក – លំហាត់ ៨ (១៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចកំណត់បាននូវអាហារសំបូរជាតិដែក និងជំរុញការប្រើប្រាស់អាហារទាំងនេះដល់ស្ត្រី។

**វិធីសាស្ត្រ** : លំហាត់ម្នាក់ៗ

**នរណា** : សិក្ខាកាមម្នាក់ៗ

**សម្ភារៈ** : លំហាត់ ៨ នៅក្នុងឧបសម្ព័ន្ធសៀវភៅសិក្ខាកាម ស្លាយទី ១៣១

**ការណែនាំ:**

- សុំឱ្យសិក្ខាកាមម្នាក់ៗធ្វើលំហាត់នេះតែឯង
- សុំឱ្យសិក្ខាកាមមើលរូបភាពអាហារខាងក្រោម ហើយគូសរង្វង់ជុំវិញអាហារ ៤ ប្រភេទ ដែលសំបូរជាតិដែក
- ពេលធ្វើចប់ ប្រាប់ពួកគាត់ឱ្យពិនិត្យមើលលទ្ធផលជាមួយនឹងអ្នកជិតខាងរបស់ខ្លួន ហើយឱ្យពួកគាត់គិតឡើងវិញពីជម្រើសរបស់ពួកគាត់។ រយៈពេល ១០ នាទី បន្ទាប់មក ផ្តល់ចម្លើយ និងការពន្យល់សិក្ខាកាម ដោយប្រើប្រាស់ស្លាយ ទី ១៣១



## ៥.១១ ការការពារ និងការព្យាបាលកង្វះជាតិដែក (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងយល់ច្បាស់ពីការការពារ និងការព្យាបាលនៃបញ្ហាកង្វះជាតិដែក ។

**វិធីសាស្ត្រ :** បាឋកថា

**នរណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយសំរាប់បង្ហាញ ទី ១៣២-១៣៤

**សម្ភារៈ :** ជំពូក ៥.១០

### ការណែនាំ:

ប្រើប្រាស់ស្លាយ ទី ១៣២-១៣៤ ដើម្បីធ្វើបាឋកថា ស្ដីពីការការពារ និងការព្យាបាលកង្វះជាតិដែក ។

សម្រាក (២០ នាទី)

## ៥.១២ តើសារគន្លឹះសំខាន់ៗស្ដីពីជាតិដែកមានអ្វីខ្លះ? ការងារជាក្រុម (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចប្រើប្រាស់សារគន្លឹះសំខាន់ៗសំរាប់ជាតិដែក ។

**វិធីសាស្ត្រ :** ការងារជាក្រុម

**នរណា :** សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់

**សម្ភារៈ :** ក្រដាសផ្ទាំងធំ និងប៊ិចហ្វឺត
ស្លាយសំរាប់បង្ហាញ ទី ១៣៥-១៣៦

**សៀវភៅសិក្ខាកាម :** ជំពូក ៥.១០-៥.១១

### ការណែនាំ

- ប្រាប់សិក្ខាកាមទាំងអស់ឱ្យធ្វើការជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់
- សុំឱ្យពួកគាត់កំណត់សារគន្លឹះពីកម្មវិធីជាតិដែក ដោយផ្អែកលើបាឋកថាមុននេះ
- សុំឱ្យពួកគាត់សរសេរសារទាំងអស់នេះនៅលើក្រដាសផ្ទាំងធំ ហើយបិទផ្ទាំងក្រដាសនេះនៅលើជញ្ជាំង
- បន្ទាប់មក សុំឱ្យសិក្ខាមទាំងអស់ពិនិត្យមើលក្រដាសផ្ទាំងធំទាំងនោះ រួចឱ្យពួកគាត់ទៅកាន់កន្លែងអង្គុយវិញ ហើយផ្ដល់សារគន្លឹះនៃកម្មវិធីជាតិដែក ប្រើប្រាស់ស្លាយ ១៣៥ និង ១៣៦

## ៤.១៣ សំនួរ និងចម្លើយ (២៥ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរំលឹកឡើងវិញ និងស្រាយបំភ្លឺគំនិតនៃកម្មវិធីជីវជាតិអា និងជាតិដែក ។

**វិធីសាស្ត្រ** : សំណួរ-ចម្លើយ

**នរណា** : ក្រុមដែលមានអ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងតូចៗ ប៊ិច ប្រអប់ដែលមានរន្ធមួយ

### ការណែនាំ:

- ប្រាប់សិក្ខាកាមឱ្យគិតរកឱ្យបានសំណួរមួយ អំពីមេរៀនសិក្សាល្ងាចនេះ ដែលពួកគាត់ចង់សួរ ។
- ប្រាប់ឱ្យពួកគាត់សរសេរសំនួរទាំងនោះនៅលើកូនក្រដាសតូច រួចបត់វាជា២ ហើយដាក់វាទៅក្នុងប្រអប់ដែលនៅកណ្តាលបន្ទប់ ។
- ក្រោយពីបាន ៥ នាទី អ្នកសម្របសម្រួលចាប់ផ្តើមទាញសំនួរមួយម្តងៗចេញពីប្រអប់ រួចឆ្លើយទៅនឹងសំណួរទាំងនោះ ។
- វាមិនអាចឆ្លើយឱ្យបានគ្រប់សំនួរទាំងអស់ក្នុងរយៈពេល ១៥ នាទីទេ ។ គ្រាន់តែឆ្លើយទៅនឹងសំនួរមួយចំនួនរហូតទាល់តែដល់ម៉ោង ហើយសន្យាថានឹងឆ្លើយសំនួរផ្សេងៗទៀតដែលនៅសល់នៅថ្ងៃស្អែក ។ ចូរអ្នករៀបចំមេរៀនសំរាប់ថ្ងៃស្អែក ដោយរៀបចំសំណួរទៅតាមប្រភេទសំណួរទុកជាមុន ហើយរៀបចំបាឋកថា ដែលឆ្លើយទៅនឹងសំនួរផ្សេងៗទៀត ។

## ៤.១៤ សេចក្ដីសន្និដ្ឋាន សំរាប់ថ្ងៃរសៀល (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តលើចំណេះដឹង និងជំនាញដែលទើបបានសិក្សា។

**វិធីសាស្ត្រ** : សង្ខេប

**នរណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដោយមានរូបនាឡិកា និងបង្ហាញម៉ោងពេល

### ការណែនាំ:

ធ្វើការសង្ខេបសកម្មភាពនាពេលរសៀលនេះ ដោយរំលឹកឡើងវិញនូវអ្វីដែលបានសិក្សា :

- សារៈសំខាន់នៃជាតិដែក
- អាហារសំបូរជាតិដែក
- ការការពារ និងការព្យាបាលបញ្ហាកង្វះជាតិដែក
- សារគន្លឹះស្ដីពីជាតិដែក

ចូរដាក់ពាក្យថា : "ល្អណាស់" "ល្អ" "ធម្មតា" និង "មិនល្អមិនអាក្រក់" នៅលើក្រដាសអា ៤ ហើយបិទវានៅលើជញ្ជាំងជ្រុងផ្សេងៗគ្នានៃបន្ទប់។ ចូរស្នើឱ្យសិក្ខាកាមទាំងអស់ទៅឈរនៅពីក្រោមពាក្យណាដែលពួកគេគិតថា វាឆ្លុះបញ្ចាំងខ្លាំងជាងគេបំផុតទៅនឹងការសិក្សាថ្ងៃនេះ។

បង្ហាញដល់សិក្ខាកាមនូវក្រដាសផ្ទាំងធំដែលមាននូវរូបនាឡិកា និងពេល/ម៉ោងដែលនឹងត្រូវត្រលប់មកវិញ។

# ថ្ងៃទី ៥៖ ជាតិដែក/អំបិលអ៊ីយ៉ូដ

## គោលបំណងថ្ងៃទី ៥៖

១ ដើម្បីឆ្លើយសំនួរស្ដីពីកម្មវិធីជាតិដែក
២ ដើម្បីរំលឹកឡើងវិញអំពីមេរៀនដែលបានរៀនពីកម្មវិធីជាតិដែក
៣ ដើម្បីបណ្ដុះបណ្ដាលអំពីជំនាញក្នុងការផ្ដល់ប្រឹក្សា សំរាប់សកម្មភាពកម្មវិធីជាតិដែក
៤ ដើម្បីផ្ដល់នូវចំណេះដឹងស្ដីអំពីកម្មវិធីអំបិលអ៊ីយ៉ូដ
៥ ដើម្បីបណ្ដុះបណ្ដាលអំពីរបៀបធ្វើតេស្ដអំបិលអ៊ីយ៉ូដដល់សិក្ខាកាម

## គោលបំណងជំនាញសំរាប់សិក្ខាកាមនៅថ្ងៃទី ៥៖

**នៅចុងបញ្ចប់នៃការសិក្សាថ្ងៃនេះ សិក្ខាកាមអាច ៖**

១ មានទំនុកចិត្តក្នុងការផ្ដល់សារជាតិដែក ដល់ស្ត្រី និងអ្នកថែទាំកុមារ
២ បំពេញទម្រង់សន្លឹកកត់ត្រា សំរាប់ការចែកចាយគ្រាប់ថ្នាំជាតិដែក
៣ ផ្ដល់សកម្មភាពអប់រំសុខភាពជាក្រុម ប្រកបដោយប្រសិទ្ធភាព

# កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨:០០ | ១០ | ៥.១ | បន្ធូរបោះទង<br>ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន និងការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ៨:១០ | ១០ | ៥.២ | គោលបំណងថ្ងៃទី ៥<br>បាឋកថា - បង្ហាញគោលបំណងប្រចាំថ្ងៃ | អ្នកសម្របសម្រួល |
| ៨:២០ | ៣០ | ៥.៣ | ការឆ្លើយទៅនឹងសំនួរស្តីពីជីវជាតិអា និងជាតិដែក<br>ឆ្លើយនឹងសំនួរដែលមិនទាន់បានឆ្លើយកាលពីម្សិលមិញ | អ្នកសម្របសម្រួល |
| ៨:៥០ | ៧០ | ៥.៤ | រឿងស្តីពីជាតិដែក<br>លំហាត់សំរាប់បុគ្គលម្នាក់ៗ និងជាគូ ដើម្បីឱ្យយល់ច្បាស់ពីសារផ្សេងៗ | បុគ្គលិកម្នាក់ៗ<br>និងជាគូ |
| ១០:០០ | ២០ | | សម្រាក | |
| ១០:២០ | ៦០ | ៥.៥ | ម៉ោងជាតិដែក<br>ការងារជាក្រុមស្តីពីការផ្តល់ប្រឹក្សាជាតិដែក | ក្រុម |
| ១១:២០ | ១០ | ៥.៦ | សេចក្តីសន្និដ្ឋានសំរាប់ពេលព្រឹក<br>សង្ខេប | អ្នកសម្របសម្រួល |
| ១១:៣០ | ១២០ | | សម្រាក | |
| ១៣:៣០ | ១០ | ៥.៧ | បង្កើតជាជួរ<br>ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន និងការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ១៣:៤០ | ៤៥ | ៥.៨ | សារៈសំខាន់នៃជាតិអ៊ីយ៉ូដ<br>បាឋកថាស្តីពីជាតិអ៊ីយ៉ូដ | អ្នកសម្របសម្រួល |
| ១៤:២៥ | ១៥ | ៥.៩ | លំហាត់: អាហារសំបូរជាតិអ៊ីយ៉ូដ<br>ការកំណត់អាហារសំបូរជាតិអ៊ីយ៉ូដ | បុគ្គលម្នាក់ៗ |
| ១៤:៤០ | ៣០ | ៥.១០ | តើយើងអាចធ្វើការណែនាំពីអំបិលអ៊ីយ៉ូដតាមវិធីណា<br>ការងារជាក្រុមស្តីពីការណែនាំអំបិលអ៊ីយ៉ូដនៅក្នុងសហគមន៍ | ក្រុម |
| ១៥:១០ | ២០ | | សម្រាក | |
| ១៥:៣០ | ២០ | ៥.១១ | តើត្រូវបង្ហាញបែបណាឱ្យមានប្រសិទ្ធភាព?<br>បាឋកថាគំរូ ស្តីពីការបង្ហាញដែលមានប្រសិទ្ធភាព | អ្នកសម្របសម្រួល |
| ១៥:៥០ | ២០ | ៥.១២ | ការឡើងបង្ហាញ "ជំហាននៃការណែនាំឱ្យសហគមន៍ស្គាល់ពីអំបិលអ៊ីយ៉ូដ"<br>ការបង្ហាញតាមក្រុម | ក្រុមមុន |

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ១៦:១០ | ១០ | ៥.១៣ | ការធ្វើតេស្តអំបិលអ៊ីយ៉ូដ<br>បាវកថា និងការធ្វើជាគំរូពីរបៀបធ្វើតេស្តអំបិល | អ្នកសម្របសម្រួល |
| ១៦:២០ | ៣០ | ៥.១៤ | ការធ្វើតេស្តអំបិល<br>ការងារជាក្រុម : ការធ្វើតេស្តអំបិល | ក្រុម |
| ១៦:៥០ | ១០ | ៥.១៥ | សេចក្តីសន្និដ្ឋានសំរាប់ថ្ងៃរសៀល<br>សង្ខេប | អ្នកសម្របសម្រួល |
| ១៧:០០ | | | ចប់ថ្ងៃទី ៥ | |

## សម្ភារៈដែលត្រូវការ

- ស្លាយសំរាប់បង្ហាញ ១៣៧-១៦០
- ក្រដាសផ្ទាំងធំដែលបានរៀបចំរួចជាស្រេច
- សម្ភារៈជំនួយការងារ
- ក្រដាសផ្ទាំងធំ
- ប៊ិចហ្វឺត
- កញ្ចប់អំបិលប្រភេទផ្សេងៗគ្នា
- កូនដបតេស្តសំរាប់ធ្វើតេស្តអំបិល
- ស្លាបព្រា

# សកម្មភាពថ្ងៃទី ៥

## ៥.១ បន្លែ (បោះទង) (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្ដើមកម្មវិធីពេលព្រឹកនេះ។

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាមទាំងអស់ដែលសម្របសម្រួលដោយអ្នកសម្របសម្រួលម្នាក់

**សម្ភារៈ** :

### ការណែនាំ:

- អញ្ជើញសិក្ខាកាមទាំងអស់ឱ្យឈរជារង្វង់។
- បន្ទាប់មកត្រូវចាប់ផ្ដើមដោយអោនបន្តិចទៅរកនរណាម្នាក់ដោយហុចដៃម្ខាងទៅរក ព្រមទាំងនិយាយថា: "*សួរស្ដី, អ្នក!*" អ្នកនោះត្រូវដាក់ដៃមួយនៅលើក្បាលរបស់ខ្លួន ដើម្បីបង្ហាញថាគាត់ត្រូវបានជាប់ទងហើយ។ ជាមួយនឹងដៃម្ខាងទៀត គាត់ឱនទៅរកជនម្នាក់ទៀត ដោយនិយាយថា "*សួរស្ដី, អ្នក!*"។ រក្សាដៃបោះទៅរកជនដែលអ្នកនិយាយ ***សួរស្ដីទៅរក***។ ធ្វើដូចនេះរហូតទាល់តែគ្រប់ៗគ្នាបានដាក់ដៃលើក្បាលរបស់គាត់រៀងៗខ្លួន។
- ធ្វើការកត់ចំណាំថា តើអ្នកណាដែលអ្នកបាននិយាយពាក្យ***សួរស្ដីទៅរក*** និងអ្នកដែលបាននិយាយ ***សួរស្ដីមកកាន់អ្នក***។
- សុំឱ្យសិក្ខាកាមដាក់ដៃចុះ។ ចាប់ផ្ដើមសាជាថ្មីម្ដងទៀត ដោយនិយាយពាក្យ "*សួរស្ដី, អ្នក!*" ទៅកាន់បុគ្គលណាម្នាក់ដែលអ្នកបាននិយាយទៅកាន់កាលពីលើកទីមួយ។ សុំឱ្យពួកគាត់បង្កើនល្បឿននៅក្នុងការលេង ពីរលើកទៀតនេះ។
- ចាប់ផ្ដើមជុំថ្មី ដោយនិយាយពាក្យ "*សួរស្ដី* (***និងបន្ទាប់មកនិយាយឈ្មោះបន្លែណាមួយ***)"។ សិក្ខាកាមមិនអាចចង្អុលទៅកាន់អ្នកដែលគាត់បានចង្អុលកាលពីលើកទីមួយទេ។
- លេងល្បែងបន្លែបោះទង ៣ ដង។
- សួរសិក្ខាកាម ថាតើពួកគេនៅតែចងចាំជុំលើកទី ១ ដែរ ឬទេ។ សុំឱ្យពួកគាត់លេងជុំទីមួយម្ដងទៀត។
- បញ្ឈប់ការលេងល្បែងថាមពលនេះ ក្រោយពីលេងបានរយៈពេល ១០ នាទីមក ហើយអញ្ជើញពួកគាត់ឱ្យចូលទៅកាន់កន្លែងអង្គុយរៀងៗខ្លួន។

## ៥.២ គោលបំណងថ្ងៃទី ៥ (១០ នាទី)

**គោលបំណង :** ដើម្បីពន្យល់ពីគោលបំណងដល់សិក្ខាកាម ។

**វិធីសាស្ត្រ :** បាឋកថា

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយសំរាប់បង្ហាញ ទី ១៣៧-១៣៨

ប្រើប្រាស់ស្លាយ ១៣៧ និង ១៣៨ ដើម្បីពន្យល់អំពីគោលបំណងសំរាប់មេរៀនសិក្សាថ្ងៃនេះ ។

## ៥.៣ ឆ្លើយទៅនឹងសំនួរស្តីពីជាតិដែក (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមយល់យ៉ាងច្បាស់ពីកម្មវិធីជាតិដែក ។

**វិធីសាស្ត្រ :** សំណួរ និង ចម្លើយ

**នរណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ក្រដាសផ្ទាំងធំដែលបានរៀបចំរួចជាស្រេច

### ការណែនាំ

- រៀបចំមេរៀននេះ ដោយរៀបសំណួរជាក្រុមតាមប្រភេទ និងឆ្លើយទៅនឹងសំណួរកាលពីថ្ងៃម្សិលមិញដែលអ្នកមិនទាន់បានឆ្លើយ ។
- ដាក់សំនួរនិមួយៗ នៅលើក្រដាសផ្ទាំងធំដោយសរសេរពណ៌ខ្មៅ ។
- ដាក់ចម្លើយនៅពីខាងក្រោមសំនួរនិមួយៗ ដោយសរសេរពណ៌ខៀវ ។
- កំណត់សម្គាល់នៅលើ ពាក្យ ឬ ឃ្លាណាដែលសំខាន់ៗ ដោយប្រើពណ៌បៃតង ឬពណ៌ក្រហម ។
- បើសិនជាចាំបាច់ សូមប្រើប្រាស់សម្ភារៈជំនួយការងារ ។

ធ្វើការបង្ហាញមុនគេនូវសំនួរណាដែលគេសួរច្រើនជាងគេបង្អស់ ។

## ៥.៤ ករណីសិក្សារឿងស្តីពីជាតិដែក – លំហាត់ ឈ (៧០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចប្រើប្រាស់សារស្តីពីជាតិដែក និងតារាងការការពារព្រមទាំងការព្យាបាល ។

**វិធីសាស្ត្រ :** ជាលក្ខណៈបុគ្គល និងជាគូ

**នរណា :** សិក្ខាកាមម្នាក់ៗ និងជាគូ

**សម្ភារៈ** : លំហាត់ ឈ នៅក្នុងឧបសម្ព័ន្ធសៀវភៅសិក្ខាកាម
សម្ភារៈជំនួយការងារ
ស្លាយទី ១៣៩-១៤១

## ការណែនាំ:

- ប្រាប់ឱ្យសិក្ខាកាមធ្វើផ្នែកទីមួយនៃការងារដោយខ្លួនឯង ដោយមិនធ្វើការពិភាក្សាជាមួយសិក្ខាកាមដទៃទៀតឡើយ ។
- ស្នើឱ្យពួកគាត់បំពេញតារាងនៃលំហាត់ ឈ (ដូចដែលបង្ហាញជូននៅខាងក្រោម) ឱ្យបានល្អ តាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយប្រើជំពូកស្ដីពីជាតិដែក និងសម្ភារៈជំនួយការងារដែលបានផ្ដល់ឱ្យ ។
- ពួកគាត់មានពេល ១០ នាទី សំរាប់ករណីសិក្សានិមួយៗ (ជាសរុប គឺ ៣០ នាទី) ។ ក្រោយពីបានបញ្ចប់ ករណីសិក្សាទាំង ៣ ហើយ សិក្ខាកាមអាចចែករំលែកលទ្ធផលរបស់ខ្លួនជាគូៗ (២០ នាទី) ។
- រយៈពេល ២០ នាទីចុងក្រោយនៃការធ្វើលំហាត់ គឺសំរាប់អ្នកសម្របសម្រួល ផ្ដល់មតិត្រលប់ដល់សិក្ខាកាម ដោយប្រើប្រាស់ស្លាយ ១៣៩-១៤១ ។

|  | | **សុគន្ធ**<br>សុគន្ធ គឺជាស្ត្រីមានផ្ទៃពោះម្នាក់ដែលមកកាន់មណ្ឌលសុខភាព ដើម្បីធ្វើការពិនិត្យផ្ទៃពោះជាលើកទី ១ របស់គាត់ ។ | | |
|---|---|---|---|---|
| | តើសំណួរអ្វីខ្លះដែលអ្នកត្រូវសួរ? | តើត្រូវផ្ដល់អ្វី? | តើត្រូវផ្ដល់សារអ្វីខ្លះ? | តើត្រូវកត់ត្រានៅកន្លែងណា? |

|  | | **បុប្ផា**<br>បុប្ផាជាកុមារីម្នាក់អាយុ ១០ ខែ ដែលមានបាតដៃស្លេកស្លាំង (palmar pallor) | | |
|---|---|---|---|---|
| | តើសំណួរអ្វីខ្លះដែលអ្នកត្រូវសួរ? | តើត្រូវផ្ដល់អ្វី? | តើត្រូវផ្ដល់សារអ្វីខ្លះ? | តើត្រូវកត់ត្រានៅកន្លែងណា? |

|  | | **សុធាវី**<br>សុធាវី ជាស្ត្រីក្រោយសម្រាលម្នាក់អាយុ ៣២ ឆ្នាំ ដែលមានបាតដៃស្លេកស្លាំងយ៉ាងខ្លាំង ។ | | |
|---|---|---|---|---|
| | តើសំណួរអ្វីខ្លះដែលអ្នកត្រូវសួរ? | តើត្រូវផ្ដល់អ្វី? | តើត្រូវផ្ដល់សារអ្វីខ្លះ? | តើត្រូវកត់ត្រានៅកន្លែងណា? |

**សម្រាក (២០ នាទី)**

## ៥.៥ ការងារក្រុម៖ សន្លឹកកត់ត្រាការចែកចាយគ្រាប់ថ្នាំជាតិដែក (៤០ នាទី)

**គោលបំណង៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចបំពេញសន្លឹកកត់ត្រាការសំរាប់ចែកចាយគ្រាប់ថ្នាំជាតិដែក។

**វិធីសាស្ត្រ** ៖ ការងារជាក្រុម

**អ្នកណា** ៖ សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់

**សម្ភារៈ** ៖ បញ្ជីទិន្នន័យ

### សន្និទានភាព

សំរាប់លំហាត់នេះ ក្រុមនិមួយៗ នឹងធ្វើការអនុវត្តន៍បំពេញសន្លឹកកត់ត្រា សំរាប់ការចែកចាយគ្រាប់ថ្នាំជាតិដែក។ ចែករំលែកលទ្ធផលជាមួយនឹងក្រុមដែលនៅជិតខាង ហើយសិក្ខាកាមចាំបាច់ត្រូវធ្វើការពិភាក្សាពីជម្រើសដែលខ្លួនបានជ្រើសយក។

### ការណែនាំ៖

- សិក្ខាកាមទាំងអស់ត្រូវធ្វើការជាក្រុមដែលមានគ្នា ៥ នាក់ ដើម្បីបំពេញសន្លឹកបញ្ជីសំរាប់ការចែកចាយ ជាតិដែក/អាស៊ីតហ្វូលិក ដោយប្រើប្រាស់ករណីសិក្សារឿងខាងក្រោម។
- ភូមិស្វាយធំ មាន ២០០ គ្រួសារ និងមានប្រជាជនប្រមាណ ១,២០០ នាក់។ ចូរធ្វើការប៉ាន់ប្រមាណ ថាតើស្ត្រីមានផ្ទៃពោះនៅក្នុងភូមិនោះមានប៉ុន្មាននាក់?
- ក្នុងអំឡុងពេលសកម្មភាពចុះមូលដ្ឋាន ស្ត្រីមានផ្ទៃពោះ ៩ នាក់ បានចូលរួម និងទទួលជាតិដែក និងអាស៊ីដហ្វូលិក។ គូសចំនួនស្ត្រីនៅលើសន្លឹកកត់ត្រា និងធ្វើការប៉ាន់ប្រមាណភាគរយនៃស្ត្រីក្នុងភូមិដែលបានទទួលជាតិដែក និងអាស៊ីតហ្វូលិក។

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ការពន្យល់ | ៥ |
| ការរៀបចំក្នុងក្រុម | ២០ |
| ការចែករំលែករវាងក្រុមអ្នកជិតខាង | ៥ |
| ការផ្តល់មតិត្រលប់ដោយអ្នកសម្របសម្រួល | ១០ |
| **សរុប** | **៤០** |

## ៥.៦ សេចក្តីសន្និដ្ឋានសំរាប់ពេលព្រឹក (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តលើចំណេះដឹង និងជំនាញដែលបានសិក្សាកាលពីព្រឹក ។

**វិធីសាស្ត្រ** : សង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងបង្ហាញពីពេលវេលា

### ការណែនាំ:

ធ្វើការសង្ខេបពីមេរៀនសិក្សានាពេលព្រឹក ដោយរំលឹកឡើងវិញនូវអ្វីដែលបានសិក្សា :

- សារស្តីពីជាតិដែក និងសកម្មភាព

បង្ហាញក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងពេលម៉ោងដែលសិក្ខាកាមត្រូវត្រលប់មកវិញ ។

**សម្រាក: (រយៈពេល ១២០ នាទី)**

## ៥.៧ បង្កើតជាជួរ (រយៈពេល ១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីសំរាប់ថ្ងៃរសៀល

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាម

**សម្ភារៈ** :

### ការណែនាំ:

- ស្នើឱ្យសិក្ខាកាមបង្កើតជាជួរមួយ: អ្នកណាដែលរស់នៅតំបន់ឆ្ងាយ និងអ្នកណាដែលរស់នៅតំបន់ជិត?
- បង្ហាញផ្នែកនៃជួរដែលឆ្ងាយជាងគេបំផុត និងផ្នែកដែលជិតជាងគេបំផុត ។
- ស្នើសិក្ខាកាមឱ្យឈរនៅក្នុងជួរណាមួយពីចំណុចឆ្ងាយបំផុតមកចំណុចជិតបំផុត ។

## ៥.៨ សារៈសំខាន់នៃជាតិអ៊ីយ៉ូដ (៤៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចយល់ដឹងអំពីសារៈសំខាន់នៃជាតិអ៊ីយ៉ូដ កម្មវិធីអ៊ីយ៉ូដ សារគន្លឹះ និងសកម្មភាពជាតិអ៊ីយ៉ូដ ។

**វិធីសាស្ត្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** ៖ ស្លាយសំរាប់បង្ហាញ ១៤២-១៥៣

**សៀវភៅសិក្ខាកាម** ៖ ជំពូក ៦.១-៦.៧

**ការណែនាំ៖**

ប្រើប្រាស់ស្លាយ ១៤២-១៥៣ ដើម្បីធ្វើបាឋកថាស្តីពីសារៈសំខាន់នៃជាតិអ៊ីយ៉ូដ។

## ៥.៩ អាហារដែលសំបូរជាតិអ៊ីយ៉ូដ (១៥ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចកំណត់អាហារដែលសំបូរជាតិអ៊ីយ៉ូដ និងជំរុញការប្រើប្រាស់ដល់ស្ត្រីទាំងឡាយ។

**វិធីសាស្ត្រ** ៖ លំហាត់ជាលក្ខណៈបុគ្គល

**អ្នកណា** ៖ សិក្ខាកាមម្នាក់ៗ

**សម្ភារៈ** ៖ លំហាត់ ញ នៅក្នុងឧបសម្ព័ន្ធសៀវភៅសិក្ខាកាម ស្លាយទី ១៥៤

**សៀវភៅសិក្ខាកាម** ៖ ជំពូក ៦.៨-៦.៩

**ការណែនាំ៖**

- សុំឱ្យសិក្ខាកាមធ្វើលំហាត់ ញ នៅក្នុងឧបសម្ព័ន្ធសៀវភៅសិក្ខាកាម។
- ក្រោយពីរយៈពេល ១០ នាទី ធ្វើការពិភាក្សាលទ្ធផលដោយប្រើប្រាស់ស្លាយ ទី ១៥៤។

## ៥.១០ តើយើងអាចធ្វើការណែនាំពីអំបិលអ៊ីយ៉ូដយ៉ាងដូចម្តេច? ការងារជាក្រុម (៣០ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចកំណត់ជំហាន និងសកម្មភាពដើម្បីធ្វើការណែនាំពីអំបិលអ៊ីយ៉ូដដល់សហគមន៍។

**វិធីសាស្ត្រ** ៖ ការងារជាក្រុម

**អ្នកណា** ៖ សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់

**សម្ភារៈ** ៖ ក្រដាសផ្ទាំងធំ និងប៊ិចហ្វឺត

**ការណែនាំ:**

- ពន្យល់សិក្ខាកាមថា ការងារជាក្រុមបន្ទាប់នេះ គឺដើម្បីកំណត់ពីវិធីថាតើគេអាចកែលំអ/ធ្វើឱ្យល្អប្រសើរឡើងនូវការប្រើប្រាស់អំបិលអ៊ីយ៉ូដនៅក្នុងសហគមន៍ របស់ខ្លួនបានយ៉ាងដូចម្ដេច។
- សុំឱ្យពួកគាត់ គិតគូរអំពីយុទ្ធសាស្ត្រដើម្បីធ្វើឱ្យល្អប្រសើរឡើងនូវការប្រើប្រាស់អំបិលអ៊ីយ៉ូដ។
- ក្រុមនិមួយៗ ត្រូវធ្វើការបង្ហាញអំពីយុទ្ធសាស្ត្ររបស់ខ្លួនបន្ទាប់ពីម៉ោងសម្រាក និងការធ្វើបទបាឋកថាអំពីការបង្ហាញដែលមានប្រសិទ្ធភាព។

**សម្រាក (រយៈពេល ២០ នាទី)**

## ៥.១១ របៀបធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព (រយៈពេល ២០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចបង្ហាញព័ត៌មានទៅក្រុមផ្សេងទៀត ប្រកបដោយប្រសិទ្ធភាព។

**វិធីសាស្ត្រ** : បាឋកថា និងការធ្វើជាគំរូ

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយសំរាប់បង្ហាញ ១៥៥-១៥៩

**សៀវភៅសិក្ខាកាម :** ជំពូក ១១.១-១១.៦

**ការណែនាំ:**

- បង្ហាញស្លាយ ១៥៥-១៥៩។
- បង្ហាញជាការអនុវត្តដ៏ល្អបំផុត ធ្វើខ្លួនឯងដូចជាអ្វីដែលស្លាយបាននិយាយ។ អ្វីៗដែលអ្នកធ្វើ គឺជាគំរូ។
- ពន្យល់អ្វីដែលអ្នកនឹងធ្វើ ហេតុអ្វីបានជាអ្នកបង្ហាញដូចតែអ្នកនឹងធ្វើ។

## ៥.១២ ការឡើងធ្វើបទបង្ហាញ "ជំហាននៃការណែនាំឱ្យសហគមន៍ស្គាល់អំបិលអ៊ីយ៉ូដ" (រយៈពេល ២០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចធ្វើការបង្ហាញដោយមានទំនុកចិត្ត។

**វិធីសាស្ត្រ** : ការងារជាក្រុម (ការបង្ហាញ)

**អ្នកណា** : សិក្ខាកាម ១ នាក់ ឬ ២ នាក់ នៃក្រុមនិមួយៗ

**សម្ភារៈ** : ក្រដាសផ្ទាំងធំ និងប៊ិចហ្វឺត

**ការណែនាំ:**

- ត្រូវហ្មត់ចត់ចំពោះម៉ោងពេល ក្រុមនិមួយៗមានពេលតែ ៤ នាទី។
- នៅចុងបញ្ចប់នៃការបង្ហាញ ផ្តល់ព័ត៌មានត្រលប់យ៉ាងខ្លីទៅលើបទបង្ហាញ។

## ៥.១៣ ការធ្វើតេស្តអំបិល (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងដឹងពីរបៀបធ្វើតេស្តអំបិលរកជាតិអ៊ីយ៉ូដ និងជំរុញការប្រើប្រាស់អំបិលអ៊ីយ៉ូដនៅក្នុងសហគមន៍របស់គាត់។

**វិធីសាស្ត្រ :** បាឋកថា និងការធ្វើបង្ហាញ

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយទី ១៦០
កញ្ចប់អំបិលផ្សេងៗគ្នា
កូនដបបន្តក់តេស្ត ស្លាបព្រា

**សៀវភៅសិក្ខាកាម :** ជំពូក ៦.១០

**ការណែនាំ:**

- ពន្យល់សិក្ខាកាមអំពីរបៀបធ្វើតេស្តអំបិល ដោយប្រើប្រាស់ស្លាយទី ១៦០ និងសម្ភារៈផ្សេងទៀតក្នុងការធ្វើបង្ហាញ។
- សង្កត់ធ្ងន់លើសារៈសំខាន់នៃការប្រើប្រាស់បរិមាណដ៏តិចតួចនៃអំបិល ហើយគ្រាន់តែប្រើប្រាស់ទឹកតេស្តអ៊ីយ៉ូដតែ ១ ឬ ២ ដំណក់ប៉ុណ្ណោះ ដោយប្រើប្រាស់ដបបន្តក់។

## ៥.១៤ ការធ្វើតេស្តអំបិល - ការងារជាក្រុម (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចធ្វើតេស្តអំបិល បកស្រាយនូវលទ្ធផល និងអាចពន្យល់ដល់អ្នកផ្សេងៗពីរបៀបធ្វើតេស្ត។

**វិធីសាស្ត្រ :** ការងារជាក្រុម

**អ្នកណា :** សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៣ នាក់

**សម្ភារៈ :** ស្លាយទី ១៦០
កញ្ចប់អំបិលផ្សេងៗគ្នា
កូនដបបន្តក់តេស្ត ស្លាបព្រា

**សៀវភៅសិក្ខាកាម :** ជំពូក ៦.១០
បង្ហាញស្លាយ ១៦០ ទៅដល់ក្រុម។

**ការណែនាំ:**

- សុំឱ្យសិក្ខាកាមចែកជាក្រុមតូចៗដែលមានគ្នា ២ ឬ ៣ នាក់។
- ផ្តល់ឱ្យក្រុមនិមួយៗនូវសំណាក ៣ ឬ ៤ និង ដបបន្តក់តេស្ត។
- ឱ្យពួកគាត់ ធ្វើតេស្តអំបិល និងកត់ត្រាលទ្ធផល។
- ក្រុមនិមួយៗមានរយៈពេល ២០ នាទី សំរាប់ធ្វើតេស្តសំណាក និងកត់ត្រាលទ្ធផលនេះ។
- រយៈពេល ១០ នាទីចុងក្រោយ គឺសំរាប់អ្នកសម្របសម្រួលឡើងធ្វើការបកស្រាយបំភ្លឺពីបញ្ហាផ្សេងៗ។

## ៥.១៥ ការសន្និដ្ឋានសំរាប់ថ្ងៃរសៀល (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តអំពីចំណេះដឹង និងជំនាញដែលបានរៀនកាលពីថ្ងៃរសៀល។

**វិធីសាស្ត្រ** : សង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងការបង្ហាញម៉ោងពេល

**ការណែនាំ:**

ធ្វើការសង្ខេបសកម្មភាពពេលថ្ងៃរសៀលដោយធ្វើការបង្ហាញនូវអ្វីដែលបានរៀនៈ

- សារៈសំខាន់នៃជាតិអ៊ីយ៉ូដ
- របៀបណែនាំឱ្យស្គាល់អំបិលអ៊ីយ៉ូដ
- វិធីធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព
- ការធ្វើតេស្តអំបិល

- ឱ្យសិក្ខាកាមម្នាក់ៗនូវកូនសន្លឹកក្រដាសតូចមួយ
- សុំឱ្យពួកគាត់ធ្វើការជ្រើសរើសនូវពាក្យណាដែលសមស្របបំផុតទៅនឹងអារម្មណ៍របស់ពួកគាត់សំរាប់ថ្ងៃនេះ
- ស្នើឱ្យពួកគាត់សរសេរពាក្យនោះនៅលើកូនក្រដាស រួចបត់ក្រដាសនោះ ហើយដាក់វាចូលទៅក្នុងប្រអប់ ដែលស្ថិតនៅក្បែរច្រកចេញ។ នៅក្នុងអំឡុងពេលនៃការប្រជុំអ្នកសម្របសម្រួល លទ្ធផលទាំងនេះនឹងត្រូវយកមកធ្វើការពិភាក្សា

បង្ហាញសិក្ខាកាមក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងម៉ោងពេលដែលត្រូវត្រលប់មកវិញ

# ថ្ងៃទី ៦: ការផ្តល់ថ្នាំបង្ការ និងការពិនិត្យផ្ទៃពោះមុនពេលសម្រាល

## គោលបំណងថ្ងៃទី ៦

១ ដើម្បីរំលឹកឡើងវិញនូវមេរៀនជាតិអ៊ីយ៉ូដដែលបានរៀនហើយ

២ ដើម្បីបង្រៀនពីសកម្មភាពនៃការផ្តល់ថ្នាំបង្ការ

៣ ដើម្បីបង្រៀនពីសកម្មភាពនៃការពិនិត្យផ្ទៃពោះមុនពេលសម្រាលដល់សិក្ខាកាម

៤ ដើម្បីបណ្តុះបណ្តាលអំពីសកម្មភាពនៃការពិនិត្យផ្ទៃពោះមុនពេលសម្រាល ដោយចុះអនុវត្តផ្ទាល់ (ការចុះអនុវត្តផ្ទាល់នៅមូលដ្ឋាន)

៥ ដើម្បីបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់សៀវភៅសុខភាពមាតា

## គោលបំណងជំនាញសំរាប់សិក្ខាកាមនៅថ្ងៃទី ៦:

**នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចៈ**

១ ផ្តល់ថ្នាំបង្ការបានសមស្របដល់ស្ត្រី និងកុមារ

២ ប្រើប្រាស់សម្ភារៈជំនួយការងារការពិនិត្យផ្ទៃពោះមុនពេលសម្រាល សំរាប់ការចុះអនុវត្តផ្ទាល់នៅថ្ងៃទី ៧

## កាលវិភាគប្រចាំថ្ងៃ

| ម៉ោង | រយៈពេល | លរ | មេរៀន | នរណា |
|---|---|---|---|---|
| ៨:០០ | ១០ | ៦.១ | ជួបជុំសែនស្នេគស្វាញ<br>ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន<br>និងការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ៨:១០ | ១០ | ៦.២ | គោលបំណងនៃថ្ងៃទី ៦<br>បាឋកថាៈ បង្ហាញពីគោលបំណងប្រចាំថ្ងៃ | អ្នកសម្របសម្រួល |
| ៨:២០ | ៥០ | ៦.៣ | ជាតិអ៊ីយ៉ូដ<br>ការងារជាក្រុមស្តីពីសារជាតិអ៊ីយ៉ូដ | ក្រុម |
| ៩:១០ | ៣០ | ៦.៤ | សារៈសំខាន់នៃការផ្តល់ថ្នាំបង្ការ<br>បាឋកថាស្តីពីកម្មវិធីផ្តល់ថ្នាំបង្ការ | អ្នកសម្របសម្រួល |
| ៩:៤០ | ២០ | ៦.៥ | ការផ្តល់ថ្នាំបង្ការ<br>ការងារជាក្រុម - អនុវត្តការផ្តល់ថ្នាំបង្ការ | ក្រុម |
| **១០:០០** | **២០** | | **សម្រាក** | |
| ១០:២០ | ៤៥ | ៦.៦ | សារអាហារូបត្ថម្ភក្នុងពេលសកម្មភាពផ្តល់ថ្នាំបង្ការ<br>បាឋកថាស្តីពីការបញ្ជ្រៀតចូលគ្នានៃអាហារូបត្ថម្ភ<br>និងការផ្តល់ថ្នាំបង្ការ | អ្នកសម្របសម្រួល |
| ១១:០៥ | ១៥ | ៦.៧ | តារាងលំហូរនៃការផ្តល់ថ្នាំបង្ការ<br>ការធ្វើលំហាត់ជាលក្ខណៈបុគ្គលពីវិធីប្រើប្រាស់<br>តារាងលំហូរនៃការផ្តល់ថ្នាំបង្ការ | បុគ្គលម្នាក់ៗ |
| ១១:២០ | ១០ | ៦.៨ | សេចក្តីសន្និដ្ឋានសំរាប់ពេលព្រឹក<br>សង្ខេប | អ្នកសម្របសម្រួល |
| **១១:៣០** | **១២០** | | **សម្រាក** | |
| ១៣:៣០ | ១០ | ៦.៩ | ច្រៀងចំរៀង<br>ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន និង<br>ការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ១៣:៤០ | ៣០ | ៦.១០ | ការរៀបចំសំរាប់ការចុះអនុវត្តនៅមូលដ្ឋាន<br>ការជួបពិនិត្យផ្ទៃទាំមុនពេលសម្រាល<br>បាឋកថា | អ្នកសម្របសម្រួល |
| ១៤:១០ | ៤៥ | ៦.១១ | ការធ្វើបង្ហាញពីកង្វះខាតជាគំរូក្នុងការជួបមុនពេលសម្រាល<br>គំរូមិនល្អដែលធ្វើដោយអ្នកសម្របសម្រួល និងមាន<br>ការពិភាក្សា បន្ទាប់ពីការធ្វើបង្ហាញ | អ្នកសម្របសម្រួល |

| ម៉ោង | រយៈពេល | លរ | មេរៀន | នរណា |
|---|---|---|---|---|
| ១៤:៥៥ | ៣៥ | ៦.១២ | ការធ្វើបង្ហាញពីគំរូល្អក្នុងការជួបពិនិត្យមុនពេលសម្រាល គំរូដ៏ល្អបំផុតដែលធ្វើបង្ហាញ ដោយអ្នកសម្របសម្រួល និងមានការពិភាក្សាបន្ទាប់ពីការធ្វើបង្ហាញ | អ្នកសម្របសម្រួល |
| ១៥:៣០ | ២០ | | សម្រាក | |
| ១៥:៥០ | ៦០ | ៦.១៣ | ការជួបពិនិត្យផ្ទៃពោះមុនពេលសម្រាល ការដើរតួតាមក្រុម ដើម្បីអនុវត្តការជួបពិនិត្យផ្ទៃពោះមុនពេលសម្រាល | ក្រុម |
| ១៦:៥០ | ១០ | ៦.១៤ | សេចក្តីសន្និដ្ឋានសំរាប់ថ្ងៃរៀន សង្ខេប | អ្នកសម្របសម្រួល |
| ១៧:០០ | | | ចប់ថ្ងៃទី ៦ | |

## សម្ភារៈដែលត្រូវការ៖

- ស្លាយសំរាប់បង្ហាញ ទី ១៦១-១៨៨
- ក្រដាសផ្ទាំងធំ
- ប៊ិចហ្វឺត
- ប័ណ្ណសំរាប់បង្កើតតារាង
- តារាងលំហូរ (នៃការផ្តល់ថ្នាំបង្ការ)
- សម្ភារៈជំនួយការងារ

# សកម្មភាពថ្ងៃទី ៦

## ៦.១ ផ្លូវដ៏សែនស្មុគស្មាញមួយ (១០ នាទី)

**គោលបំណង :** ចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីនាពេលព្រឹក ។
**វិធីសាស្ត្រ :** ល្បែងថាមពល
**អ្នកណា :** សិក្ខាកាមទាំងអស់ដែលសម្របសម្រួលដោយអ្នកសម្របសម្រួលម្នាក់
**សម្ភារៈ :**

- ស្នើឱ្យសិក្ខាកាមទាំងអស់បង្កើតជាជួរមួយ ។
- សិក្ខាកាមម្នាក់ត្រូវបានជ្រើសរើសឱ្យគិតរកល័ក្ខខ័ណ្ឌក្នុងការបង្កើតជាជួរនោះ ។ គាត់មិនអាចនិយាយប្រាប់គេថាតើល័ក្ខខ័ណ្ឌនោះមានសេចក្តីយ៉ាងម៉េចបានទេ គាត់អាចនិយាយបានត្រឹមតែថាជួរនេះត្រូវ ឬខុសតែប៉ុណ្ណោះ ។ ហើយគាត់អាចនិយាយបង្ហើបបានខ្លះៗ ដូចជាថា: បុគ្គលម្នាក់នេះឈរខុសកន្លែងហើយ ប៉ុន្តែបុគ្គលម្នាក់នេះ និងម្នាក់នោះឈរត្រូវកន្លែង ។
- បញ្ឈប់ការល្បែងនេះ ក្រោយពីលេងបានរយៈពេល ១០ នាទីមក ហើយស្នើឱ្យសិក្ខាកាមទាំងអស់ចូលទៅកាន់កន្លែងអង្គុយរៀងៗខ្លួនវិញ ។

## ៦.២ គោលបំណងថ្ងៃទី ៦ (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងដឹងពីគោលបំណងសំរាប់ថ្ងៃនេះ ។
**វិធីសាស្ត្រ :** បាឋកថា
**អ្នកណា :** អ្នកសម្របសម្រួល
**សម្ភារៈ :** ស្លាយទី ១៦២-១៨៨

ធ្វើការបង្ហាញដល់សិក្ខាកាម នូវស្លាយទី ១៦១ និង ១៦២

## ៦.៣ តើជាតិអ៊ីយ៉ូដគឺជាអ្វី?-ការងារជាក្រុម (៥០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចពន្យល់ពីសារៈសំខាន់នៃជាតិអ៊ីយ៉ូដ និងពីវិធីដើម្បីលើកកម្ពស់ ការប្រើប្រាស់អំបិលអ៊ីយ៉ូដ ដោយមានទំនុកចិត្ត ។

**វិធីសាស្ត្រ** : ការងារជាក្រុម

**អ្នកណា** : សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៥ នាក់

**សម្ភារៈ** : ក្រដាសផ្ទាំងធំ និងប៊ិចហ្វឺត

### ការណែនាំ:

- ពន្យល់ដល់សិក្ខាកាមថា ការដាក់ការងារឱ្យធ្វើតាមក្រុមនេះ គឺដើម្បីធ្វើឱ្យនឹកឃើញឡើងវិញនូវចំណុចសំខាន់ៗនៃមេរៀនដែលបានរៀនកាលពីម្សិលមិញ ស្តីពីអ៊ីយ៉ូដ ។
- ស្នើឱ្យពួកគាត់ បង្កើតជាក្រុមដែលមានគ្នាចំនួន ៥នាក់ ហើយត្រូវរៀបចំក្រដាសផ្ទាំងធំដែលមានសារជាមូលដ្ឋាន និងសកម្មភាព ព្រមទាំងរបៀបលើកកម្ពស់ការប្រើប្រាស់អំបិលអ៊ីយ៉ូដ ។
- មានពេល ៣០ នាទី សំរាប់រៀបចំក្រដាសផ្ទាំងធំដ៏ទាក់ទាញមួយ ។ ក្រដាសផ្ទាំងធំទាំងអស់ ត្រូវបិទភ្ជាប់ទៅនឹងជញ្ជាំង ។
- រយៈពេល ២០ នាទី បន្ទាប់មកទៀត អ្នកសម្របសម្រួលត្រូវធ្វើការរំលឹកឡើងវិញ ដោយប្រើប្រាស់ក្រដាសផ្ទាំងធំរបស់សិក្ខាកាម ។

## ៦.៤ សារៈសំខាន់នៃការផ្តល់ថ្នាំបង្ការ (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងយល់ដឹងអំពីសារៈសំខាន់ និងកម្មវិធីការផ្តល់ថ្នាំបង្ការ ។

**វិធីសាស្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយទី ១៦៣-១៦៩

**សៀវភៅសិក្ខាកាម** : ជំពូក ៧.១-៧.៤

### ការណែនាំ:

- បង្ហាញស្លាយទី ១៦៣-១៦៩ ដើម្បីពន្យល់ណែនាំសិក្ខាកាមពីការផ្តល់ថ្នាំបង្ការ

## ៦.៥ ការផ្តល់ថ្នាំបង្ការ – ការងារជាក្រុម៖ (២០ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចប្រើប្រាស់ព័ត៌មានស្តីពីការផ្តល់ថ្នាំបង្ការ និងអាចបង្កើតបាននូវទិដ្ឋភាពរួមមួយស្តីពីសកម្មភាពនៃការផ្តល់ថ្នាំបង្ការ ។

**វិធីសាស្រ្ត** ៖ ការងារជាក្រុម

**អ្នកណា** ៖ ក្រុមធំ

**សម្ភារៈ** ៖ ដុំនៃប័ណ្ណ (សម្ភារៈជំនួយការបណ្តុះបណ្តាលនៅក្នុងឧបសម្ព័ន្ធ)

### ការណែនាំ៖

- សុំឱ្យក្រុមបង្កើតនូវទិដ្ឋភាពរួមមួយស្តីពីព័ត៌មានដែលបានផ្តល់ឱ្យពួកគាត់ នៅក្នុងអំឡុងពេលធ្វើបាឋកថារយៈពេល ២០ នាទីមុន ។
- សិក្ខាកាមត្រូវដាក់ផ្ទាំងប័ណ្ណតម្រៀបគ្នាតាមរបៀបមួយ ដែលត្រឹមត្រូវទៅតាមទិដ្ឋភាពរួមនោះ ។

សម្រាក (២០នាទី)

## ៦.៦ សារអាហារូបត្ថម្ភនៅក្នុងអំឡុងពេលធ្វើសកម្មភាពផ្តល់ថ្នាំបង្ការ (៤៥ នាទី)

**គោលបំណង** ៖ ដើម្បីពង្រីងចំណេះដឹងដល់សិក្ខាកាម ស្តីពីការផ្តល់ថ្នាំបង្ការ និងដើម្បីបង្ហាញពីរបៀបដែលគេអាចប្រើប្រាស់សេវាផ្តល់ថ្នាំបង្ការសំរាប់សកម្មភាពអាហារូបត្ថម្ភ ។

**វិធីសាស្រ្ត** ៖ បាឋកថា

**អ្នកណា** ៖ អ្នកសម្របសម្រួល

**សម្ភារៈ** ៖ ស្លាយសំរាប់បង្ហាញ ទី១៧០-១៨៣

### ការណែនាំ៖

- ប្រើប្រាស់ស្លាយ ១៧០-១៨៣ ដើម្បីពន្យល់សិក្ខាកាមពីរបៀបដែលសារអាហារូបត្ថម្ភត្រូវបានដាក់បញ្ចូលនៅក្នុងសកម្មភាពនៃការផ្តល់ថ្នាំបង្ការ ។

## ៦.៧ តារាងលំហូរស្តីពីការផ្តល់ថ្នាំបង្ការ–លំហាត់ ៨ (១៥ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចប្រើប្រាស់តារាងលំហូរស្តីពីការផ្តល់ថ្នាំបង្ការ ។

**វិធីសាស្រ្ត** ៖ លំហាត់ជាលក្ខណៈបុគ្គល

**អ្នកណា** ៖ សិក្ខាកាមម្នាក់ៗ អ្នកសម្របសម្រួលម្នាក់អានឱ្យឮខ្លាំងៗ

**សម្ភារៈ** ៖ លំហាត់ ដ នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្ខាកាម ស្លាយទី ១៧៩

**សៀវភៅសិក្ខាកាម៖** ជំពូក ៧.៥

**ការណែនាំ៖**

- សុំឱ្យសិក្ខាកាមទាំងអស់មើលលំហាត់ ដ
- ពន្យល់ពួកគាត់ថា អ្នកនឹងពិនិត្យមើលតារាងលំហូរជាមួយគាត់ ដោយប្រើប្រាស់ឧទាហរណ៍នៃរឿង ណារិទ្ធ។
- បង្ហាញស្លាយទី ១៧៩ ដើម្បីបង្ហាញរឿងណារិទ្ធ

## ៦.៨ សេចក្ដីសន្និដ្ឋានសំរាប់ពេលព្រឹក (១០ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តលើចំណេះដឹង និងជំនាញដែលបានសិក្សាកាលពីព្រឹក។

**វិធីសាស្ត្រ** ៖ សង្ខេប

**អ្នកណា** ៖ អ្នកសម្របសម្រួល

**សម្ភារៈ** ៖ ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា ហើយដែលបង្ហាញពេលម៉ោង

**ការណែនាំ៖**

សង្ខេបមេរៀនសិក្សាពីព្រឹក ដោយផ្ដោតទៅលើអ្វីដែលបានរៀន៖

- កម្មវិធីអំបិលអ៊ីយ៉ូដ
- សារៈសំខាន់នៃការផ្ដល់ថ្នាំបង្ការ និងការងារអាហារូបត្ថម្ភនៅក្នុងកម្មវិធីផ្ដល់ថ្នាំបង្ការ
- របៀបដាក់បញ្ចូលសារអាហារូបត្ថម្ភទៅក្នុងសកម្មភាពផ្ដល់ថ្នាំបង្ការ

បង្ហាញសិក្ខាកាមនូវក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងពេលម៉ោងដែលពួកគាត់ត្រូវត្រលប់មកវិញ។

សម្រាក (១២០នាទី)

## ៦.៩ ច្រៀងចំរៀង! (១០ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្ដើមកម្មវិធីថ្ងៃរសៀល។

**វិធីសាស្ត្រ** ៖ ល្បែងថាមពល

**អ្នកណា** ៖ សិក្ខាកាម និងអ្នកសម្របសម្រួលជាក្រុមដែលមានគ្នាយ៉ាងច្រើន ១០ នាក់

**សម្ភារៈ** ៖

**ការណែនាំ :**

- សុំឱ្យសិក្ខាកាមគិតរកចំរៀងមួយបទដើម្បីច្រៀង។ ចំរៀងនោះគួរតែមានលក្ខណៈសាមញ្ញ ហើយងាយចាំ។
- អញ្ជើញសិក្ខាកាមម្នាក់ឱ្យឡើងច្រៀងចំរៀងនោះ ហើយបង្រៀនចំរៀងនេះដល់អ្នកផ្សេងទៀត។
- ក្នុងរយៈពេល ១០ នាទី ម្នាក់ៗត្រូវចងចាំចំរៀងនោះ ហើយអាចច្រៀងចំរៀងនោះបានរួមគ្នា។ សូមទះដៃដើម្បីបន្ទរជាចង្វាក់ភ្លេង។

## ៦.១០ ការរៀបចំសំរាប់ការចុះអនុវត្តនៅមូលដ្ឋាន ការជួបពិនិត្យផ្ទៃទំមុនពេលសម្រាល (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន និងសារដែលត្រូវផ្តល់ក្នុងអំឡុងពេលការជួបពិនិត្យផ្ទៃទំមុនពេលសម្រាល

**វិធីសាស្ត្រ :** បាឋកថា

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយទី ១៨៥-១៨៧
បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សា
សម្ភារៈជំនួយការងារ

**ការណែនាំ :**

- ពន្យល់សិក្ខាកាមថាថ្ងៃស្អែក ពួកគាត់នឹងទៅធ្វើការអនុវត្តផ្ទាល់នៅមូលដ្ឋាននៅពេលព្រឹក
- បញ្ជាក់ប្រាប់គាត់ថាយើងផ្តោតតែទៅលើស្ត្រីដែលមកទទួលការពិនិត្យមុនពេលសម្រាលនៅមណ្ឌលសុខភាពតែប៉ុណ្ណោះ
- រំលឹកសិក្ខាកាមថាពួកគាត់ត្រូវប្រើសម្ភារៈជំនួយការងារ "ការជួបពិនិត្យផ្ទៃទំមុនពេលសម្រាល"
- ពន្យល់ពីរបៀបប្រើសម្ភារៈជំនួយការងារ ដោយប្រើប្រាស់ស្លាយ ទី ១៨៥-១៨៧
- ពន្យល់ពីបញ្ជីផ្ទៀងផ្ទាត់ដើម្បីវាយតម្លៃការផ្តល់ប្រឹក្សាស្ត្រីមានផ្ទៃពោះ។ បញ្ជីផ្ទៀងផ្ទាត់នេះ ជួយពីរបៀបផ្តល់ប្រឹក្សាតាមវិធីមួយដ៏ល្អបំផុត

## ៦.១១ ការធ្វើបង្ហាញពីកង្វះខាតក្នុងការជួបពិនិត្យថែទាំមុនពេលសម្រាល (៤៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចកំណត់កង្វះខាតក្នុងការផ្ដល់ការថែទាំមុនពេលសម្រាល ក្នុងអំឡុងពេលការជួបពិនិត្យផ្ទៃពោះមុនពេលសម្រាល

**វិធីសាស្ត្រ :** ការធ្វើបង្ហាញ និងការពិភាក្សា

**អ្នកណា :** សិក្ខាកាម ២ នាក់ សំរាប់ការធ្វើបង្ហាញ អ្នកសម្របសម្រួលជាអ្នកដឹកនាំការពិភាក្សា

**សម្ភារៈ :** សម្ភារៈជំនួយការងារ និងបញ្ជីផ្ទៀងផ្ទាត់
ស្លាយទី ១៨៨

**ការណែនាំ :**

- អញ្ជើញសិក្ខាកាមពីរនាក់ឱ្យឡើងមកធ្វើបង្ហាញពីការពិនិត្យថែទាំផ្ទៃពោះមុនពេលសម្រាល ។
- បញ្ជាក់ថា ការធ្វើបង្ហាញឱ្យមើលនេះគឺក្នុងបំណងសិក្សាតែប៉ុណ្ណោះ ហើយថាយើងទាំងអស់គ្នាអាចរៀនពីកំហុសឆ្គង ។
- ការធ្វើខុសក្នុងអំឡុងពេលនៃការអនុវត្តន៍សាកល្បង គឺមិនមែនជាការអាក្រក់ទេ ប៉ុន្តែវាជាការមានប្រយោជន៍ណាស់ ។
- រៀបចំកន្លែងសំរាប់ការដើរតួនៅមុខក្រុម ដោយការដើរតួនោះគឺបែរមុខទៅរកក្រុម ។
- សុំឱ្យសិក្ខាកាមពីរនាក់ចាប់ផ្ដើម ការមកពិនិត្យថែទាំមុនពេលសម្រាលដោយប្រើប្រាស់សម្ភារៈជំនួយការងារសំរាប់ការមកពិនិត្យការថែទាំមុនពេលសម្រាល
- សុំឱ្យសិក្ខាកាមដទៃទៀតរកមើលកង្វះខាតនៅក្នុងការធ្វើបង្ហាញ ដោយផ្អែកទៅលើសម្ភារៈជំនួយការងារ និងបញ្ជីផ្ទៀងផ្ទាត់ ។
- ប្រើរយៈពេល ៥ នាទី សំរាប់ការណែនាំ
- ល្បែងដើរតួចំនាយពេលយ៉ាងយូរ ១០ នាទី
- ការពិភាក្សានៅ ៣០ នាទីចុងក្រោយ គឺផ្ដោតជុំវិញទៅលើសំណួរដូចនៅស្លាយ ១៨៨

## ៦.១២ ការធ្វើបង្ហាញឱ្យមើលជាគំរូ ការជួបពិនិត្យថែទាំមុនពេលសម្រាល (៣៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចចងចាំនូវជំនាញអនុវត្តផ្ទាល់ដ៏ល្អបំផុត សំរាប់ការជួបពិនិត្យថែទាំមុនពេលសម្រាល ។

**វិធីសាស្ត្រ :** ការធ្វើបង្ហាញ និងសំណួរ - ចម្លើយ

**អ្នកណា :** អ្នកសម្របសម្រួល ២ នាក់

**សម្ភារៈ :** សម្ភារៈជំនួយការងារ និងបញ្ជីផ្ទៀងផ្ទាត់

## ការណែនាំ ៖

- ចំនាយពេល ១០ នាទី ដើម្បីធ្វើគំរូឱ្យសិក្ខាកាមមើល ពីការពិនិត្យផ្ទៃទាំផ្ទៃពោះមុនពេលសម្រាល ។
- ធ្វើអ្វីៗទាំងអស់ដោយផ្អែកទៅតាមសៀវភៅ ។ វាគួរតែជាគំរូដែលល្អឥតខ្ចោះនៃអ្វីដែលយើងចង់ឱ្យសិក្ខាកាមធ្វើតាមក្នុងពេលចុះទៅអនុវត្តនៅតាមមូលដ្ឋាន និងនៅមណ្ឌលសុខភាព ។
- សុំឱ្យសិក្ខាកាមប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ក្នុងអំឡុងពេលការសំដែងតួ ។
- សុំឱ្យសិក្ខាកាមផ្តល់ព័ត៌មានត្រលប់នៅពេលដែលអ្នកបានបញ្ចប់ការសំដែង ។ ពិភាក្សាព័ត៌មានត្រលប់ជាមួយក្រុមធំ ។

សម្រាក (២០ នាទី)

## ៦.១៣ ការជួបពិនិត្យផ្ទៃទាំមុនពេលសម្រាល - ការងារជាក្រុម (៦០ នាទី)

**គោលបំណង ៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចធ្វើការផ្តល់ប្រឹក្សាក្នុងអំឡុងពេលនៃការជួបពិនិត្យផ្ទៃទាំមុនពេលសម្រាល ។

**វិធីសាស្ត្រ ៖** ល្បែងដើរតួ

**អ្នកណា ៖** សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៤ នាក់

**សម្ភារៈ ៖** សម្ភារៈជំនួយការងារ

### សន្និទានភាព

ក្នុងអំឡុងពេលលេងល្បែងដើរតួនេះ សិក្ខាកាមនឹងរៀនសូត្រអំពីរបៀបផ្តល់ប្រឹក្សាដល់ស្ត្រីមានផ្ទៃពោះក្នុងអំឡុងពេលពួកគាត់មកពិនិត្យនៅមណ្ឌលសុខភាព ។ ល្បែងដើរតួនេះ ជួយពង្រឹងដល់ការប្រស្រ័យទាក់ទង និងជំនាញផ្តល់ប្រឹក្សារបស់សិក្ខាកាម ។ មើលផ្នែកស្តីពីជំនាញក្នុងការប្រស្រ័យទាក់ទង និងបញ្ជីផ្ទៀងផ្ទាត់ សំរាប់ការពិនិត្យផ្ទៃទាំមុនពេលសម្រាល ដែលមាននៅក្នុងសៀវភៅ មុនពេលលេងល្បែងដើរតួ ។

### ការណែនាំ ៖

- បង្កើតជាក្រុមដែលមានគ្នា ៤ នាក់ ។
- ក្រុមនិមួយៗនឹងដើរតួ ២ រឿង ។ ល្បែងដើរតួនិមួយៗ ត្រូវសំដែងដោយមានសិក្ខាកាមម្នាក់ដើរតួជាបុគ្គលិកមណ្ឌលសុខភាព ហើយសិក្ខាកាមម្នាក់ទៀតដើរតួជាស្ត្រីមានផ្ទៃពោះ ។ ចំណែកឯសិក្ខាកាម ២ នាក់ ទៀតជាអ្នកសង្កេតការណ៍ ។
- ចាត់តាំងតួនាទីសមាជិកក្រុម ។
- អ្នកសំដែងម្នាក់ៗ នឹងពិភាក្សាដោយសង្ខេបពីអ្វីដែលត្រូវធ្វើជាមួយអ្នកសង្កេតការណ៍ម្នាក់ក្នុងចំណោមអ្នកសង្កេតការណ៍ទាំងពីរ ។
- បន្ទាប់ពីការរៀបចំបាន ៥ នាទីមក ល្បែងដើរតួត្រូវចាប់ផ្តើម ។

- បន្ទាប់ពីលេងបាន ១០ នាទី ល្បែងដើរតួត្រូវបានបញ្ចប់ ហើយក្រុមតូចត្រូវធ្វើការពិភាក្សាពីល្បែងដើរតួនេះ រយៈពេល ១៥ នាទី។
- បន្ទាប់មក ល្បែងដើរតួនេះត្រូវលេងជាថ្មីម្តងទៀត។ ឥឡូវនេះគឺអ្នកសង្កេតការណ៍ជាអ្នកសំដែង ចំណែកសមាជិក ២ នាក់ទៀត គឺធ្វើជាអ្នកសង្កេតការណ៍ម្តង។ បន្ទាប់ពីលេងបាន ១០ នាទីមក គេត្រូវធ្វើការពិភាក្សាពីល្បែងដើរតួនេះ។

## កាលវិភាគ

| ល្បែងដើរតួ (x២) | នាទី |
|---|---|
| រៀបចំ (ជុំទី១) | ៥ |
| សំដែងជុំទី ១ | ១០ |
| ការពិភាក្សា | ១៥ |
| សំដែងសារជាថ្មី (អ្នកសំដែងផ្សេង) | ១០ |
| សំដែងសារជាថ្មី (អ្នកសំដែងផ្សេង) | ១៥ |
| **សរុប** | **៥៥** |

## ៦.១៤ ការសន្និដ្ឋានសំរាប់ថ្ងៃរសៀល (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តអំពីចំណេះដឹង និងជំនាញដែលបានរៀនពីល្ងាចនេះ។

**វិធីសាស្ត្រ :** សង្ខេប

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងការបង្ហាញម៉ោងពេល ការពិពណ៌នាពីមធ្យោបាយទៅកាន់មណ្ឌលសុខភាព។

### ការណែនាំ :

ធ្វើការបូកសរុបសកម្មភាពនាពេលរសៀលនេះ ដោយបង្ហាញពីអ្វីដែលបានសិក្សា:

- របៀបប្រើប្រាស់សម្ភារៈជំនួយការងារ សំរាប់ការពិនិត្យថៃទាំមុនពេលសម្រាល
- របៀបផ្តល់ប្រឹក្សាដែលមានប្រសិទ្ធភាព សំរាប់ការពិនិត្យថៃទាំមុនពេលសម្រាល
- របៀប/វិធីធ្វើឱ្យប្រសើរឡើងនូវជំនាញក្នុងការផ្តល់ប្រឹក្សារបស់ខ្លួន

ស្នើឱ្យសិក្ខាកាមទាំងអស់ឈរជាជួរនៅចំកណ្ដាលបន្ទប់ ។ ទាំងអស់គ្នាសម្លឹងមើលទៅមុខ ។ សួរពួកគេនូវសំនួរដូចខាងក្រោម ។ កំរាលឥដ្ឋ គឺ "**ទេ**" ដៃទាំងពីរលើកឡើងទៅលើ គឺ "**បាទ/ចាស៎, ច្រើនណាស់**" ។ ស្នើឱ្យពួកគាត់ចង្អុលដៃរបស់ពួកគាត់ទៅតាមអារម្មណ៍របស់ពួកគាត់ដែលមានៈ

**១** មេរៀនស្ដីពីការផ្ដល់ថ្នាំបង្ការ គឺមានប្រយោជន៍ខ្លាំងណាស់

**២** មេរៀនស្ដីពីការអនុវត្តន៍នៅមូលដ្ឋាន គឺមានប្រយោជន៍ខ្លាំងណាស់

**៣** ខ្ញុំមានអារម្មណ៍ជឿទុកចិត្តលើខ្លួនឯង អំពីការអនុវត្តន៍នៅមូលដ្ឋាននៅថ្ងៃស្អែកនេះ

**៤** ខ្ញុំកំពុងរង់ចាំចុះធ្វើការអនុវត្តន៍នៅមូលដ្ឋាននៅថ្ងៃស្អែកនេះ

បង្ហាញសិក្ខាកាមពីក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងពេលវេលាដែលត្រូវទៅដល់មណ្ឌលសុខភាពនៅថ្ងៃស្អែក និងពីមធ្យោបាយទៅកាន់ទីនោះ ។

# ថ្ងៃទី ៧: កម្មសិក្សាអនុវត្តន៍នៅតាមមូលដ្ឋាន ការពិនិត្យផ្ទៃពោះមុនពេលសម្រាល/ ពេលសម្រាល និងក្រោយសម្រាល

## គោលបំណងថ្ងៃទី ៧:

១ ដើម្បីអនុវត្តជំនាញផ្តល់ប្រឹក្សាការពិនិត្យមុនពេលសម្រាល

២ ដើម្បីបង្រៀនអំពីការធ្វើសកម្មភាពនៃការពិនិត្យស្ត្រីពេលសម្រាល និងក្រោយសម្រាល ទៅដល់សិក្ខាកាម

៣ ដើម្បីបណ្តុះបណ្តាលការអនុវត្តន៍ធ្វើសកម្មភាពនៃការពិនិត្យពេលសម្រាល និងក្រោយសម្រាល ( កម្មសិក្សា) ។

## គោលបំណងជំនាញសំរាប់សិក្ខាកាមនៅថ្ងៃទី ៧:

**នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចៈ**

១ ផ្តល់ប្រឹក្សាដល់ស្ត្រីមានផ្ទៃពោះ អំពីអាហារូបត្ថម្ភក្នុងអំឡុងពេលការជួបពិនិត្យផ្ទៃពោះមុនពេលសម្រាល ដោយប្រើប្រាស់សម្ភារៈជំនួយការងារការជួបពិនិត្យផ្ទៃពោះមុនពេលសម្រាល

២ ប្រើប្រាស់សម្ភារៈជំនួយការងារការជួបពិនិត្យពេលសម្រាល និងក្រោយពេលសម្រាល

## កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨:០០ | ៣០ | ៧.១ | ណែនាំសិក្ខាកាមទៅដល់មណ្ឌលសុខភាព និងណែនាំពីការធ្វើកម្មសិក្សា | ទាំងអស់គ្នា |
| ៨:៣០ | ១៨០ | ៧.២ | ការជួបពិនិត្យផ្ទៃទាំមុនពេលសម្រាល កម្មសិក្សាអនុវត្តន៍ | ក្រុម |
| **១១:៣០** | **១២០** | | **សម្រាក** | |
| ១៣:៣០ | ១០ | ៧.៣ | ញាក់ភ្នែកដាក់ដោយមិត្តភាព ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន និងការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ១៣:៤០ | ៦០ | ៧.៤ | ការពិភាក្សាកម្មសិក្សាអនុវត្តន៍ ព្យុះគំនិតនិងការពិភាក្សាលើកម្មសិក្សាអនុវត្តន៍កាលពីព្រឹក | បុគ្គលម្នាក់ៗ |
| ១៤:៤០ | ២០ | ៧.៥ | ការជួបពិនិត្យពេលសម្រាល និងក្រោយពេលសម្រាល បាច់កថា | អ្នកសម្របសម្រួល |
| ១៥:០០ | ១៥ | ៧.៦ | ការធ្វើបង្ហាញជាគំរូ ការជួបពិនិត្យពេលសម្រាល ការធ្វើបង្ហាញ និងសំណួរចម្លើយ | អ្នកសម្របសម្រួល |
| **១៥:១៥** | **២០** | | **សម្រាក** | |
| ១៥:៣៥ | ៣០ | ៧.៧ | ការជួបពិនិត្យពេលសម្រាល ល្បែងដើរតួ | ក្រុម |
| ១៦:០៥ | ១៥ | ៧.៨ | ការធ្វើបង្ហាញជាគំរូ ការជួបពិនិត្យក្រោយពេលសម្រាល ការធ្វើបង្ហាញ និងសំណួរចម្លើយ | អ្នកសម្របសម្រួល |
| ១៦:២០ | ៣០ | ៧.៩ | ការជួបពិនិត្យក្រោយពេលសម្រាល ល្បែងដើរតួ | ក្រុម |
| ១៦:៥០ | ១០ | ៧.១០ | សេចក្ដីសន្និដ្ឋាននៅពេលថ្ងៃរសៀល សង្ខេប | អ្នកសម្របសម្រួល |
| **១៧:០០** | | | **បញ្ចប់ការសិក្សាថ្ងៃទី ៧** | |

## សម្ភារៈដែលត្រូវការ៖

- ស្លាយសំរាប់បង្ហាញ ទី ១៨៩-១៩៧
- សម្ភារៈជំនួយការងារ
- សៀវភៅសុខភាពមាតា
- បណ្ណ័សុខភាពកុមារ
- បញ្ជីផ្ទៀងផ្ទាត់

# សកម្មភាពថ្ងៃទី ៧

## នៅមណ្ឌលសុខភាព

### ៧.១ ណែនាំសិក្ខាកាមដល់បុគ្គលិកមណ្ឌលសុខភាព និងការធ្វើកម្មសិក្សាអនុវត្តន៍ (៣០ នាទី)

**គោលបំណង** ៖ នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចសំរាប់កម្មសិក្សាអនុវត្តស្ដីពី ការជួបពិនិត្យមុនពេលសម្រាល

**វិធីសាស្រ្ត** ៖ ការណែនាំឱ្យស្គាល់

**អ្នកណា** ៖ សិក្ខាកាមទាំងអស់ អ្នកសម្របសម្រួលម្នាក់ សម្របសម្រួលក្រុមដែលមានសមាជិក ៨ នាក់

**សម្ភារៈ** ៖ សម្ភារៈជំនួយការងារ សៀវភៅសុខភាពមាតា ប័ណ្ណសុខភាពកុមារ នឹងតារាងកាលវិភាគ

### ការណែនាំ

- ពន្យល់ពីអត្ថន័យនៃការធ្វើកម្មសិក្សាអនុវត្តន៍ និងអំពីពេលវេលាតាមកាលវិភាគ
- ប្រាប់សិក្ខាកាមថា គឺមានតែសិក្ខាកាមម្នាក់គត់ដែលត្រូវផ្ដល់ប្រឹក្សាដល់អតិថិជនម្នាក់ដែលបានចូលមកពិនិត្យសុខភាព ចំណែកអ្នកឯទៀត គឺជាអ្នកសង្កេតការណ៍
- នៅក្រោយការពិនិត្យអតិថិជននិមួយៗរួច ត្រូវធ្វើការប្រៀបធៀបបញ្ជីផ្ទៀងផ្ទាត់ និងពិភាក្សាលើការផ្ដល់ប្រឹក្សា
- សម្រាប់ស្រ្តីចូលមកពិនិត្យបន្ទាប់ទៀត សិក្ខាកាមម្នាក់ផ្សេងទៀតអាចធ្វើការផ្ដល់ប្រឹក្សា
- ប្រើប្រាស់សម្ភារៈជំនួយការងារសម្រាប់ផ្ដល់ប្រឹក្សាដល់ស្រ្តី
- បញ្ជាក់ពីពេលម៉ោងដែលត្រូវសម្រាក

## ៧.២ សិក្សាកម្មអនុវត្តន៍ (ធ្វើរហូតដល់ម៉ោង ១១:៣០)

សម្រាក (១២០ នាទី)

## នៅក្នុងថ្នាក់

## ៧.៣ ម៉ិចភ្នែកដាក់អោយមិត្តភាព (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្ដើមកម្មវិធីពេលរសៀល។

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាម និងអ្នកសម្របសម្រួលជាក្រុមដែលមានគ្នាយ៉ាងច្រើន ១០ នាក់

**សម្ភារៈ** :

### ការណែនាំ

- ពន្យល់ថាល្បែងនេះ នឹងបង្ហាញថាតើអារម្មណ៍រត់លឿនយ៉ាងណានៅក្នុងបន្ទប់។
- ធ្វើការណែនាំថាយើងនឹងប្រើ ការម៉ិចភ្នែកដាក់ ដើម្បីបញ្ជូនអារម្មណ៍។
- បើអ្នកបានទទួលសញ្ញាម៉ិចភ្នែកពីនរណាម្នាក់ ពេលនោះអ្នកនឹងក្លាយទៅជាមហាមិត្តសម្រាប់អ្នកដទៃទៀត។ ប៉ុន្តែអ្នកត្រូវបានទទួលការម៉ិចភ្នែកដាក់ពីនរណាម្នាក់សិន នៅមុនពេលអ្នកអាចចាប់ផ្ដើមម៉ិចភ្នែកដាក់អ្នកដទៃ។
- ប្រសិនបើគេម៉ិចភ្នែកដាក់អ្នក អ្នកអាចញាក់ភ្នែកដាក់អ្នកផ្សេងទៀតបានតែ ៣ នាក់ទេ។
- ដំបូងត្រូវឈរជារង្វង់មូល។
- សូមបិទភ្នែកទាំងអស់គ្នា រហូតទាល់តែខ្ញុំនិយាយថាបើកភ្នែក នោះទើបអ្នកអាចបើកភ្នែកបាន។
- បើសិនជាខ្ញុំទះស្មារបស់នរណាម្នាក់ អ្នកនោះនឹងជាអ្នកដែលអនុញ្ញាតិឱ្យម៉ិចភ្នែកដាក់ មនុស្ស ៣ នាក់ ផ្សេងទៀត។
- សូមចាំថាមិនឱ្យលើសពី ៣ ដងទេ។ សូមបិទភ្នែករបស់អ្នក។
- ពេលនេះអ្នកសម្របសម្រួលចាប់ផ្ដើមទះស្មានរណាម្នាក់ដើម្បីចាប់ផ្ដើមការម៉ិចភ្នែក។
- សុំឱ្យសិក្ខាកាមបើកភ្នែកឡើងវិញ។
- ចាប់ផ្ដើមដើរពាសពេញបន្ទប់ ជួបជាមួយអ្នកផ្សេងៗទៀត និយាយលេងទៅរកពួកគេក្នុងរបៀបធម្មតា។ នៅពេលគេម៉ិចភ្នែកដាក់អ្នក រក្សាការជជែកដដែល ប៉ុន្តែជជែកបែបរាក់ទាក់បំផុត។
- សុំឱ្យពួកគាត់ប្រើពាក្យថា "អូ អូ ថ្ងៃនេះអ្នកមើលទៅស្រស់ស្អាតណាស់" ឬ "កាលពីម្សិលមិញ អ្នកធ្វើការបង្ហាញបានល្អណាស់"។
- សូមរំលឹកថាសិក្ខាកាមអាចម៉ិចភ្នែកដាក់អ្នកផ្សេងបានចំនួន ៣ នាក់។
- ៨ នាទីក្រោយ ការលេងល្បែងត្រូវបានបញ្ចប់ ហើយសាកសួរសិក្ខាកាម ថាតើគាត់មានអារម្មណ៍យ៉ាងណា។

- ពន្យល់ទៅពួកគាត់ ការប្រព្រឹត្តរបស់អ្នកផ្សេងទៀត គឺមានឥទ្ធិពលមកលើអារម្មណ៍របស់អ្នក។ ដូចគ្នានេះដែរ នៅពេលដែលយើងមានអារម្មណ៍មិនសូវល្អ អ្នកផ្សេងទៀតធ្វើការកត់សម្គាល់ ហើយគាត់មានអារម្មណ៍ដូចនេះដែរ។
- នៅពេលធ្វើការផ្តល់ប្រឹក្សាត្រូវចង់ចាំថា អ្នកត្រូវរួសរាយ រាក់ទាក់ ញញឹម និងស្តាប់អ្នកដែលទទួលការផ្តល់ប្រឹក្សាពីអ្នក។

## ៧.៤ ពិភាក្សាលើការធ្វើកម្មសិក្សាអនុវត្តន៍ (៦០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាប្រកបដោយទំនុកចិត្ត។

**វិធីសាស្ត្រ** : ព្យុះគំនិត និងការពិភាក្សា

**អ្នកណា** : សិក្ខាកាមម្នាក់ៗ ឬ ជាគូ

**សម្ភារៈ** : សម្ភារៈជំនួយការងារ ស្លាយទី ១៨៩-១៩០

### ការណែនាំ

- រៀបចំក្រដាសផ្ទាំងធំមួយ ដើម្បីកត់ត្រានូវអ្វីដែលខុសគ្នាតាមក្រុមនិមួយៗ។
- ចែកក្រដាសផ្ទាំងធំជាពីរផ្នែក នៅផ្នែកខាងឆ្វេង គឺសំរាប់បញ្ហា ហើយនៅផ្នែកខាងស្តាំ គឺដំណោះស្រាយ។
- បង្ហាញពីគោលបំណង និងគោលបំណងជំនាញសំរាប់ថ្ងៃទី ៧។
- ប្រាប់សិក្ខាកាមឱ្យបង្កើតជាក្រុមដែលមានសមាជិក ៥ នាក់។
- ផ្តល់ឱ្យពួកគាត់នូវក្រដាសផ្ទាំងធំ។
- ហើយផ្តល់ឱ្យទៅក្រុមនិមួយៗនូវប៊ិចហ្វឺតពណ៌មួយ ដែលក្រុមនិមួយៗមានពណ៌ខុសៗគ្នា (ពណ៌តាមក្រុម)។
- ពួកគាត់អនុញ្ញាតិឱ្យបំពេញតែផ្នែកខាងឆ្វេងនៃក្រដាសផ្ទាំងធំតែប៉ុណ្ណោះ គឺបំពេញតែបញ្ហា មិនឱ្យបំពេញផ្នែកដំណោះស្រាយទេ។
- សុំឱ្យសិក្ខាកាមបញ្ចប់ការងារនេះក្នុងរយៈពេល ១០ នាទី។
- ពន្យល់ទៅដល់សិក្ខាកាមថា រាល់បញ្ហាលំបាកដែលបានលើកឡើងនៅលើក្រដាសផ្ទាំងធំនេះ នឹងត្រូវប្រគល់ទៅឱ្យក្រុមមួយផ្សេងទៀតដែលនៅខាងស្តាំដៃនៃក្រុម។
- ក្រុមនិមួយៗត្រូវផ្តល់ដំណោះស្រាយសំរាប់រាល់បញ្ហាលំបាកទាំងឡាយដែលបានលើកឡើង។
- បន្ទាប់ពីបាន ៥ នាទី ក្រដាសផ្ទាំងធំនេះត្រូវប្រគល់ទៅឱ្យក្រុមមួយទៀតដែលនៅបន្ទាប់ខាងស្តាំដៃ។
- ការប្រគល់នេះគឺធ្វើឡើងរាល់ ៥ នាទីម្តង។
- បន្ទាប់មកក្រដាសផ្ទាំងធំទាំងនោះ នឹងត្រូវបានប្រគល់ត្រលប់ទៅឱ្យក្រុមដើមវិញ។
- ក្រុមនិមួយៗបានទទួលក្រដាសផ្ទាំងធំរបស់ខ្លួនវិញ ដែលមានកត់ត្រានូវរាល់បញ្ហាលំបាក និងដំណោះស្រាយរបស់ក្រុម ៤ ទៀត ដែលបានផ្តល់ឱ្យ ហើយដែលមានពណ៌ផ្សេងៗគ្នាទៅតាមក្រុម។
- ស្នើសុំឱ្យក្រុមទាំងអស់ កំណត់រកដំណោះស្រាយផ្សេងៗដែលពួកគាត់គិតថា ជាដំណោះស្រាយដ៏ប្រសើរបំផុតសំរាប់បញ្ហាលំបាកទាំងនោះ។

- ឱ្យពួកគាត់ធ្វើការគូសសម្គាល់ដំណោះស្រាយដ៏ល្អបំផុតនោះ ក្នុងរយៈពេល ៥ នាទី ។
- ក្នុងរយៈពេល ២៥ នាទីបន្ទាប់មកទៀត គឺការឡើងបង្ហាញតាមក្រុមនិមួយៗ : ៥ នាទី សំរាប់មួយក្រុម ។
- ប្រាប់ឱ្យក្រុមនិមួយៗបិទផ្ទាំងក្រដាសនេះនៅជញ្ជាំង ។
- អញ្ជើញសិក្ខាកាមទាំងអស់ឱ្យមើលក្រដាសផ្ទាំងធំទាំងនេះនៅពេលសម្រាក ។

## កាលវិភាគ

| ការកំណត់រកបញ្ហា | នាទី |
|---|---|
| សេចក្ដីណែនាំ | ៥ |
| ស្វែងរកបញ្ហា | ១០ |
| ស្វែងរកដំណោះស្រាយ ជុំទី ១ (៥ នាទី ម្ដង) | ១៥ |
| ស្វែងរកដំណោះស្រាយណាដែលល្អបំផុត | ៥ |
| ការឡើងបង្ហាញ | ២៥ |
| **សរុប** | **៦០** |

## ៧.៥ ការរៀបចំសំរាប់ការជួបពិនិត្យផ្ទៃទំពេលសម្រាល និងក្រោយសម្រាល (២០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចធ្វើការផ្ដល់ប្រឹក្សាក្នុងអំឡុងពេល ការជួបពិនិត្យផ្ទៃទំ ក្រោយសម្រាល

**វិធីសាស្ត្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយសំរាប់បង្ហាញ ទី ១៩១-១៩៧
សម្ភារៈជំនួយការងារ

### ការណែនាំ

- ពន្យល់ប្រាប់សិក្ខាកាមថានៅព្រឹកស្អែកពួកគាត់នឹងត្រូវចុះទៅធ្វើកម្មសិក្សាអនុវត្តន៍រយៈពេលមួយព្រឹក ។
- ធ្វើការរំលឹកសិក្ខាកាមថា ការអនុវត្តន៍ គឺផ្ដោតតែទៅលើការពិនិត្យដល់ស្ត្រីក្រោយសម្រាល ដែលបានចូលមកក្នុងមណ្ឌលសុខភាព ។ ហើយបើសំណាងល្អនោះ នឹងមានការចូលមកសម្រាលមួយ ។
- ពន្យល់ប្រាប់ពួកគាត់ថា យើងនឹងប្រើប្រាស់សម្ភារៈជំនួយការងារជាឯកសារ : "ពេលសម្រាល" និង "ក្រោយសម្រាល"។
- ធ្វើការបង្ហាញស្លាយទី ១៩១-១៩៧ ដើម្បីពន្យល់ពីរបៀបប្រើប្រាស់សម្ភារៈជំនួយការងារ ។

- ធ្វើការពន្យល់អំពីបញ្ជីផ្ទៀងផ្ទាត់ រូបភាពដែលពួកគាត់អាចយកមកប្រើប្រាស់សំរាប់ការផ្តល់ប្រឹក្សា និងអំពីតារាងព្យាបាល ។

## ៧.៦ ការធ្វើបង្ហាញជាគំរូ ការជួបពិនិត្យថៃទាំពេលសម្រាល (១៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចចងចាំជំនាញអនុវត្តដ៏ល្អបំផុត ក្នុងការជួបពិនិត្យថៃទាំពេលសម្រាលជាគំរូមួយ ។

**វិធីសាស្ត្រ :** ការធ្វើបង្ហាញជាគំរូ និងសំណួរចម្លើយ

**អ្នកណា :** អ្នកសម្របសម្រួល ២ រូប

**សម្ភារៈ :** សម្ភារៈជំនួយការងារ និងបញ្ជីផ្ទៀងផ្ទាត់

### ការណែនាំ

- ជាអ្នកសម្របសម្រួល អ្នកធ្វើបង្ហាញជាគំរូ ការជួបពិនិត្យថៃទាំពេលសម្រាលនៅមណ្ឌលសុខភាព នៅមុខសិក្ខាកាម ។
- ធ្វើអ្វីៗទាំងអស់ដោយផ្អែកទៅតាមសៀវភៅ ។ វាគួរតែជាគំរូដែលល្អឥតខ្ចោះ នៃអ្វីដែលយើងចង់ឱ្យសិក្ខាកាមធ្វើតាមក្នុងពេលចុះទៅអនុវត្តនៅតាមមូលដ្ឋាន និងនៅមណ្ឌលសុខភាព ។
- សុំឱ្យសិក្ខាកាមប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ក្នុងអំឡុងពេលការសំដែងតួ ។
- សុំឱ្យសិក្ខាកាមផ្តល់ព័ត៌មានត្រលប់នៅពេលដែលអ្នកបានបញ្ចប់ការសំដែង ។ ពិភាក្សាព័ត៌មានត្រលប់នៅក្នុងក្រុមធំ ។

**សម្រាក (២០ នាទី)**

## ៧.៧ ការជួបពិនិត្យថៃទាំពេលសម្រាល– ការងារជាក្រុម (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាដល់ស្ត្រីក្នុងអំឡុងពេល ការជួបពិនិត្យថៃទាំពេលសម្រាល ។

**វិធីសាស្ត្រ :** ល្បែងដើរតួ

**អ្នកណា :** សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៤នាក់

**សម្ភារៈ :** សម្ភារៈជំនួយការងារ

### សន្និទានភាព :

នៅក្នុងពេលសំដែងល្បែងដើរតួ សិក្ខាកាមនឹងរៀនរបៀបផ្តល់សេវាពិនិត្យថៃទាំពេលសម្រាល ។ ល្បែងដើរតួនេះ គឺដើម្បីពង្រឹងការប្រស្រ័យទាក់ទង និងជំនាញនៃការផ្តល់ប្រឹក្សារបស់សិក្ខាកាម ។ សូមមើលផ្នែកស្តីពីជំនាញប្រស្រ័យទាក់ទង និងបញ្ជីផ្ទៀងផ្ទាត់សំរាប់ការផ្តល់ការប្រឹក្សាដែលមាននៅក្នុងសៀវភៅសិក្ខាកាម នៅមុនពេលសម្តែងនូវល្បែងដើរតួនេះ ។

## ការណែនាំ

- បង្កើតជាក្រុមដែលមានគ្នា ៤ នាក់ ។
- ក្រុមនិមួយៗ នឹងដើរតួ ២ រឿង ។
- ល្បែងដើរតួនិមួយៗ ត្រូវសំដែងដោយមានសិក្ខាកាមម្នាក់ ដើរតួជាបុគ្គលិកមណ្ឌលសុខភាព ហើយសិក្ខាកាមម្នាក់ទៀតដើរតួជាស្ត្រីទើបសម្រាលកូនហើយ ។ ចំណែកឯសិក្ខាកាម ២ នាក់ទៀត ជាអ្នកសង្កេតការណ៍ ។
- ចាត់តាំងតួនាទី សមាជិកក្រុម ។
- បន្ទាប់ពីការរៀបចំបាន ៥ នាទីមក ល្បែងដើរតួត្រូវចាប់ផ្តើម ។
- បន្ទាប់ពីលេងបាន ១០ នាទី ល្បែងដើរតួត្រូវបានបញ្ចប់ ហើយក្រុមតូចត្រូវធ្វើការពិភាក្សាពីល្បែងដើរតួនោះ ។
- បន្ទាប់មកល្បែងដើរតួនេះត្រូវលេងជាថ្មីម្តងទៀត ដោយឥឡូវនេះគឺអ្នកសង្កេតការណ៍ជាអ្នកសំដែង ។
- ចំណែកសមាជិក ២ នាក់ទៀត គឺធ្វើជាអ្នកសង្កេតការណ៍ម្តង ។

## តារាងកាលវិភាគ:

| ល្បែងដើរតួ | នាទី |
|---|---|
| ការណែនាំការសំដែងដល់សិក្ខាកាម | ៥ |
| ការសម្តែងនៅជុំទី១ | ១០ |
| ការធ្វើការពិភាក្សា | ៥ |
| ការសម្តែងម្តងទៀត( តួសំដែងផ្សេង) | ១០ |
| **សរុប** | **៣០** |

## ៧.៨ ការធ្វើបង្ហាញជាគំរូ ការជួបពិនិត្យថែទាំក្រោយសម្រាល (១៥ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចចងចាំជំនាញអនុវត្តដ៏ល្អបំផុត ក្នុងការជួបពិនិត្យថែទាំក្រោយសម្រាល ជាគំរូមួយ។

**វិធីសាស្ត្រ** : ការធ្វើបង្ហាញ និងសំណួរចម្លើយ

**អ្នកណា** : អ្នកសម្របសម្រួល ២ នាក់

**សម្ភារៈ** : សម្ភារៈជំនួយការងារ និងបញ្ជីផ្ទៀងផ្ទាត់

### ការណែនាំ

- ចំណាយពេល ១០ នាទី ដើម្បីបង្ហាញជាគំរូ ការជួបពិនិត្យថែទាំក្រោយសម្រាលនៅមុខសិក្ខាកាម។
- ធ្វើអ្វីៗទាំងអស់ដោយផ្អែកទៅតាមសៀវភៅ។ វាគួរតែជាគំរូដែលល្អឥតខ្ចោះ នៃអ្វីដែលយើងចង់ឱ្យសិក្ខាកាមធ្វើតាមក្នុងពេលចុះទៅអនុវត្តនៅតាមមូលដ្ឋាន និងនៅមណ្ឌលសុខភាព។
- សុំឱ្យសិក្ខាកាមប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ក្នុងអំឡុងពេលការសំដែងតួ។
- សុំឱ្យសិក្ខាកាមផ្តល់ព័ត៌មានត្រលប់នៅពេលដែលអ្នកបានបញ្ចប់ការសំដែង។
- ពិភាក្សាព័ត៌មានត្រលប់នៅក្នុងក្រុមធំ។

## ៧.៩ ការជួបពិនិត្យថែទាំក្រោយសម្រាល–ការងារជាក្រុម (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាដល់ស្ត្រីក្នុងអំឡុងពេល ការជួបពិនិត្យថែទាំក្រោយសម្រាល។

**វិធីសាស្ត្រ** : ល្បែងដើរតួ

**អ្នកណា** : សិក្ខាកាមជាក្រុមដែលមានគ្នា យ៉ាងច្រើន ៤ នាក់

**សម្ភារៈ** : សម្ភារៈជំនួយការងារ "**ការជួបពិនិត្យថែទាំក្រោយសម្រាល**"

### សន្និទានភាព

នៅក្នុងពេលសម្តែងល្បែងដើរតួ សិក្ខាកាមនឹងរៀនរបៀបផ្តល់សេវាក្រោយសម្រាល។ ល្បែងដើរតួនេះគឺដើម្បីពង្រឹងការប្រស្រ័យទាក់ទង និងជំនាញនៃការផ្តល់ប្រឹក្សារបស់សិក្ខាកាម។ សូមមើលផ្នែកស្តីពីជំនាញប្រស្រ័យទាក់ទង និងបញ្ជីផ្ទៀងផ្ទាត់សំរាប់ការផ្តល់ការប្រឹក្សាដែលមាននៅក្នុងសៀវភៅសិក្ខាកាម នៅមុនពេលសម្តែងល្បែងដើរតួនេះ។

## ការណែនាំ :

- បង្កើតជាក្រុមដែលមានគ្នា ៤ នាក់ ។
- ក្រុមនិមួយៗ នឹងដើរតួ ២ រឿង ។
- ល្បែងដើរតួនិមួយៗ ត្រូវសំដែងដោយមានសិក្ខាកាមម្នាក់ ដើរតួជាបុគ្គលិកមណ្ឌលសុខភាព ហើយសិក្ខាកាមម្នាក់ទៀតដើរតួជាស្ត្រីដែលមានកូនតូច ។ ចំណែកឯសិក្ខាកាម ២ នាក់ទៀតជាអ្នកសង្កេតការណ៍ ។
- ចាត់តាំងតួនាទី សមាជិកក្រុម ។
- បន្ទាប់ពីការរៀបចំបាន ៥ នាទីមក ល្បែងដើរតួត្រូវចាប់ផ្តើម ។
- បន្ទាប់ពីលេងបាន ១០ នាទី ល្បែងដើរតួត្រូវបានបញ្ចប់ ហើយក្រុមតូចត្រូវធ្វើការពិភាក្សាពីល្បែងដើរតួនេះ ។ បន្ទាប់មក ល្បែងដើរតួនេះត្រូវលេងជាថ្មីម្តងទៀត ឥឡូវនេះគឺអ្នកសង្កេតការណ៍ជាអ្នកសំដែង ។ ចំណែកសមាជិក ២ នាក់ទៀត គឺធ្វើជាអ្នកសង្កេតការណ៍ម្តង ។

## កាលវិភាគ

| ល្បែងដើរតួ | នាទី |
|---|---|
| ការណែនាំការសំដែងដល់សិក្ខាកាម | ៥ |
| សម្តែងនៅលើទី១ | ១០ |
| ការពិភាក្សា | ៥ |
| ការសម្តែងម្តងទៀត( តួសំដែងផ្សេង) | ១០ |
| **សរុប** | **៣០** |

## ៧.១០ សេចក្ដីសន្និដ្ឋាននៅពេលរសៀល (១០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តអំពីចំណេះដឹង និងជំនាញដែលបានសិក្សានៅពេលរសៀលនេះ។

**វិធីសាស្ត្រ :** សង្ខេប

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ក្រដាសផ្ទាំងធំដែលមានរូបនាឡិកាដែលបង្ហាញពេលម៉ោង និងមធ្យោបាយទៅកាន់មណ្ឌលសុខភាព។

### ការណែនាំ :

សង្ខេបមេរៀនសិក្សាពេលរសៀលដោយផ្ដោតទៅលើអ្វីដែលបានរៀនៈ

- បទពិសោធន៍មេរៀនដែលបានរៀនពី កម្មសិក្សាអនុវត្តន៍ស្ដីពីការជួបពិនិត្យផ្ទៃទាំមុនពេលសម្រាល
- របៀបផ្ដល់ប្រឹក្សាក្នុងអំឡុងពេលការជួបពិនិត្យផ្ទៃទាំពេលសម្រាល
- របៀបផ្ដល់ប្រឹក្សាក្នុងអំឡុងពេលការជួបពិនិត្យផ្ទៃទាំក្រោយសម្រាល

បង្ហាញសិក្ខាកាមពីក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងពេលវេលាដែលត្រូវទៅដល់មណ្ឌលសុខភាពនៅថ្ងៃស្អែក និងពីមធ្យោបាយទៅកាន់ទីនោះ។

# ថ្ងៃទី ៨ – កម្មសិក្សាអនុវត្តន៍ ការពិនិត្យថែទាំក្រោយសម្រាល/ការផ្តល់ថ្នាំបង្ការ និងការពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ

## គោលបំណងថ្ងៃទី ៨ :

១ ដើម្បីអនុវត្តន៍ជំនាញការផ្តល់ប្រឹក្សា ដល់ស្ត្រីពេលសម្រាល និងក្រោយសម្រាល

២ ដើម្បីបង្រៀនពីសកម្មភាពការផ្តល់ថ្នាំបង្ការ និងការពិនិត្យថែទាំកុមារដល់សិក្ខាកាម

៣ ដើម្បីបណ្តុះបណ្តាលការអនុវត្តន៍សកម្មភាពការផ្តល់ថ្នាំបង្ការ និងការពិនិត្យថែទាំកុមារ (កម្មសិក្សាអនុវត្តន៍)

## គោលបំណងជំនាញសំរាប់សិក្ខាកាមថ្ងៃទី ៨

នៅចុងបញ្ចប់នៃមេរៀនសិក្សាថ្ងៃនេះ សិក្ខាកាមអាចៈ

១ ផ្តល់ប្រឹក្សាដល់ស្ត្រីគ្រប់គ្រាន់ ស្តីពីអាហារូបត្ថម្ភក្នុងអំឡុងពេលការជួបពិនិត្យថែទាំពេលសម្រាល និងក្រោយសម្រាលដោយប្រើប្រាស់សម្ភារៈជំនួយការងារ

២ ប្រើប្រាស់សម្ភារៈជំនួយការងារស្តីពី ការជួបពិនិត្យថែទាំកុមារ និងការផ្តល់ថ្នាំបង្ការ

# កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨:០០ | ៣០ | ៨.១ | ណែនាំសិក្ខាកាមដល់មណ្ឌលសុខភាព និងណែនាំពីការធ្វើកម្មសិក្សា<br>ការណែនាំ | ទាំងអស់គ្នា |
| ៨:៣០ | ១៨០ | ៨.២ | ការជួបពិនិត្យថែទាំក្រោយសម្រាល<br>ការធ្វើកម្មសិក្សាអនុវត្តន៍ | ក្រុម |
| **១១:៣០** | **១២០** | | **សម្រាក** | |
| ១៣:៣០ | ១០ | ៨.៣ | រឿងចេញមកពីក្រុម<br>ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន និងការលើកទឹកចិត្ត | ទាំងអស់គ្នា |
| ១៣:៤០ | ៦០ | ៨.៤ | ពិភាក្សាកម្មសិក្សាអនុវត្តន៍<br>ព្យុះគំនិត និងពិភាក្សាស្តីពីកម្មសិក្សាអនុវត្តន៍កាលពីព្រឹក | ម្នាក់ៗ ឬ ជាគូ |
| ១៤:៤០ | ២០ | ៨.៥ | ការផ្តល់ថ្នាំបង្ការ និងការជួបពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ<br>បាឋកថា | អ្នកសម្របសម្រួល |
| ១៥:០០ | ១៥ | ៨.៦ | ការធ្វើបង្ហាញជាគំរូ ការជួបការផ្តល់ថ្នាំបង្ការ<br>ការធ្វើបង្ហាញ និងសំណួរចម្លើយ | អ្នកសម្របសម្រួល |
| **១៥:១៥** | **២០** | | **សម្រាក** | |
| ១៥:៣៥ | ៣០ | ៨.៧ | ការជួបការផ្តល់ថ្នាំបង្ការ<br>ល្បែងដើរតួ | ក្រុម |
| ១៦:០៥ | ១៥ | ៨.៨ | ការធ្វើបង្ហាញជាគំរូ ការជួបពិនិត្យកុមារ<br>ការធ្វើបង្ហាញ និងសំណួរចម្លើយ | អ្នកសម្របសម្រួល |
| ១៦:២០ | ៣០ | ៨.៩ | ការជួបពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ<br>ល្បែងដើរតួ | ក្រុម |
| ១៦:៥០ | ១០ | ៨.១០ | សេចក្តីសន្និដ្ឋានថ្ងៃរសៀល<br>សង្ខេប | អ្នកសម្របសម្រួល |
| **១៧:០០** | | | **ចប់** | |

## សម្ភារៈដែលត្រូវការ

- ស្លាយទី ១៩៨-២០៦
- សម្ភារៈជំនួយការងារ
- សៀវភៅសុខភាពមាតា
- ប័ណ្ណសុខភាពកុមារ
- បញ្ជីផ្ទៀងផ្ទាត់

# សកម្មភាពថ្ងៃទី ៨

## នៅមណ្ឌលសុខភាព

### ៨.១ ណែនាំសិក្ខាកាមដល់មណ្ឌលសុខភាព និងការធ្វើកម្មសិក្សាអនុវត្តន៍ (៣០នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេច សំរាប់កម្មសិក្សារអនុវត្តស្តីពីការជួបពិនិត្យថៃទាំក្រោយពេលសម្រាល

**វិធីសាស្ត្រ** : ការណែនាំឱ្យស្គាល់

**អ្នកណា** : សិក្ខាកាមទាំងអស់ អ្នកសម្របសម្រួលម្នាក់សម្របសម្រួលក្រុមដែលមានសមាជិក ៨ នាក់

**សម្ភារៈ** : សម្ភារៈជំនួយការងារ សៀវភៅសុខភាពមាតា ប័ណ្ណសុខភាពកុមារ និងបញ្ជីផ្ទៀងផ្ទាត់

### ការណែនាំ

- ពន្យល់ពីអត្ថន័យនៃការធ្វើកម្មសិក្សាអនុវត្តន៍ និងអំពីពេលវេលាតាមកាលវិភាគ។
- ប្រាប់សិក្ខាកាមថា គឺមានតែសិក្ខាកាមម្នាក់គត់ដែលត្រូវផ្តល់ប្រឹក្សាដល់ស្ត្រីម្នាក់ដែលបានចូលមកពិនិត្យសុខភាព ចំណែកអ្នកឯទៀត គឺជាអ្នកសង្កេតការណ៍។
- នៅក្រោយការពិនិត្យអតិថិជននិមួយៗរួច ត្រូវធ្វើការប្រៀបធៀបបញ្ជីផ្ទៀងផ្ទាត់ និងពិភាក្សាលើការផ្តល់ប្រឹក្សា។
- សំរាប់ស្ត្រីចូលមកពិនិត្យបន្ទាប់ទៀត សិក្ខាកាមម្នាក់ផ្សេងទៀតអាចធ្វើការផ្តល់ប្រឹក្សា។
- ប្រើប្រាស់សម្ភារៈជំនួយការងារសំរាប់ការផ្តល់ប្រឹក្សាដល់ស្ត្រី។
- បញ្ជាក់ពីពេលម៉ោងដែលត្រូវសម្រាក។

## ៨.២ កម្មសិក្សាអនុវត្តន៍ (រហូតដល់ម៉ោង ១១:៣០)

សម្រាក (១២០ នាទី)

## នៅក្នុងថ្នាក់

## ៨.៣ រឿងចេញពីក្រុម (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីពេលរសៀល។

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាម និងអ្នកសម្របសម្រួលជាក្រុមដែលមានគ្នាយ៉ាងច្រើន ១០ នាក់

**សម្ភារៈ** :

### ការណែនាំ

- ប្រាប់ទៅដល់សិក្ខាកាមថា យើងនឹងសំដែងរឿងមួយជាមួយគ្នា។
- អញ្ជើញសិក្ខាកាមទាំងអស់ឱ្យឈរជារង្វង់មូល។
- ពន្យល់ប្រាប់សិក្ខាកាមថា សិក្ខាកាមម្នាក់អាចនិយាយបានតែមួយពាក្យទេក្នុងមួយដង។
- ការនិយាយរឿងគឺរត់តាមលំដាប់លំដោយរង្វង់នៃក្រុមដែលឈរនោះ។
- ប្រាប់ឱ្យសិក្ខាកាម ធ្វើដូចធម្មតា។
- សុំឱ្យសិក្ខាកាមសំដែងចេញនូវពាក្យដែលពួកគាត់បានប្រើ(ឧទាហរណ៍បើសិនជារងារ ត្រូវបញ្ចេញសម្លេងញ័រៗ)
- រំលឹកសិក្ខាកាមធ្វើឱ្យលឿន ព្យាយាមនិយាយរឿងនេះអោយបានលឿនតាមដែលអាចធ្វើទៅបាន។
- ចាប់ផ្តើមរឿងដោយពាក្យ " កាលពី,,,"
- បញ្ចប់ការលេងល្បែងនេះបន្ទាប់ពីលេងបាន ១០ នាទី ហើយធ្វើការពន្យល់ដល់សិក្ខាកាមថា សារគួរត្រូវបានផ្តល់ឱ្យបានលឿន និងមានភាពរាក់ទាក់។ ភ្នែកសម្លឹងទៅរកអ្នកដែលយើងនិយាយជាមួយអាចជួយបានយ៉ាងច្រើន ព្រមទាំងញញឹមផង។

## ៨.៤ ពិភាក្សាលើការធ្វើកម្មសិក្សាអនុវត្តន៍ (៦០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្ដល់ប្រឹក្សាប្រកបដោយទំនុកចិត្ត ។

**វិធីសាស្ត្រ** : ព្យុះគំនិត និងការពិភាក្សា

**អ្នកណា** : សិក្ខាកាមម្នាក់ៗ និងជាគូ

**សម្ភារៈ** : សម្ភារៈជំនួយការងារ ស្លាយទី ១៩៨-១៩៩

### ការណែនាំ

- រៀបចំក្រដាសផ្ទាំងធំមួយ ដើម្បីកត់ត្រានូវអ្វីដែលខុសគ្នាតាមក្រុមនិមួយៗ ។
- ចែកក្រដាសផ្ទាំងធំជាពីរផ្នែក នៅផ្នែកខាងឆ្វេងគឺសំរាប់បញ្ហា ហើយនៅផ្នែកខាងស្ដាំគឺដំណោះស្រាយ ។
- បង្ហាញស្លាយទី ១៩៨-១៩៩ ពីគោលបំណង និងគោលបំណងជំនាញ ។
- ប្រាប់សិក្ខាកាមឱ្យបង្កើតជាក្រុមដែលមានសមាជិក ៥ នាក់ ។
- ផ្ដល់ឱ្យពួកគាត់នូវក្រដាសផ្ទាំងធំ ។
- ហើយផ្ដល់ឱ្យទៅក្រុមនិមួយៗនូវប៊ិចហ្វឺតពណ៌មួយ ដែលជាវិធីមួយដែលក្រុមនិមួយៗមានពណ៌ខុសៗគ្នា (ពណ៌តាមក្រុម) ។
- ពួកគាត់អនុញ្ញាតិឱ្យបំពេញតែផ្នែកខាងឆ្វេងនៃក្រដាសផ្ទាំងធំតែប៉ុណ្ណោះ គឺបំពេញតែបញ្ហា មិនឱ្យបំពេញផ្នែកដំណោះស្រាយទេ ។
- សុំឱ្យសិក្ខាកាមបញ្ចប់ការងារនេះក្នុងរយៈពេល ១០ នាទី ។
- ពន្យល់ទៅដល់សិក្ខាកាមថារាល់បញ្ហាលំបាកដែលបានលើកឡើងនៅលើក្រដាសផ្ទាំងធំនេះ នឹងត្រូវប្រគល់ទៅឱ្យក្រុមមួយផ្សេងទៀតដែលនៅខាងស្ដាំដៃនៃក្រុម ។
- ក្រុមនិមួយៗត្រូវផ្ដល់ដំណោះស្រាយសំរាប់រាល់បញ្ហាលំបាកទាំងឡាយដែលបានលើកឡើង ។
- បន្ទាប់ពីបាន ៥ នាទី ក្រដាសផ្ទាំងធំនេះត្រូវប្រគល់ទៅឱ្យក្រុមមួយផ្សេងទៀតដែលនៅបន្ទាប់ខាងស្ដាំដៃ ។
- ប្រគល់នេះគឺធ្វើឡើងរាល់ ៥ នាទីម្ដង ។
- បន្ទាប់មក ក្រដាសផ្ទាំងធំទាំងនោះ នឹងត្រូវបានប្រគល់ត្រលប់ទៅឱ្យក្រុមដើមវិញ ។
- ក្រុមនិមួយៗនឹងបានទទួលក្រដាសផ្ទាំងធំរបស់ខ្លួនវិញ ដែលមានកត់ត្រានូវរាល់បញ្ហាលំបាក និងដំណោះស្រាយរបស់ក្រុម ៤ ទៀតដែលបានផ្ដល់ឱ្យ ហើយដែលមានពណ៌ផ្សេងៗគ្នាទៅតាមក្រុម ។
- ស្នើសុំឱ្យក្រុមទាំងអស់ កំណត់រកដំណោះស្រាយផ្សេងៗដែលពួកគាត់គិតថាជាដំណោះស្រាយដ៏ប្រសើរបំផុតសំរាប់បញ្ហាលំបាកនិមួយៗនោះ ។
- ឱ្យពួកគាត់ធ្វើការគូសសម្គាល់ ដំណោះស្រាយដ៏ប្រសើបំផុតនោះ ក្នុងរយៈពេល ៥ នាទី ។
- ក្នុងរយៈពេល ២៥ នាទីបន្ទាប់មកទៀត គឺសំរាប់ការឡើងបង្ហាញតាមក្រុមនិមួយៗ : ៥ នាទី សំរាប់មួយក្រុម ។
- ប្រាប់ឱ្យក្រុមនិមួយៗបិទផ្ទាំងក្រដាសនេះនៅជញ្ជាំង ។
- អញ្ជើញសិក្ខាកាមទាំងអស់ឱ្យមើលក្រដាសផ្ទាំងធំទាំងនេះ នៅពេលសម្រាក ។

## កាលវិភាគ

| ការកំណត់រកបញ្ហា | នាទី |
|---|---|
| ការណែនាំ | ៥ |
| ការកំណត់រកបញ្ហា | ១០ |
| ការកំណត់រកដំណោះស្រាយ ជុំទី ១ (៥ នាទីម្តង) | ១៥ |
| ការកំណត់រកដំណោះស្រាយដែលប្រសើរបំផុត | ៥ |
| ការឡើងបង្ហាញ | ២៥ |
| **សរុប** | **៦០** |

## ៨.៥ ការរៀបចំសំរាប់ការផ្តល់ថ្នាំបង្ការ និងការជួបពិនិត្យកុមារ (២០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាក្នុងអំឡុងពេលការផ្តល់ថ្នាំបង្ការ និងការជួបពិនិត្យថែទាំកុមារ

**វិធីសាស្ត្រ :** បាឋកថា

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ស្លាយទី ២០០-២០៦
សម្ភារៈជំនួយការងារ

### ការណែនាំ

- ពន្យល់សិក្ខាកាមថាថ្ងៃស្អែក ពួកគាត់នឹងទៅធ្វើការអនុវត្តន៍ផ្ទាល់នៅមូលដ្ឋាននៅពេលព្រឹក ។ បញ្ជាក់ប្រាប់គាត់ថា យើងផ្តោតតែទៅលើស្ត្រីដែលមកមណ្ឌលសុខភាពជាមួយកូនគាត់តែប៉ុណ្ណោះ។
- រំលឹកសិក្ខាកាមថា ពួកគាត់ត្រូវប្រើសម្ភារៈជំនួយការងារ" ការជួបពិនិត្យថែទាំកុមារឈឺ
- ពន្យល់ពីរបៀបប្រើសម្ភារៈជំនួយការងារ ដោយប្រើប្រាស់ស្លាយ ទី ២០០-២០៦។
- ពន្យល់ពីបញ្ជីផ្ទៀងផ្ទាត់ រូបភាពដែលពួកគាត់អាចប្រើសំរាប់ការផ្តល់ប្រឹក្សា និងតារាងព្យាបាល។

## ៨.៦ ការធ្វើបង្ហាញជាគំរូ ការផ្តល់ថ្នាំបង្ការ (១៥ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចចងចាំជំនាញអនុវត្តជាគំរូដ៏ល្អបំផុត ក្នុងការជួបផ្តល់ថ្នាំបង្ការ ។

**វិធីសាស្ត្រ** : ការធ្វើបង្ហាញជាគំរូ និងសំណួរចម្លើយ

**អ្នកណា** : អ្នកសម្របសម្រួល ២ រូប

**សម្ភារៈ** : សម្ភារៈជំនួយការងារ និងបញ្ជីផ្ទៀងផ្ទាត់

### ការណែនាំ

- ចំណាយពេល ១០ នាទី ធ្វើបង្ហាញជាគំរូក្នុងការជួបផ្តល់ថ្នាំបង្ការនៅមុខសិក្ខាកាម ។
- ធ្វើអ្វីៗទាំងអស់ដោយផ្អែកទៅតាមសៀវភៅ ។ វាគួរតែជាគំរូដែលល្អឥតខ្ចោះ នៃអ្វីដែលយើងចង់ឱ្យសិក្ខាកាមធ្វើតាមក្នុងពេលចុះទៅអនុវត្តកម្មសិក្សា និងនៅពេលចុះផ្តល់សេវាតាមមូលដ្ឋាន ។
- សុំឱ្យសិក្ខាកាមប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ក្នុងអំឡុងពេលការសំដែងតួ ។
- សុំឱ្យសិក្ខាកាមផ្តល់ព័ត៌មានត្រលប់នៅពេលដែលអ្នកបានបញ្ចប់ការសំដែង ។
- ពិភាក្សាព័ត៌មានត្រលប់នៅក្នុងក្រុមធំ ។

**សម្រាក (២០ នាទី)**

## ៨.៧ ការផ្តល់ថ្នាំបង្ការ-ការងារជាក្រុម (៣០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាដល់ស្ត្រីក្នុងអំឡុងពេលសកម្មភាពផ្តល់ថ្នាំបង្ការ ។

**វិធីសាស្ត្រ** : ល្បែងដើរតួ

**អ្នកណា** : សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៤ នាក់

**សម្ភារៈ** : សម្ភារៈជំនួយការងារ

### សន្និទានភាព

នៅក្នុងពេលសំដែងល្បែងដើរតួ សិក្ខាកាមនឹងរៀនរបៀបផ្តល់សេវាអាហារូបត្ថម្ភ ក្នុងអំឡុងពេលសកម្មភាពចុះផ្តល់ថ្នាំបង្ការ ។ ល្បែងដើរតួនេះ គឺដើម្បីពង្រឹងការប្រស្រ័យទាក់ទង និងជំនាញនៃការផ្តល់ប្រឹក្សារបស់សិក្ខាកាម ។ សូមមើលផ្នែកមួយនៃជំនាញប្រស្រ័យទាក់ទង និងបញ្ជីផ្ទៀងផ្ទាត់សំរាប់ការផ្តល់ការប្រឹក្សា ដែលមាននៅក្នុងសៀវភៅ នៅមុនពេលធ្វើការសំដែង ។

### ការណែនាំ

- បង្កើតជាក្រុមដែលមានគ្នា ៤ នាក់។
- ក្រុមនិមួយៗនឹងដើរតួ ២ រឿង។
- ល្បែងដើរតួនិមួយៗ ត្រូវសំដែងដោយមានសិក្ខាកាមម្នាក់ ដើរតួជាបុគ្គលិកមណ្ឌលសុខភាព ហើយសិក្ខាកាមម្នាក់ទៀតដើរតួជាស្ត្រីដែលនាំកូនមកទទួលថ្នាំបង្ការ។ ចំណែកឯសិក្ខាកាម២ នាក់ទៀត ជាអ្នកសង្កេតការណ៍។
- ចាត់តាំងតួនាទី សមាជិកក្រុម។
- បន្ទាប់ពីការរៀបចំបាន ៥ នាទីមក ល្បែងដើរតួត្រូវចាប់ផ្តើម។
- បន្ទាប់ពីលេងបាន ១០ នាទី ល្បែងដើរតួត្រូវបានបញ្ចប់ ហើយក្រុមតូចត្រូវធ្វើការពិភាក្សាពីល្បែងដើរតួនេះ។ បន្ទាប់មក ល្បែងដើរតួនេះត្រូវលេងជាថ្មីម្តងទៀត ឥឡូវនេះគឺអ្នកសង្កេតការណ៍ជាអ្នកសំដែង។ ចំណែកសមាជិក២ នាក់ទៀត គឺធ្វើជាអ្នកសង្កេតការណ៍ម្តង។

### កាលវិភាគ

| ល្បែងដើរតួ | នាទី |
|---|---|
| ការណែនាំការសំដែងដល់សិក្ខាកាម | ៥ |
| ការសំដែងនៅលើកទី១ | ១០ |
| ការពិភាក្សា | ៥ |
| ការសំដែងម្តងទៀត( តួសំដែងផ្សេង) | ១០ |
| **សរុប** | **៣០** |

## ៨.៨ ការធ្វើបង្ហាញជាគំរូ ការជួបពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ (១៥ នាទី)

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចចងចាំជំនាញអនុវត្តជាគំរូដ៏ល្អបំផុត ក្នុងការជួបពិនិត្យថែទាំកុមារ។

**វិធីសាស្ត្រ** : ការធ្វើបង្ហាញជាគំរូ និងសំណួរចម្លើយ

**អ្នកណា** : អ្នកសម្របសម្រួល ២ រូប

**សម្ភារៈ** : សម្ភារៈជំនួយការងារ និងបញ្ជីផ្ទៀងផ្ទាត់

## ការណែនាំ:

- ចំណាយពេល ១០ នាទី ដើម្បីធ្វើជាគំរូក្នុងការផ្ដល់ថ្នាំបង្ការនៅមុខសិក្ខាកាម។ ធ្វើអ្វីៗទាំងអស់ដោយផ្អែកទៅតាមសៀវភៅ។ វាគួរតែជាគំរូដែលល្អឥតខ្ចោះ នៃអ្វីដែលយើងចង់ឱ្យសិក្ខាកាមធ្វើតាមក្នុងពេលចុះទៅអនុវត្តនៅតាមមូលដ្ឋាន និងនៅមណ្ឌលសុខភាព។
- សុំឱ្យសិក្ខាកាមប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ក្នុងអំឡុងពេលការសំដែងតួ។
- សុំឱ្យសិក្ខាកាមផ្ដល់ព័ត៌មានត្រលប់នៅពេលដែលអ្នកបានបញ្ចប់ការសំដែង។
- ពិភាក្សាព័ត៌មានត្រលប់នៅក្នុងក្រុមធំ។

## ៨.៩ ការជួបពិនិត្យផ្ទៃទាំកុមារឈឺ និងកុមារមានសុខភាពល្អ-ការងារជាក្រុម (៣០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្ដល់ប្រឹក្សាដល់ស្ត្រីក្នុងអំឡុងពេលការជួបពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ។

**វិធីសាស្ត្រ :** ល្បែងដើរតួ

**អ្នកណា :** សិក្ខាកាមជាក្រុមដែលមានគ្នាយ៉ាងច្រើន ៤នាក់

**សម្ភារៈ :** សម្ភារៈជំនួយការងារ

## សន្និទានភាព:

នៅក្នុងពេលសំដែង សិក្ខាកាមនឹងរៀនពីរបៀបផ្ដល់សេវាពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ។ ល្បែងដើរតួនេះ គឺដើម្បីពង្រឹងការប្រស្រ័យទាក់ទង និងជំនាញនៃការផ្ដល់ប្រឹក្សារបស់សិក្ខាកាម។ សូមមើលផ្អែកស្ដីពីជំនាញប្រស្រ័យទាក់ទង និងបញ្ជីផ្ទៀងផ្ទាត់សំរាប់ការផ្ដល់ការប្រឹក្សាដែលមាននៅក្នុងសៀវភៅ មុនពេលធ្វើការសម្ដែង។

## ការណែនាំ:

- បង្កើតជាក្រុមដែលមានគ្នា ៤ នាក់។
- ក្រុមនិមួយៗនឹងដើរតួ ២ រឿង។
- ល្បែងដើរតួនិមួយៗ ត្រូវសំដែងដោយមានសិក្ខាកាមម្នាក់ ដើរតួជាបុគ្គលិកមណ្ឌលសុខភាព ហើយសិក្ខាកាមម្នាក់ទៀតដើរតួជាស្ត្រីដែលនាំកូនឈឺមកមណ្ឌលសុខភាព។ ចំណែកឯសិក្ខាកាម ២ នាក់ទៀត ជាអ្នកសង្កេតការណ៍។
- ចាត់តាំងតួនាទី សមាជិកក្រុម។
- បន្ទាប់ពីការរៀបចំបាន ៥ នាទីមក ល្បែងដើរតួត្រូវចាប់ផ្ដើម។
- បន្ទាប់ពីសំដែងបាន ១០ នាទី ល្បែងដើរតួត្រូវបានបញ្ចប់ ហើយក្រុមតូចត្រូវធ្វើការពិភាក្សាពីល្បែងដើរតួនេះ។ បន្ទាប់មក ល្បែងដើរតួនេះត្រូវលេងជាថ្មីម្ដងទៀត ប៉ុន្តែពេលនេះគឺអ្នកសង្កេតការណ៍ជាអ្នកសំដែង។ ចំណែកសមាជិក ២ នាក់ទៀត គឺធ្វើជាអ្នកសង្កេតការណ៍ម្ដង។

## កាលវិភាគ

| ល្បែងដើរតួ | នាទី |
|---|---|
| ការណែនាំការសំដែងដល់សិក្ខាកាម | ៥ |
| ការសំដែងនៅលើកទី១ | ១០ |
| ការពិភាក្សា | ៥ |
| ការសំដែងម្តងទៀត( តួសំដែងផ្សេង) | ១០ |
| **សរុប** | **៣០** |

## ៨.១០ សេចក្តីសន្និដ្ឋាននៅពេលរសៀល (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តអំពីចំណេះដឹង និងជំនាញដែលបានសិក្សានៅពេលរសៀលនេះ ។

**វិធីសាស្ត្រ** : សង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកាដែលបង្ហាញពេលម៉ោង និងពីមធ្យោបាយទៅកាន់មណ្ឌលសុខភាព ។

### ការណែនាំ :

**សង្ខេបមេរៀនពេលរសៀលដោយផ្តោតទៅលើអ្វីដែលបានរៀនៈ**

- បទពិសោធន៍មេរៀនដែលបានពីកម្មសិក្សាអនុវត្តន៍ស្តីពីការជួបពិនិត្យពេលសម្រាល និងក្រោយសម្រាល ។
- របៀបផ្តល់ប្រឹក្សាក្នុងអំឡុងពេលការជួបពិនិត្យដើម្បីផ្តល់ថ្នាំបង្ការ ។
- របៀបផ្តល់ប្រឹក្សាក្នុងអំឡុងពេលការជួបពិនិត្យថែទាំកុមារឈឺ និងកុមារមានសុខភាពល្អ ។

បង្ហាញសិក្ខាកាមពីក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងពេលវេលាដែលត្រូវទៅដល់មណ្ឌលសុខភាពនៅថ្ងៃស្អែក និងពីមធ្យោបាយទៅកាន់ទីនោះ ។

# ថ្ងៃទី ៩–ការចែកចាយគ្រាប់ថ្នាំជីវជាតិអា និង ការប៉ាន់ប្រមាណក្រុមគោលដៅ

## គោលបំណងថ្ងៃទី ៩:

១ ដើម្បីអនុវត្តន៍ជំនាញការផ្តល់ប្រឹក្សាក្នុងការជួបពិនិត្យផ្ទៃទាំងទាំងអស់
២ ដើម្បីបង្រៀនពីសកម្មភាពការចែកចាយគ្រាប់ថ្នាំជីវជាតិអាដល់សិក្ខាកាម
៣ ដើម្បីបង្រៀនពីរបៀបគណនាការប៉ាន់ប្រមាណក្រុមគោលដៅ និងរបៀបកំណត់រកកង្វះខាត និងដោះស្រាយកង្វះខាត ចំពោះបញ្ហាគ្រប់ដណ្តប់ និងបញ្ហាស្តុក។

## គោលបំណងជំនាញសំរាប់សិក្ខាកាមនៅថ្ងៃទី ៩

**នៅចុងបញ្ចប់នៃមេរៀនថ្ងៃនេះ សិក្ខាកាមអាចៈ**

១ ផ្តល់ប្រឹក្សាដល់ស្ត្រីគ្រប់គ្រាន់ ស្តីពីអាហារូបត្ថម្ភ ក្នុងអំឡុងពេលការជួបពិនិត្យផ្ទៃទាំងអស់ដោយប្រើប្រាស់សម្ភារៈជំនួយការងារ
២ ប៉ាន់ប្រមាណចំនួនក្រុមគោលដៅនិមួយៗ
៣ កំណត់រកដំណោះស្រាយសំរាប់ការគ្របដណ្តប់ និងបញ្ហាស្តុកគ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមេបង់ដាសុល

## កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨:០០ | ៣០ | ៩.១ | ណែនាំសិក្ខាកាមដល់មណ្ឌលសុខភាព<br>និងណែនាំពីការធ្វើកម្មសិក្សា<br>ការណែនាំ | ទាំងអស់គ្នា |
| ៨:៣០ | ១៨០ | ៩.២ | ការជួបពិនិត្យថៃទាំទាំងអស់<br>ការធ្វើកម្មសិក្សាអនុវត្តន៍ | ក្រុម |
| **១១:៣០** | **១២០** | | **សម្រាក** | |
| ១៣:៣០ | ១៥ | ៩.៣ | ស្រែកពីសារ<br>ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន<br>និងការលើកទឹកចិត្ត | ក្រុម |
| ១៣:៤៥ | ៦០ | ៩.៤ | ពិភាក្សាកម្មសិក្សាអនុវត្តន៍<br>ឮុះគំនិត និងពិភាក្សាស្តីពីកម្មសិក្សាអនុវត្តន៍កាលពីព្រឹក | ម្នាក់ៗ និង<br>ជាគូរ |
| ១៤:៤៥ | ១៥ | ៩.៥ | ការរៀបចំ សំរាប់ការចែកចាយគ្រាប់ថ្នាំជីវជាតិអា<br>បាវកថា | អ្នកសម្របសម្រួល |
| **១៥:០០** | **២០** | | **សម្រាក** | |
| ១៥:២០ | ៣០ | ៩.៦ | របៀបគណនាការគ្រប់ដណ្តប់ និងស្តុក<br>បាវកថា | អ្នកសម្របសម្រួល |
| ១៥:៥០ | ៦០ | ៩.៧ | របៀបគណនាការគ្រប់ដណ្តប់ និងស្តុក<br>ការងារជាក្រុម | ក្រុម |
| ១៦:៥០ | ១០ | ៩.៨ | សេចក្តីសន្និដ្ឋានថ្ងៃរសៀវល<br>សង្ខេប | អ្នកសម្របសម្រួល |
| **១៧:០០** | | | **ចប់ការសិក្សាប្រចាំថ្ងៃ** | |

## សម្ភារៈដែលត្រូវការ៖

- ស្លាយទី ២០៧-២១៣
- សម្ភារៈជំនួយការងារ
- សៀវភៅសុខភាពមាតា
- ប័ណ្ណសុខភាពកុមារ
- បញ្ជីផ្ទៀងផ្ទាត់

# សកម្មភាពថ្ងៃទី ៩

## នៅមណ្ឌលសុខភាព

### ៩.១ ណែនាំសិក្ខាកាមដល់មណ្ឌលសុខភាព និងកម្មសិក្សាអនុវត្តន៍ (៣០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេច ក្នុងការចុះធ្វើកម្មសិក្សាអនុវត្តន៍ពីការជួបពិនិត្យថៃទាំកុមារឈឺ និងកុមារមានសុខភាពល្អ ។

**វិធីសាស្ត្រ** : ការណែនាំឱ្យស្គាល់

**អ្នកណា** : សិក្ខាកាមទាំងអស់ អ្នកសម្របសម្រួលម្នាក់សម្របសម្រួលក្រុមដែលមានសមាជិក ៨ នាក់

**សម្ភារៈ** : សម្ភារៈជំនួយការងារ សៀវភៅសុខភាពមាតា ប័ណ្ណសុខភាពកុមារ និងបញ្ជីផ្ទៀងផ្ទាត់

**ការណែនាំ**

- ពន្យល់ពីអត្ថន័យនៃការធ្វើកម្មសិក្សាអនុវត្តន៍ និងអំពីពេលវេលាតាមកាលវិភាគ ។
- ប្រាប់សិក្ខាកាមថា គឺមានតែសិក្ខាកាមម្នាក់គត់ដែលត្រូវផ្តល់ប្រឹក្សាដល់អតិថិជន ចំណែកអ្នកឯទៀត គឺជាអ្នកសង្កេតការណ៍ ។
- នៅក្រោយការពិនិត្យអតិថិជននិមួយៗរួច ត្រូវធ្វើការប្រៀបធៀបបញ្ជីផ្ទៀងផ្ទាត់ និងពិភាក្សាលើការផ្តល់ប្រឹក្សា ។
- ចំពោះអតិថិជនបន្ទាប់ សិក្ខាកាមម្នាក់ផ្សេងទៀតអាចធ្វើការផ្តល់ប្រឹក្សា ។
- ប្រើប្រាស់សម្ភារៈជំនួយការងារសំរាប់ផ្តល់ប្រឹក្សាដល់ស្ត្រី ។
- បញ្ជាក់ពីពេលម៉ោងដែលត្រូវសម្រាក ។

### ៩.២ កម្មសិក្សាអនុវត្តន៍ (រហូតដល់ម៉ោង ១១:៣០)

សម្រាក (១២០ នាទី)

## នៅក្នុងថ្នាក់

### ៩.៣ ស្រែកអំពីសារ(១០នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីចាប់ផ្តើមកម្មវិធីពេលរសៀល ។

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាម និងអ្នកសម្របសម្រួលជាក្រុមដែលមានគ្នាយ៉ាងច្រើន ១០ នាក់

#### ការណែនាំ

- ល្បែងនេះនឹងបង្ហាញថា តើយើងអាចចងចាំនូវសារទាំងអស់ដែលយើងផ្តល់ទៅនោះបានកំរិតណា ។
- អញ្ជើញសិក្ខាកាមឱ្យរកអ្នកដែលពាក់អាវមានពណ៌ដូចគ្នា ។
- បន្ទាប់មកបង្កើតក្រុមមួយដែលមានគ្នា ៤ នាក់ ។ ឈរជាជួរៗទៅតាមក្រុមនិមួយៗ ។
- បន្ទាប់មកជួរទាំងនោះត្រូវបង្កើតជារាងពាក់កណ្តាលរង្វង់ ។ ហើយអ្នកដែលនៅខាងមុខនៃក្រុមនិមួយៗ ត្រូវស្រែកអំពីកម្មវិធីផ្សេងៗ ឧទាហរណ៍ យើងប្រើសារអំពីជីវជាតិអា ។
- សុំឱ្យអ្នកឈរនៅជួរមុខគេស្រែក "**ជីវជាតិអា**" ។ អ្នកនៅជួរជិតនោះស្រែកថា" **ពីរដងក្នុងមួយឆ្នាំ**" អ្នកនៅជួរបន្ទាប់មកទៀតស្រែកបន្ទរថា "**បន្លែស្លឹកពណ៌បៃតង**" ។ បើសិនជាមានអ្នកណាម្នាក់មានកំហុស ឬរកនឹកនិយាយដូចជាថា "**អឹម/អរ** ,,," អ្នកនោះនឹងត្រូវទៅនៅខាងចុងនៃជួរ ហើយអ្នកបន្ទាប់នឹងក្លាយជាអ្នកនៅជួរមុខគេវិញ ។
- ចាប់ផ្តើមស្រែកជាមួយកម្មវិធីផ្សេងៗទៀត ដូចជា "**អំបិលអ៊ីយ៉ូដ**" ។
- បញ្ចប់ល្បែងនេះបន្ទាប់ពីលេងបាន ១០-១៥ នាទី ។

### ៩.៤ ពិភាក្សាលើការធ្វើកម្មសិក្សាអនុវត្តន៍ (៦០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាប្រកបដោយទំនុកចិត្ត ។

**វិធីសាស្ត្រ** : ព្យុះគំនិត និងការពិភាក្សា

**អ្នកណា** : ក្រុមកម្មសិក្សាអនុវត្តន៍

**សម្ភារៈ** : សម្ភារៈជំនួយការងារ ស្លាយទី ២០៧-២០៩

#### ការណែនាំ

- ឱ្យសិក្ខាកាមធ្វើការនៅក្នុងក្រុមដដែល ដូចការពិកម្មសិក្សាអនុវត្តន៍លើកមុន ។
- សុំឱ្យពួកគាត់ធ្វើការពិភាក្សាលើការផ្តល់ប្រឹក្សាឱ្យបានហ្មត់ចត់ ប៉ុន្តែមិនត្រូវឱ្យលើសពី ១០ នាទី ឬ ១៥ នាទីក្នុងការផ្តល់ប្រឹក្សាម្តងៗទេ (អាស្រ័យទៅលើចំនួននៃការផ្តល់ប្រឹក្សា) ។ ប្រសិនបើមិនមានច្រើនទេ ការពិភាក្សាអាចប្រើពេល ១៥ នាទី ។
- បង្ហាញស្លាយទី ២០៧-២០៨ ដែលបញ្ជាក់ពីគោលបំណង និងគោលបំណងជំនាញ

- ផ្តល់ឱ្យក្រុមនិមួយៗ នូវក្រដាសផ្ទាំងធំ រួចឱ្យគូសចែកជា ៤ ការេ ។
- ប្រាប់ឱ្យពួកគាត់សរសេរបទពិសោធន៍មេរៀនដែលបានពីមេរៀនណាមួយទៅក្នុងការេមួយនៃក្រដាសផ្ទាំធំនោះ ។
- នៅពេលរាល់មេរៀនទាំងអស់ត្រូវបានលើកយកមកពិភាក្សា និងបទពិសោធន៍មេរៀនបានសរសេរនៅក្នុងការេនោះរួចហើយ ប្រាប់សិក្ខាកាមឱ្យធ្វើការជ្រើសរើសយកបទពិសោធន៍មេរៀនណាដែលសំខាន់ជាងបំផុត ។
- ប្រាប់ពួកគាត់ឱ្យកំណត់បង្ហាញពីបទពិសោធន៍មេរៀនសំខាន់ៗយ៉ាងតិចចំនួន ៤ ដែលបានរៀន ។
- សុំឱ្យក្រុមនិមួយៗធ្វើការបង្ហាញពីបទពិសោធន៍មេរៀនរបស់ពួកគាត់ ។

## កាលវិភាគ

| ការកំណត់រកបញ្ហា | នាទី |
|---|---|
| ការណែនាំ | ៥ |
| ការពិភាក្សាលើមេរៀនផ្តល់ប្រឹក្សា | ៣០ |
| ការជ្រើសរើសបទពិសោធន៍មេរៀនដែលសំខាន់ៗ | ៥ |
| ការឡើងបង្ហាញ | ២០ |
| **សរុប** | **៦០** |

## ៩.៥ ការរៀបចំសំរាប់ការចែកចាយជីវជាតិអា និងកម្មសិក្សាអនុវត្តន៍ចុងក្រោយ (២០ នាទី)

**គោលបំណង** : ដើម្បីរៀបចំសិក្ខាកាមសំរាប់ការផ្តល់ការចែកចាយគ្រាប់ថ្នាំជីវជាតិអា និងកម្មសិក្សាអនុវត្តន៍នៅថ្ងៃស្អែក ។

**វិធីសាស្ត្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយទី ២០៩-២១០
សម្ភារៈជំនួយការងារ

### ការណែនាំ

- ពន្យល់សិក្ខាកាមថាថ្ងៃស្អែក ពួកគាត់នឹងទៅធ្វើការអនុវត្តផ្ទាល់នៅមូលដ្ឋាននៅពេលព្រឹក ។
- ក្នុងអំឡុងពេលកម្មសិក្សាអនុវត្តន៍ថ្ងៃស្អែក សិក្ខាកាមនឹងផ្តល់ប្រឹក្សាគ្រប់ស្ត្រីនិងកុមារទាំងអស់ដោយប្រើប្រាស់សម្ភារៈជំនួយការងារផ្សេងៗ ។ ដោយសារយើងបានអនុវត្តន៍ការជួបពិនិត្យថៃទាំទាំងអស់រួចហើយ នៅពីរ-បីថ្ងៃមុននោះ ការសំដែងតួថ្ងៃនេះនឹងផ្តោតតែទៅលើការចែកចាយគ្រាប់ថ្នាំជីវជាតិអាប៉ុណ្ណោះ ។
- បង្ហាញតែការចែកចាយគ្រាប់ថ្នាំជីវជាតិអាប៉ុណ្ណោះ ។
- ពន្យល់ពីរបៀបប្រើសម្ភារៈជំនួយការងារដោយប្រើប្រាស់ស្លាយ ទី ២០៩-២១០ ។

- ពន្យល់ពីបញ្ជីផ្ទៀងផ្ទាត់ រូបភាពដែលពួកគាត់ត្រូវប្រើសំរាប់ការផ្ដល់ប្រឹក្សា និងពីតារាងព្យាបាលដែលមាននៅខាងក្រោយ ។

សម្រាក (១២០ នាទី)

## ៩.៦ របៀបគណនាក្រុមគោលដៅសំរាប់គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និង មេបង់ដាសុល (៣០នាទី)

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមដឹងពីរបៀបគណនា ក្រុមគោលដៅសំរាប់គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និង មេបង់ដាសុល ។

**វិធីសាស្ត្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយទី ២១១-២១៣
សម្ភារៈជំនួយការងារ

### ការណែនាំ

- ពន្យល់ពីសារៈសំខាន់ដែលអាចគណនាក្រុមគោលដៅសំរាប់គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមេបង់ដាសុល ។
- ប្រសិនបើមិនអាចគណនាក្រុមគោលដៅសំរាប់គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមេបង់ដាសុលទេ វាជាការលំបាកនឹងដឹងបានថាតើអ្នកមានស្តុកគ្រប់គ្រាន់សំរាប់ក្រុមគោលដៅដែល ឬទេ ។
- ជាអនុសាសន៏ រក្សាស្តុកគ្រប់គ្រាន់ដើម្បីគ្របដណ្តប់យ៉ាងហោចណាស់ឱ្យបាន ២ ខែខាងមុខ ។
- បើសិនជាស្តុកស្ថិតនៅក្រោមចំនួននោះ ស្តុកថ្មីត្រូវតែស្នើសុំ ។
- ក្នុងអំឡុងពេលនៃបាឋកថានេះ និងការងារជាក្រុមបន្តបន្ទាប់នេះ អ្នកនឹងរៀនអំពីរបៀបគណនាស្តុកដែលត្រូវការ ។
- ដើម្បីគណនាស្តុកដែលត្រូវការ អ្នកត្រូវការគណនាក្រុមគោលដៅ ។

## ៩.៧ របៀបគណនាការគ្របដណ្តប់ និងស្តុក-ការងារជាក្រុម (៦០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចគណនាតម្រូវការ និងកង្វះខាតនៃគ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមេបង់ដាសុល ។

**វិធីសាស្ត្រ** : ការងារជាក្រុម

**អ្នកណា** : ក្រុមដែលមានគ្នា ៤ នាក់

**សម្ភារៈ** : "ការគណនាក្រុមគោលដៅ" នៅក្នុងសៀវភៅសិក្ខាកាម

## សន្និទានភាព

នៅក្នុងអំឡុងពេលការធ្វើការងារជាក្រុម សិក្ខាកាមនឹងអនុវត្តការគណនា ៖

- ក្រុមគោលដៅសំរាប់គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមេបង់ដាសុល
- ស្តុកដែលត្រូវការ
- កង្វះខាតក្នុងការគ្រប់ដណ្តប់

ដោយប្រើប្រាស់ចំនួនទាំងនេះ សិក្ខាកាមនឹងរៀនអំពីរបៀបដោះស្រាយបញ្ហាកង្វះខាតទាំងនេះ ។

## ការណែនាំ

- ក្រុមការងារដែលមានសមាជិក ៤ នាក់
- សុំឱ្យសិក្ខាកាមប្រើប្រាស់លំហាត់ជាក្រុម "**ការគណនាក្រុមគោលដៅនិងស្តុកដែលត្រូវការ**" ដែលមាននៅក្នុងសៀវភៅសិក្ខាកាម ។
- ស្នើឱ្យសិក្ខាកាមគណនាក្រុមគោលដៅ និងស្តុកដែលត្រូវការសំរាប់ជុំចែកចាយគ្រប់ថ្នាំជីវជាតិអា ដោយប្រើប្រាស់ករណីសិក្សារឿងខាងក្រោម ។
- ភូមិមួយស្វាយមាន ២២៥ គ្រួសារ និងមានប្រជាជនប្រមាណ ១.៣៥០ នាក់ ។
- សូមធ្វើការគណនាក្រុមគោលដៅ និងចំនួនស្តុកដែលត្រូវការសំរាប់ក្រុមគោលដៅនិមួយៗ (គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមេបង់ដាសុល)
    - កុមារអាយុ ៦ - ១១ ខែ
    - កុមារអាយុ ១២ - ៥៩ ខែ
    - ស្ត្រីមានផ្ទៃពោះ
    - ស្ត្រីក្រោយសម្រាល

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ពន្យល់ | ៥ |
| ការរៀបចំក្នុងក្រុម | ៣០ |
| ការផ្លាស់ប្តូរលទ្ធផលរវាងក្រុមជិតខាង | ១០ |
| ការផ្តល់ព័ត៌មានត្រលប់ពីអ្នកសម្របសម្រួល | ១៥ |
| **សរុប** | **៦០** |

## ៩.៨ សេចក្តីសន្និដ្ឋានសំរាប់ពេលរសៀល (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមមានទំនុកចិត្តលើចំណេះដឹង និងជំនាញដែលបានសិក្សាកាលពីរសៀលនេះ ។

**វិធីសាស្រ្ត** : សង្ខេប

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលមានរូបនាឡិកាដែលបង្ហាញពេលម៉ោង និងពណ៌នាពីមធ្យោបាយដែលត្រូវទៅកាន់មណ្ឌលសុខភាព ។

### ការណែនាំ

**សង្ខេបមេរៀនដែលបានសិក្សាពេលរសៀល និងផ្តោតទៅលើអ្វីដែលបានរៀន:**

- បទពិសោធន៍ដែលបានមកពីកម្មសិក្សាអនុវត្តន៍
- របៀបផ្តល់ប្រឹក្សាក្នុងអំឡុងពេលការចែកចាយគ្រាប់ថ្នាំជីវជាតិអា
- របៀបគណនាការគ្របដណ្តប់ និងស្តុកដែលត្រូវការសំរាប់គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមេបង់ដាសុល

បង្ហាញពួកគាត់ នូវក្រដាសផ្ទាំងធំដែលមានរូបនាឡិកា និងបង្ហាញពេលម៉ោងដែលត្រូវទៅដល់មណ្ឌលសុខភាព និងមធ្យោបាយទៅកាន់ទីនោះ ។

# ថ្ងៃទី ១០ – កម្មសិក្សាអនុវត្តន៍បញ្ចប់

## គោលបំណងថ្ងៃទី ១០

១ ដើម្បីអនុវត្តន៍នូវរាល់ជំនាញនៃការផ្តល់ការប្រឹក្សា និងសារអប់រំអាហារូបត្ថម្ភទាំងអស់ នៅអំឡុងពេលកម្មសិក្សាអនុវត្តន៍បញ្ចប់ ។

២ ដើម្បីណែនាំអំពីរបៀបរៀបចំការប្រជុំគាំទ្រមិត្តរួមការងារ ។

៣ ដើម្បីធ្វើការវាយតម្លៃការសិក្សារបស់សិក្ខាកាមតាមរយៈការធ្វើតេស្តក្រោយការសិក្សា ។

៤ ដើម្បីធ្វើការវាយតម្លៃវគ្គបណ្តុះបណ្តាលដោយប្រើប្រាស់ទម្រង់វាយតម្លៃរយៈពេលខ្លី ។

## គោលបំណងជំនាញសំរាប់សិក្ខាកាមនៅថ្ងៃទី ១០

**នៅចុងបញ្ចប់នៃថ្ងៃនេះ សិក្ខាកាមនឹងអាច :**

១ ផ្តល់ប្រឹក្សាដល់ម្តាយ/អ្នកថែទាំកុមារទាំងអស់ ដោយមាន ឬគ្មានកុមារមកជាមួយ អំពីការផ្តល់អាហារូបត្ថម្ភដោយដាក់បញ្ចូលគ្រប់បទអន្តរាគមន៍អាហារូបត្ថម្ភទាំងអស់ និងដោយប្រើប្រាស់សម្ភារៈជំនួយការងារ ។

២ រៀបចំ និងធ្វើការប្រជុំគាំទ្រមិត្តរួមការងារ ។

## កាលវិភាគប្រចាំថ្ងៃ

| ម៉ោងសិក្សា | រយៈពេល | លរ | មេរៀន | អ្នកណា |
|---|---|---|---|---|
| ៨:០០ | ៣០ | ១០.១ | ណែនាំសិក្ខាកាមដល់មណ្ឌលសុខភាព និងណែនាំពីការធ្វើកម្មសិក្សា ការណែនាំ | ទាំងអស់គ្នា |
| ៨:៣០ | ១៨០ | ១០.២ | ការជួបពិនិត្យផ្ទៃទាំ ការធ្វើកម្មសិក្សាអនុវត្តន៍ | ក្រុម |
| **១១:៣០** | **១២០** | | **សម្រាក** | |
| ១៣:៣០ | ១០ | ១០.៣ | អ្វីដែលខ្ញុំបានរៀនគឺ............. ល្បែងថាមពលដើម្បីបង្កើតថាមពលវិជ្ជមាន និងការលើកទឹកចិត្ត | ក្រុម |
| ១៣:៤០ | ៤០ | ១០.៤ | ពិភាក្សាកម្មសិក្សាអនុវត្តន៍ ព្យុះគំនិត និងពិភាក្សាស្ដីពីកម្មសិក្សាអនុវត្តន៍កាលពីព្រឹក | បុគ្គលម្នាក់ៗ |
| ១៤:២០ | ១៥ | ១០.៥ | ការរៀបចំដឹកនាំការប្រជុំគាំទ្រមិត្តរួមការងារ បាឋកថា | អ្នកសម្របសម្រួល |
| ១៤:៣៥ | ៨០ រួមទាំងសម្រាក | ១០.៦ | ការដឹកនាំការប្រជុំគាំទ្រមិត្តរួមការងារ ការងារជាក្រុម | ក្រុម |
| ១៥:៥៥ | ៤៥ | ១០.៧ | តើអ្វីខ្លះដែលយើងបានសិក្សា ? ការធ្វើតេស្តក្រោយការសិក្សា និងការវាយតម្លៃ | សិក្ខាកាមម្នាក់ៗ |
| ១៦:៤០ | ២០ | ១០.៨ | សេចក្ដីសន្និដ្ឋាន និងការបិទវគ្គ | អ្នកសម្របសម្រួល មន្ត្រី |
| **១៧:០០** | | | **ចប់** | |

## សម្ភារៈដែលត្រូវការ

- ស្លាយទី ២១៤-២១៨
- សម្ភារៈជំនួយការងារ
- សៀវភៅសុខភាពមាតា
- ប័ណ្ណសុខភាពកុមារ
- បញ្ជីផ្ទៀងផ្ទាត់
- កូនបាល់
- តារាងគាំទ្រមិត្តរួមការងារ

- ក្រដាសផ្ទាំងធំ
- ក្រដាសអា៤
- ប៊ិចហ្វឺត
- សំនួរតេស្តក្រោយការសិក្សា
- ទម្រង់វាយតម្លៃការសិក្សា

# សកម្មភាពថ្ងៃទី ១០

## នៅមណ្ឌលសុខភាព

### ១០.១ ណែនាំសិក្ខាកាមដល់មណ្ឌលសុខភាពនិងកម្មសិក្សាអនុវត្តន៍ (៣០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមរៀបចំខ្លួនជាស្រេចក្នុងការចុះធ្វើកម្មសិក្សាអនុវត្តន៍សំរាប់ការជួបពិនិត្យថៃទាំទាំងអស់។

**វិធីសាស្ត្រ** : ការណែនាំឱ្យស្គាល់

**អ្នកណា** : សិក្ខាកាមទាំងអស់ អ្នកសម្របសម្រួលម្នាក់សម្របសម្រួលក្រុមដែលមានសមាជិក ៨ នាក់

**សម្ភារៈ** : សម្ភារៈជំនួយការងារ សៀវភៅសុខភាពមាតា ប័ណ្ណសុខភាពកុមារ និងបញ្ជីផ្ទៀងផ្ទាត់

### ការណែនាំ

- ពន្យល់ពីអត្ថន័យនៃការធ្វើកម្មសិក្សាអនុវត្តន៍ និងអំពីពេលវេលាតាមកាលវិភាគ។
- ប្រាប់សិក្ខាកាមថា គឺមានតែសិក្ខាកាមម្នាក់គត់ដែលត្រូវផ្តល់ប្រឹក្សាដល់អតិថិជន ចំណែកអ្នកឯទៀត គឺជាអ្នកសង្កេតការណ៍។
- នៅក្រោយការពិនិត្យអតិថិជនម្នាក់ៗរួច ត្រូវធ្វើការប្រៀបធៀបបញ្ជីផ្ទៀងផ្ទាត់ និងពិភាក្សាលើការផ្តល់ប្រឹក្សា។
- ចំពោះអតិថិជនបន្ទាប់ សិក្ខាកាមម្នាក់ផ្សេងទៀតអាចធ្វើការផ្តល់ប្រឹក្សា។
- ប្រើប្រាស់សម្ភារៈជំនួយការងារសំរាប់ផ្តល់ប្រឹក្សាដល់ស្ត្រី។
- បញ្ជាក់ពីពេលម៉ោងដែលត្រូវសម្រាក។

## ១០.២ កម្មសិក្សាអនុវត្តន៍ (រហូតដល់ម៉ោង ១១:៣០)

សម្រាក (១២០ នាទី)

## នៅក្នុងថ្នាក់

## ១០.៣ អ្វីដែលខ្ញុំបានរៀនគឺ.... (១០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមត្រៀមខ្លួនជាស្រេចដើម្បីចាប់ផ្ដើមកម្មវិធីនាពេលរសៀលនេះ។

**វិធីសាស្ត្រ** : ល្បែងថាមពល

**អ្នកណា** : សិក្ខាកាម និងអ្នកសម្របសម្រួលជាក្រុមដែលមានគ្នាយ៉ាងច្រើន ១០ នាក់

**សម្ភារៈ** : កូនបាល់

### ការណែនាំ

- ពន្យល់សិក្ខាកាមថា ល្បែងនេះនឹងជួយសិក្ខាកាមឱ្យភ្ជាប់គ្នានូវអ្វីដែលពួកគាត់បានរៀនសូត្រក្នុងរយៈពេល ១០ថ្ងៃ កន្លងមកនេះ។
- អញ្ជើញសិក្ខាកាមឱ្យឈរជារង្វង់មូល។
- បង្ហាញកូនបាល់ដែលត្រូវប្រើនៅក្នុងការលេងល្បែងនេះ។
- ប្រាប់សិក្ខាកាមឱ្យនឹកគិតទៅដល់ ៣ ចំណុច ដែលពួកគាត់បានសិក្សានៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ។
- ពេលបោះកូនបាល់ទៅឱ្យសិក្ខាកាមណាម្នាក់ត្រូវនិយាយថា "**អ្វីដែលខ្ញុំបានសិក្សាកន្លងមកគឺ ... ហើយចុះអ្នកវិញ អ្វីដែលអ្នកបានសិក្សា**"។
- បន្ទាប់មកអោបដៃខ្វែងដើម្បីបញ្ជាក់ថាអ្នកបានធ្វើរួចហើយ។
- អ្នកបន្ទាប់បោះកូនបាល់ទៅឱ្យសិក្ខាកាមណាម្នាក់ទៀតហើយត្រូវនិយាយថា " **អ្វីខ្លះដែលខ្ញុំបានសិក្សាកន្លងមកគឺ ...**"។
- នៅពេលដែលសិក្ខាកាមទាំងអស់បានឈរអោបដៃខ្វែងទាំងអស់គ្នាហើយ សុំឱ្យសិក្ខាកាមទម្លាក់ដៃចុះ និងបន្តលេងល្បែងនេះទៀត រហូតទាល់តែគ្រប់ៗគ្នាបានផ្ដល់នូវអ្វីដែលពួកគាត់បានរៀនយ៉ាងហោចណាស់ ២ ឬ ៣ ចំណុច។
- បញ្ចប់ការលេងនៅក្រោយ ពី ១០ នាទី

## ១០.៤ ពិភាក្សាអំពីការធ្វើកម្មសិក្សាអនុវត្តន៍ (៤០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចផ្តល់ប្រឹក្សាប្រកបដោយមានទំនុកចិត្ត។
**វិធីសាស្ត្រ :** ព្យុះគំនិត និងការពិភាក្សា
**អ្នកណា :** សិក្ខាកាមម្នាក់ៗ អ្នកសម្របសម្រួល
**សម្ភារៈ :** សម្ភារៈជំនួយការងារ ស្លាយទី ២១៤-២១៥

### ការណែនាំ

- បង្ហាញពីស្លាយ ទី ២១៤-២១៥ ដែលមានគោលបំណង និងគោលបំណងជំនាញ។
- ប្រាប់ឱ្យសិក្ខាកាមគិតពីការសិក្សាផ្ទាល់ខ្លួនដែលគាត់បានរៀនពីកម្មសិក្សាអនុវត្តន៍។
- ផ្តល់ឱ្យពួកគាត់នូវក្រដាស ២ សន្លឹក (អា៤)។
- សុំឱ្យពួកគាត់សរសេរនៅលើសន្លឹកទីមួយ នូវអ្វីៗដែលបានរៀនសូត្រកន្លងមក។
- នៅលើសន្លឹកទី ២ ពួកគាត់អាចសរសេរនូវអ្វីមួយដែលពួកគាត់ចង់បានការស្រាយបំភ្លឺបន្ថែម។
- ក្រោយពេល ១០ នាទី បន្ទាប់មក ប្រមូលក្រដាសដែលមានបញ្ហាដែលសិក្ខាកាមចង់ឱ្យធ្វើការបំភ្លឺបន្ថែម។
- ជ្រើសរើសបញ្ហា ១ ឬ ២ ដែលសិក្ខាកាមនៅមិនទាន់ច្បាស់ ហើយធ្វើការពន្យល់បញ្ហាទាំងនោះម្តងទៀត។

## កាលវិភាគ

| ការកំណត់រកបញ្ហា | នាទី |
|---|---|
| សេចក្តីណែនាំ | ៥ |
| លំហាត់សំរាប់បុគ្គលម្នាក់ៗ | ១០ |
| ពន្យល់ពីបញ្ហាដែលនៅមិនទាន់ច្បាស់ | ២៥ |
| **សរុប** | **៤០** |

## ១០.៥ របៀបដឹកនាំការប្រជុំការគាំទ្រមិត្តរួមការងារ (២៥ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងដឹងពីរបៀបរៀបចំការប្រជុំគាំទ្រមិត្តរួមការងារ ។

**វិធីសាស្ត្រ** : បាឋកថា

**អ្នកណា** : អ្នកសម្របសម្រួល

**សម្ភារៈ** : ស្លាយទី ២១៦-២១៨

### ការណែនាំ

- ពន្យល់សិក្ខាកាមពីការប្រជុំគាំទ្រមិត្តរួមការងារ
- ប្រើប្រាស់ស្លាយទី ២១៦-២១៨

## ១០.៦ ការដឹកនាំការប្រជុំគាំទ្រមិត្តរួមការងារ – លំហាត់ជាក្រុម : (៨០ នាទី – រួមទាំងសម្រាក ២០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចរៀបចំ និងដឹកនាំការប្រជុំគាំទ្រមិត្តរួមការងារដោយខ្លួនឯង ។

**អ្នកណា** : ក្រុមនៃមណ្ឌលសុខភាពចំនួន ២

**សម្ភារៈ** : តារាងគាំទ្រមិត្តរួមការងារ
ស្លាយទី ២១៨
ក្រដាសផ្ទាំងធំ ក្រដាសអា៤ ប៊ិចហ្វឺត

### សន្និទានភាព

នៅក្នុងអំឡុងពេលនៃសកម្មភាពនេះ សិក្ខាកាមត្រូវអនុវត្តដោយធ្វើការប្រជុំគាំទ្រមិត្តរួមការងារ ។ ជាទូទៅការប្រជុំគាំទ្រមិត្តរួមការងារ គឺត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ៣ ទៅ ៦ ខែ ក្រោយពីការបណ្តុះបណ្តាល ។ ការប្រជុំគាំទ្រមិត្តរួមការងារ អាចប្រជុំតែមួយដង ឬច្រើនដងដោយទៀងទាត់ ។ ជាធម្មតាការប្រជុំនេះ ក៏អាចធ្វើឡើងជាទៀងរាល់ខែបានដែរ ។

គោលបំណងនៃការប្រជុំគាំទ្រមិត្តរួមការងារ គឺដើម្បីពិភាក្សាពីបញ្ហាប្រឈមមុខ និងផ្តល់រាល់ព័ត៌មានត្រលប់ទៅវិញទៅមក ដើម្បីស្វែងរកដំណោះស្រាយសមស្របដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមមុខទាំងនោះ ។ ជាធម្មតា សមាជិកទាំងអស់សុទ្ធតែធ្លាប់ជួបប្រទះបញ្ហាប្រហាក់ប្រហែលគ្នា ហើយធ្លាប់រកឃើញដំណោះស្រាយផ្សេងៗ ឬផ្នែកណាមួយនៃដំណោះស្រាយ ដែលអាចឈានទៅរកដំណោះស្រាយសំរាប់បញ្ហាប្រឈមមុខទាំងនោះ ។

## ការណែនាំ

- ពន្យល់សិក្ខាកាមថា ជាទូទៅការប្រជុំមិត្តគាំទ្រមិត្តរួមការងារ គឺត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ១ ទៅ ៦ ខែ ក្រោយពីការបណ្តុះបណ្តាល។
- ដោយសារយើងនៅមិនទាន់ធ្វើការបណ្តុះបណ្តាលចប់សព្វគ្រប់ យើងនឹងអនុវត្តន៍ការប្រជុំគាំទ្រមិត្តរួមការងារ ដោយក្រឡេកមើលទៅពេលអនាគត។
- ធ្វើការណែនាំសិក្ខាកាមថា ការប្រជុំគាំទ្រមិត្តរួមការងារ គួររៀបចំធ្វើឡើងនៅក្នុងអំឡុងពេល ១ ទៅ ៦ខែ ក្រោយពីការបណ្តុះបណ្តាលនេះ ហើយនឹងត្រូវផ្តោតទៅលើបទពិសោធន៍របស់ពួកគាត់បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ និងនៅក្នុងការប្រជុំគាំទ្រមិត្តរួមការងារ។ នៅពេលប្រជុំ ពួកគាត់នឹងត្រូវកំណត់រកបញ្ហាប្រឈមមុខដែលពួកគាត់ពិតជាបានជួប និងដំណោះស្រាយដែលជួយឱ្យពួកគាត់អាចដោះស្រាយបញ្ហាទាំងនោះ។
- ឥឡូវនេះ យើងនឹងអនុវត្តន៍ដោយការកំណត់រកបញ្ហាដែលអ្នកអាចជួបប្រទះនៅពេលអ្នកដាក់បញ្ចូល MPA១០ ទៅក្នុងការងារបច្ចុប្បន្នរបស់អ្នក។ អ្នកក៏នឹងត្រូវស្វែងរក ដំណោះស្រាយដែលអាចទៅរួច សំរាប់បញ្ហាទាំងអស់នោះ។
- សូមមើលតារាងខាងក្រោម ហើយបង្ហាញស្លាយទី ២១៨។
- ធ្វើការប្រៀបធៀបតារាងនេះជាមួយតារាងនៅក្នុងសៀវភៅសិក្ខាកាម។
- ធ្វើការកត់សម្គាល់ថា តារាងនៅក្នុងសៀវភៅសិក្ខាកាម គឺពិនិត្យមើលបទពិសោធន៍របស់អ្នក រវាងនៅក្នុងវគ្គបណ្តុះបណ្តាល និងនៅក្នុងការប្រជុំគាំទ្រមិត្តរួមការងារ ដូចនេះគឺមើលត្រលប់មកក្រោយវិញ។ តារាងនៅខាងក្រោមវានឹងសួរដល់អ្នកថាអ្វីខ្លះទៀតដែលអ្នករំពឹងថានឹងកើតមានឡើងនាពេលខាងមុខ។
- សូមអង្គុយជាមួយគ្នារយៈពេលមួយម៉ោង។
- នៅក្នុង ១៥ នាទីដំបូង ចូរព្យាយាមកំណត់រកបញ្ហាទាំងឡាយដែលអ្នកអាចជួបប្រទះ នៅពេលអនុវត្តន៍នូវសកម្មភាពអាហារូបត្ថម្ភ ដែលអ្នកបានរៀននៅក្នុងវគ្គនេះ។
- ក្រោយពីបានកំណត់រកបញ្ហាដែលអាចកើតមានឡើង សូមចំណាយពេល ១០នាទីបន្ទាប់ ដើម្បីកំណត់រកដំណោះស្រាយដែលអាចកើតមាន: តើអ្វីដែលត្រូវធ្វើ? តើអ្នកណាគួរធ្វើការងារនេះ? ហើយមានខ្លះអ្វីទៀតដែលអ្នកអាចធ្វើវាដោយខ្លួនឯង។
- ចំណាយពេល៥នាទីចុងក្រោយ ដើម្បីធ្វើការសម្រេចចិត្តជ្រើសយកបញ្ហា២ដែលអ្នកចង់យកមកធ្វើការបង្ហាញទៅក្រុម។

| បញ្ហាប្រឈមមុខ | អ្វីខ្លះដែលត្រូវធ្វើ? | អ្នកណាត្រូវធ្វើការងារនេះ? | អ្វីផ្សេងទៀតដែលខ្ញុំអាចធ្វើដោយខ្លួនឯង? |
|---|---|---|---|
| យើងពុំមានសម្ភារៈគ្រប់គ្រាន់ | បុគ្គលិកមណ្ឌលសុខភាពគួរសុំស្រុកប្រតិបត្តិឱ្យផ្តល់ ១០ កញ្ចប់ថែមទៀត | ស្រុកប្រតិបត្តិ ផ្តល់តាមសំណើររបស់យើង | ផលិតសម្ភារៈខ្លះដោយខ្លួនយើង |
| | | | |
| | | | |
| | | | |
| | | | |

- នៅ ២៥ នាទីចុងក្រោយ គឺជាការឡើងបង្ហាញនូវបញ្ហាប្រឈមមុខ ២ ជាមួយដំណោះស្រាយទៅកាន់ក្រុមធំ ។
- នៅចុងបញ្ចប់ ធ្វើការសម្រេចលើកាលបរិច្ឆេទសំរាប់មណ្ឌលសុខភាពនិមួយៗ ឬ មណ្ឌលសុខភាពពីររួមគ្នាក្នុងការរៀបចំការប្រជុំគាំទ្រមិត្តរួមការងារលើកដំបូង ក្រោយពីការបណ្តុះបណ្តាល ។

## តារាងកាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ការណែនាំ | ៥ |
| ការរៀបចំក្នុងក្រុមៈ កំណត់រកបញ្ហាប្រឈមមុខ | ១៥ |
| ការរៀបចំក្នុងក្រុមៈ ដំណោះស្រាយ | ១០ |
| ការជ្រើសរើសបញ្ហាចម្បង២ | ៥ |
| ការឡើងបង្ហាញ | ២០ |
| សម្រាក | ២០ |
| **សរុប** | **៨០** |

## ១០.៧ ការធ្វើតេស្តក្រោយការសិក្សា និងការវាយតម្លៃ(៤០ នាទី)

**គោលបំណង** : នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនិងអ្នកសម្របសម្រួលនឹងវាយតម្លៃពីអ្វីដែលសិក្ខាកាមបានរៀន ដោយធ្វើការប្រៀបធៀបជាមួយនឹងការធ្វើតេស្តមុនការសិក្សា និងដោយចែករំលែកគំនិតយោបល់របស់សិក្ខាកាមអំពីវគ្គបណ្តុះបណ្តាលនេះ ។

**វិធីសាស្ត្រ** : ការធ្វើតេស្តក្រោយការសិក្សា និងការវាយតម្លៃ

**អ្នកណា** : សិក្ខាកាមម្នាក់ៗ

**សម្ភារៈ** : ក្រដាសតេស្តក្រោយការសិក្សា លទ្ធផលតេស្តមុនការសិក្សា ទម្រង់វាយតម្លៃ

### ការណែនាំ

- ពន្យល់សិក្ខាកាមថា ពួកគាត់ត្រូវបំពេញឯកសារពីរ : ទីមួយគឺតេស្តក្រោយការសិក្សា បន្ទាប់មកគឺទម្រង់វាយតម្លៃ ។
- ពន្យល់ទៅដល់សិក្ខាកាមថា ក្រោយពីការប្រៀបធៀបជាមួយលទ្ធផលតេស្តមុនការសិក្សា ការធ្វើតេស្តក្រោយការសិក្សានេះនឹងផ្តល់ព័ត៌មានអំពីទំហំនៃការសិក្សាដែលពួកគាត់បានឆ្លងកាត់ក្នុងអំឡុងវគ្គបណ្តុះបណ្តាលនេះ ។
- ការវាយតម្លៃនឹងផ្តល់ព័ត៌មាន ថាតើពួកគាត់មានអារម្មណ៍យ៉ាងណាចំពោះវគ្គបណ្តុះបណ្តាលនេះ ។
- សុំឱ្យសិក្ខាកាមអង្គុយឃ្លាតៗពីគ្នា ។
- ពន្យល់ទៅសិក្ខាកាមថា ពួកគាត់ត្រូវឆ្លើយនឹងសំណួរដោយខ្លួនឯង ។

- ពួកគាត់មានពេល ២០ នាទី ដើម្បីធ្វើតេស្តនេះ ។
- នៅពេលដែលពួកគាត់បានធ្វើតេស្តក្រោយការសិក្សារួចរាល់ហើយ គាត់គួរត្រូវបន្តការបំពេញទម្រង់វាយតម្លៃ ។
- ក្រោយពីបានបញ្ចប់ការធ្វើតេស្ត និងការវាយតម្លៃ សិក្ខាកាមគួររក្សាភាពស្ងៀមស្ងាត់ដើម្បីទុកឱកាសដល់សិក្ខាកាមផ្សេងទៀតបានបញ្ចប់តេស្តរបស់ពួកគាត់ ។
- សៀវភៅ ឬសម្ភារៈជំនួយការងារមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងអំឡុងពេលធ្វើតេស្តឡើយ ។

## ១០.៨ សេចក្តីសន្និដ្ឋានសំរាប់ពេលរសៀល និងការបិទវគ្គសិក្សា (២០ នាទី)

**គោលបំណង :** នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមមានទំនុកចិត្តលើចំណេះដឹង និងជំនាញដែលបានសិក្សានៅក្នុងសកម្មភាពមុន ។

**វិធីសាស្ត្រ :** សង្ខេប

**អ្នកណា :** អ្នកសម្របសម្រួល និងមន្ត្រីរដ្ឋាភិបាល

### ការណែនាំ

**សង្ខេបមេរៀនដែលបានសិក្សាពេលរសៀល និងផ្តោតទៅលើអ្វីដែលបានរៀនៈ**

- ល្បែងថាមពល
- ការពិភាក្សាពីកម្មសិក្សាអនុវត្តន៍
- បាឋកថាអំពីការគាំទ្រមិត្ត
- អនុវត្តន៍ការគាំទ្រមិត្ត
- ការធ្វើតេស្តក្រោយការសិក្សា
- ទម្រង់វាយតម្លៃ
- សកម្មភាពវាយតម្លៃបញ្ចប់ គួរតែធ្វើនៅខាងក្រៅ ពីព្រោះវាចាំបាច់ត្រូវការកន្លែងទូលាយ ។ អញ្ជើញឱ្យសិក្ខាកាមចេញទៅខាងក្រៅ ។
- ត្រូវឱ្យប្រាកដថា សិក្ខាកាមទាំងអស់អាចស្តាប់អ្នកឮយ៉ាងច្បាស់ ។ ដើម្បីសម្រេចបានបែបនេះ អ្នកត្រូវតែតម្លើងសម្លេង ប៉ុន្តែរក្សាវាឱ្យនៅទាបល្មម ។ សម្លេងទាបលឺបានឆ្ងាយជាងសម្លេងខ្ពស់ ។
- សុំឱ្យសិក្ខាកាម ឈរជាជួរដោយសម្លឹងទៅមុខទាំងអស់គ្នា ។
- សិក្ខាកាមទាំងអស់អនុញ្ញាតិឱ្យបើកភ្នែកបាន ។
- អ្នកនឹងធ្វើការប្រកាសជាប្រយោគ ។
- បើសិនជាពួកគាត់ឯកភាពជាវិជ្ជមាន ពួកគាត់អាចដើរ១ ឬ ២ ឬ ៣ ជំហានទៅមុខ ។
- បើសិនជាពួកគាត់មិនឯកភាពទេ ពួកគាត់អាចឈរនៅកន្លែងដដែល ឬបោះជំហានថយក្រោយ ១ ឬ ២ ឬ ៣ ជំហានទៅតាមកំរិតនៃការមិនឯកភាព ។

- ឧទាហរណ៍ បើសិនជាខ្ញុំឯកភាពទាំងស្រុង ខ្ញុំត្រូវដើរ ៣ ជំហានទៅមុខ។ តែបើសិនជាខ្ញុំមិនយល់ស្របតិច តួច ខ្ញុំត្រូវដើរ ១ ជំហានមកក្រោយ។
- នៅចុងបញ្ចប់ ចូរក្រឡេកមើលជុំវិញខ្លួនអ្នក រកមើលទីកន្លែងដែលអ្នកចាប់ផ្តើម ហើយនៅពេលនេះ អ្នកកំពុងនៅកន្លែងណា។
- ទាំងអស់នេះជាការវិវឌ្ឍន៍របស់អ្នកក្រោយពីការបណ្តុះបណ្តាលរយៈពេល ១០ ថ្ងៃ។

## ការប្រកាសប្រយោគ

១ ខ្ញុំបានរៀនច្រើនណាស់អំពីអាហារូបត្ថម្ភ

២ ពេលនេះខ្ញុំបានដឹងច្រើនជាងមុនអំពីជីវជាតិអា

៣ ខ្ញុំអាចរៀបចំជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា

៤ ខ្ញុំមានទំនុកចិត្តយ៉ាងខ្លាំងមកលើខ្លួនឯងក្នុងការផ្តល់ប្រឹក្សាដល់ស្ត្រីអំពីអាហារូបត្ថម្ភ

៥ ខ្ញុំបានរៀនច្រើនណាស់អំពីអ្វីៗដែលថ្មី

៦ ពីមុនខ្ញុំមិនបានដឹងអ្វីពីការផ្តល់ថ្នាំបង្ការទេ

៧ ខ្ញុំចូលចិត្តកម្មសិក្សាអនុវត្តន៍ ពីព្រោះវាធ្វើឱ្យខ្ញុំមានទំនុកចិត្តមកលើខ្លួនឯង

៨ ពេលនេះខ្ញុំដឹងពីរបៀបផ្តល់ប្រឹក្សា/ដំបូន្មានដល់ស្ត្រី

៩ ខ្ញុំមានមោទនៈ ពីអ្វីដែលបានរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាលនេះ

# ឯកសារយោង


គោលការណ៍ណែនាំសំរាប់គ្រូបណ្តុះបណ្តាល អំពីការផ្តល់ប្រឹក្សាការបំបៅកូនដោយទឹកដោះម្តាយ (១៩៩៣) WHO and UNICEF

ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា (ឆ្នាំ២០០៥) ។វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និងវិទ្យាស្ថានជាតិស្ថិតិ ភ្នំពេញ កម្ពុជា។ ORC Macro, Calverton, Maryland, USA ។

យុទ្ធសាស្ត្រការរស់រានមានជីវិតរបស់កុមារ កម្ពុជា ក្រសួងសុខាភិបាល (មេសា ២០០៧)

គោលការណ៍ណែនាំជាតិស្តីពីការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែកនិងអាស៊ីដហ្វូលីកសំរាប់ការពារ និងព្យាបាលភាពស្លេកស្លាំងចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយសម្រាល (សីហា ២០០៧) កម្មវិធីជាតិអាហារូបត្ថម្ភ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។ ភ្នំពេញ កម្ពុជា

យុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ ២០០៨-២០១៥។ កម្មវិធីជាតិអាហារូបត្ថម្ភ មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ភ្នំពេញ កម្ពុជា (ពង្រាង)

គោលនយោបាយជាតិស្តីពិជីវជាតិអា (កែសំរួលឡើងវិញ ២០០៧) កម្មវិធីជាតិអាហារូបត្ថម្ភ មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក នៃក្រសួងសុខភិបាល។ ភ្នំពេញ កម្ពុជា

របាយការណ៍ស្តីពីការពិនិត្យឡើងវិញនៃការអនុវត្តន៏សំណុំសកម្មភាពអប្បបរមា ម៉ូឌូលទី១០ នៅឆ្នាំ២០០៤។ (មិនា ២០០៥) ។ កម្មវិធីជាតិអាហារូបត្ថម្ភ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក នៃក្រសួងសុខភិបាល។ ភ្នំពេញ កម្ពុជា

វិធី ១០០ បែបដែលផ្តល់ថាមពលដល់ក្រុមៈ ល្បែងថាមពលដែលប្រើនៅក្នុងសិក្ខាសិលា ការប្រជុំ និងនៅក្នុងសហគមន៏។ (២០០៣) ។ សម្ព័ន្ធភាពអន្តរជាតិប្រយុទ្ធនឹងជម្ងឺអេដស៏ Brighton, United Kingdom ។


គំនូរខ្មែរ ដោយលោក រិន្ទ ហឿត

# ឧបសម្ព័ន្ធ


១ គោលការណ៍ណែនាំ/បញ្ជីផ្ទៀងផ្ទាត់សំរាប់រៀបចំការបណ្តុះបណ្តាល

២ វគ្គសម្របសម្រួលរយៈពេលកន្លះថ្ងៃសំរាប់ការបណ្តុះបណ្តាលអ្នកសម្របសម្រួល

៣ តេស្តមុនការសិក្សា

៤ តេស្តក្រោយការសិក្សា

៥ ចម្លើយទៅនឹងតេស្តមុននិងក្រោយការសិក្សា

៦ ល្បែងថាមពលបន្ថែម

៧ សម្ភារៈជំនួយការបណ្តុះបណ្តាល

៨ បញ្ជីផ្ទៀងផ្ទាត់ការសម្របសម្រួល

៩ បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សា

១០ ឧបករណ៍គាំទ្រមិត្តរួមការងារ

១១ ទម្រង់វាយតម្លៃ

# គោលការណ៍ណែនាំ/បញ្ជីផ្ទៀងផ្ទាត់ សំរាប់រៀបចំការបណ្តុះបណ្តាល

## សេចក្តីផ្តើម

គោលការណ៍ណែនាំនេះ គឺរៀបរៀងឡើងក្នុងគោលបំណងជួយអ្នកសម្របសម្រួល ដើម្បីរៀបចំការបណ្តុះបណ្តាលដោយមានប្រសិទ្ធភាព។ គោលការណ៍នេះបំពេញបង្គ្រប់ឯកសារបណ្តុះបណ្តាលសំណុំសកម្មភាពអប្បបរមាម៉ូឌុលទី១០។ សៀវភៅអ្នកសម្របសម្រួលមានជំពូកស្តីពីជំនាញសម្របសម្រួល ការបង្ហាញ និងការប្រស្រ័យទាក់ទង។ មេរៀនសម្របសម្រួលបន្ថែមកន្លះថ្ងៃ ត្រូវបានរៀបចំឡើងសំរាប់ការបណ្តុះបណ្តាលជំនាញសម្របសម្រួលសំរាប់គ្រូបង្គោលថ្នាក់មន្ទីរសុខាភិបាលខេត្ត/ស្រុកប្រតិបត្តិ។ បញ្ជីផ្ទៀងផ្ទាត់ជំនាញសម្របសម្រួល គឺជាផ្នែកមួយនៃសៀវភៅអ្នកសម្របសម្រួល និងគោលការណ៍ណែនាំនេះ។ អ្នកសម្របសម្រួលអាចប្រើប្រាស់វាដើម្បីវាយតម្លៃជំនាញសម្របសម្រួលរបស់ខ្លួនផ្ទាល់ ឬជំនាញសម្របសម្រួលរបស់អ្នកសម្របសម្រួលផ្សេងទៀត។

គោលការណ៍ណែនាំនេះ មានបញ្ជីផ្ទៀងផ្ទាត់៣សំរាប់ ការរៀបចំ ការដឹកនាំ និងការវាយតម្លៃការបណ្តុះបណ្តាល។ បញ្ជីផ្ទៀងផ្ទាត់ទី ១ ប្រើប្រាស់ដើម្បីរៀបចំមាតិកានៃវគ្គបណ្តុះបណ្តាល កាលវិភាគ និងសម្ភារៈ។ បញ្ជីផ្ទៀងផ្ទាត់ទី ២ គឺដើម្បីឱ្យប្រាកដថាអ្វីៗទាំងអស់ត្រូវបានរៀបចំជាស្រេច ពីរ-បីសប្តាហ៍មុនវគ្គបណ្តុះបណ្តាល និងក្នុងពេលបណ្តុះបណ្តាល។ បញ្ជីផ្ទៀងផ្ទាត់ទី ៣ ជួយក្នុងការវាយតម្លៃវគ្គបណ្តុះបណ្តាល។

បញ្ជីផ្ទៀងផ្ទាត់ត្រូវបានរៀបចំឡើងក្នុងបែបមួយដែលអ្នកអាចគូសនៅក្នុងប្រអប់ ដើម្បីឱ្យច្បាស់ថាអ្នកមិនមានភ្លេចជំហានណាមួយក្នុងការរៀបចំ ការអនុវត្តន៍ និងការវាយតម្លៃការបណ្តុះបណ្តាលឡើយ។

**សូមឱ្យសំណាងល្អជាមួយនឹងការសម្របសម្រួលវគ្គបណ្តុះបណ្តាលរបស់អ្នក!**

# បញ្ជីផ្ទៀងផ្ទាត់

## បញ្ជីផ្ទៀងផ្ទាត់ទី ១
## ដំណាក់កាលនៃការបង្កើតវគ្គបណ្តុះបណ្តាល

ប្រសិនបើអ្នកបានធ្វើជំហានណាមួយ សូមគូសក្នុងប្រអប់៖ ☑

១ ☐ ត្រូវការវគ្គបណ្តុះបណ្តាល (ផ្អែកលើផែនការប្រចាំឆ្នាំ)
២ ☐ ជ្រើសរើសប្រធានបទបណ្តុះបណ្តាល
៣ ☐ កំណត់គោលដៅ និងគោលបំណង
៤ ☐ ការធ្វើផែនការថវិកា សំណើរទៅម្ចាស់ជំនួយ
៥ ☐ កំណត់ក្រុមគោលដៅនៃសិក្ខាកាម/អ្នកចូលរួម
៦ ☐ ជ្រើសរើសអ្នកសម្របសម្រួល
៧ ☐ ប្រជុំជាមួយក្រុមអ្នកសម្របសម្រួល
៨ ☐ វាយតម្លៃលើតម្រូវការវគ្គបណ្តុបណ្តាលដោយគ្រូបង្គាត់
៩ ☐ ប្រជុំជាមួយក្រុមគ្រូ/អ្នកសម្របសម្រួលស្តីពីលទ្ធផលនៃការវាយតម្លៃ
១០ ☐ ការជ្រើសរើសសកម្មភាពដោយក្រុមគ្រូ/អ្នកសម្របសម្រួល
១១ ☐ ជ្រើសរើសសម្ភារៈបណ្តុះបណ្តាល
១២ ☐ ឆែកពិនិត្យមើលកំរិតនៃការចូលរួម ៖ តើជាការបណ្តុះបណ្តាលបែបចូលរួម?
១៣ ☐ បង្កើតកាលវិភាគសំរាប់ការបណ្តុះបណ្តាល
១៤ ☐ បង្កើតតេស្តមុននិងក្រោយការសិក្សា (ប្រសិនជាអាចអនុវត្តបាន)
១៥ ☐ សម្រេចចិត្ត និងរៀបចំទីកន្លែង ចំនួនថ្ងៃ ពេលវេលា
១៦ ☐ ពណ៌នាថវិកា
១៧ ☐ សម្រេចចិត្តលើយុទ្ធសាស្ត្រពិនិត្យគាំទ្រនិងវាយតម្លៃ
១៨ ☐ សម្រេចចិត្តលើយុទ្ធសាស្ត្រតាមដាន

# បញ្ជីផ្ទៀងផ្ទាត់ទី ២
# ដំណាក់កាលនៃការអនុវត្តន៍វគ្គបណ្តុះបណ្តាល

ប្រសិនបើអ្នកបានធ្វើជំហានណាមួយ សូមគូសក្នុងប្រអប់: ☑

**បីសប្តាហ៍ទៅមួយសប្តាហ៍មុនការណ្តុះបណ្តាល**

១ ☐ ពិនិត្យមើលទីកន្លែង ពេលវេលា និងថ្ងៃជាមួយអ្នកចាត់ការទីកន្លែង
២ ☐ ផ្ញើសំបុត្រអញ្ជើញចេញ

**ពីរ_បីថ្ងៃមុនការបណ្តុះបណ្តាល**

៣ ☐ រៀបចំក្រដាសផ្ទាំងធំដែលមានគោលដៅ ឬ ស្លាយសំរាប់បង្ហាញ ។ល។
៤ ☐ រៀបចំទម្រង់វាយតម្លៃ
៥ ☐ រៀបចំសម្ភារៈសំរាប់បង្រៀន
៦ ☐ រៀបចំឯកសារសំរាប់សិក្ខាកាម
៧ ☐ រៀបចំឯកសារតេស្តមុន និងក្រោយការសិក្សា
៨ ☐ ពិនិត្យមើល និងបញ្ជាក់ពីទីកន្លែង
៩ ☐ ពិនិត្យមើល និងបញ្ជាក់ពីសិក្ខាកាម
១០ ☐ រៀបចំបញ្ជីសិក្ខាកាម និងបញ្ជីប្រាក់ឧបត្ថម្ភ
១១ ☐ ចាត់ចែង និងរៀបចំស្លាយ អិលស៊ីឌី និងឯកសារបម្រុង (ពេលមានបញ្ហា)

**មួយថ្ងៃមុនការបណ្តុះបណ្តាល**

១២ ☐ ពិនិត្យមើលសម្ភារៈទាំងអស់ (ឯកសារ បញ្ជីឈ្មោះ ផ្លាកសញ្ញា ប្រាក់ឧបត្ថម្ភ)
១៣ ☐ ពិនិត្យមើលស្លាយ អិលស៊ីឌី និងឯកសារបម្រុង
១៤ ☐ ពិនិត្យមើល និងរៀបចំបន្ទប់ (កន្លែងអង្គុយ ម៉ាស៊ីនត្រជាក់ ។ល។)
១៥ ☐ រៀបចំអាហារសម្រន់ និងភេសជ្ជៈ

**នៅថ្ងៃបណ្តុះបណ្តាល**

១៦ ☐ ពិនិត្យមើលរាល់អ្វីដែលបានពិនិត្យមើលពីថ្ងៃមុន (១២-១៥)
១៧ ☐ បើកវគ្គ និងគោរពភ្លេងជាតិ
១៨ ☐ ផ្តល់បទបញ្ជាផ្ទៃក្នុង: ពេលវេលា ម៉ោងសម្រាក វិន័យ ។ល។
១៩ ☐ ធ្វើតេស្តមុនកាសិក្សា (បើអាចអនុវត្តន៍ទៅបាន)
២០ ☐ សុំឱ្យមានការប្តេជ្ញាចិត្ត
២១ ☐ ធ្វើតេស្តក្រោយការសិក្សា (បើអាចអនុវត្តន៍ទៅបាន)
២២ ☐ ធ្វើការវាយតម្លៃ
២៣ ☐ ឯកសារសំរាប់ចែកចាយ ប្រាក់ឧបត្ថម្ភ
២៤ ☐ បិទវគ្គ
២៥ ☐ ប្រជុំគ្រូ/អ្នកសម្របសម្រួលនៅចុងបញ្ចប់នៃថ្ងៃនិមួយៗ និងរក្សាកំណត់ហេតុនៃការប្រជុំ

**ជំនាញនៃការសម្របសម្រួល**

២៦ ☐ ស្ងិតស្ងាលរាក់ទាក់ មានចិត្តទូលាយ ស្មោះត្រង់
២៧ ☐ បង្កើតបរិយាកាសសុវត្ថិភាព មិនស្តីបន្ទោស
២៨ ☐ ផ្តល់ព័ត៌មានត្រលប់បែបវិជ្ជមាន (គំរូសាន់វិច)
២៩ ☐ មានចរិកដូចកូន"ទីទុយ": សួរខ្លួនឯង ហេតុអ្វី ធ្វើយ៉ាងម៉េច អ្វី (ឆ្លុះបញ្ចាំងខ្លួនឯង)

## បញ្ជីផ្ទៀងផ្ទាត់ទី ៣
## ដំណាក់កាលចុងក្រោយនៃវគ្គបណ្តុះបណ្តាល

ប្រសិនបើអ្នកបានធ្វើជំហានណាមួយ សូមគូសក្នុងប្រអប់ : ☑

សប្តាហ៍ក្រោយវគ្គបណ្តុះបណ្តាល

១ ☐ សរសេររបាយការណ៍ពីការពិភាក្សាគ្រូ/អ្នកសម្របសម្រួល
២ ☐ វិភាគទិន្នន័យបានមកពីទម្រង់វាយតម្លៃ
៣ ☐ សរសេររបាយការណ៍ទីមួយស្តីពីការបណ្តុះបណ្តាល
៤ ☐ ពិភាក្សារបាយការណ៍ជាមួយគ្រូ/អ្នកសម្របសម្រួល
៥ ☐ ផ្ញើរបាយការណ៍ទៅឱ្យប្រធាន
៦ ☐ ពិនិត្យមើលរបាយការណ៍ឡើងវិញ
៧ ☐ ពិនិត្យមើលការបណ្តុះបណ្តាលឡើងវិញសំរាប់ប្រើប្រាស់នៅពេលខាងមុខ
៨ ☐ ផ្ញើរបាយការណ៍ទៅឱ្យប្រធាន និងម្ចាស់ជំនួយ
៩ ☐ ពិនិត្យមើលផែនការសកម្មភាពគាំទ្រឡើងវិញ
១០ ☐ ចាប់ផ្តើមសកម្មភាពគាំទ្រ

# វគ្គសម្របសម្រួលរយៈពេលកន្លះថ្ងៃសំរាប់ការបណ្តុះបណ្តាលអ្នកសម្របសម្រួល

## សេចក្តីផ្តើម

វគ្គនេះគឺមានរយៈពេលមួយព្រឹក (ឬល្ងាច)។ នៅក្នុងអំឡុងពេលនៃវគ្គនេះ សិក្ខាកាមនឹងរៀនបន្ថែមទៀតអំពីការសម្របសម្រួល។ យើងនឹងបង្ហាញពីអ្វីជាការសម្របសម្រួល ហើយនិងគួរធ្វើយ៉ាងណាដើម្បីឱ្យការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។ វគ្គនេះគឺតម្រូវឱ្យមានការចូលរួមខ្ពស់ និងអញ្ជើញសិក្ខាកាមឱ្យចូលរួមនិងផ្តល់គំនិតយោបល់។ សិក្ខាកាមនឹងត្រូវបានស្នើសុំឱ្យចូលរួម ដោយចែករំលែកគំនិតយោបល់ពីជំនាញនៃការសម្របសម្រួល។

## ធ្វើឱ្យប្រសើរឡើងនូវជំនាញសម្របសម្រួល

នៅក្នុងអំឡុងពេលនៃសកម្មភាពផ្សេងៗ សិក្ខាកាមត្រូវបានអញ្ជើញឱ្យធ្វើការបង្ហាញពីវិធីដែលពួកគាត់ធ្វើការសម្របសម្រួល ក្នុងគោលបំណងផ្តល់ព័ត៌មានត្រលប់ដល់ពួកគាត់វិញពីវិធីធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលរបស់

ពួកគាត់ ។ របៀបដែលគេធ្វើការសម្របសម្រួលមានលក្ខណៈបុគ្គលផ្ទាល់ខ្លួន ។ គេអាចកែលំអបានប្រសិនបើគេយល់ថាហេតុអ្វីបានជាការសម្របសម្រួលខ្លះដែលគេបានធ្វើមិនមានប្រសិទ្ធភាព ហើយគេគួរធ្វើបែបណាដើម្បីផ្លាស់ប្ដូររបៀបសម្របសម្រួលគេឱ្យមានប្រសិទ្ធភាពវិញ ។ ប្រការនេះអាចកើតមានឡើងតែនៅក្នុងបរិយាកាសសុវត្ថិភាព និងរាក់ទាក់ស្និទ្ធស្នាលប៉ុណ្ណោះ ។

## គោលការណ៍សំខាន់ៗ

បរិយាកាសស្និទ្ធស្នាល និងសុវត្ថិភាព គឺជាការទទួលខុសត្រូវរបស់សិក្ខាកាមទាំងអស់ និងអ្នកដែលធ្វើការសម្របសម្រួលនៅក្នុងវគ្គនោះ ។ សិក្ខាកាមគួរមានអារម្មណ៍ មានសុវត្ថិភាពក្នុងវគ្គបណ្ដុះបណ្ដាល ព្រមទាំងទទួលព័ត៌មានត្រលប់តាមបែបវិជ្ជមាន ។ ការស្ដីបន្ទោសក្នុងរូបភាពបែបណាមួយ ឬការកំប្លែងចំពោះបុគ្គលគួរតែជៀសវាង ។ ការផ្ដល់ព័ត៌មានត្រលប់គួរផ្ដល់តាមបែបវិជ្ជមាន ដោយប្រើប្រាស់គំរូសាន់វិច ។ គំរូសាន់វិច មានន័យថាដំបូងអ្នកនិយាយអ្វីមួយបែបវិជ្ជមាន បន្ទាប់មកអ្នកផ្ដល់ព័ត៌មានត្រលប់បែបស្ថាបនា ហើយអ្នកបញ្ចប់ដោយអ្វីមួយដែលល្អ ។

**វិន័យសំរាប់វគ្គនេះ:**

- សិក្ខាកាមគួរមានអារម្មណ៍ថាមានសុវត្ថិភាព
- មិនត្រូវស្ដីបន្ទោសសិក្ខាកាម
- ផ្ដល់ព័ត៌មានត្រលប់បែបវិជ្ជមាន

## ការបង្រៀនមនុស្សពេញវ័យ

ការសិក្សារបស់មនុស្សពេញវ័យគឺមានលក្ខណៈស្មុគស្មាញ ប៉ុន្តែជាដំណើរការគួរឱ្យចាប់អារម្មណ៍ ។ ការសម្របសម្រួលការសិក្សារបស់កុមារមានលក្ខណៈងាយស្រួលជាង ។ ភាគច្រើននៃអ្វីដែលអ្នកបង្រៀនទៅកុមារ គឺថ្មីសំរាប់ពួកគេ ហើយជាទូទៅពួកគេធ្វើសកម្មភាពទាំងអស់នោះដោយគ្មានសួរអ្វីឡើយ ។ ប៉ុន្តែចំពោះមនុស្សពេញវ័យវិញ មានបទពិសោធន៍យ៉ាងច្រើន ហើយតែងតែព្យាយាមផ្សាភ្ជាប់អ្វីដែលពួកគាត់បានរៀនទៅនឹងការងាររបស់ពួកគាត់ ។ ទាំងនេះធ្វើឱ្យពួកគាត់ជាអ្នករៀនដែលវិភាគល្អិតល្អន់ជាងកុមារ ។ ហើយវាក៏ធ្វើឱ្យគាត់អាចប្រើប្រាស់ចំណេះដឹង និងជំនាញរបស់គាត់នៅក្នុងវគ្គបណ្ដុះបណ្ដាលផងដែរ ។ ឧទាហរណ៍ អ្នកអាចសុំឱ្យគាត់ប្រើប្រាស់បទពិសោធន៍របស់ពួកគាត់សំរាប់ល្បែងដើរតួ ជំនួសការបង្កើតប័ណ្ណល្បែងដើរតួ ។ ឬអ្នកអាចសុំឱ្យគាត់ពិភាក្សាគ្នា តើរឿងអ្វីមួយជាទូទៅកើតឡើងមកយ៉ាងដូចម្ដេច និងឱ្យពួកគាត់ចែករំលែកជាមួយសិក្ខាកាមផ្សេងទៀត ។

## វគ្គសិក្សាសម្របសម្រួល

កម្មវិធីសម្របសម្រួលគឺជាសមាសភាពមួយនៃបាវកថា និងសកម្មភាពផ្សេងៗ ។ អ្នកសម្របសម្រួលមានតួនាទីពិសេសមួយ: គាត់ត្រូវពន្យល់នូវអ្វីៗទាំងអស់ដែលគាត់កំពុងធ្វើក្នុងអំឡុងពេលនៃការសម្របសម្រួល ។ ឧទាហរណ៍: នៅពេលធ្វើបាវកថា អ្នកត្រូវប្រាប់សិក្ខាកាមថា ហេតុអ្វីបានជាអ្នកឈរនៅទីនេះ ហេតុដែលអ្នកប្រើពណ៌ផ្សេងៗគ្នានៅលើក្រដាសផ្ទាំងធំ របៀបដែលអ្នកប្រើសម្លេង និងរបៀបរក្សាការសម្លឹងមើលទៅសិក្ខាកាមនៅពេលអ្នកបង្រៀន ។

| ម៉ោងសិក្សា | ពេលល្វាច | រយៈពេល | មេរៀន | អ្នកណា |
| --- | --- | --- | --- | --- |
| ៨:០០ | ១.៣០ | ២០ | ភ្ជាប់ចំណុច<br>ល្បែងថាមពល | ទាំងអស់គ្នា |
| ៨:២០ | ១.៥០ | ១៥ | សេចក្តីផ្តើមបាឋកថា<br>អ្វីជាការសម្របសម្រួល | អ្នកសម្របសម្រួល |
| ៨:៣៥ | ២.០៥ | ៤៥ | អ្នកសម្របសម្រួលល្អ<br>ការងារជាក្រុមដើម្បីកំណត់ចរិកលក្ខណៈ<br>អ្នកសម្របសម្រួល | ក្រុម |
| ៩:២០ | ២.៥០ | ១០ | កូនទីទុយ<br>ល្បែងថាមពល | ក្រុមធំ |
| ៩:៣០ | ៣.០០ | ២០ | រឿងកូនទីទុយ<br>បាឋកថាស្តីពីការឆ្លុះបញ្ចាំងលើជំនាញនៃការ<br>សម្របសម្រួល | អ្នកសម្របសម្រួល |
| **៩:៥០** | **៣.២០** | **២០** | **សម្រាក** | |
| ១០:១០ | ៣.៤០ | ១៥ | ការសម្របសម្រួលមានប្រសិទ្ធភាព<br>បាឋកថា | អ្នកសម្របសម្រួល |
| ១០:២៥ | ៣.៥៥ | ១៥ | ប្រើប្រាស់ភាសាកាយវិការ<br>សកម្មភាពដើម្បីបង្ហាញពីសារៈសំខាន់នៃភាសាកាយវិការល្អ | អ្នកសម្របសម្រួល<br>សិក្ខាកាម |
| ១០:៤០ | ៤.១០ | ៤៥ | តួនាទីនិងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួល<br>លំហាត់តាមក្រុមដើម្បីកំណត់រកតួនាទី និងការទទួល<br>ខុសត្រូវរបស់អ្នកសម្របសម្រួល | បុគ្គលម្នាក់ៗ<br>៤ក្រុម<br>ក្រុមធំ |
| ១១:២៥ | ៤.៥៥ | ៥ | សង្ខេប<br>សង្ខេបសំរាប់ពេលព្រឹក | អ្នកសម្របសម្រួល |
| **១១:៣០** | **៥.០០** | | **បញ្ចប់** | |

## ម៉ោងសិក្សា

### ភ្ជាប់ចំណុច

**គោលបំណង** : នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមអាចចូលរួមក្នុងសកម្មភាពខាងក្រោម ដោយមានការលើកទឹកចិត្ត និងប្រកបដោយថាមពល ។

**អ្នកណា** : សិក្ខាកាមដោយមានការណែនាំពីអ្នកសម្របសម្រួល

**សម្ភារៈ** : ក្រដាសដែលមានលំហាត់ចំណុច (សូមមើលលំហាត់ទី ១២ សៀវភៅទំព័រ ៣៣ " ល្បែងទាំង ១០០ក្នុងវគ្គបណ្តុះបណ្តាល ")
ប៊ិច ឬដៃខ្មៅ

ការរៀបចំ

- ធ្វើការណែនាំសិក្ខាកាមឱ្យធ្វើការជាបុគ្គល
- ប្រគល់លំហាត់ទី ១ ដោយដាក់បញ្ច្រាស់ក្បាលចុះក្រោម ហើយសុំឱ្យសិក្ខាកាមរង់ចាំរហូតទាល់តែអ្នកសម្របសម្រួលបានពន្យល់ពីលំហាត់នោះ និងធ្វើជាសញ្ញាឱ្យត្រលប់ក្រដាសមកវិញ
- ពន្យល់ពីវិន័យនៃល្បែង :

វាអាស្រ័យទៅនឹងចំនួននៃចំណុចដែលមាននៅលើក្រដាស ចំណុចទាំងនោះគួរត្រូវបានភ្ជាប់គ្នាដោយ :

- ខ្សែ ៤ (លំហាត់ទី ១ មាន ៩ ចំណុច)
- ខ្សែ ៥ (លំហាត់ទី ២ មាន ១២ ចំណុច)
- ខ្សែ ៦ (លំហាត់ទី ៣ មាន ១៦ ចំណុច)
- មិនត្រូវហើបប៊ិចចេញពីក្រដាសទេ
- សិក្ខាកាមដែលឈ្នះនៅទីកទីមួយ ត្រូវបានប្រកាសថាជាអ្នកឈ្នះ និងត្រូវសុំឱ្យធ្វើការពន្យល់
- សិក្ខាកាមដែលឈ្នះនៅទីកទីពីរ ត្រូវបានប្រកាសថាជាអ្នកឈ្នះ និងត្រូវសុំឱ្យធ្វើការពន្យល់
- សិក្ខាកាមដែលឈ្នះនៅទីកទីបី ត្រូវបានប្រកាសថាជាអ្នកឈ្នះ និងត្រូវសុំឱ្យធ្វើការពន្យល់

## សេចក្តីផ្តើមការសម្របសម្រួល-១៥ នាទី

**គោលបំណង** : នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមអាចពន្យល់ពីអ្វីដែលជាការសម្របសម្រួល និងអ្វីដែលជាការលើកទឹកចិត្តដល់មនុស្សពេញវ័យឱ្យរៀន ។

**អ្នកណា** : បាឋកថា

**សម្ភារៈ** : ក្រដាសផ្ទាំងធំដែលបានរៀបចំជាស្រេច ឬស្លាយសំរាប់បង្ហាញ

## ការសម្របសម្រួល = ជួយមនុស្សឱ្យរៀន

ពន្យល់ដូចខាងក្រោម៖

**មនុស្សយើងរៀនតាមរយៈ**

| | |
|---|---|
| ការស្តាប់ | ការអាន |
| ការមើលឃើញ | ការសាកល្បង |
| ការគិត | ការធ្វើតាម |

**មនុស្សយើងនឹងរៀននៅពេលណាដែលគេយល់ឃើញថាអ្វីដែលគេរៀននោះមានប្រយោជន៍ចំពោះគេប៉ុណ្ណោះ។ នេះមានន័យថាគេអាចប្រើប្រាស់វាបាននៅក្នុងការរស់នៅ ឬនៅក្នុងការងាររបស់គេ។**

**ដូចនេះ,,, វាគ្រាន់តែលើសពីការជួយឱ្យមនុស្សរៀនតែបន្តិចប៉ុណ្ណោះ : ការសម្របសម្រួល=ការជួយមនុស្សឱ្យកែលំអនៅពេលដែលគេអនុវត្តជំនាញថ្មីនិងប្រើប្រាស់ចំណេះដឹងថ្មី។**

ពន្យល់អ្វីដែលអ្នកកំពុងធ្វើ :

- អ្នកឈរឆ្ងាយពីក្រដាសផ្ទាំងធំ/អេក្រង់
- អ្នកចង្អុលពាក្យសំខាន់ៗ
- អ្នកបញ្ជាក់ពីពាក្យសំខាន់ៗពេលនិយាយ និងគូសពីក្រោមពាក្យទាំងនោះ
- អ្នកក្រឡេកចុះឡើងក្នុងពេលធ្វើការបង្ហាញដើម្បីមើលសិក្ខាកាមទាំងអស់
- អ្នកប្រើប្រាស់ចំណុចគោលៗ និងមិនប្រើប្រាស់អត្ថបទច្រើនពេកនៅលើក្រដាសផ្ទាំងធំ ឬស្លាយ
- .........

# អ្នកសម្របសម្រួលដ៏ល្អម្នាក់-៤៥ នាទី

**គោលបំណង** : នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមនឹងឯកភាពទៅលើជំនាញសម្របសម្រួលដែលចង់បានសំរាប់អ្នកសម្របសម្រួលនៃវគ្គបណ្តុះបណ្តាល ។

**អ្នកណា** : ក្រុមដែលមានគ្នា ៤ នាក់ (យ៉ាងច្រើន)

**សម្ភារៈ** : ក្រដាសផ្ទាំងធំពីរដែលមានរូបគំនូរតុក្កតានៅលើនោះ ប៊ិចហ្វឺត បង់ស្អិត សកម្មភាព ង១ នៅក្នុងសៀវភៅអ្នកសម្របសម្រួល

## សន្ទិទានភាព

លំហាត់នៃការសម្របសម្រួលនេះ គឺសំរាប់តែការបណ្តុះបណ្តាលអ្នកសម្របសម្រួលប៉ុណ្ណោះ ។ លំហាត់នេះផ្តោតទៅលើលក្ខណៈវិនិច្ឆ័យនៃអ្នកសម្របសម្រួលល្អ ។ លំហាត់ខាងក្រោមនេះ នឹងរៀបរាប់លំអិតពីវិធីដែលមានលក្ខណៈជាការអនុវត្តន៍ជាក់ស្តែងជាង ។

## ការណែនាំ:

- ផ្តល់ដល់ក្រុមនិមួយៗនូវក្រដាសផ្ទាំងធំចំនួនពីរផ្ទាំងដែលមានរូបតុក្កតានៅនៅលើនោះ ។ ក្រដាសផ្ទាំងធំ ទីមួយគឺសំរាប់កត់ត្រាអំពីចរិកលក្ខណៈនៃអ្នកសម្របសម្រួលល្អ ។ ឯផ្ទាំងក្រដាសទី ២ គឺសំរាប់កត់ត្រាអំពីចរិកលក្ខណៈនៃអ្នកសម្របសម្រួលដែលមិនល្អ ។ ក្រដាសផ្ទាំងធំទី ១ នឹងឆ្លុះបញ្ចាំងទៅលើជំនាញសម្របសម្រួល ដែលចង់បានហើយក្រដាសផ្ទាំងធំទី ២ គឺជាការសម្របសម្រួលដែលគេមិនចង់បាន ។
- សុំឱ្យសិក្ខាកាមមានគំនិតឆ្នៃប្រឌិត ។
- អនុញ្ញាតិឱ្យក្រុមបញ្ចប់ការងារនេះក្នុងរយៈពេល ១០ នាទី ។ បន្ទាប់មកក្រុមនិមួយៗមានពេល ៥ នាទី ដើម្បីធ្វើការបង្ហាញ ។
- បន្ទាប់ពីការបង្ហាញ អ្នកសម្របសម្រួលនឹងធ្វើការសង្ខេប ព្រមទាំងធ្វើការបង្ហាញអំពីមាតិកានៃជំពូកនេះ ។

## តារាងកាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| សេចក្តីផ្តើម | ៥ |
| ការងារតាមក្រុម | ១៥ |
| ការបង្ហាញ | ២៥ |
| **សរុប** | **៤៥** |

## ទីទុយ - ល្បែងថវមពល - ១០ នាទី

**គោលបំណង :** នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមអាចចូលរួមក្នុងសកម្មភាពបន្តបន្ទាប់ទៀត ដោយមានការលើកទឹកចិត្ត និងថាមពល ។

**អ្នកណា :** សិក្ខាកាមដែលមានការណែនាំពីអ្នកសម្របសម្រួល

**សម្ភារៈ :** មិនមាន

### ការណែនាំ:

- អញ្ជើញសិក្ខាកាមឱ្យឈរជារង្វង់មួយ ។ សុំឱ្យពួកគេធ្វើតាមការណែនាំរបស់អ្នក ។
- ប្រាប់ឱ្យសិក្ខាកាមសម្លឹងមើលពីខាងលើស្មាខាងស្តាំរបស់ពួកគាត់ ហើយត្រូវចាំចំណុចឆ្ងាយបំផុតដែលពួកគាត់អាចមើលឃើញ ។
- ប្រាប់ឱ្យសិក្ខាកាមសម្លឹងមើលពីលើស្មាខាងឆ្វេងរបស់ពួកគាត់ ហើយក៏ត្រូវចាំចំណុចឆ្ងាយបំផុតដែលគាត់អាចមើលឃើញដែរ ។
- ពន្យល់ប្រាប់ថាអ្នកនឹងសុំឱ្យពួកគាត់បិទភ្នែក ហើយវាជាការសំខាន់ណាស់ក្នុងការរក្សាភ្នែកនៅបិទដដែលនោះរហូតដល់ពេលអ្នកប្រាប់ឱ្យបើកភ្នែកឡើងវិញ ។
- សួរសិក្ខាកាមថា តើអ្វីដែលបានពន្យល់ច្បាស់ដែល ឬទេ ។
- សុំឱ្យសិក្ខាកាមបិទភ្នែករបស់គាត់ ។
- ធ្វើការណែនាំពួកគាត់ឱ្យងាកក្បាលពីលើស្មាស្តាំឱ្យបានឆ្ងាយតាមដែលអាចធ្វើទៅបាន បន្ទាប់មកងាកមកខាងឆ្វេង ។ ងាកបែបនេះ ៣ ដង ។ រំលឹកពួកគាត់ឱ្យបិទភ្នែកដដែល ។
- សុំឱ្យសិក្ខាកាមបើកភ្នែក
- សុំឱ្យសិក្ខាកាមព្យាយាមមើលពីខាងលើស្មាស្តាំឱ្យបានឆ្ងាយទៅតាមដែលអាចធ្វើទៅបាន ។ តើពួកគាត់អាចមើលឃើញឆ្ងាយជាងពីមុនទេ? ចុះចំណែកខាងឆ្វេងវិញ?

## រឿងកូនទីទុយ - ២០ នាទី

**គោលបំណង :** នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមអាចសួរខ្លួនឯងនូវសំណួរ "ហេតុអ្វី " "អ្វី " និង "យ៉ាងម៉េច" ?

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** សៀវភៅរឿងកូនទីទុយ

### ការណែនាំ:

និទានរឿងកូនទីទុយ រឿងព្រេងបុរាណខ្មែរដែលនិយាយអំពីកូនទីទុយដែលចង់ដឹង ។

## រឿងកូនទីទុយ

កូនទីទុយរស់នៅជាមួយឪពុកម្តាយវា នៅក្នុងដើមឈើមួយដើមនៅក្នុងព្រៃ។ មើលពីដើមឈើដែលក្រុមគ្រួសារកូនទីទុយរស់នៅ កូនទីទុយឃើញអ្វីៗទាំងអស់ដែលកើតឡើងនៅក្នុងព្រៃ។ វាតែងតែសួរថា៖ "ហេតុអ្វី?" "ហេតុអ្វី?" ទៅកាន់សត្វទាំងអស់ដែលបានឆ្លងកាត់ដើមឈើដែលវារស់នៅ ឬដែលកំពុងធ្វើអ្វីមួយនៅក្នុងព្រៃនោះ។

ឪពុកម្តាយកូនទីទុយមិនសូវសប្បាយចិត្តនឹងសំណួររបស់កូនទីទុយដែលសួររាល់ពេលនោះទេ ពីព្រោះសត្វទីទុយ គួរស្រែកសួរ "នរណា! នណា!" ជំនួសសំណួរ "ហេតុអ្វី? " "ហេតុអ្វី?" គ្រប់តែពេលនោះ។

ដូចនេះឪពុកទីទុយក៏បាននាំកូនទីទុយទៅជួបតាទីទុយ ដើម្បីឱ្យប្រាកដថា តាទីទុយនឹងព្យាបាលកូនទីទុយឱ្យជា ហើយនិងអាចស្រែកដូចទីទុយពិតប្រាកដនៅពេលអនាគត។ ប៉ុន្តែតាទីទុយ គឺជាទីទុយចាស់ហើយឆ្លាតណាស់។ គាត់និយាយទៅកាន់កូនទីទុយថា កូនទីទុយគួរតែរក្សាសំណួរដដែល "ហេតុអ្វី?" "ហេតុអ្វី?" ពីព្រោះសំណួរនេះនឹងធ្វើឱ្យវាយល់ដឹងពីអ្វីៗទាំងអស់នៅក្នុងជីវិត និងធ្វើឱ្យវាជាសត្វឆ្លាតជាងគេនៅក្នុងព្រៃនោះ។

ពន្យល់ថាអ្នកចង់ឱ្យសិក្ខាកាមទាំងអស់ដូចកូនទីទុយ និងលើកជាសំណួរថា តើពួកគេកំពុងធ្វើអ្វី និងហេតុអ្វី នៅក្នុងអំឡុងពេលនៃការសម្របសម្រួល

**ដូចនេះ ,,, តែងតែសួរខ្លួនឯងថា៖**

## "ហេតុអ្វី? " "ហេតុអ្វី? "

**ដូចជា៖**

- ហេតុអ្វីបានជាខ្ញុំធ្វើដូចនេះ?
- ហេតុអ្វីបានជាសិក្ខាកាមកំពុងធ្វើបែបនោះ?
- ហេតុអ្វីបានជាពួកគេមិនធ្វើដូចអ្វីដែលខ្ញុំបានសង្ឃឹមទុក?
- ហេតុអ្វីបានជាឈរ/អង្គុយនៅទីនេះ?
- ហេតុអ្វីបានជាខ្ញុំមានអារម្មណ៍ល្អ?
- ហេតុអ្វីបានជាខ្ញុំមានអារម្មណ៍មិនល្អ?

**ប៉ុន្តែក៏ដូចនេះផងដែរ៖**

- តើខ្ញុំកំពុងធ្វើអ្វី?
- តើពួកគេកំពុងធ្វើអ្វី?
- តើខ្ញុំកំពុងឈរ/អង្គុយ/ដើរទៅកន្លែងណា?

សំណួរទាំងនេះជួយអ្នកដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលអ្នកកំពុងធ្វើ ឬបានធ្វើក្នុងអំឡុងពេលសម្របសម្រួល។ អ្នកសម្របសម្រួលល្អ តែងតែសម្លឹងមើលអ្វីដែលគេអាចធ្វើការកែលំអបាន។ គាត់តែងតែសួរខ្លួនឯងថា ហេតុអ្វីបានជាខុស ឬតើគាត់ធ្វើខុសអ្វី។

នៅពេលអ្វីមួយដំណើរការ ឬបានដំណើរការទៅខុស មិនត្រូវបន្ទោសកំហុសនេះទៅសិក្ខាកាមទេ ប៉ុន្តែព្យាយាមរកឱ្យឃើញថា អ្វីដែលអ្នកពន្យល់មិនបានល្អ អ្វីដែលអ្នកមិនបានប្រាប់សិក្ខាកាម និងអ្វីដែលអ្នកភ្លេចធ្វើ។

**សម្រាក ២០ នាទី**

## ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព–១៥ នាទី

**គោលបំណង :** នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមនឹងដឹងពីសារៈសំខាន់នៃឥរិយាបទរបស់ពួកគេក្នុងពេលធ្វើការសម្របសម្រួល។

**អ្នកណា :** អ្នកសម្របសម្រួល

**សម្ភារៈ :** ក្រដាសផ្ទាំងធំដែលបានរៀបចំរួចស្រេច ឬស្លាយសំរាប់បង្ហាញ

### ការណែនាំ:

ពន្យល់សិក្ខាកាមដូចខាងក្រោមនេះ :

## ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព

ការសម្របសម្រួលដែលមានប្រសិទ្ធភាពវាអាស្រ័យទៅលើអ្នកសម្របសម្រួល។ អ្នកសម្របសម្រួលគឺជាសិល្បៈករមួយរូបដែលសំដែលជាមួយខ្លួនឯង។

**ជាទូទៅគាត់:**

- រាក់ទាក់
- មានចិត្តទូលាយ
- ស្មោះត្រង់
- ចូលចិត្តជួយ

ឥរិយាបទដែលផ្ទុយពីនេះ នឹងមានឥទ្ធិពលអវិជ្ជមានទៅលើការលើកទឹកចិត្ត និងចិត្តចង់ទទួលរបស់សិក្ខាកាម។

**ឧទាហរណ៍ (បង្ហាញទៅសិក្ខាកាមថាអ្នកកំពុងតែខឹង) :**

អ្នកសម្របសម្រួលម្នាក់ដែលមានទឹកមុខខឹង ស្រែក ស្តីបន្ទោស ឬគំរាម គឺមិនល្អទេ។

**ឥឡូវធ្វើផ្ទុយមកវិញ**

**ឧទាហរណ៍ (បង្ហាញទៅសិក្ខាកាមថាអ្នកជាមនុស្សល្អគួរឱ្យចូលចិត្ត) :**

អ្នកសម្របសម្រួលម្នាក់ដែលមានទឹកមុខសប្បាយ ញញឹម និងស្ងប់ស្ងៀម គឺល្អជាងអ្នកសម្របសម្រួលមុនច្រើន។

**ប៉ុន្តែជួនកាលគាត់ត្រូវតែ :**

- ច្បាស់លាស់
- ម៉ឺងម៉ាត់
- មានការសម្រេចចិត្ត

ឧទាហរណ៍ : ប្រសិនបើក្រុមមួយដែលពិបាកគ្រប់គ្រង ឬគិតតែពីជជែកគ្នាក្នុងអំឡុងពេលនៃវគ្គសិក្សា។

## ការប្រើភាសាកាយវិការ-១៥ នាទី

**គោលបំណង ៖** នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមអាចប្រើភាសាកាយវិការសំរាប់ការសម្របសម្រួល ។

**អ្នកណា ៖** អ្នកសម្របសម្រួល សិក្ខាកាម

**សម្ភារៈ ៖**

**ការណែនាំ៖**

ពន្យល់ទៅសិក្ខាកាមថា ភាសាកាយវិការគឺជាទិដ្ឋភាពដ៏សំខាន់ក្នុងការសម្របសម្រួល ។ ប្រើភាសាកាយវិការខុស អ្នកអាចមានឥទ្ធិពលអវិជ្ជមានទៅលើអារម្មណ៍សិក្ខាកាម ។ ភាសាកាយវិការត្រឹមត្រូវនឹងទាក់ទាញសិក្ខាកាមឱ្យស្តាប់នូវអ្វីដែលអ្នកនិយាយ ។

### សួរសំណួរ

**តែងតែ៖**

- អញ្ជើញសិក្ខាកាមឱ្យសួរសំណួរ
- ថាឡើងវិញខ្លាំងៗនូវសំណួរដែលសិក្ខាកាមណាម្នាក់បានសួរ ដូចនេះសិក្ខាកាមទាំងអស់នឹងដឹងពីសំណួរដែលបានលើកឡើង
- ធ្វើការស្រាយបំភ្លឺសំណួរ ប្រសិនជាចាំបាច់
- ឆ្លើយទៅនឹងសំណួរឱ្យបានខ្លីនិងច្បាស់

ប្រសិនបើអ្នកមិនដឹងពីចម្លើយ សូមសួរទៅសិក្ខាកាមក្រែងលោមាននរណាម្នាក់ចង់ឆ្លើយនឹងសំណួរនោះ ឬអ្នកអាចប្រាប់ទៅសិក្ខាកាមថា អ្នកឆ្លើយនឹងសំណួរនោះនៅពេលក្រោយនៅថ្ងៃនេះ ឬនៅថ្ងៃស្អែក ។

ប្រសិនបើអ្នកសន្យាថានឹងឆ្លើយនឹងសំណួរនៅពេលក្រោយនោះ ដូចនេះអ្នកមិនត្រូវភ្លេចទេ ។

### អ្នកសម្របសម្រួលដែលមានប្រសិទ្ធភាពប្រើ៖

- ដៃ
- សម្លេង
- ភ្នែក
- មាត់

ធ្វើចលនាចុះឡើង

ឧទាហរណ៍:

- ប្រើដៃរបស់អ្នកដើម្បីចង្អុលទៅអ្វីមួយនៅលើក្រដាសផ្ទាំងធំ ឬស្លាយ
- ប្រើដៃរបស់អ្នកដើម្បីបង្ហាញពីអ្វីៗដូចជា "ធំ" "តូច" "ឆ្វេង" "ស្តាំ"
- លើក និងដាក់សម្លេងរបស់អ្នក ដើម្បីធ្វើអោយគេចង់ស្តាប់អ្នក
- សម្លឹងមើលទៅសិក្ខាកាម បើកភ្នែកធំៗឬតូច ក្រឡាប់ភ្នែកចុះឡើង
- ធ្វើចលនាចុះឡើងបន្តិច ពីស្តាំទៅឆ្វេងនៃក្រដាសផ្ទាំងធំ
- ដើរទៅរកក្រុម ហើយថយក្រោយមកវិញ

អញ្ជើញសិក្ខាកាមឱ្យក្រោកឈរ ហើយឈរជារង្វង់។ ចាប់ផ្តើមធ្វើមុខចំឡែកហើយអញ្ជើញសិក្ខាកាមទាំងអស់ធ្វើមុខដូចនោះនៅពេលតែមួយ និងមើលមុខគ្នាទៅវិញទៅមក។ សុំឱ្យអ្នកដែលនៅក្បែរអ្នកដូរមុខ ហើយសុំឱ្យសិក្ខាកាមទាំងអស់ធ្វើមុខដូចនោះនៅពេលតែមួយ។ បន្តធ្វើបែបនេះរហូតដល់សិក្ខាកាមទាំងអស់ធ្វើមុខត្រឹមត្រូវមួយ។ គេក៏អាចប្រើប្រាស់សម្លេង និងប្រើប្រាស់ដៃផងដែរ។

## តួនាទី និងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួល-៤៥ នាទី

**គោលបំណង :** នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមនឹងដឹងពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួល។

**អ្នកណា :** ៤ ក្រុម

**សម្ភារៈ :** ក្រដាសសំរាប់សរសេរ អា ៤
ប៊ិចហ្វឺត ៤ពណ៌ខុសៗគ្នា

### ការណែនាំ:

- រៀបចំរង្វង់ពាក់កណ្តាល ៤ នៅក្នុងបន្ទប់ ដោយមានកន្លែងអង្គុយគ្រប់គ្រាន់សំរាប់សិក្ខាកាមដែលធ្វើការជា ៤ ក្រុម។
- សុំឱ្យសិក្ខាកាមកុំប្តូរផ្លាស់កៅអី។
- ត្រូវប្រាកដថា មានក្រដាស អា ៤ គ្រប់គ្រាន់សំរាប់សិក្ខាកាមនៅក្នុងក្រុមនិមួយៗ។
- ផ្តល់ឱ្យសិក្ខាកាមទាំងអស់នូវប៊ិចហ្វឺតមួយ ដោយប្រាកដថាគ្រប់ក្រុមប្រើតែពណ៌មួយ (ក្រុមទី ១ ប្រើពណ៌ខៀវ ទី ២ ប្រើពណ៌បៃតង ,,,)។
- ពន្យល់ទៅសិក្ខាកាមថាសំរាប់ជុំទី ១ នៃលំហាត់នេះ ពួកគេត្រូវធ្វើការដោយស្ងៀមស្ងាត់ដោយខ្លួនឯង។
- សុំឱ្យសិក្ខាកាមគិតថា ការទទួលខុសត្រូវរបស់អ្នកសម្របសម្រួលម្នាក់។
- សុំឱ្យពួកគាត់សរសេរគំនិត ១ នៅលើក្រដាស ១ សន្លឹក។ បើនរណាម្នាក់មានគំនិត ៦ គាត់ត្រូវសរសេរគំនិត ១ នៅលើក្រដាស ១។ នៅចុងបញ្ចប់គាត់នឹងកាន់ក្រដាស ៦ សន្លឹក ដែលមានគំនិតនិមួយៗនៅលើនោះ។
- ទុកពេល ៥ នាទី សំរាប់ព្យុះគំនិតជាបុគ្គលម្នាក់ៗ។
- សុំឱ្យសិក្ខាកាមចែករំលែកគំនិតរបស់ពួកគេនៅក្នុងក្រុម។ សិក្ខាកាមម្នាក់ៗអាចផ្តល់តែគំនិត ១ តែប៉ុណ្ណោះក្នុង ១ ដង។

- ធ្វើតាមរបៀបនេះ សិក្ខាកាមទាំងអស់អាចផ្តល់គំនិតរបស់ពួកគេ។ ប្រសិនបើសិក្ខាកាមណាម្នាក់នៅក្នុងក្រុមបានផ្តល់គំនិតដូចគ្នារួចហើយ សិក្ខាកាមម្នាក់ទៀតអាចដាក់ក្រដាសរបស់គាត់នៅលើក្រដាសដែលមានគំនិតដូចគ្នានោះ។
- អញ្ជើញក្រុមនិមួយៗធ្វើការសម្រេចចិត្តពីសារៈសំខាន់នៃគំនិតរបស់គាត់តាមលំដាប់។ ពួកគាត់ធ្វើការងារនេះនៅក្នុងក្រុមតូចរបស់ពួកគាត់។
- ដាក់ក្រដាសផ្ទាំងធំដែលមាន "តួនាទី និងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួល" នៅខាងក្រោមចំកណ្តាលបន្ទប់។
- អញ្ជើញក្រុមទី ១ ឱ្យផ្តល់ឱ្យអ្នកនូវគំនិតសំខាន់បំផុតរបស់ពួកគេ ហើយដាក់វានៅខាងក្រោម នៅជុំវិញក្រដាសផ្ទាំងធំ។
- សុំឱ្យក្រុមទី ២ ផ្តល់នូវគំនិតសំខាន់បំផុតរបស់ពួកគេ ហើយធ្វើការសម្រេចថាតើដាក់វានៅកន្លែងណានៅខាងក្រោមនោះ។
- អ្នកធ្វើ "ផែនទីគំនិត" នៃ "តួនាទី និងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួល"។ បន្តរហូតដល់គំនិតរបស់ក្រុមទាំងអស់ត្រូវបានដាក់នៅក្នុងផែនទីគំនិតនោះ។
- ពិភាក្សាពីលទ្ធផលជាមួយសិក្ខាកាម។

## កាលវិភាគ

| សកម្មភាព | នាទី |
|---|---|
| ការណែនាំ | ៥ |
| ព្យុះគំនិតជាបុគ្គលម្នាក់ៗ | ៥ |
| ការជ្រើសរើសក្នុងក្រុមតូច | ១០ |
| ធ្វើផែនទីគំនិត | ១៥ |
| ពិភាក្សា | ១០ |
| **សរុប** | **៤៥** |

## សង្ខេប – ៥ នាទី

**គោលបំណង :** ការបិទវគ្គនៃការសម្របសម្រួល

**វិធីសាស្ត្រ :** សង្ខេប

### ការណែនាំ

- ធ្វើការសង្ខេបសកម្មភាពទាំងឡាយដែលបានធ្វើ និងធ្វើឡើងវិញនូវអ្វីដែលសំខាន់បំផុត។
- បង្ហាញគំរូដ៏ល្អមួយនៃការសម្របសម្រួល និងលើកឡើងនូវអ្វីដែលបានធ្វើ ដោយប្រើប្រាស់មេរៀនដែលបានរៀនកន្លែងមក។

# តេស្តមុន/ក្រោយការសិក្សា

១. សូមសរសេរបីចំណុច ដែលអ្នកត្រូវប្រាប់ទៅកាន់ស្ត្រីមានផ្ទៃពោះម្នាក់ អំពីអាហារូបត្ថម្ភក្នុងពេលមានផ្ទៃពោះ

២. តើអ្នកនឹងត្រូវធ្វើដូចម្តេចចំពោះបញ្ហាដូចខាងក្រោមនេះ :

សូលីដា មានផ្ទៃពោះកូនទីពីរ។ នាងមានផ្ទៃពោះប្រាំពីរខែហើយ។ នាងចិញ្ចឹមកូនទីមួយរបស់នាងដោយឱ្យម្សៅទឹកដោះគោ ដោយនាងគិតថានាងមិនមានទឹកដោះគ្រប់គ្រាន់សំរាប់កូនរបស់នាងទេ។ សូលីដាមានផែនការបំបៅកូនទីពីររបស់នាងដោយឱ្យម្សៅទឹកដោះគោដូចកូនទីមួយដែរ។

៣. សូមរៀបរាប់សញ្ញានៃការកង្វះជីវជាតិអា ឱ្យបាន ២

៤. ចូរបំពេញតារាងខាងក្រោមដើម្បីពន្យល់ថាតើអ្នកនឹងត្រូវធ្វើការព្យាបាលស្ត្រីមានផ្ទៃពោះម្នាក់ដែលមានសញ្ញាកង្វះជីវជាតិអា ដូចម្តេច?

## ការព្យាបាលកង្វះជីវជាតិអា នៅក្នុងអំឡុងពេលមានផ្ទៃពោះ

| សញ្ញាកង្វះជីវជាតិអា ធ្ងន់ធ្ងរ ជម្ងឺស្ងួតភ្នែកសកម្ម (ដំបៅកញ្ចក់ភ្នែក) | ខ្វាក់មាន់ ស្ងួតភ្នែក ឬស្នាមប៊ីតុត |
|---|---|
| ព្យាបាល | ព្យាបាល |
| | |

៥. ហេតុអ្វីបានជាការការពារភាពស្លេកស្លាំងចំពោះស្ត្រីមានផ្ទៃពោះ គឺជាការសំខាន់?

៦. តើអ្នកនឹងធ្វើការព្យាបាលស្ត្រីមានផ្ទៃពោះដែលមានភាពស្លេកស្លាំងខ្លាំង (បាតដៃស្លេកស្លាំងខ្លាំង) បែបណា?

៧. តើគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិកប៉ុន្មានគ្រាប់ ដែលអ្នកត្រូវផ្តល់ឱ្យទៅស្ត្រីមានផ្ទៃពោះ នៅការជួបពិនិត្យលើកទី១ និងនៅការជួបពិនិត្យលើកទី២?

៨. សូមសរសេរផលរំខាននៃថ្នាំជាតិដែក/អាស៊ីតហ្វូលិកឱ្យបាន ៣ ចំណុច និងដំបូន្មានដែលអ្នកនឹងផ្តល់ទៅឱ្យស្ត្រីអំពីផលរំខាននៃថ្នាំ

៩. តើមានផ្ទៃពោះបានប៉ុន្មានខែទើបអ្នកមានផ្ទៃពោះទទួលថ្នាំមេបង់ដាសុល ហើយក្នុងកំរិតដូសប៉ុន្មាន?

១០. តើហេតុអ្វីបានជាអ៊ីយ៉ូដមានសារៈសំខាន់នៅក្នុងអំឡុងពេលមានផ្ទៃពោះ?

១១. តើស្ត្រីមានផ្ទៃពោះអាចធ្វើដូចម្តេច ដើម្បីឱ្យច្បាស់ថាគាត់ទទួលជាតិអ៊ីយ៉ូដគ្រប់គ្រាន់នៅក្នុងអំឡុងពេលនៃការមានផ្ទៃពោះ?

១២. តើសារបីដែលអ្នកត្រូវផ្តល់ឱ្យទៅស្ត្រីមានផ្ទៃពោះអំពីការបំបៅកូនដោយទឹកដោះម្តាយគឺអ្វីខ្លះ?

១៣. សូមសរសេរផលប្រយោជន៍ ៣ នៃការពិនិត្យថៃទាំមុនពេលសម្រាល

១៤. សូមសរសេរ សកម្មភាពអាហារូបត្ថម្ភសំខាន់ៗ ៣ ដែលអ្នកនឹងត្រូវធ្វើនៅពេលសម្រាល និងបន្ទាប់ពី ២-៣ ម៉ោងដំបូងបន្ទាប់ពីសម្រាល

១៥. រាល់ស្ត្រីក្រោយសម្រាលគ្រប់រូបគួរទទួលគ្រាប់ថ្នាំជីវជាតិអា ជាតិដែក/អាស៊ីតហ្វូលីកនិងមេបង់ដាសុល។ សូមបំពេញតារាងខាងក្រោមដោយដាក់កំរិតដូស/បរិមាណ/ចំនួនកំរិតដូស ពេលវេលា និងកន្លែងដែលត្រូវចុះកំណត់ហេតុនៃជីវជាតិអា ជាតិដែក/អាស៊ីតហ្វូលីក និងមេបង់ដាសុលសំរាប់ស្ត្រីក្រោយសម្រាល

| ថ្នាំ | កំរិតដូស | ចំនួនគ្រាប់ថ្នាំ | ពេលណាដែលត្រូវឱ្យ | កត់ត្រានៅកន្លែងណា |
|---|---|---|---|---|
| ជីវជាតិអា | | | | |
| ជាតិដែក/អាស៊ីតហ្វូលីក | | | | |
| មេបង់ដាសុល | | | | |

១៦. សូមសរសេរសារឱ្យបានបីដែលអ្នកនឹងត្រូវផ្តល់ទៅឱ្យឪពុកម្តាយ/អ្នកថែទាំកុមារ អំពីការផ្តល់អាហារបន្ថែម

១៧. កុមារគ្រប់រូបចាប់ពីអាយុពី ៦-៥៩ ខែ ត្រូវទទួលគ្រាប់ថ្នាំជីវជាតិអា ពីរដងក្នុងមួយឆ្នាំ នៅខែឧសភា និងខែវិច្ឆិកា។

សូមបំពេញតារាងខាងក្រោម ហើយបំពេញតារាងការផ្តល់ថ្នាំមេបង់ដាសុលផងដែរ

| ក្រុមគោលដៅ | ដូសគ្រាប់ថ្នាំជីវជាតិអា | ដូសមេបង់ដាសុល | កត់ត្រានៅកន្លែងណា |
|---|---|---|---|
| កុមារ ៦-១១ ខែ | | | |
| កុមារ ១២-៥៩ ខែ | | ១២-២៣ ខែ<br>២៤-៥៩ ខែ | |

១៨. សូមសរសេរមូលហេតុនៃកង្វះអាហារូបត្ថម្ភចំពោះកុមារតូចឱ្យបាន ៣

១៩. តើសារគន្លឹះ ៤ ដែលអ្នកនឹងផ្តល់ទៅឱ្យឪពុកម្តាយ/អ្នកថែទាំកុមារ អំពីការចិញ្ចឹមទារក និងកុមារមានអ្វីខ្លះ?

២០. តើអ្នកមានដំបូន្មានអ្វីនឹងផ្តល់ សំរាប់បញ្ហាដូចខាងក្រោមៈ

រស្មីអាយុ ១២ ខែ។ នាងបានឈប់បៅដោះម្តាយនាងហើយ។ សព្វថ្ងៃនេះម្តាយនាង បញ្ចុកបបរដែលទិញពីផ្សារឱ្យនាង ២ ដង ក្នុង១ថ្ងៃ។ ម្តាយនាងក៏បានទិញឱ្យនាងផងដែរនូវទំកញ្ចប់ផ្សេងៗដែលគេលក់នៅក្នុងភូមិ។

២១. ធីតាសម្រាលកូនដំបូងបានមួយសប្តាហ៍ហើយ។នាងមានការព្រួយបារម្មណ៍យ៉ាងខ្លាំងដោយសារកូននាងយំ ជាញឹកញាប់។ ធីតាគិតថា នេះមកពីកូនរបស់នាងឃ្លាន ហើយនាងនិយាយថា នាងមិនមានទឹកដោះគ្រប់គ្រាន់ទេ

សូមរៀបរាប់ពីវិធីដែលអ្នកគ្រប់គ្រងបញ្ហានេះ

# ចម្លើយសំរាប់តេស្តមុន/ក្រោយការសិក្សា

១.  សូមសរសេរបីចំណុច ដែលអ្នកត្រូវប្រាប់ទៅកាន់ស្ត្រីមានផ្ទៃពោះម្នាក់ អំពីអាហារូបត្ថម្ភក្នុងពេលមានផ្ទៃពោះ

**ចម្លើយ**

- បរិភោគអាហារផ្សេងៗគ្នា ដូចជា ត្រី សាច់ ថ្លើម សណ្តែក គ្រាប់ធញ្ញជាតិ និងបន្លែផ្លែឈើគ្រប់ប្រភេទ
- បរិភោគអាហារបន្ថែម មួយពេលទៀតក្នុង១ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងការលូតលាស់របស់កុមារ និងម្តាយ
- ត្រូវដាក់អំបិលអ៊ីយ៉ូដជានិច្ច នៅក្នុងគ្រប់ម្ហូបអាហារគ្រួសារ
- បរិភោគទឹកស្អាតឱ្យបានច្រើន
- ចៀសវាងការតមអាហារតាមបែបជំនឿ

**២. តើអ្នកនឹងត្រូវធ្វើដូចម្តេចចំពោះបញ្ហាដូចខាងក្រោមនេះ :**

សូលីដា មានផ្ទៃពោះកូនទីពីរ ។ នាងមានផ្ទៃពោះប្រាំពីរខែហើយ ។ នាងចិញ្ចឹមកូនទីមួយរបស់នាងដោយឱ្យម្សៅទឹកដោះគោ ដោយនាងគិតថានាងមិនមានទឹកដោះគ្រប់គ្រាន់សំរាប់កូនរបស់នាងទេ ។ សូលីដាមានផែនការបំបៅកូនទីពីររបស់នាងដោយឱ្យម្សៅទឹកដោះគោដូចកូនទីមួយដែរ ។

**ចម្លើយ**

ធ្វើការពិភាក្សាជាមួយសូលីដាពីគុណសម្បត្តិនៃការបំបៅកូនដោយទឹកដោះម្តាយ ដោយប្រៀបធៀបទៅនឹងការបំបៅកូនដោយទឹកដោះគោម្សៅ: ទឹកដោះម្តាយតែងមានជានិច្ច អាចបំបៅកូនបានភ្លាមៗ មិនបាច់ចំណាយលុយ មានគ្រប់សារជាតិចិញ្ចឹម និងជាតិទឹកដែលកុមារត្រូវការរហូតដល់កុមារអាយុ ៦ ខែ ការពារកុមារពីជម្ងឺទូទៅផ្សេងៗ បង្កើនភាពស្និទ្ធស្នាលរវាងម្តាយ និងកូន ព្រមទាំងបង្កើនភាពវៃឆ្លាតរបស់កុមារ ។

ធ្វើការពិភាក្សាថាតើធ្វើយ៉ាងណាដើម្បីធានាថាម្តាយមានទឹកដោះគ្រប់គ្រាន់: ម្តាយត្រូវបរិភោគអាហារដែលមានសារជាតិចិញ្ចឹមក្នុងអំឡុងពេលមានផ្ទៃពោះ បរិភោគអាហារបន្ថែមមួយពេលទៀតក្នុងអំឡុងពេលមានផ្ទៃពោះ និងក្នុងអំឡុងពេលបំបៅកូន សម្រាកឱ្យបានគ្រប់គ្រាន់ ចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយភ្លាមបន្ទាប់ពីសម្រាល (នៅក្នុង១ម៉ោងដំបូង) និងបំបៅកូនឱ្យបានញឹកញាប់ ។

៣. សូមរៀបរាប់សញ្ញានៃការកង្វះជីវជាតិអាឱ្យបាន២:

**ចម្លើយ**

- ខ្វាក់មាន់
- ស្នាមប៊ីតុត
- រលាកកញ្ចក់ភ្នែក

៤. ចូរបំពេញតារាងខាងក្រោម ដើម្បីពន្យល់ថាតើអ្នកនឹងត្រូវធ្វើការព្យាបាលស្ត្រីមានផ្ទៃពោះម្នាក់ដែលមានសញ្ញាកង្វះជីវជាតិអា ដូចម្តេច?

## ការព្យាបាលកង្វះជីវជាតិអា នៅក្នុងអំឡុងពេលមានផ្ទៃពោះ

| សញ្ញាកង្វះជីវជាតិអា ធ្ងន់ធ្ងរ ជម្ងឺស្ងួតភ្នែកសកម្ម (ដំបៅកញ្ចក់ភ្នែក) | ខ្វាក់មាន់ ស្ងួតភ្នែក ឬស្នាមប៊ីតុត |
|---|---|
| ព្យាបាល | ព្យាបាល |
| | |

**ចម្លើយ**

| សញ្ញាកង្វះជីវជាតិអា ធ្ងន់ធ្ងរ ជម្ងឺស្ងួតភ្នែកសកម្ម (ដំបៅកញ្ចក់ភ្នែក) | ខ្វាក់មាន់ ស្ងួតភ្នែក ឬស្នាមប៊ីតុត |
|---|---|
| ព្យាបាល | ព្យាបាល |
| ឱ្យគ្រាប់ថ្នាំជីវជាតិអា ១គ្រាប់លេខ ២០០.០០០IU ហើយបញ្ជូនទៅកាន់មន្ទីរពេទ្យដើម្បីធ្វើការព្យាបាល | ឱ្យគ្រាប់ថ្នាំជីវជាតិអា ១ដូស ១០.០០០IU ក្នុង១ថ្ងៃ រយៈពេល ៣០ ថ្ងៃ<br>ប្រសិនបើមិនមានកំរិតដូសនេះទេ ឱ្យគ្រាប់ថ្នាំជីវជាតិចំរុះ (Multivitamin) ២ គ្រាប់ ក្នុង១ថ្ងៃ រយៈពេល ៣០ ថ្ងៃ |

**៥. ហេតុអ្វីបានជាការការពារភាពស្លេកស្លាំងចំពោះស្ត្រីមានផ្ទៃពោះ គឺជាការសំខាន់?**

**ចម្លើយ**

ភាពស្លេកស្លាំងនៅក្នុងអំឡុងពេលមានផ្ទៃពោះអាចចូលរួមចំណែកទៅក្នុងបញ្ហាខាងក្រោមៈ

- ប្រឈមនឹងការធ្លាក់ឈាមក្រោមពេលសម្រាល
- ការបង្ករោគ
- មរណៈភាពរបស់ម្តាយ
- កូនស្លាប់ក្នុងផ្ទៃបន្ទាប់ពីខែទី៧ នៃការមានផ្ទៃពោះ ឬនៅក្នុងអាទិត្យទី១ក្រោយការសម្រាល
- កូនកើតមិនគ្រប់គីឡូ

**៦. តើអ្នកនឹងធ្វើការព្យាបាលស្ត្រីមានផ្ទៃពោះដែលមានភាពស្លេកស្លាំងខ្លាំង (បាតដៃស្លេកស្លាំងខ្លាំង) បែបណា?**

**ចម្លើយ**

- ប្រសិនបើការមានផ្ទៃពោះតិចជាង ៣៦ សប្តាហ៍ ផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក១គ្រាប់ x ២ ដង ក្នុង១ថ្ងៃ ( ព្រឹក និងល្ងាច) រយៈពេល ៣ ខែ
- ប្រសិនបើការមានផ្ទៃពោះលើសពី ៣៦ សប្តាហ៍ ដោយមានបាតដៃស្លេកស្លាំងខ្លាំងនោះ ស្ត្រីនោះគួរត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែកដែលនៅជិតជាងគេដើម្បីទទួលការព្យាបាល

**៧. តើគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិកប៉ុន្មានគ្រាប់ ដែលអ្នកត្រូវផ្តល់ឱ្យទៅស្ត្រីមានផ្ទៃពោះនៅការជួបពិនិត្យលើកទី១ និងនៅការជួបពិនិត្យលើកទី២?**

**ចម្លើយ**

| លើទី ១ | លើកទី ២ |
|---|---|
| • ៦០ គ្រាប់ | ៣០ គ្រាប់ |

**៨. សូមសរសេរផលរំខាននៃថ្នាំជាតិដែក/អាស៊ីតហ្វូលិកឱ្យបាន៣ចំណុច និងដំបូន្មានដែលអ្នកនឹងផ្តល់ទៅឱ្យស្ត្រីអំពីផលរំខាននៃថ្នាំ**

**ចម្លើយ**

- លាមកពណ៌ខ្មៅ - ផ្តល់ដំបូន្មានថា នេះជាការធម្មតាទេ ហើយវាមិនមានប៉ះពាល់អ្វីទេ។ វាជាការសំខាន់ក្នុងការបន្តលេបគ្រាប់ថ្នាំ
- ចង្អោរ - ផ្តល់ដំបូន្មានឱ្យលេបគ្រាប់ថ្នាំ ជាមួយអាហារពេលល្ងាច
- រមួលពោះ - ផ្តល់ដំបូន្មានឱ្យលេបគ្រាប់ថ្នាំ ជាមួយអាហារពេលល្ងាច

- ទល់លាមក - ផ្តល់ដំបូន្មានឱ្យលេបគ្រាប់ថ្នាំជាតិដែក ជាមួយអាហារពេលល្ងាច ។ ហូបទឹកឱ្យបានច្រើន និងបរិភោគបន្លែផ្លែឈើឱ្យបានច្រើន

**៩. តើមានផ្ទៃពោះបានប៉ុន្មានខែទើបអ្នកមានផ្ទៃពោះទទួលថ្នាំមេបង់ជាសុល ហើយក្នុងកំរិតដូសប៉ុន្មាន?**

**ចម្លើយ**

- ក្រោយពីខែទី៣នៃការមានផ្ទៃពោះ ស្ត្រីគួរទទួល មេបង់ជាសុល១គ្រាប់ ៥០០មក្រ តែមួយដង ។

**១០. តើហេតុអ្វីបានជាអ៊ីយ៉ូដមានសារៈសំខាន់នៅក្នុងអំឡុងពេលមានផ្ទៃពោះ?**

**ចម្លើយ**

- អ៊ីយ៉ូដមានសារៈសំខាន់នៅក្នុងអំឡុងពេលមានផ្ទៃពោះ ពីព្រោះវាជួយឱ្យម្តាយ និងកូនមានសុខភាពល្អ ព្រមទាំងជួយឱ្យកូនលូតលាស់បានល្អ

**១១. តើស្ត្រីមានផ្ទៃពោះអាចធ្វើដូចម្តេច ដើម្បីឱ្យច្បាស់ថាគាត់ទទួលជាតិអ៊ីយ៉ូដគ្រប់គ្រាន់នៅក្នុងអំឡុងពេលនៃការមានផ្ទៃពោះ?**

**ចម្លើយ**

- ស្ត្រីមានផ្ទៃពោះគួរប្រើប្រាស់អំបិលអ៊ីយ៉ូដសំរាប់ការដាំស្ល និងបរិភោគអាហារសមុទ្រដូចជា មឹក បង្គាក្តាម និងត្រីសមុទ្រប្រសិនបើមាន

**១២. តើសារបីដែលអ្នកត្រូវផ្តល់ឱ្យទៅស្ត្រីមានផ្ទៃពោះអំពីការបំបៅកូនដោយទឹកដោះម្តាយគឺអ្វីខ្លះ?**

**ចម្លើយ**

- បំបៅកូនដោយទឹកដោះម្តាយភ្លាមបន្ទាប់ពីសម្រាលនៅក្នុងម៉ោងដំបូង
- ទឹកដោះព្រៃ (ទឹកដោះដំបូង) គឺសំបូរដោយសារជាតិចិញ្ចឹម នឹងផ្តល់ការការពារប្រឆាំងនឹងជម្ងឺកុមារភាពទូទៅ
- បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់កូនអាយុ ៦ ខែ
- មិនត្រូវផ្តល់អាហារផ្សេងៗនៅមុនការផ្តល់ទឹកដោះដំបូងម្តាយឡើយ សូម្បីតែទឹក ។ ទឹកដោះម្តាយមានគ្រប់សារជាតិចិញ្ចឹម និងទឹកដែលទារកត្រូវការសំរាប់ ៦ ខែដំបូង ។
- ការដាក់ស្បែកប៉ះស្បែករវាងម្តាយ និងទារកភ្លាមបន្ទាប់ពីសម្រាល ជំរុញដល់ការបំបៅដោះ និងភាពស្និទ្ធស្នាលរវាងម្តាយ និងទារក

១៣. សូមសរសេរផលប្រយោជន៍៣ នៃការពិនិត្យផ្ទៃទាំមុនពេលសម្រាល

**ចម្លើយ**

- ពិនិត្យមើលដើម្បីឱ្យដឹងថាម្តាយ និងទារកមានសុខភាពល្អ
- ផ្តល់ព័ត៌មាន និងការអប់រំសុខភាព អំពីវិធីដែលរក្សាសុខភាពឱ្យនៅល្អក្នុងពេលមានផ្ទៃពោះ
- ទទួលគ្រាប់ថ្នាំជាតិដែកដើម្បីការពារភាពស្លេកស្លាំង
- ទទួលគ្រាប់ថ្នាំមេបង់ដាសុល បន្ទាប់ពីបីខែដំបូងនៃការមានផ្ទៃពោះ
- រកមើលបញ្ហាទាន់ពេល និងធ្វើការបញ្ជូន ប្រសិនបើចាំបាច់
- ជួយម្តាយឱ្យរៀបចំផែនការសម្រាល

១៤. សូមសរសេរ សកម្មភាពអាហារូបត្ថម្ភសំខាន់ ៣ ដែលអ្នកនឹងត្រូវធ្វើនៅពេលសម្រាល និងបន្ទាប់ពី ២-៣ម៉ោងដំបូងបន្ទាប់ពីសម្រាល

**ចម្លើយ**

១ - ជួយម្តាយឱ្យដាក់ទារកបៅនៅម៉ោងដំបូងនៃការសម្រាល ដូចនេះទារកអាចទទួលផលប្រយោជន៍ពីទឹកដោះព្រៃ

២ - ជូតទារកឱ្យស្ងួត ហើយដាក់ទារកនៅលើទ្រូងម្តាយ ដើម្បីឱ្យស្បែកប៉ះស្បែក និងជំរុញកាបំបៅភ្លាមៗ

៣ - ផ្តល់ឱ្យម្តាយនូវគ្រាប់ថ្នាំជីវជាតិអា ជាតិដែក/អាស៊ីដហ្វូលីក និងមេបង់ដាសុលក្រោយពីការសម្រាលហើយ និងពន្យល់ប្រាប់ទៅគាត់នូវអ្វីដែលអ្នកបានឱ្យទៅគាត់ និងពន្យល់ថាហេតុអ្វីបានជាវាមានសារៈសំខាន់

១៥. រាល់ស្ត្រីក្រោយសម្រាលគ្រប់រូបគួរទទួលគ្រាប់ថ្នាំជីវជាតិអាជាតិដែក/អាស៊ីតហ្វូលីកនិងមេបង់ដាសុល។ សូមបំពេញតារាងខាងក្រោមដោយដាក់កំរិតដូស/បរិមាណ/ចំនួនកំរិតដូស ពេលវេលា និងកន្លែងដែលត្រូវចុះកំណត់ហេតុនៃជីវជាតិអា ជាតិដែក/អាស៊ីតហ្វូលីក និងមេបង់ដាសុលសំរាប់ស្ត្រីក្រោយសម្រាល

| ថ្នាំ | កំរិតដូស | ចំនួនគ្រាប់ថ្នាំ | ពេលណាដែលត្រូវឱ្យ | កត់ត្រានៅកន្លែងណា |
|---|---|---|---|---|
| ជីវជាតិអា | | | | |
| ជាតិដែក/ អាស៊ីតហ្វូលីក | | | | |
| មេបង់ដាសុល | | | | |

**ចម្លើយ**

| ថ្នាំ | កម្រិតដូស | ចំនួនគ្រាប់ថ្នាំ | ពេលណាដែលត្រូវឱ្យ | កត់ត្រានៅកន្លែងណា |
|---|---|---|---|---|
| ជីវជាតិអា | ២០០.០០០IU | ១ គ្រាប់ | ក្នុងអំឡុងពេល ៦សប្តាហ៍ដំបូង ក្រោយសម្រាល | |
| ជាតិដែក/ អាស៊ីតហ្វូលីក | ៦០ មក្រ ជាតិដែក | ៤២ គ្រាប់ | ១គ្រាប់ ក្នុង១ថ្ងៃ ក្រោយសម្រាល រយៈពេល៤២ថ្ងៃ | |
| មេបង់ដាសូល | ៥០០ មក្រ | ១ គ្រាប់ | ម្តងនៅក្នុង៦សប្តាហ៍ ដំបូង ក្រោយសម្រាល | |

១៦. សូមសរសេរសារឱ្យបានបីដែលអ្នកនឹងត្រូវផ្តល់ទៅឱ្យឪពុកម្តាយ/អ្នកថែទាំកុមារ អំពីការផ្តល់អាហារបន្ថែម

**ចម្លើយ**

- កុមារគ្រប់រូបត្រូវការ ការផ្តល់អាហារបន្ថែមនៅពេលដែលពួកគេមានអាយុបាន ៦ ខែ។ មុនអាយុ ៦ ខែ ទឹកដោះម្តាយមានសារជាតិចិញ្ចឹមគ្រប់គ្រាន់សំរាប់តម្រូវការរបស់កុមារ
- នៅអាយុ ៦ ខែ ទឹកដោះម្តាយមិនគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការអាហារូបត្ថម្ភ និងការលូតលាស់របស់កុមារទេ។ កុមារគួរត្រូវបានផ្តល់អាហារបន្ថែម។ ការបំបៅកូនដោយទឹកដោះម្តាយគួរបន្តឱ្យបានរយៈពេលវែងតាមដែលអាចធ្វើទៅបាន រហូតដល់កុមារអាយុបាន ២៤ ខែ ឬលើសពីនេះ
- ចាប់ផ្តើមផ្តល់អាហារបន្ថែមនៅអាយុ ៦ ខែ។ ចាប់ផ្តើមឱ្យបបរ ឬ ចេក ដំឡូងវល្លិ ឬល្ពៅពាចឱ្យម៉ត់ ចាប់ផ្តើមពីបរិមាណតិច (២-៣ ស្លាព្រាក្នុងមួយពេល) ហើយបង្កើនចំនួនបន្តិចម្តងៗ ព្រមទាំងផ្តល់ប្រភេទអាហារផ្សេងៗ
- ឱ្យបបរគ្រឿង (បបរដែលមានប្រភេទអាហារចំរុះ ដូចជា ត្រី សាច់ចញ្ច្រាំ ស៊ុត បន្លែបៃតង និង អំបិលអ៊ីយ៉ូដ។

១៧. កុមារគ្រប់រូបចាប់ពីអាយុពី ៦-៥៩ ខែ ត្រូវទទួលគ្រាប់ថ្នាំជីវជាតិអា ពីរដងក្នុងមួយឆ្នាំ នៅខែ ឧសភា និង ខែ វិច្ឆិកា។

សូមបំពេញតារាងខាងក្រោម ហើយបំពេញតារាងការផ្តល់ថ្នាំមេបង់ដាសុលផងដែរ

| ក្រុមគោលដៅ | ដូសគ្រាប់ថ្នាំ ជីវជាតិអា | ដូសមេបង់ដាសុល | កត់ត្រានៅកន្លែងណា |
|---|---|---|---|
| កុមារ ៦-១១ ខែ | | | |
| កុមារ ១២-៥៩ ខែ | | ១២-២៣ ខែ<br><br>២៤-៥៩ ខែ | |

**ចម្លើយ**

| ក្រុមគោលដៅ | ដូសគ្រាប់ថ្នាំ ជីវជាតិអា | ដូសមេបង់ដាសុល | កត់ត្រានៅកន្លែងណា |
|---|---|---|---|
| កុមារ ៦-១១ ខែ | ១០០.០០០IU<br>(១គ្រាប់) | មិនឱ្យមេបង់ដាសុលទេ | ប័ណ្ណលឿង<br>សន្លឹកកត់ត្រា<br>បញ្ជីសំរាប់អ្នកស្ម័គ្រចិត្ត |
| កុមារ ១២-៥៩ ខែ | ២០០.០០០IU<br>(១គ្រាប់) | ១២-២៣ ខែ<br>កន្លះគ្រាប់ (២៥០ មក្រ)<br>២៤-៥៩ខែ<br>១គ្រាប់ (៥០០ មក្រ) | ប័ណ្ណលឿង<br>សន្លឹកកត់ត្រា<br>បញ្ជីសំរាប់អ្នកស្ម័គ្រចិត្ត |

១៨. សូមសរសេរមូលហេតុនៃកង្វះអាហារូបត្ថម្ភចំពោះកុមារតូចឱ្យបាន៣

**ចម្លើយ**

- មិនបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់អាយុ ៦ ខែ
- មិនបានផ្តល់អាហារគ្រប់គ្រាន់/បរិមាណគ្រប់គ្រាន់ក្នុងមួយពេលៗ
- មិនបានផ្តល់អាហារឱ្យបានញឹកញាប់
- មិនបានផ្តល់អាហារប្រភេទផ្សេងៗគ្នា
- អាហារមិនមានសារជាតិចិញ្ចឹមគ្រប់គ្រាន់
- កុមារមានជម្ងឺ

**១៩. តើសារគន្លឹះ ៤ដែលអ្នកនឹងផ្តល់ទៅឱ្យឪពុកម្តាយ/អ្នកថែទាំកុមារ អំពីការចិញ្ចឹមទារក និងកុមារមានអ្វីខ្លះ?**

**ចម្លើយ**

- បំបៅកូនដោយទឹកដោះម្តាយនៅក្នុងម៉ោងដំបូងបន្ទាប់ពីសម្រាល
- បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់៦ខែ
- មិនត្រូវផ្តល់អាហារអ្វីផ្សេងនៅក្នុង៦ខែដំបូង
- ចាប់ផ្តើមផ្តល់អាហារបន្ថែមដល់កុមារនៅអាយុ ៦ ខែ ផ្តល់ប្រភេទអាហារដែលមានសារជាតិចិញ្ចឹមប្លែកៗគ្នា
- មានអនាម័យល្អ នៅពេលរៀបចំធ្វើ និងនៅពេលបញ្ចុកកុមារ
- បន្តបំបៅកូនដោយទឹកដោះម្តាយ យ៉ាងហោចណាស់រហូតដល់កូនមានអាយុបាន ២៤ ខែ ឬលើសពីនោះ
- នាំកូនទៅទទួលថ្នាំបង្ការ តាមការផ្តល់ដំបូន្មានរបស់បុគ្គលិកសុខាភិបាល
- នាំកូនដែលមានអាយុពី ៦-៥៩ ខែ ទៅទទួលគ្រាប់ថ្នាំជីវជាតិអានៅ ខែ ឧសភា និង ខែ វិច្ឆិកា
- ប្រើប្រាស់អំបិលអ៊ីយ៉ូដក្នុងគ្រប់អាហារគ្រួសារ

**២០. តើអ្នកមានដំបូន្មានអ្វីនឹងផ្តល់ សំរាប់បញ្ហាដូចខាងក្រោមៈ**

រស្មីអាយុ ១២ ខែ ។ នាងបានឈប់បៅដោះម្តាយនាងហើយ ។ សព្វថ្ងៃនេះម្តាយនាង បញ្ចុកបបរដែលទិញពីផ្សារឱ្យនាង ២ ដង ក្នុង១ថ្ងៃ ។ ម្តាយនាងក៏បានទិញឱ្យនាងផងដែរនូវនំកញ្ចប់ផ្សេងៗដែលគេលក់នៅក្នុងភូមិ ។

**ចម្លើយ**

រស្មីត្រូវការញ៉ាំអាហារ ៣ ដង ក្នុងមួយថ្ងៃ។ បបរគ្រឿង ៣ ចានចង្កើះ ឬអាហារគ្រួសារដែលពាចឱ្យម៉ត់ ឬចិញ្ច្រាំ បើចាំបាច់ រួមនិងអាហារក្រៅពេល ២ ដង ក្នុងមួយថ្ងៃ ដូចជាផ្លែឈើ ឬនំប៉័ង។ លើកទឹកចិត្តរស្មីឱ្យញ៉ាំជាមួយគ្រួសារ ។ ចៀសវាងនំកញ្ចប់ខ្លះ ដោយសារវាថ្លៃ ហើយប្រហែលជាមិនសូវសំបូរសារជាតិចិញ្ចឹមផងដែរ ។

**២១. ធីតាសម្រាលកូនដំបូងបានមួយសប្តាហ៍ហើយ។ នាងមានការព្រួយបារម្ភណ៍យ៉ាងខ្លាំងដោយសារកូននាងយំជាញឹកញាប់។ ធីតាគិតថា នេះមកពីកូនរបស់នាងឃ្លាន ហើយនាងនិយាយថា នាងមិនមានទឹកដោះគ្រប់គ្រាន់ទេ សូមរៀបរាប់ពីវិធីដែលអ្នកគ្រប់គ្រងបញ្ហានេះ**

**ចម្លើយ**

អង្គុយជាមួយធីតាដើម្បីធ្វើការសង្កេតមើលកូនរបស់នាងបៅ ។ ប្រាប់ធីតាថា នាងមិនអីទេ ។
ពិនិត្យមើលថាតើកូននាងបានផ្អិបមាត់ទៅនឹងដោះដែរ ឬទេ ដោយសង្កេតមើលៈ

- មាត់ទារកបើកធំ
- បបូរមាត់ខាងក្រោមបើកចេញទៅក្រៅ
- រង្វង់ខ្មៅជុំវិញដោះនៅក្នុងមាត់ទារកច្រើន
- ចង្កាទារកប៉ះនឹងដោះម្តាយ

- ខ្លួនរបស់ទារកកៀកទៅនឹងខ្លួនម្តាយ ខ្លួនទាំងមូលបែរទៅរកដោះ
- ថ្ពាល់ទារកឡើងមូល
- ទារកជញ្ជក់មួយៗ ដោយមានសម្រាក
- អាចឃើញ ឬលឺពេលទារកលេបទឹកដោះ
- ខ្លួនទារកទ្រទ្របានល្អ

ប្រសិនបើការដាក់មាត់ផ្ទឹបទៅនឹងដោះមិនជួយគាំទ្រម្តាយបានល្អទេ ផ្តល់ដំបូន្មានម្តាយឱ្យបំបៅកូនឱ្យបាន ញឹកញាប់ យប់ និងថ្ងៃ

# ល្បែងថាមពលបន្ថែម

## អ្នកណាជាអ្នកដឹកនាំ

សិក្ខាកាមអង្គុយជារង្វង់។ សិក្ខាកាមម្នាក់ស្ម័គ្រចិត្តចាកចេញពីបន្ទប់។ បន្ទាប់ពីគាត់បានចាកចេញពីបន្ទប់ អ្នកដែលនៅសល់ជ្រើសរើស "អ្នកដឹកនាំ" ម្នាក់។ អ្នកដឹកនាំត្រូវធ្វើកាយវិកាមួយចំនួនដូចជា ទះដៃ គោះជើង ។ល។ ដែលត្រូវបានធ្វើតាមដោយក្រុមទាំងមូល។ អ្នកស្ម័គ្រចិត្តត្រូវបានអញ្ជើញឱ្យត្រលប់ចូលក្នុងបន្ទប់វិញឱ្យឈរ នៅចំកណ្តាលនៃបន្ទប់និងព្យាយាមធ្វើការទស្សន៍ទាយថា តើអ្នកណាកំពុងដឹកនាំសកម្មភាពនេះដែលធ្វើត្រាប់ដោយអ្នកផ្សេងទៀតនោះ។ សមាជិកការពារអ្នកដឹកនាំដោយមិនសម្លឹងមើលទៅគាត់ទេ។ អ្នកដឹកនាំត្រូវផ្លាស់ប្តូរកាយវិកានៅក្នុងរយៈពេលមួយដ៏ទៀងទាត់ដោយមិនឱ្យគេចាប់បាន។ នៅពេលដែលអ្នកស្ម័គ្រចិត្តរកឃើញអ្នកដឹកនាំ គាត់ត្រូវចង្អុលទៅអ្នកដឹកនាំនោះ។ ឥឡូវអ្នកដឹកនាំក្លាយជាអ្នកបន្ទាប់ដែលត្រូវចាកចេញពីបន្ទប់។ អ្នកស្ម័គ្រចិត្តពីមុនចូលរួមក្នុងរង្វង់ ហើយល្បែងនេះត្រូវបានចាប់ផ្តើមឡើងវិញ។

## តើអ្នកឯងជាអ្នកណា?

សុំឱ្យអ្នកស្ម័គ្រចិត្តចាកចេញពីបន្ទប់។ នៅពេលអ្នកស្ម័គ្រចិត្តមិននៅនោះ សិក្ខាកាមដែលនៅសល់ ធ្វើការសម្រេចចិត្តរើសមុខរបរមួយសំរាប់គាត់ ដូចជា អ្នករត់ម៉ូតូឌុប អ្នកនេសាទ ឬអ្នកលក់នំប៉ុង។ នៅពេលដែលអ្នកស្ម័គ្រចិត្តត្រលប់មកវិញ សិក្ខាកាមទាំងអស់ធ្វើត្រាប់សកម្មភាពដែលឆ្លុះបញ្ចាំងទៅនឹងមុខរបរដែលពួកគាត់បានជ្រើសរើសសំរាប់អ្នកស្ម័គ្រចិត្ត។ អ្នកស្ម័គ្រចិត្តត្រូវតែធ្វើការទាយពីមុខរបរដែលគេបានជ្រើសរើសសំរាប់គាត់ ពីសកម្មភាពដែលពួកគេធ្វើត្រាប់។

## ព្រះអាទិត្យរះនៅលើ...

សិក្ខាកាមឈរជារង្វង់កៀកគ្នាមួយដែលមានសិក្ខាកាមម្នាក់នៅចំកណ្តាល។ អ្នកដែលឈរនៅចំកណ្តាលស្រែកថា៖ "ព្រះអាទិត្យរះនៅលើ,,," និងហៅឈ្មោះពណ៌មួយ ឬសំលៀកបំពាក់ដែលក្រុមស្លៀក។ ឧទាហរណ៍៖ "ព្រះអាទិត្យរះនៅលើអ្នកដែលស្លៀកពាក់ពណ៌ខៀវ " ឬ "ព្រះអាទិត្យរះនៅលើអ្នកដែលពាក់ស្រោមជើង"។ សិក្ខាកាមដែលមានរបស់នោះត្រូវប្តូរទីកន្លែងជាមួយម្នាក់ផ្សេងទៀត។ នៅពេលដែលពួកគាត់ធ្វើការផ្លាស់ប្តូរកន្លែង អ្នកដែលនៅកណ្តាលគេព្យាយាមដណ្តើមយកកន្លែងរបស់អ្នកផ្សេងទៀង ដូចនេះនឹងមានមនុស្សម្នាក់នៅសល់នៅកណ្តាលគេដោយពុំមានកន្លែង។ អ្នកថ្មីនោះត្រូវស្រែក "ព្រះអាទិត្យរះនៅលើ ... " និងហៅឈ្មោះពណ៌ផ្សេងមួយទៀត ឬប្រភេទសំលៀកបំពាក់។

## ធ្វើជារូបចម្លាក់...

សុំឱ្យសិក្ខាកាមដើរជុំវិញនៅក្នុងបន្ទប់ បង់បោយដៃខ្លាំងៗ និងធ្វើចលនាសម្រួលក្បាល និងកបន្តិចៗផង។ ក្រោយពីបានដើរមួយភ្លែត អ្នកត្រូវស្រែកពាក្យមួយ។ សិក្ខាកាមទាំងអស់ត្រូវរួមគ្នាធ្វើជារូបចម្លាក់ដែលឆ្លើយតបទៅនឹងពាក្យដែលបានស្រែក ដូចជា "អ្នករត់ម៉ូតូឌុប" ឬ "ដំរេតខ្លួននៅមាត់សមុទ្រ" ឬ "ដើមឈើ" ជាដើម។ សិក្ខាកាមទាំងអស់ត្រូវធ្វើជារូបចម្លាក់ភ្លាមៗដោយមិនជជែកគ្នា។ ធ្វើលំហាត់នេះឡើងវិញជាច្រើនសារដោយពាក្យផ្សេងៗ។

## ទឹកជោរ ទឹកនាច

គូរបន្ទាត់មួយនៅខាងក្រោម (លើឥដ្ឋ/ដី) ដែលតំណាងឱ្យជ្រាំងសមុទ្រ។ សុំឱ្យសិក្ខាកាមឈរនៅខាងក្រោយបន្ទាត់។ នៅពេលអ្នកសម្របសម្រួលស្រែកថា "ទឹកនាច" គ្រប់ៗគ្នាត្រូវលោតទៅមុខរំលងបន្ទាត់។ នៅពេលដែលអ្នកសម្របសម្រួលស្រែកថា "ទឹកជោរ" គ្រប់គ្នាត្រូវលោតមករំលងបន្ទាត់មកក្រោយវិញ។ អ្នកសម្របសម្រួលអាចស្រែក "ទឹកនាចៗ" ពីរដង។ អ្នកណាដែលលោតទៅមុខពេលស្រែកលើកទីពីរ នឹងត្រូវជំរុសចេញពីការលេងល្បែងនោះ។

## យកមកឱ្យខ្ញុំ

ចែកសិក្ខាកាមជា ៥ ក្រុម។ ពួកគាត់ឈរឱ្យឆ្ងាយពីអ្នកសម្របសម្រួលតាមដែលអាចធ្វើទៅបាន។ បន្ទាប់មកអ្នកសម្របសម្រួលស្រែកឡើងថា "យកមកឱ្យខ្ញុំ..." និងហៅឈ្មោះវត្ថុអ្វីមួយ។ ឧទាហរណ៍ៈ "យកមកឱ្យខ្ញុំស្រោមជើង បុរស ឬស្ត្រីម្នាក់"។ ក្រុមទាំងឡាយប្រណាំងគ្នាទៅយកអ្វីដែលអ្នកសម្របសម្រួលបានស្នើឡើង។ វាគួរជារបស់ដែលក្រុមអាចយកបានដោយមិនចាំបាច់ចាកចេញពីបន្ទប់។ សុំឱ្យគាត់យកឱ្យរបស់ផ្សេងៗ។ ក្រុមដែលយករបស់បានច្រើនជាងគេ លឿនជាងគេ គឺជាអ្នកឈ្នះ។

## បញ្ជូនថាមពល

សិក្ខាកាមឈរជារង្វង់មួយ កាន់ដៃគ្នាហើយផ្តោតអារម្មណ៍ដោយស្ងៀមស្ងាត់។ អ្នកសម្របសម្រួលបញ្ជូនចរន្តអគ្គិសនី តាមផ្លូវទាំងពីរជុំវិញដោយច្របាច់ដៃអ្នកដែលនៅជាប់នឹងគាត់។ សិក្ខាកាមបញ្ជូនចរន្តអគ្គិសនីបន្តជុំវិញជារង្វង់ដោយច្របាច់ដៃអ្នកដែលនៅជាប់នឹងគាត់។

## កន្ទុយនាគ

### ត្រូវការក្រមាពីរ

ប្រាប់ឱ្យសិក្ខាកាមចែកជាពីរក្រុម។ ក្រុមទាំងពីរធ្វើជាសត្វនាគដោយកាន់ចង្កេះបន្តគ្នាជាខ្សែវែងមួយ។ អ្នកដែលនៅចុងក្រោយគេមានក្រមាពណ៌ភ្លឺមួយស៊កចូលក្នុងខោ ឬសំពត់របស់គាត់ដើម្បីធ្វើជារាងកន្ទុយនាគ។ ក្រុមមួយទៀត ត្រូវតាមចាប់កន្ទុយនាគរបស់ក្រុមមួយផ្សេងទៀត ដោយមិនឱ្យបាត់បង់កន្ទុយរបស់ខ្លួននៅក្នុងពេលដណ្តើមកន្ទុយគ្នានោះ។

## ការរាប់លេខ

សុំឱ្យសិក្ខាកាមឈរជារង្វង់ ។ ពន្យល់ក្រុមត្រូវរាប់ជាមួយគ្នាពី ១ ដល់ ៥០ មួយម្តងៗ ។ មានវិន័យមួយចំនួនៈ សិក្ខាកាមមិនអនុញ្ញាតិឱ្យថាលេខ" ប្រាំពីរ" ឬលេខដែលជាពហុគុណនៃប្រាំពីរ ។ ជំនួសដោយការរាប់នោះ សិក្ខាកាមត្រូវតែទះដៃ ។ បើសិនជាអ្នកណាម្នាក់ថាលេខប្រាំពីរ ឬពហុគុណនៃប្រាំពីរនោះ គេត្រូវចាក់ចេញពីរង្វង់ ។

## អូ កាបីតា !

សុំឱ្យសិក្ខាកាមឈរជារង្វង់។ គ្រប់គ្នាត្រូវនិយាយពាក្យ "អូ កាបីតា " ម្នាក់ម្តងៗ តាមវិធីផ្សេងៗគ្នាតាមតែអាចធ្វើទៅបាន។ ឧទាហរណ៏ៈ ដោយកំហឹង ដោយអស់សំណើចជាដើម។ សិក្ខាកាមម្នាក់ៗអាចថាពាក្យ "អូ កាបីតា" តែម្តងនៅពេលនិមួយៗ។ ក្រោយពីជុំទីមួយ សុំឱ្យសិក្ខាកាមត្រូវនិយាយពាក្យនេះឱ្យលឿន។

# សម្ភារៈជំនួយការបណ្តុះបណ្តាល -១ .១៣
# ការរៀបមុខម្ហូបចូលគ្នា - ការងារតាមក្រុម

ដុំនៃរូបភាព ត្រូវផ្តល់ទៅឱ្យសិក្ខាកាមនៃក្រុមនិមួយៗ។ ថតចម្លងសន្លឹករូបភាពហើយកាត់រូបភាពទាំងនោះដាក់ជាដុំនៃរូបភាព។


























# សម្ភារៈជំនួយការបណ្តុះបណ្តាល – ៣.៣
# ការចិញ្ចឹមទារកនិងកុមារ – ការងារជាក្រុម

ថតចម្លងរូបភាពនិងអត្ថបទដែលពាក់ព័ន្ធ ហើយកាត់វាជាប័ណ្ណតូចៗ ។ ផ្តល់ទៅឱ្យក្រុមនិមួយៗនូវប័ណ្ណ១ជុំ ។ ពង្រីករូបភាពនៅពេលថតចម្លង ។

**០–៦ ខែ**





**៦–១១ ខែ**

**>១២ ខែ**



## សម្ភារៈជំនួយការបណ្តុះបណ្តាល-៣.៤ ការអនុវត្តន៍នូវសារចិញ្ចឹមទារក និងកុមារ

ថតចម្លងប័ណ្ណល្បែងដើរតួខាងក្រោម ហើយកាត់វាដាក់ជាដុំៗសំរាប់ក្រុមនិមួយៗ។

### ល្បែងដើរតួទី១:

អ្នកជាឆ្មបនៃមណ្ឌលសុខភាពមួយ។ ថាវីទើបតែសម្រាលកូនដំបូងនៅមណ្ឌលសុខភាព។ កូនស្រីរបស់ថាវីតូច។ នៅពេលដែលអ្នកថ្លឹងនាង នាងមានទម្ងន់ ២,២ គក្រ។ អ្នកដៅចំណុចទម្ងន់នៅលើប័ណ្ណសុខភាពកុមារ។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជានាងថាវី ហើយម្នាក់ទៀតដើរតួជាឆ្មបនៅមណ្ឌលសុខភាព។ តើអ្នកគ្រប់គ្រងបញ្ហានេះយ៉ាងដូចម្តេច?

### ល្បែងដើរតួទី២:

ឆវីនាំកូនប្រុសនាងអាយុ ៧ ខែ ឈ្មោះ បូរ័ត្ន ទៅមណ្ឌលសុខភាពដោយសារផ្តាសាយ។ អ្នកជាបុគ្គលិកមណ្ឌលសុខភាព។ នៅពេលអ្នកថ្លឹងបូរ័ត្ន នាងមានទម្ងន់ ៧ គក្រ។ អ្នកដៅចំណុចទម្ងន់នៅលើប័ណ្ណសុខភាពកុមារ។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជាឆវី ហើយម្នាក់ទៀតដើរតួជាបុគ្គលិកមណ្ឌលសុខភាព។ តើអ្នកគ្រប់គ្រងបញ្ហានេះយ៉ាងដូចម្តេច?

### ល្បែងដើរតួទី៣:

កូនស្រីរបស់សារឿនអាយុបាន ១២ ខែ។ គាត់បាននាំកូនស្រីរបស់គាត់ទៅមណ្ឌលសុខភាពដោយសារកូនគាត់រាក ២ ថ្ងៃ មកហើយ។ នៅពេលអ្នកថ្លឹងកូនស្រីរបស់សារឿន កូននាងមានទម្ងន់ស្មើនឹងទម្ងន់កាលពីបួនខែមុន។ ទម្ងន់របស់កូនស្រីនោះប្រហែល ៨ គក្រ។ ដៅចំណុចទម្ងន់នៅលើប័ណ្ណសុខភាពកុមារ។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជាសារឿន ហើយម្នាក់ទៀតដើរតួជាបុគ្គលិកមណ្ឌលសុខភាព។ តើអ្នកគ្រប់គ្រងបញ្ហានេះយ៉ាងដូចម្តេច?

### ល្បែងដើរតួទី៤:

សូភីបំបៅកូនប្រុសនាងអាយុ ៤ ខែ ដោយទឹកដោះម្តាយ។ គាត់បាននាំកូនទៅមណ្ឌលសុខភាពដើម្បីទទួលថ្នាំបង្ការបន្ទាប់។ នៅពេលអ្នកថ្លឹងកូនប្រុសរបស់នាង កូននោះទម្ងន់ ៥ គក្រ កូនសូភីឡើងទម្ងន់។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជាសូភី ហើយម្នាក់ទៀតដើរតួជាបុគ្គលិកមណ្ឌលសុខភាព។ តើព័ត៌មានអ្វីខ្លះដែលអ្នកនឹងផ្តល់ទៅឱ្យសូភី អំពីសុខភាពកូនរបស់នាង និងការចិញ្ចឹមកូន?

### ល្បែងដើរតួទី៥:

កូនប្រុសធីតាអាយុ ៩ ខែ។ គាត់បាននាំកូនគាត់ទៅមណ្ឌលសុខភាព ដោយសារកូនប្រុសគាត់ក្អក និងមិនសូវញ៉ាំអ្វីពីរបីថ្ងៃមកហើយ។ នៅពេលអ្នកថ្លឹងកូនប្រុសរបស់នាង កូននោះទម្ងន់៩គក្រ។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជាធីតា ហើយម្នាក់ទៀតដើរតួជាបុគ្គលិកមណ្ឌលសុខភាព។ តើអ្នកគ្រប់គ្រងបញ្ហានេះយ៉ាងដូចម្តេច?

### ល្បែងដើរតួទី៦:

ចាន់ថា នាំកូនស្រីគាត់អាយុ ៩ ខែ ទៅមណ្ឌលសុខភាព ដើម្បីទទួលថ្នាំបង្ការ។ នៅពេលអ្នកថ្លឹងកូនស្រីរបស់នាង ទម្ងន់របស់នាងគឺ ៦,៥ គក្រ។ ចូលដៅចំណុចទម្ងន់របស់កូនចាន់ថា នៅលើប័ណ្ណសុខភាពកុមារ។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជាចាន់ថា ហើយម្នាក់ទៀតដើរតួជាបុគ្គលិកមណ្ឌលសុខភាព។ តើព័ត៌មានអ្វីខ្លះដែលអ្នកនឹងត្រូវផ្តល់ទៅឱ្យចាន់ថា អំពីសុខភាពកូនរបស់នាង និងការចិញ្ចឹមកូន?

**ល្បែងដើរតួទី៧:**

ស៊ីណានាំកូនប្រុសរបស់គាត់អាយុ ៧ ខែ ទៅមណ្ឌលសុខភាព ដោយសារគាត់បារម្ភពីកូនរបស់គាត់ដែលចេះតែស្គមទៅ។ នៅពេលអ្នកថ្លឹងកូនប្រុសរបស់ស៊ីណា កូននោះទម្ងន់ ៦,៥ គក្រ។ ចូលដៅចំណុចទម្ងន់នៅលើប័ណ្ណសុខភាពកុមារ។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជាស៊ីណា ហើយម្នាក់ទៀតដើរតួជាបុគ្គលិកមណ្ឌលសុខភាព។ តើអ្នកគ្រប់គ្រងបញ្ហានេះយ៉ាងដូចម្តេច?

**ល្បែងដើរតួទី៨:**

កូនស្រីរបស់បូផា អាយុ ៧ ខែ។ បូផានាំកូនស្រីរបស់គាត់ទៅមណ្ឌលសុខភាពដើម្បីទទួលថ្នាំបង្ការ។ នៅពេលអ្នកថ្លឹងកូនស្រីរបស់បូផា កូននោះមានទម្ងន់ ៦,៥ គក្រ។ ចូលដៅចំណុចទម្ងន់នៅលើប័ណ្ណសុខភាពកុមារ។

សំដែងល្បែងដើរតួ។ ម្នាក់ដើរតួជាបូផា ហើយម្នាក់ទៀតដើរតួជាបុគ្គលិកមណ្ឌលសុខភាព។ តើអ្នកគ្រប់គ្រងបញ្ហានេះយ៉ាងដូចម្តេច?

## សម្ភារៈជំនួយការបណ្តុះបណ្តាល-៦.៥ ការផ្តល់ថ្នាំបង្ការ-ការងារជាក្រុម

| | |
|---|---|
| ការពារជម្ងឺរបេង តែ១ដូស | ការពារជម្ងឺ ប្រភេទបេ០-១ដូស |
| OPV,DPT or DPT-HB | ដូសទី១ ៦ សប្តាហ៍ ក្រោយសម្រាល |
| ដូសទី២-យ៉ាងហោចណាស់ ៤ សប្តាហ៍ ក្រោយពីដូសទី១ | ដូសទី៣-យ៉ាងហោចណាស់ ៤ សប្តាហ៍ ក្រោយពីដូសទី២ |
| ការពារជម្ងឺកញ្ជ្រិល | យ៉ាងហោចណាស់ ៩ ខែ ក្រោយពីសម្រាល-១ដូស |

BCG : អាចផ្តល់បានរហូតដល់ កុមារអាយុ ១ ឆ្នាំ

HBO:ត្រូវផ្តល់ក្នុងរយៈពេល ២៤ ម៉ោង ក្រោយពេលសម្រាល ប៉ុន្តែគេអាចផ្តល់ បានក្នុងរយៈពេលរហូតដល់ក្រោម ៧ ថ្ងៃ

មិនត្រូវខកខាន កាលបរិច្ឆេទ ក្នុងការផ្តល់ថ្នាំបង្ការណាមួយឡើយ

ថ្នាំបង្ការនឹងមិនដំណើរការ ឡើយ បើសិនជាខកខានមិនបាន ទទួលដូសណា១នោះ

មិនត្រូវផ្តល់ DPT/DPT-HB នៅ ពេលដែលដឹងថា កុមារធ្លាប់មាន ប្រតិកម្មជាមួយនឹងថ្នាំបង្ការនេះទេ

កត់ត្រាការផ្តល់ថ្នាំបង្ការទៅក្នុងប័ណ្ណ សុខភាពកុមារ និងក្នុងសៀវភៅ កត់ត្រារបស់មណ្ឌលសុខភាព

ពិនិត្យមើលថាតើម្តាយបានទទួល ថ្នាំបង្ការជម្ងឺតេតាណូសកាលពី លើកមុនហើយឬនៅ

ធ្វើការសម្រេចចិត្តថាតើត្រូវផ្តល់ ដូសមួយណាដល់ម្តាយ

បើសិនជាគ្រប់ដូសទាំងអស់ ត្រូវ បានផ្តល់រួចហើយកាលពីលើកមុន មិនត្រូវផ្តល់ឱ្យទៀតឡើយ

ដូសទី១ ក្នុងអំឡុងពេល មកជួបពិនិត្យលើកទី១

ដូសទី២ យ៉ាងហោចណាស់ ១ ខែ ក្រោយពីដូសទី១

ដូសទី៣ យ៉ាងហោចណាស់ ៦ ខែ ក្រោយពីដូសទី២

ដូសទី៤ យ៉ាងហោចណាស់ ១ ឆ្នាំ ក្រោយពីដូសទី៣

ដូសទី៥ យ៉ាងហោចណាស់ ១ ឆ្នាំ ក្រោយពីដូសទី៤













# បញ្ជីផ្ទៀងផ្ទាត់ការសម្របសម្រួល សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី១០

| ការបង្ហាញ/ការធ្វើបាឋកថា | | | |
|---|---|---|---|
| តើអ្នកសម្របសម្រួលបាន..... | បាទ / ចាស់ | ទេ | មតិយោបល់ |
| ...ប្រើប្រាស់ស្លាយ ឬ ក្រដាសផ្ទាំងធំដែលបានរៀបចំទុកជាមុនដែរ ឬទេ? | | | |
| ...ប្រើប្រាស់រូបភាពនៅក្នុងស្លាយ ឬ ក្រដាសផ្ទាំងធំដែរ ឬទេ? | | | |
| ...ប្រើចំណុចគោល១នៅលើស្លាយ ឬ ក្រដាសផ្ទាំងធំដែរ ឬទេ? | | | |
| ...ជ្រើសយកជំហរល្អមួយនៅមុខក្រុមដែរ ឬទេ? | | | |
| ...ធ្វើបាឋកថាទៅតាមកាលវិភាគដែលបានកំណត់ដែរ ឬទេ? | | | |
| ...ធ្វើការពិនិត្យថាតើសិក្ខាកាមយល់ពីខ្លឹមសារដែរ ឬទេ? | | | |
| ...យល់ច្បាស់ពីខ្លឹមសារដែល ឬទេ? | | | |
| ...ប្រើប្រាស់កិរិតមួយត្រឹមត្រូវក្នុងការពន្យល់សិក្ខាកាមដែរ ឬទេ? (មិនសាមញ្ញពេក ឬមិនពិបាកពេក) | | | |

| ការសម្របសម្រួលការងារបុគ្គល ឬការងារតាមក្រុម | | | |
|---|---|---|---|
| តើអ្នកសម្របសម្រួលបាន..... | បាទ / ចាស់ | ទេ | មតិយោបល់ |
| ...ធ្វើការណែនាំ និងពន្យល់ពីសកម្មភាពទេ? | | | |
| ...ធ្វើការគាំទ្រការវិវឌ្ឍន៍បុគ្គលម្នាក់១/ក្រុមដែរឬទេ? | | | |
| ...ផ្តល់ព័ត៌មានត្រលប់តាមបែបវិជ្ជមានដែរឬទេ? | | | |
| ...អនុញ្ញាតិឱ្យសិក្ខាកាមរៀនសូត្រពីកំហុសរបស់ពួកគេតាមវិធី ...មិនប្រឈមមុខដែរឬទេ? | | | |
| ...ធ្វើការសង្ខេបសកម្មភាពទាំងនេះដោយធានាថាមានលក្ខណៈ គ្រប់ជ្រុងជ្រោយដោយសិក្ខាកាមឬទេ? | | | |
| ...រក្សាពេលវេលាដែលបានកំណត់ដែរឬទេ? | | | |

| តួនាទីរបស់អ្នកសម្របសម្រួល (សូមបង្ហាញនៅលើបន្ទាត់ថាតើល្អកម្រិតណា ________x________) | | |
|---|---|---|
| តើអ្នកសម្របសម្រួលបង្កើតបរិយាកាសសុវត្ថិភាពល្អកម្រិតណា? | ល្អណាស់ ____________ | មិនល្អទាល់តែសោះ |
| តើអ្នកសម្របសម្រួលយកចិត្តទុកដាក់កម្រិតណា? | ល្អណាស់ ____________ | មិនល្អទាល់តែសោះ |
| តើអ្នកសម្របសម្រួលមានប្រយោជន៍កម្រិតណា? | ល្អណាស់ ____________ | មិនល្អទាល់តែសោះ |
| តើអ្នកសម្របសម្រួលរាក់ទាក់កម្រិតណា? | ល្អណាស់ ____________ | មិនល្អទាល់តែសោះ |

| ការរៀបចំវគ្គ / សកម្មភាព | បាទ / ចាស | ទេ | មតិយោបល់ |
|---|---|---|---|
| តើវគ្គរៀបចំបានល្អដែរ ឬទេ? | | | |
| តើវគ្គបានចាប់ផ្តើមទាន់ពេលវេលាដែរ ឬទេ? | | | |
| តើវគ្គបានបញ្ចប់តាមម៉ោងពេលដែរ ឬទេ? | | | |
| តើអ្នកសម្របសម្រួលបានធ្វើការវាយតម្លៃវគ្គដែរ ឬទេ? | | | |
| តើអ្នកសម្របសម្រួលបានចូលរួមការប្រជុំអ្នកសម្របសម្រួលប្រចាំថ្ងៃដែរ ឬទេ? | | | |

# បញ្ជីផ្ទៀងផ្ទាត់សំរាប់ការផ្តល់ប្រឹក្សា

| បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សា<br>អាហារូបត្ថម្ភ មណ្ឌលសុខភាព | | <br>ល្អ | <br>មិនល្អ | មតិយោបល់ |
|---|---|---|---|---|
| ក. ជំនាញប្រស្រ័យទាក់ទង<br>បុគ្គលិក ... | | | | |
| ១ | ជិតស្និតរាក់ទាក់ | | | |
| ២ | យកចិត្តទុកដាក់ស្តាប់ | | | |
| ៣ | បង្ហាញការយកចិត្តទុកដាក់តាមរយៈភាសាកាយវិការ | | | |
| ៤ | សួរសំណួរបើក | | | |
| ៥ | បង្ហាញពីការចាប់អារម្មណ៍ | | | |
| ៦ | ប្រើពាក្យសាមញ្ញ | | | |
| ៧ | ពន្យល់ពីអ្វីដែលគាត់កំពុងធ្វើ | | | |
| ៨ | មិនធ្វើការវិនិច្ឆ័យ | | | |
| ៩ | ចិត្តទូលាយចំពោះអារម្មណ៍ និងការគិតរបស់ម្តាយៗ | | | |
| ១០ | លើកសរសើនូវអ្វីដែលម្តាយ និងកូនធ្វើត្រឹមត្រូវ | | | |
| ខ. ជំនាញអាហារូបត្ថម្ភ<br>បុគ្គលិកផ្តល់ព័ត៌មានគ្រប់គ្រាន់ពី ... | | | | |
| ១ | ជីវជាតិអា | | | |
| ២ | ជាតិដែក | | | |
| ៣ | អ៊ីយ៉ូដ | | | |
| ៤ | ការបំបៅកូនដោយទឹកដោះម្តាយ | | | |
| ៥ | ការបំបៅកូនភ្លាម និងការបំបៅកូនដោយទឹកដោះម្តាយតែ១មុខគត់ | | | |
| ៦ | ការផ្តល់អាហារបន្ថែម | | | |
| ៧ | កត់ត្រាលើប័ណ្ណសុខភាព និងសៀវភៅកត់ត្រាមណ្ឌលសុខភាព | | | |
| ៨ | ការត្រលប់មកពិនិត្យលើកក្រោយ | | | |

| បញ្ជីផ្ទៀងផ្ទាត់ការផ្ដល់ប្រឹក្សាអាហារូបត្ថម្ភ មណ្ឌលសុខភាព | | <br>ល្អ | <br>មិនល្អ | មតិយោបល់ |
|---|---|---|---|---|
| **គ. ការបញ្ច្រៀតចូលគ្នា និងការប្រើប្រាស់សម្ភារៈជំនួយការងារ បុគ្គលិក ...** | | | | |
| ១ | បញ្ចូលសារអាហារូបត្ថម្ភទៅក្នុងសកម្មភាព | | | |
| ២ | ប្រើប្រាស់សម្ភារៈជំនួយការងារអាហារូបត្ថម្ភ | | | |
| ៣ | ប្រើប្រាស់សន្លឹកផ្ទាត់ជំនួយការងារ | | | |
| ៤ | ប្រើប្រាស់សម្ភារៈជំនួយការងារផ្សេងទៀត | | | |
| ៥ | ផ្ដល់ឱ្យស្ត្រីនូវសម្ភារៈអប់រំសំរាប់យកទៅផ្ទះ | | | |
| **ឃ. ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល បុគ្គលិក ...** | | | | |
| ១ | ធ្វើរោគវិនិច្ឆ័យអ្នកជម្ងឺ | | | |
| ២ | ផ្ដល់វេជ្ជបញ្ជាសំរាប់ការព្យាបាលបានគ្រប់គ្រាន់ | | | |
| ៣ | ពន្យល់គ្រប់គ្រាន់ពីស្ថានភាពដល់អ្នកជម្ងឺ | | | |
| ៤ | ពន្យល់គ្រប់គ្រាន់ពីការព្យាបាលដល់អ្នកជម្ងឺ | | | |

# ឧបករណ៍គាំទ្រមិត្តរួមការងារ

| បញ្ហាប្រឈម | អ្វីដែលគួរត្រូវធ្វើ | អ្នកណាត្រូវធ្វើអ្វី | អ្វីទៀតដែលខ្ញុំអាចធ្វើ |
|---|---|---|---|
| យើងមិនមាន សម្ភារៈគ្រប់គ្រាន់ (ឧទាហរណ៍) | បុគ្គលិកមណ្ឌលសុខភាព គួរស្នើសុំស្រុក ប្រតិបត្តិឱ្យផ្តល់១០កញ្ចប់ថែមទៀត | ស្រុកប្រតិបត្តិ ផ្តល់ឱ្យតាម ពិនិត្យសំណើរបស់យើង | ផលិតសម្ភារៈខ្លះ ដោយខ្លួន |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

# ទម្រង់វាយតម្លៃការបណ្តុះបណ្តាល

**ប្រធានបទ:** **កាលបរិច្ឆេទ:**

**ផ្នែក:** **តួនាទី:** **ឈ្មោះ (ស្រេចចិត្ត):**

**ទិសដៅ:** ខាងក្រោមគឺជាសំណួរស្តីពីការបណ្តុះបណ្តាលដែលអ្នកទើបឆ្លងកាត់។ សូមឆ្លើយនឹងសំណួរ ទាំងនេះដោយស្មោះត្រង់។ ព័ត៌មានដែលប្រមូលនៅក្នុងទម្រង់នេះនឹងត្រូវបានយកទៅប្រើប្រាស់ដើម្បីធ្វើការកែលំអខ្លឹមសារ និងការរៀបចំការបណ្តុះបណ្តាល សំរាប់ពេលអនាគត។

## អំពីការរៀបចំនៃវគ្គបណ្តុះបណ្តាល/សិក្ខាសាលា

សូមជ្រើសរើសចម្លើយដែលល្អបំផុតដែលស៊ីគ្នាទៅនឹងជម្រើសរបស់អ្នក។ សូមគូសសញ្ញាខ្វែង (**x**) នៅក្នុងប្រអប់

| | សំណួរ | ល្អប្រសើរ | ល្អ | មធ្យម | មិនល្អ |
|---|---|---|---|---|---|
| ១ | តើការបណ្តុះបណ្តាលនេះរៀបចំបានយ៉ាងណាដែរ? | | | | |
| ២ | តើពេលវេលាដែលប្រើប្រាស់ក្នុងការបណ្តុះបណ្តាលយ៉ាងណាដែរ? | | | | |
| ៣ | តើទីកន្លែងបណ្តុះបណ្តាលយ៉ាងណាដែរ? | | | | |
| ៤ | តើការបណ្តុះបណ្តាលនេះមានប្រយោជន៍យ៉ាងណាដែរចំពោះការងាររបស់អ្នក? | | | | |
| ៥ | តើអាហារសម្រន់យ៉ាងណាដែរ? | | | | |
| ៦ | តើមានការប្រើប្រាស់វិធីផ្សេងៗគ្នាទេ ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនេះ? (ប្រើប្រាស់ក្រដាសផ្ទាំងធំ ប្រដាប់បញ្ចាំងស្លាយ អិលស៊ីឌី) | | | | |
| ៧ | តើកៅអីអង្គុយស្រួលទេ? | | | | |
| ៨ | តើការបកប្រែក្នុងអំឡុងពេលបណ្តុះបណ្តាលយ៉ាងណាដែរ? (ប្រសិនបើមាន) | | | | |

## អំពីខ្លឹមសារនៃវគ្គបណ្តុះបណ្តាល/សិក្ខាសាលា

សូមជ្រើសរើសចម្លើយដ៏ល្អំផុត បាទ/ចាស៎ ឬ ទេ ព្រមទាំងផ្តល់ហេតុផលនៅក្កូលោនចុងក្រោយ ។

| | សំណួរ | បាទ / ចាស៎ | ទេ | សូមផ្តល់ហេតុផល |
|---|---|---|---|---|
| ៩ | តើខ្លឹមសារនៃការបណ្តុះបណ្តាល ឆ្លើយតបទៅនឹងគោលបំណងនៃវគ្គដែរ ឬទេ? | | | |
| ១០ | តើការបណ្តុះបណ្តាលឆ្លើយតបទៅនឹងតម្រូវការ របស់អ្នកដែរ ឬទេ? | | | |
| ១១ | តើការបណ្តុះបណ្តាលនេះទាក់ទងទៅនឹង ការងារអ្នកដែរ ឬទេ? | | | |
| ១២ | តើប្រធានបទទាំងនោះមានសារៈសំខាន់ សំរាប់អ្នកដែរ ឬទេ? | | | |
| ១៣ | តើមានប្រធានបទណាខ្លះដែលអ្នកមិនយល់? | | | |
| ១៤ | តើអ្នកបានទទួលចំណេះដឹងថ្មី ពីការ បណ្តុះបណ្តាលនេះដែរ ឬទេ? | | | |
| ១៥ | តើអ្នកបានទទួលជំនាញថ្មី ពីការបណ្តុះបណ្តាលនេះដែរ ឬទេ? | | | |
| ១៦ | តើអ្នកបានអនុវត្តន៍ជំនាញថ្មីក្នុងអំឡុងពេលនៃ ការបណ្តុះបណ្តាលនេះដែរ ឬទេ? | | | |
| ១៧ | តើគ្រូបង្ហាត់បានគោរពកាលវិភាគដែរ ឬទេ? | | | |
| ១៨ | តើគ្រូបង្ហាត់មានទំនាក់ទំនងល្អជាមួយសិក្ខាកាម ដែរ ឬទេ? | | | |
| ១៩ | តើគ្រូបង្ហាត់បានធ្វើការពន្យល់ច្បាស់លាស់ ដែរ ឬទេ? | | | |
| ២០ | តើគ្រូបង្ហាត់បានធ្វើការសង្ខេបនៅចុងបញ្ចប់ នៃប្រធានបទនិមួយៗដែរ ឬទេ? | | | |
| ២១ | តើគ្រូបង្ហាត់បានប្រើប្រាស់សម្ភារៈ ប្រកប ដោយប្រសិទ្ធភាពដែរ ឬទេ? | | | |

**សូមឆ្លើយទៅនឹងសំណួរដូចខាងក្រោមនេះ**

២២. តើប្រធានបទអ្វីដែលអ្នកចង់រៀនថែមទៀត?

២៣. តើមានចំណុចអ្វីនៅក្នុងការបណ្ដុះបណ្ដាលដែលគួរធ្វើការកែលំអ?

២៤. អ្នកបានរៀនពីចំណេះដឹង និងជំនាញថ្មីនៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ។ តើចំណេះដឹង និងជំនាញអ្វីដែលអ្នកនឹងយកទៅប្រើប្រាស់ញឹកញាប់ជាងគេនៅក្នុងការងារប្រចាំថ្ងៃរបស់អ្នក?

សៀវភៅអ្នកសម្របសម្រួលនេះត្រូវបានរចនា និងបោះពុម្ពដោយមានការឧបត្ថម្ភថវិកាពី
ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)
តាមរយៈ គំរោងមីក្រូសារជាតិ A2Z

Design by **nova**: info@novacambodia.com